

## កម្រងអត្ថបទជ្រើសរើស

# សិក្សាតំបន់អាស៊ីអាគ្នេយ៍

# ជនជាតិភាគតិចចិននៅកម្ពុជា
# ក្នុងបរិបទអាស៊ីអាគ្នេយ៍

បកប្រែពីភាសាអង់គ្លេសដោយ

ថា លាងអាង, ទូច សុពុទ្ធី, ថុល ឌីណា, វង់ សុធារ៉ា, វង្ស ម៉េង

**Ethnic Chinese in Cambodia :**
**In The Southeast Asian Context**

Translated from English by Tha Leang Ang, Touch Soputhy, Thol Dina, Vong Sotheara, Vong Meng

ជំពូកទី ១ ៖ តួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិន នៅក្នុងប្រទេសកម្ពុជា

ជំពូកទី ២ ៖ សន្ធិសញ្ញាច្បាប់ និងលក្ខខណ្ឌក្នុងការកំណត់លក្ខណៈត្រឹមត្រូវស្របច្បាប់ របស់ជនជាតិចិននៅកម្ពុជា

ជំពូកទី ៣ ៖ ស្ថាប័នសង្គម នៃសហគមន៍ចិននៅកម្ពុជា

ជំពូកទី ៤ ៖ ការលេចឡើង និងការរួបរួមនៃក្រុមវរជន

*អត្ថបទទាំងនេះដកស្រង់ចេញពីសៀវភៅ ÷* **ជនជាតិចិននៅកម្ពុជា** *។*

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យប្រ៊ីធីសកូឡុំបៀ ។*

**Copyright © 1967 by University of British Columbia**

ជំពូកទី ៥ ៖ ការធ្លាក់ចុះនៃសម្ព័ន្ធភាពរវាងចៅហ្វាយនាយ-អ្នកពឹងពាក់ និងបម្រែបម្រួលសង្គម នៅតំបន់អាស៊ីអាគ្នេយ៍ជនបទ

*អត្ថបទនេះដកស្រង់ចេញពីព្រឹត្តិបត្រ ÷* **សិក្សាអាស៊ី** *ទំព័រ ៥-៣៧ ។*

*រក្សាសិទ្ធិ គ.ស. ១៩៧៣*

**Copyright © 1973 Journal of Asian Studies**

រក្សាសិទ្ធិក្នុងការបកប្រែ និងចេញផ្សាយជាភាសាខ្មែរ © គ.ស. ២០០៨ ដោយមជ្ឈមណ្ឌលខេមរសិក្សា ។

**Copyright © 2008 Center for Khmer Studies for the Khmer translation.**

**រូបភាពក្របមុខដោយ** ◢ **Cover picture**

អ្នកស្រី តាន់ សូដានី (រក្សាសិទ្ធិ) គ.ស. ២០០៨ **Copyright © 2008 Tan Sodany.**

ការបកប្រែ និងបោះពុម្ពសៀវភៅនេះ ទទួលបានការឧបត្ថម្ភពីមូលនិធិ រ៉ុកហ្វេល័រ នៅញូយ៉ក ។

**The publication of this book was supported by the Rockefeller Foundation (New York).**

លសខអ ១៣ ៖ ៩៧៨-៩៩៩៥០-៥១-០៨-២ ISBN-13: 978-99950-51-08-2

បោះពុម្ពនៅភ្នំពេញ ប្រទេស កម្ពុជា ។ **Printed in Phnom Penh, Cambodia.**

# សារបណ្ណា

**អារម្ភកថា** ០៧

**ជំពូកទី ១ ៖ តួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិន នៅក្នុងប្រទេសកម្ពុជា** ១១

*ជនជាតិចិនក្នុងវិស័យកសិកម្ម* ១៧

*ចម្ការម្រេច* ១៨

*ចម្ការដំណាំ និងផ្លែឈើ* ១៩

*ជនជាតិចិនក្នុងវិស័យពាណិជ្ជកម្ម* ២០

*ជំនួញស្រូវ* ២១

*ការនាំចូល-ការនាំចេញ* ២៣

*វិស័យពាណិជ្ជកម្មក្នុងស្រុក ឧស្សាហកម្ម និងការដឹកជញ្ជូន* ២៣

*វិស័យហិរញ្ញវត្ថុ និងឥណទាន* ២៤

*ម្ចាស់តៀមជនជាតិចិននៅតាមជនបទ* ២៥

*កម្លាំងពលកម្មចិននៅកម្ពុជា* ២៧

*សន្និដ្ឋាន ៖ វេទនាសម្ព័ន្ធវណ្ណៈជនជាតិចិន* ២៨

**ជំពូកទី ២ ៖ សន្ធិសញ្ញាច្បាប់ និងលក្ខខណ្ឌក្នុងការកំណត់លក្ខណៈត្រឹមត្រូវស្របច្បាប់ របស់ជនជាតិចិននៅកម្ពុជា** ៣៥

*ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិនមុនសម័យអាណានិគមន៍បារាំង* ៣៨

*ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិននៅសម័យអាណានិគមន៍បារាំង* ៤១

*ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិននៅសម័យឯករាជ្យ* ៤៩

*សេចក្ដីសន្និដ្ឋាន* ៥៣

**ជំពូកទី ៣ ៖ ស្ថាប័នសង្គមនៃសហគមន៍ចិននៅកម្ពុជា** ៥៥

*សមាគមស្ម័គ្រចិត្ត* ៥៨

*អត្តសញ្ញាណវប្បធម៌* ៦០

*វេទនាសម្ព័ន្ធនយោបាយ* ៦២

*ស្ថាប័នសង្គមរបស់ជនជាតិនៅតាមទីក្រុងតូចៗ* ៦៣

*សន្និដ្ឋាន* ៦៣

**ជំពូកទី ៤ ៖ ការលេចឡើង និងការរួបរួមនៃក្រុមឧកញ៉ា** ៦៥
ចំណាប់អារម្មណ៍របស់ជនជាតិចិនក្នុងការធ្វើពាណិជ្ជកម្ម ៦៧
វរជនចិនកាត់កម្ពុជា ៧០
សង្គមចម្រុះ និងគោលនយោបាយ ៧១
**ជំពូកទី ៥ ៖ ការធ្លាក់ចុះនៃសម្ព័ន្ធភាពរវាងចៅហ្វាយនាយ-អ្នកពឹងពាក់**
**និងបម្រែបម្រួលសង្គម នៅតំបន់អាស៊ីអាគ្នេយ៍ជនបទ** ៧៩
ចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ ៨០
សមាសភាពនៃការដោះដូរ ៨១
ការផ្ដល់ឲ្យរបស់ចៅហ្វាយនាយទៅកូនចៅ ៨១
ការផ្ដល់ឲ្យពីសំណាក់កូនចៅចំពោះចៅហ្វាយនាយ ៨២
ការពឹងពាក់អាស្រ័យ នឹងភាពស្របច្បាប់ ៨២
ភាពស្មុគស្មាញ និងតថភាព ៨៣
ការបែកបាក់នៃស្ថិរភាពក្នុងការដោះដូរ ៨៤
សិទ្ធិសង្គមជាមូលដ្ឋាន ៨៤
តួនាទី ឬដំណែងអាស្រ័យនឹងការចរចារ ៨៥
ស្ថានភាពទូទៅ នៃភាពជាចៅហ្វាយនាយនាសម័យបុរាណ ៨៦
ការប្រែប្រួលនៃការទាក់ទងក្នុងការពឹងពាក់ ៩១
ភាពខុសៗគ្នា យ៉ាងសម្បូរបែបនៅក្នុងសង្គម ៩២
ការចម្រើនឡើងនៃរដ្ឋអំណាចអាណានិគម ៩៣
ដី និងការដោះដូរគ្នារវាងចៅហ្វាយនាយ-អ្នកពឹងពាក់ ៩៤
កំណើននៃការពឹងពាក់លើជំនួយជាសំខាន់បែបដីធ្លី ៩៤
ការសង្កេតឲ្យច្បាស់លើការពឹងផ្អែកលើដីធ្លី និងការឧបត្ថម្ភក្នុងស្រុក ៩៨
ការបាត់បង់ធនធានធម្មជាតិកំប៉ិកកំប៉ុកនៅក្នុងភូមិ ១០២
កម្សោយន្ដការកម្រិតសមភាពក្នុងភូមិ និងការបន្ថយតម្រូវការរកអ្នកពឹងពាក់ ១០៤
ការដោះដូរដែលត្រូវគេគេងប្រវ័ញ្ច និងការបាត់បង់ភាពស្របច្បាប់ ១០៨
កសិដ្ឋានស្រូវទីនិញ្ញ ១០៨
ភាពគ្រប់គ្រាន់ និងការចែករំលែកហានិភ័យ ១១២

**កំណត់ចំណាំ** **១១៧**

ជំពូកទី ១ ១១៧

ជំពូកទី ២ ១១៩

ជំពូកទី ៣ ១២៥

ជំពូកទី ៤ ១២៧

ជំពូកទី ៤ ១៣០

ឯកសារពិគ្រោះ ១៤០

# អារម្ភកថា

ចាប់តាំងពីឆ្នាំ ២០០៤ មក មជ្ឈមណ្ឌលខេមរសិក្សា បានដំណើរការកម្មវិធីបណ្ដុះបណ្ដាលដ៏សំខាន់មួយ សម្រាប់គ្រូបង្រៀនថ្នាក់ឧត្ដមសិក្សាវ័យក្មេង ។ កម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀនថ្នាក់ឧត្ដមសិក្សា ជួយឲ្យនិសិត្សកម្ពុជាដែលជិតបញ្ចប់ការសិក្សា ឬគ្រូបង្រៀនតាមសាកលវិទ្យាល័យនានា ពង្រីកការស្រាវជ្រាវ និងការបង្រៀនរបស់ពួកគេនៅក្នុងវិស័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ ។ ដោយបានទទួលការឧបត្ថម្ភពីមូលនិធិរ៉ុក្គីហ្វេល័រ កម្មវិធីនេះមានបើកនូវវគ្គបណ្ដុះបណ្ដាលរយៈពេល ៦ ខែជាច្រើនវគ្គ ដឹកនាំដោយសាស្ត្រាចារ្យដែលបានទទួលការអញ្ជើញមួយរូប ។ នៅក្នុងវគ្គសិក្សានីមួយៗ មានប្រធានបទផ្សេងៗគ្នា ហើយប្រធានបទនីមួយៗផ្ដោតលើទិដ្ឋភាពមួយ នៃសង្គមកម្ពុជាសម័យទំនើប ។ យើងបានធ្វើការជាមួយអ្នកតំណាង មកពីសកលវិទ្យាល័យនៅកម្ពុជា ដើម្បីកំណត់ប្រធានបទសម្រាប់វគ្គនីមួយៗ ក្នុងគោលបំណងទាក់ទាញអ្នកចូលរួម ដែលមានជំនាញផ្សេងៗគ្នានិងសម្រាប់ប្រើទស្សនវិស័យប្រៀបធៀប ដែលក្នុងនោះកម្ពុជាត្រូវបានសិក្សាជាមួយប្រទេសជិតខាងដទៃទៀត ដូចជាប្រទេសថៃ វៀតណាម ឡាវ ភូមា និងប្រទេសដទៃទៀតនៅក្នុងតំបន់ ។ វគ្គសិក្សានីមួយៗមានសកម្មភាពជាច្រើនដូចជាការសិក្សានៅក្នុងថ្នាក់សិក្ខាសិលា ការចុះកម្មសិក្សានៅតាមបណ្ដាប្រទេសជិតខាង ការចុះស្រាវជ្រាវរបស់អ្នកចូលរួមម្នាក់ៗ ។ សកម្មភាពបន្តទៀតធ្វើឡើងជាទម្រង់សិក្ខាសិលាអន្តរជាតិមួយ ដែលផ្ដោតលើមូលបទរបស់វគ្គសិក្សានីមួយៗ ហើយនិងការជ្រើសរើសអត្ថបទសិក្សាជាច្រើន ដោយសាស្ត្រាចារ្យដែលបង្រៀននៅក្នុងវគ្គនីមួយៗ ។ អត្ថបទទាំងនោះ ត្រូវបានបកប្រែជាភាសាខ្មែរដោយអ្នកសិក្សា ដើម្បីបោះពុម្ពផ្សាយ ។ គោលបំណងនៃការងារបកប្រែ និងបោះពុម្ពផ្សាយនេះ គឺដើម្បីបង្កើនចំនួនឯកសារសិក្សាជាភាសាខ្មែរ ដែលកំពុងតែខ្វះខាតនៅក្នុងវិស័យមនុស្សសាស្ត្រ សង្គមសាស្ត្រ ដែលជាតម្រូវការរបស់គ្រូបង្រៀននៅតាមសាកលវិទ្យាល័យ និងនិសិត្ស ។

សៀវភៅវគ្គបីនេះ មានអត្ថបទចំនួន ៥ បានជ្រើសរើសដោយលោកបណ្ឌិត ភិតថឺ ហាំមីរ សាស្ត្រាចារ្យនៃសកលវិទ្យាល័យវេន ។ អត្ថបទទាំងនេះ បានឆ្លុះបញ្ចាំងពីប្រធានបទនៃកម្មវិធីសិក្សាវគ្គទី ៥ ស្ដីពី ជនជាតិភាគតិច ដែនកំណត់ ហើយនិងព្រំដែន ។ ក្នុងនោះមានអត្ថបទចំនួន ៤ ដកស្រង់ចេញពីការសិក្សាស្រាវជ្រាវនាសម័យមុនសង្គ្រាម ដែលនិយាយអំពី **«ជនជាតិចិននៅកម្ពុជា»** ដោយលោកវីល្មៀម. អ៊ី. វីលមូតត៍ ក្នុងឆ្នាំ ១៩៦៧ ។ អត្ថបទទី ១ ស្ដីពី «តួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិននៅកម្ពុជា» អត្ថបទទី ២ ស្ដីពី «សន្ធិសញ្ញាច្បាប់ និងលក្ខខណ្ឌក្នុងការកំណត់លក្ខណៈត្រឹមត្រូវស្របច្បាប់ របស់ជនជាតិចិននៅកម្ពុជា» អត្ថបទទី ៣ ស្ដីពី «ស្ថាប័នសង្គមនៃសហគមន៍ចិននៅកម្ពុជា» អត្ថបទទី ៤ ស្ដីពី «ការលេចឡើង និងការរួបរួមនៃក្រុមវរជន» ។ អត្ថបទទាំងអស់នេះ ក្រៅតែពីការពិពណ៌នា អំពីស្ថានភាពជនជាតិចិននៅក្នុងកម្ពុជានាមុនសម័យសង្គ្រាមបានផ្ដល់នូវការពិពណ៌នាដ៏រស់រវើក នៃសមាគមជនជាតិភាគតិចនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ អត្ថបទទី ៥ ស្ដីពី «ការធ្លាក់ចុះនៃសម្ព័ន្ធភាពរវាងចៅហ្វាយនាយ-អ្នកពឹងពាក់ និងបម្រែបម្រួលសង្គម នៅតំបន់អាស៊ីអាគ្នេយ៍ជនបទ» ដោយលោកជេមស៍ ស្កត់ បានផ្ដល់នូវការវិភាគបែបនរវិទ្យាមួយទៀត អំពីការផ្លាស់ប្ដូរដែលបានកើតឡើងនាសម័យក្រោយ ទទួលបានឯករាជ្យក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

នៅក្នុងការបង្រៀនរបស់គាត់ ភីតថឺ ហាំមីរ បានប្រើប្រាស់អត្ថបទទាំងអស់នេះ ដើម្បីគូសបញ្ជាក់ពីសភាពនៃព្រំដែន ដែលមិនត្រឹមតែផ្ដោតទៅលើតែបន្ទាត់ព្រំដែននោះទេ ប៉ុន្តែក៏សំដៅទៅលើគំនូសក្រើតដែលមើលមិនឃើញ ឬក៏ការផ្ដាច់ចេញដែលជាហេតុនាំឲ្យមានការបង្កើតចិត្តគំនិត និងសង្គមឡើង ដូចទៅនឹងជាតិ និងអត្តសញ្ញាណដែរ ។ ការសិក្សាពីជនជាតិចិននៅកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៥០-១៩៦០ បានផ្ដល់ដល់អ្នកអាននូវរូបភាព នៃស្ថានភាពជនជាតិភាគតិចនៅតំបន់ ក្នុងទស្សនវិស័យប្រវត្តិសាស្ត្រ និងប្រៀបធៀប ហើយនេះក៏អាចផ្ដល់ជាប្រយោជន៍ ចំពោះអ្នកសិក្សាទាំងឡាយណា ដែលចង់ប្រៀបធៀប ឬ

ពិពណ៌នាអំពីស្ថានភាពសហគមន៍ជនជាតិចិនមុន និងក្រោយពេលសង្គ្រាមក្នុងកម្ពុជា និងអាចប្រៀបធៀបជាមួយនឹងស្ថានភាពនៅប្រទេសផ្សេងៗទៀតនៅក្នុងតំបន់ដែរ ។ ភីតថឺ ក៏បានណែនាំដល់និសិត្សអំពីសភាព នៃការផ្លាស់ប្តូរដែលបានកើតឡើងនៅក្នុងជីវិតជនបទរបស់តំបន់អាស៊ីអាគ្នេយ៍ ។ អត្ថបទចុងក្រោយមិនត្រឹមតែជាឧទាហរណ៍ដ៏ល្អ អំពីការវិភាគ និងស្រាវជ្រាវបែបនរវិទ្យាប៉ុណ្ណោះទេ ថែមទាំងផ្តល់ជាឧបករណ៍នៃវិធីសាស្ត្រចាំបាច់ ដើម្បីស្វែងយល់អំពីការផ្លាស់ប្តូរសង្គម និងនយោបាយ ដែលកើតឡើងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ជនបទ ។

ដោយព្យាយាមរក្សានូវគោលបំណងគរុកោសល្យ នៃកម្មវធីបណ្តុះបណ្តាលនេះ យើងសង្ឃឹមថាអត្ថបទបកប្រែទាំងនេះ និងបម្រើដល់សាស្ត្រាចារ្យ និសិត្សនៅក្នុងផ្នែក ប្រវត្តិសាស្ត្រ សង្គមសាស្ត្រ សេដ្ឋកិច្ច នរវិទ្យា វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ និងផ្នែកដទៃជាច្រើនទៀត ។ យើងក៏សង្ឃឹមថា អត្ថបទនេះនឹងជួយជំរុញឲ្យអ្នកអាន អ្នកស្រាវជ្រាវបន្ថែម ហើយវិភាគរិះគន់ ដោយប្រើនូវការសិក្សាប្រៀបធៀប និងរៀនសូត្រទៅវិញទៅមក ។

ខ្ញុំសូមបញ្ចប់សេចក្តីដោយសូមថ្លែងអំណរគុណចំពោះលោកបណ្ឌិត ភីតថឺ ហាំមីរ ជាគ្រូបង្រៀន និងជាអ្នកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលវគ្គនេះ។ រីឯលោក ឈាន មែន នាយកកម្មវិធីបណ្តុះបណ្តាលក៏ដូច្នេះដែរ ភាពស្វាហាប់ និងការទទួលធ្វើការងាររបស់គាត់មានសារៈសំខាន់ណាស់សម្រាប់ជោគជ័យរបស់កម្មវិធីយើងទាំងមូល ។ សូមអរគុណជាពិសេស ចំពោះក្រុមការងារបកប្រែវ័យក្មេង ដែលមានលោកថា លាងអាង, ទូច សុពុទ្ធី, ថុល ឌីណា, វង់ សុធារ៉ា, និង វង្ស ម៉េង ក្រោមការដឹកនាំដ៏ហ្មត់ចត់របស់អ្នកស្រី តាន់សូដានី ដែលជាអ្នកសម្របសម្រួលកម្មវិធីបកប្រែរបស់មជ្ឈមណ្ឌលយើងខ្ញុំ ។ ខ្ញុំសូមសម្តែងការដឹងគុណចំពោះការជួយជ្រោមជ្រែងរបស់លោកខេង ពិទូកេត្យា ដែលជាអ្នកសម្របសម្រួលបោះពុម្ពផ្សាយ សម្រាប់ស្នាដៃដ៏ល្អក្នុងការចាត់ចែងរឿងបណ្ណាធិការ និងការបោះពុម្ពផ្សាយ ។

ហ្វីលីព្ព ប៊ីកាំ
នាយកមជ្ឈមណ្ឌលខេមរសិក្សា

## PREFACE

Since 2004, the Center for Khmer Studies has conducted a major training program for young aspiring Cambodian university faculty. The Junior Faculty Training program (JFT) helps those Cambodians in the final stages of higher education, or in the formative years of their university teaching career, to expand their research and teacher training in the fields of the humanities and social sciences. Funded by the Rockefeller Foundation, the JFT program comprises a series of semester-long research and training seminars led by an international Visiting Professor. Each seminar has a different theme, and each focuses on one aspect of modern Cambodian society. Seminar topics were defined in coordination with representatives of Cambodian universities so as to attract participants from diverse disciplinary backgrounds, and employing a comparative perspective, where Cambodia is studied alongside its neighbors, Thailand and Vietnam, as well as Burma, Laos and other countries in the region. Each semester session combines lectures, interactive seminars, field visits to Thailand or Vietnam, and individual research project carried out by each participant. Follow-up takes the form of an international conference on the semester's topic set within the broader framework of Southeast Asia, and the selection of key seminar texts chosen by the session's Visiting Professor and translated into Khmer by the Cambodian participants for publication. The objective of this latter task is to increase the otherwise extremely limited corpus of reading materials available in Khmer in the social sciences and humanities needed for both university faculty and students.

This third volume consists of 5 reading texts selected by Dr. Peter Hammers, illustrating the theme covered by the program's session, Minorities, Margins and borders. These includes four articles excerpted from the seminal pre-war study The Chinese in Cambodia, by William Willmott, 1967: Article 1: "The Economic Position of the Chinese in Cambodia"; Article 2 " Treaty Law and Condition: The Legal definition of the chinese in Cambodia ", "The Social Organization of the Chinese Community" and "The Emerging and Merging Elites in Cambodia". These texts, by describing the situation of the ethnic Chinese in pre-war post-colonial Cambodia, offer a vivid depiction of a minority community encountered in all Southeast Asian societies. The fifth selected article, "The Erosion of Patron-Client Relations in Southeast Asia", by James Scott, gives another anthropological view on the social and political changes that have occurred in post-independence rural Southeast Asia.

In his seminar, Peter used these texts to underscore the notion of border, which not only focuses on physical demarcations but also on invisible margins, or separations, the result of mental and social constructions like those of nationality and identity. The case of the Chinese minority in Cambodia in the 1950-60s offers readers an opportunity to picture the situation of ethnic minorities in the region in an historical and comparative perspective. This will be of interest for scholars wishing to describe the situation of the Chinese community before and after the war in Cambodia. They will also draw comparison with the situation prevailing in other countries in the region. Peter also introduced students to the notion of changes that have taken place in rural Southeast Asian life-style. The last text is not only a fine example of anthropological research analysis. It also provides the kinds

of methodological tools needed to comprehend the social and political changes taking place in rural Southeast Asia.

In keeping with the pedagogical objectives of the JFT, we sincerely hope that these translated texts will be used by both professors and students, in the fields of history, sociology, economics, anthropology, political sciences, international relations and others. We also hope that they will encourage readers to investigate further, using comparative and interdisciplinary approaches in their research.

I will end this short word to thank Dr. Peter Hammer, both as a teacher and a supervisor of the Session 3 of the Junior Faculty Training Program. No less important was the work of my colleague Chean Men, Director of the program, whose energy and enterprise were critical to the success of our entire program. Special thanks also to the young team of translators, particularly Tha Leang Ang,Touch Soputhy, Thol Dina, Vong Sotheara,and Vong Meng who worked under the careful supervision of Tan Sodany, the CKS Translation Coordinator. I want also to acknowledge the contribution of Kheng Pytou Kethya, Publishing Coordinator, for his excellent work in managing the editorial and publishing aspects of this truly collective undertaking.

Philippe Peycam, PhD., Director
Center for Khmer Studies.

# ជំពូកទី ១

## តួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិន នៅក្នុងប្រទេសកម្ពុជា

*ដោយ វីល្លៀម. អ៊ី. វីលម៉ូតត៍*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "The Economic Position of the Chinese in Cambodia" ។

*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖* **ជនជាតិចិននៅកម្ពុជា** ។

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យប្រ៊ីធីសកូឡុំបៀ ។*

# CHAPTER 1:

## The Economic Position of the Chinese in Cambodia

William E. Willmott

(*The Chinese in Cambodia*)

**Copyright © 1967 by University of British Columbia**

បកប្រែដោយ ថា លាងអាង

# ជំពូកទី ១
# តួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិន នៅក្នុងប្រទេសកម្ពុជា

*នៅក្នុងការសិក្សាយ៉ាងលម្អិតស្ដីពីកសិករកម្ពុជា លោក ហ្សង់ ឌែលវីត បានសរសេររៀបរាប់ថា៖*

> កសិកម្មជាមុខរបរថ្នាក់ជាតិ ។ ជនជាតិខ្មែរគឺជាកសិករ ហើយជនជាតិខ្មែរនេះបានទុកមុខរបរផ្សេងៗទៀតឲ្យជនជាតិបរទេសធ្វើ គឺមានតែជនជាតិខ្មែរនេះឯងដែលធ្វើស្រែ ។ យើងគិតថាមិនងាយនឹងរកបានជាតិសាសន៍ណាដែលមានឯកទេសវិជ្ជាជីវៈជាប្រចាំដូចជាតិសាសន៍ខ្មែរនេះណាស់ ។ ជនជាតិខ្មែរនៅពេលដែលគាត់លែងធ្វើស្រែ គាត់ធ្វើមន្ត្រីរាជការ...(ឌែលវីត, ទំ. ៣១) ។

*ការលើកឡើងខាងលើ គឺជាទស្សនៈរបស់អ្នកនិពន្ធភាគច្រើនស្ដីពីប្រទេសកម្ពុជា ។ ប្រសិនបើការលើកឡើងនេះជាការពិតមែននោះ គេប្រហែលជាមានភាពងាយស្រួល ក្នុងពិពណ៌នាអំពីតួនាទីរបស់ជនជាតិចិននៅក្នុងវិស័យសេដ្ឋកិច្ចនៃប្រទេសកម្ពុជាជាមិនខានៗ គេប្រហែលជាអាចនិយាយបានយ៉ាងសាមញ្ញថា ពួកជនជាតិចិនបង្កើតបានជាវណ្ណៈកណ្ដាលមួយ ក្នុងការធ្វើជំនួញដូរញដូរធុនតូច ល្មមនឹងអាចផ្គត់ផ្គង់ដល់កសិករកម្ពុជាបាន ។ ប៉ុន្តែទោះបីជាភាពពិតនៃទស្សនៈខាងលើ ត្រូវបានបញ្ជាក់ដោយសារលទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីជនជាតិចិនក៏ដោយ ក៏ការលើកឡើងនោះ បានបង្កប់នូវការបំផ្លើសខុសពីការពិតមួយចំនួន ដែលយើងគួរតែពិនិត្យឡើងវិញឲ្យបានហ្មត់ចត់ ។ ឧទាហរណ៍ លោកឌែលវីត ខ្លួនគាត់ផ្ទាល់បានប៉ាន់ស្មានថា នៅឆ្នាំ ១៩៥៨ មានជនជាតិខ្មែរចំនួនប្រាំបីភាគរយ (គាត់ហៅថាជនជាតិកម្ពុជា) រស់នៅតំបន់ប្រជុំជន ហើយសូម្បីតែតួលេខទាបបែបនេះ ( ប្រមាណ ៣០០.០០០នាក់ ) ក៏បានចង្អុលផងដែរថា នៅតាមទីប្រជុំជន ក្នុងចំណោមឋានៈជាកម្មករ (វណ្ណៈអធន) ក៏មានជនជាតិខ្មែរផងដែរ ។ ដូច្នេះទស្សនៈដែលថា ខ្មែរគឺជាក្រុមមនុស្សតែមួយគត់ ដែលប្រកបរបរដាំដុះ មិនមែនសុទ្ធតែជាការពិតទាំងអស់នោះទេ ។ ជនជាតិចិនក៏មានមុខរបរពាក់ព័ន្ធនឹងវិស័យកសិកម្មដែរ តែលក្ខណៈពាក់ព័ន្ធដោយប្រើជំនាញច្បាស់លាស់របស់ពួកគេ អាចជាតឹកតាងមួយទ្រទ្រង់ដល់ការលើកឡើងរបស់លោក ឌែល វីត ដូចដែលយើងនឹងឃើញជាបន្តបន្ទាប់ទៅទៀតនេះ ។*

*ទោះបីជាជំនាញការងារដែលលោក ឌែល វីត បានរកឃើញនៅក្នុងប្រទេសកម្ពុជា មិនមានលក្ខណៈខុសប្លែកពីគេក៏ដោយ (នៅតំបន់អាស៊ីអាគ្នេយ៍ទាំងមូល មានការបែងចែកជំនាញការងារទៅតាមប្រភេទជនជាតិ)[១] ក៏ប្រទេសនេះ ពិតជាមានការបែងចែកជំនាញការងារដាច់ពីគ្នា សម្រាប់ក្រុមជនជាតិនីមួយៗ ជាងប្រទេសដទៃទៀតនៅក្នុងតំបន់ ។ បញ្ហាដែលខ្ញុំចង់ពិភាក្សានៅក្នុងជំពូកនេះគឺៈ តើជនជាតិចិននៅក្នុងប្រទេសកម្ពុជាពាក់ព័ន្ធនឹងសកម្មភាពពាណិជ្ជកម្មដល់កម្រិតណា? ឬថា តើជនជាតិចិនទាំងនោះ បង្កើតជាវណ្ណៈអ្នកជំនួញបានធំកម្រិតណា? ដើម្បីឆ្លើយតបនឹងសំណួរទាំងនេះ យើងចាំបាច់ត្រូវស្វែងយល់ពីតួនាទីសេដ្ឋកិច្ច នៃជនជាតិចិននៅក្នុងវិស័យកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ហិរញ្ញវត្ថុ និងការលក់កម្លាំងពលកម្ម ។*

*ការពិភាក្សានៅពេលនេះ គឺយកចិត្តទុកដាក់លើស្ថានភាពបច្ចុប្បន្ន (ការស្រាវជ្រាវនេះធ្វើនៅឆ្នាំ ១៩៦៧)*

ដោយសារយើងអាចទទួលបានព័ត៌មានតាមរយៈការចុះស្រាវជ្រាវដល់ទីកន្លែង ច្រើនជាងតាមរយៈឯកសារសរសេរដែលមានពីមុនមក ។ ប៉ុន្តែការលើកឡើងជាទូទៅ ក៏ឆ្លុះបញ្ចាំងពីការពិតនៅក្នុងសម័យអាណាព្យាបាលបារាំងដែរ ពីព្រោះថានៅពេលដែលស្ថាប័នសេដ្ឋកិច្ចនៅក្នុងសហគមន៍ជនជាតិចិន មានការប្រែប្រួលគួរឲ្យកត់សម្គាល់នោះ តួនាទីជនជាតិចិនទាំងមូល មិនមានការផ្លាស់ប្តូរឡើយក្នុងអំឡុងពេល ៥០ ឆ្នាំចុងក្រោយនេះ ។ ដើម្បីបញ្ជាក់ថា អំណះអំណាងខាងក្រោយជាការត្រឹមត្រូវ យើងនឹងពិភាក្សាលើការប្រែប្រួលមួយចំនួនដែលបានកើតមាន ។

ការប្រែប្រួលមួយដែលបានកើតមានឡើង គឺការប្រែប្រួលនៃប្រព័ន្ធកសិកម្មផ្តាច់មុខ ដែលមានតាំងពីសម័យមុនរហូតដល់សម័យអាណានិគមបារាំង ។ មុនសម័យអាណានិគមបារាំង ព្រះរាជាខ្មែរតែងតែផ្តល់អភ័យឯកសិទ្ធិផ្តាច់មុខ ដល់ជនជាតិចិននៅក្នុងស្រុកក្នុងការប្រមូលថវិកាជាតិពីការធ្វើស្រែចម្ការ អភ័យឯកសិទ្ធិរកស៊ីផ្តាច់មុខលើល្បែងស៊ីសង (និងឆ្នោត) អាភៀន គ្រឿងស្រវឹង ការនេសាទ ហើយនៅកន្លែងខ្លះទៀត ជនជាតិចិនទទួលបានសិទ្ធិផ្តាច់មុខក្នុងការកាប់ឈើ (ឌូប្រ៊ីអ៊ីល ទំ.៧១-៦, អែម៉ូនីញ៉េ ទំ.៣៩, អ៊ី ទំ.១៦៣, ជីឡាប្រ៊ីស្ស៍ ទំ.១៣២១) ។ កំណែទម្រង់នៅឆ្នាំ ១៨៨៤ បានបញ្ចប់ការធ្វើស្រែចម្ការដោយបង់ពន្ធ ហើយបង្វែរផលទុនទាំងស្រុង ទៅក្នុងកណ្តាប់ដៃរដ្ឋបាលបារាំង ។ កាលពីឆ្នាំ ១៨៩០ ការលេងល្បែងស៊ីសងគឺជាអំពើខុសច្បាប់ ។ ក្រោយមកទៀតនៅក្នុងសម័យបារាំង គេអនុញ្ញាតឲ្យលេងល្បែងដោយស្របច្បាប់ (ឌូប្រ៊ីអ៊ីល ទំ.៩៩អេហ្វ) ចំណែកឯនៅពេលបច្ចុប្បន្នមុខរបរនេះឋិតនៅក្រោមការគ្រប់គ្រងផ្តាច់មុខដោយរដ្ឋ និងអនុញ្ញាតឲ្យតែជនជាតិបរទេសចូលលេងប៉ុណ្ណោះ ។ គេក៏អាចបើកក្រុមហ៊ុនឆ្នោតផង បើគេមានលិខិតអនុញ្ញាត ចំណែករដ្ឋាភិបាលវិញបានបង្កើតឆ្នោតជាតិ ដែលចេញលទ្ធផលរៀងរាល់កន្លះខែម្តង ។ ព្រះរាជាខ្មែរ បានប្រគល់សិទ្ធិអំណាចគ្រប់គ្រងចម្ការអាភៀនទៅឲ្យរដ្ឋាភិបាលបារាំងនៅឆ្នាំ ១៨៨៦ ដើម្បីទទួលប្រាក់ឈ្នួលជាប្រចាំឆ្នាំ បន្ទាប់ពីមានការរឹតបន្តឹងការធ្វើចរាចរណ៍និងការប្រើប្រាស់អាភៀនមក (ជាពិសេសរបស់ជនជាតិចិន) (ឌូប្រ៊ីអ៊ីល ទំ. ៧៤) ។ ឥឡូវនេះ អាភៀនជាទំនិញខុសច្បាប់ [២] ចំណែកឯគ្រឿងស្រវឹងវិញ បានធ្លាក់ទៅក្នុងកណ្តាប់ដៃពួកជនជាតិចិនស្ទើរតែទាំងអស់ដែរនៅក្នុងសម័យបារាំង (អ៊ី ទំ.១៦៣) ។ តែសម័យឥឡូវ ជំនួញនេះត្រូវបានគ្រប់គ្រង និងប្រមូលពន្ធដោយរដ្ឋាភិបាល [៣] បើទោះបីគេមិនបានប្រមូលពន្ធពីកន្លែងបិទស្រា និងកន្លែងបិទទឹកត្នោតជូរសម្រាប់តម្រូវការនៅតាមភូមិទាំងឡាយក៏ដោយ ។ សិទ្ធិនេសាទត្រីនៅបឹងទន្លេសាប ត្រូវគេជួលទៅឲ្យអ្នកម៉ៅការ ហើយអ្នកម៉ៅការទាំងនោះបានលក់សិទ្ធិនេះជាបន្តបន្ទាប់ទម្រាំបានដល់ដៃអ្នកនេសាទ គឺមានរហូតដល់ទៅ ៥ ឬ ៦ តំណាងណោះ (វ៉ាង វិនយន់ ទំ.៥១) ។ ទោះជាអ្នកនេសាទភាគច្រើនជាជនជាតិវៀតណាមក៏ដោយ ក៏អ្នកម៉ៅការទាំងអស់សុទ្ធតែជាជនជាតិចិន ។ ប្រព័ន្ធបែបនេះ នៅតែមានប្រសិទ្ធភាពរហូតដល់សព្វថ្ងៃ ដូចច្នេះហើយនៅក្នុងសម័យបារាំង យើងអាចមើលឃើញយ៉ាងច្បាស់ថា រាល់កសិដ្ឋានចិញ្ចឹមត្រីទាំងអស់ (លើកលែងតែផលទុន) អាចត្រូវបានគេចាត់ចូលជារូបភាពពាណិជ្ជកម្មរបស់ជនជាតិចិន ជាជាងចាត់ទុកជាប្រព័ន្ធមួយដាច់ដោយឡែក ។ ប៉ុន្តែសម័យបច្ចុប្បន្ននេះអ្វីដែលខុសគ្នានោះ គឺខុសត្រង់តែកម្រិតពាក់ព័ន្ធរបស់ពួកគេតែប៉ុណ្ណោះ ។

ភាពខុសគ្នារវាងស្ថានភាពសេដ្ឋកិច្ចរបស់ជនជាតិចិន នៅសម័យអាណាព្យាបាលបារាំង និងនៅសម័យបច្ចុប្បន្ននេះ គឺស្ថិតនៅត្រង់ថា រដ្ឋអំណាចបារាំងមិនមានការដាក់កំហិតប្រភេទការងារ ចំពោះពួកជនជាតិចិនទេ តែសព្វថ្ងៃនេះ ពួកជនបរទេសត្រូវគេហាមមិនឲ្យធ្វើការងារចំនួន ១៨ ប្រភេទ ។ ជាការពិតណាស់ ការដាក់កំហិតលើការកាន់កាប់ទ្រព្យសម្បត្តិ អាចរារាំងមិនឲ្យជនជាតិចិនកាន់កាប់ចម្ការកៅស៊ូ ឬអណ្តូងរ៉ែ (រ៉ូប៊ឺកាំង ទំ.៣៦) ប៉ុន្តែ

ក្រៅពីនេះ ជនជាតិចិនអាចប្រកបការងារផ្សេងទៀត សូម្បីតែជាគ្រូបង្រៀន អ្នកបោះពុម្ព និងម្ចាស់សណ្ឋាគារ ដែលការងាររបស់ជនបរទេសផ្សេងទៀត ក្រៅពីជនជាតិបារាំង មិនអាចប្រកបការងារទាំងអស់នេះបានឡើយ (ឡេវ៉ាស័រ ទំ.១២០អេហ្វអេហ្វ) ។ ដូច្នេះហើយទើបលោកឡេវ៉ាស័រ បានលើកឡើងថា ជនជាតិចិននៅឥណ្ឌូចិន មានសិទ្ធិសេរីភាពច្រើនជាងជនជាតិបរទេសនៅរាជធានីបារាំងទៅទៀត (ប្រភពដដែល)។

ច្បាប់ដែលកំហិតមុខរបរទាំង ១៨មិនឲ្យជនបរទេសនៅកម្ពុជា ត្រូវបានប្រកាសដោយជំពូកទី ២៦ នៃច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៥៦ (ក្រមលេខ ៨៣ ន.ស. ព្រឹត្តិបត្ររដ្ឋាភិបាលកម្ពុជាឆ្នាំ ១៩៥៦ ទំ.៧៨៩-៧៩៨)។ ច្បាប់នេះបានចែងដូចខាងក្រោម (ការបកប្រែរបស់អ្នកនិពន្ធផ្ទាល់)÷

មិនមានជនបរទេសណាម្នាក់ អាចប្រកបមុខរបរដូចខាងក្រោមឡើយ÷

- ភ្នាក់ងារពន្ធដារ
- ភ្នាក់ងារដឹកជញ្ជូនតាមកាណូត ឬកប៉ាល់
- ភ្នាក់ងារស៊ើបការណ៍សម្ងាត់ ឬភ្នាក់ងារប៉ូលិសឯកជន
- ភ្នាក់ងារអន្តោប្រវេសន៍
- នាយកភ្នាក់ងារផ្តល់ការងារ
- អ្នកចែកចាយទំនិញទូទៅ
- អ្នកជួញអាវុធ និងគ្រាប់រំសេវ
- អ្នកផលិត ឬចែកចាយវិទ្យុ ឬគ្រឿងផ្គួសផុល
- អ្នកបោះពុម្ព
- ជាងកាត់សក់មនុស្សប្រុសទោះជាថៅកែ ឬកូនជាង
- អ្នកចែកចាយសម្ភារៈប្រើប្រាស់ផ្ទះ ឬអ្នកចងការប្រាក់
- អ្នកបើកកប៉ាល់តាមទន្លេ ឬសមុទ្រ
- អ្នកលក់គ្រឿងអលង្ការ ឬជាងមាស ទោះជាថៅកែ ឬកូនជាង
- អ្នកបើកឡានអូតូតាក់ស៊ី និងយានយន្តគ្រប់ប្រភេទ
- អ្នកដើរកេប៉ាល់ផ្លូវឆ្ងាយ
- អ្នកកាត់ឈើ
- អ្នកជំនួញគ្រាប់ធញ្ញជាតិ
- អ្នកចែកចាយអំបិល

ទោះបីការហាមឃាត់ការងារមួយចំនួនខាងលើ ត្រូវកំណត់ឡើងដោយសារមានការពាក់ព័ន្ធនឹងសន្តិសុខជាតិក៏ដោយ ក៏បម្រាមទាំងនេះ ភាគច្រើនមានគោលដៅធ្វើជាតូបនីយកម្មមុខរបរជនជាតិ ដែលនេះមានន័យថាជាដំណើរការណ៍ដកយកមុខរបរ ដែលធ្លាប់តែជារបស់ជនជាតិចិនមកឲ្យជនជាតិកម្ពុជាវិញ ។ ដំណើរការណ៍ជាតូបនីយកម្មនេះ បានកើតមានឡើងនៅពាសពេញតំបន់អាស៊ីអាគ្នេយ៍នាកំឡុងពេលនោះ(៤) ។ យ៉ាងណាមិញបើយើងពិចារណាអំពីការប្រែប្រួល នៃទ្រង់ទ្រាយជាតិពន្ធុក្រោយសម័យឯករាជ្យ និងកង្វះជនអន្តោប្រវេសមកពីស្រុកចិនការហាមប្រាមខាងលើ មិនមានភាពខុសប្លែកច្រើនឡើយ លើកលែងតែការងារកម្លាំងពលកម្ម

សំខាន់ៗ ។ នាវិកកប៉ាល់ឆ្ងាយៗ ជាងកាត់សក់ និងអ្នកបើកឡាន ដែលពីមុនមកសុទ្ធតែជាជនជាតិចិន ឥឡូវនេះភាគច្រើនជាជនជាតិខ្មែរ ។ តែជនជាតិចិននៅតែបន្តបើកមុខរបរបោះពុម្ព និងបើកហាងលក់វិទ្យុ ហាងមាស គ្រឿងអលង្ការ និងរត់កាណូតតាមដងទន្លេមេគង្គ ។

នេះជាភស្តុតាងបង្ហាញថា ហេតុអ្វីបានជាជនជាតិបារាំង មិនបានដាក់ការរឹតបន្តឹងលើជនជាតិចិននៅកម្ពុជា និងនៅតំបន់ផ្សេងទៀតនៃឥណ្ឌូចិន ។ ចំពោះបារាំងសកម្មភាពអ្នកជំនួញចិនមានសារៈសំខាន់ និងគួរជាទីប្រាថ្នា ដោយសារជនជាតិចិនទាំងនោះ រកស៊ីមុខរបរដែលក្រុមហ៊ុនបារាំងមិនសូវចាប់អារម្មណ៍ (អ៊ុ ទំ.១៦៩ អ៊ុ, គូលេ ទំ. ៤៦៣, ថមសុន ទំ. ១៦៧, ឌូប្រ៊ីអ៊ីល ទំ. ៧១, រ៉ូប៊ីកាំង ទំ. ៤២) លើសពីនេះទៅទៀតជនជាតិចិនអាចផ្គត់ផ្គង់សម្ភារៈប្រើប្រាស់ដល់រដ្ឋបាលអាណានិគម ក្នុងតម្លៃថោកជាងក្រុមហ៊ុនបារាំង ហើយជនជាតិបារាំងជាច្រើនពឹងផ្អែកលើជនជាតិចិនវណ្ណៈកណ្ដាល ក្នុងការចែកចាយទំនិញនាំចូល និងប្រមូលទិញផលិតផលពីទីជនបទ ។ ទោះបីជាមានជនជាតិបារាំងមួយចំនួនយល់ថា ពួកជនជាតិចិនជាគ្រោះថ្នាក់សម្រាប់ពួកគេក៏ដោយ តែជាទូទៅ ជនជាតិចិនបានរួមចំណែកយ៉ាងច្រើន នៅក្នុងសេដ្ឋកិច្ចនៃឥណ្ឌូចិនបារាំង ។ ដូចច្នេះហើយ ទើបគេហៅជនជាតិចិនថាជា «មេដំបែដ៏មានតម្លៃ» សម្រាប់របបអាណានិគម (ហេប, ទំ.២៥៥ ឌូប្រ៊ីអ៊ីល ទំ.៩៧អេហ្វ) ។

ភាពខុសប្លែកគ្នាមួយទៀត រវាងសម័យអាណាព្យាបាលបារាំង និងសម័យកម្ពុជាបច្ចុប្បន្ន នោះគឺថា ប្រទេសកម្ពុជា គឺជាតំបន់ឃ្លាតឆ្ងាយពីសេដ្ឋកិច្ច និងនយោបាយនៅកូសាំងស៊ីននៅពេញមួយសម័យដែលបារាំងគ្រប់គ្រង ហើយសូម្បីតែកាលពីមួយសតវត្សមុនក៏ដោយ ។ (ចូរប្រៀបធៀបជាមួយ វីញុន ទំ. ៣៧៦-៧) ។ ត្រង់ចំណុចនេះ យើងគួរកត់សម្គាល់ជាពិសេស ពីការដឹកជញ្ជូនស្រូវនៅកម្ពុជា។ នៅពេលនោះ ផលិតផលស្រូវកម្ពុជាទាំងអស់ទោះជាស្រូវនៅបាត់ដំបង ដែលស្ថិតក្រោមការត្រួតត្រារបស់សៀម ក៏ត្រូវដឹកជញ្ជូនទៅរោងម៉ាស៊ីនកិនស្រូវនៅក្រុងសៃហ្គន់-សូឡុង(Saigon-Cholon)ដែរ ។ ទោះបីជាគ្មានភស្តុតាងជាក់ច្បាស់ស្ដីពីរឿងហ្នឹងក៏ដោយ ក៏ខ្ញុំជឿថាក្រុមហ៊ុនសារជីវកម្មភាគច្រើននៅទីក្រុងភ្នំពេញ ត្រូវបានបង្កើតឡើងសម្រាប់ធ្វើជាតំណាងសាខា និងជាភ្នាក់ងារតំណាងឲ្យក្រុមហ៊ុនធំៗនៅសូឡុង និងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីទីនោះមក ។ សំខាន់ជាងនេះទៅទៀតតម្រូវការចាំបាច់សម្រាប់រដ្ឋបាលបារាំងទាំងអស់មាននៅក្រុងសៃហ្គន ហើយជនអន្តោប្រវេសចិនស្ទើរតែទាំងអស់ត្រូវបានគេបណ្ដេញចេញពីទីនោះ និងបន្តភៀសខ្លួនមកកាន់ប្រទេសកម្ពុជាតែមួយគត់ ដោយសារពួកគេមិនមានឱកាសល្អនៅកូសាំងស៊ីន ។ សព្វថ្ងៃនេះ ដោយសារទំនាក់ទំនងមិនល្អ រវាងប្រទេសជិតខាងទាំងពីរ មានជំនួញស្របច្បាប់ឆ្លងកាត់ព្រំដែនតិចតួចប៉ុណ្ណោះ ។ ទំនិញនាំចេញរបស់កម្ពុជា ត្រូវបានដឹកជញ្ជូនផ្ទាល់ពីក្រុងភ្នំពេញនិងក្រុងព្រះសីហនុឆ្ពោះទៅកាន់ប្រទេសសិង្ហបុរី ទីក្រុងហុងកុង និងកំពង់ផែដទៃទៀត ។ រហូតមកដល់ខែមករាឆ្នាំ ១៩៦៤ នៅពេលមានដំណើរការជាតូបនីយកម្មលើការនាំចេញ-នាំចូលនោះ ក្រុមហ៊ុនឯកជនដែលមានអាជ្ញាប័ណ្ណនៅកម្ពុជាបានកាន់កាប់រាល់ជំនួញក្រៅប្រទេសរបស់កម្ពុជាទាំងអស់ ។ ការកាត់ផ្ដាច់ពីក្រុងសូឡុង បានដះឥទ្ធិពលកាន់តែខ្លាំង លើរចនាសម្ព័ន្ធផ្ទៃក្នុងនៃសហគមន៍ជំនួញជនជាតិចិននៅក្រុងភ្នំពេញ ជាជាងតួនាទីផ្អែកជំនួញរបស់ពួកគេនៅក្នុងសហគមន៍ទាំងមូល ។

ចំណុចខុសប្លែកគ្នាចុងក្រោយរវាងសម័យបារាំង និងសម័យកាលនៃការស្រាវជ្រាវនេះ គឺថានាមុនសង្គ្រាមចិន និងជប៉ុន បារាំងជាអ្នកគ្រប់គ្រងផ្ដាច់មុខនូវការនាំចេញ-នាំចូល នេះគឺជាព័ត៌មាន ដែលបានមកពីអ្នកផ្ដល់ព័ត៌មានរបស់ខ្ញុំ ។ មានតែនៅក្នុងអំឡុងពេលសង្គ្រាមចិន-ជប៉ុនប៉ុណ្ណោះ ដែលក្រុមហ៊ុនចិនបានរៀបចំការនាំចេញ

របស់ពួកគេផ្ទាល់ ហើយនៅក្នុងឆ្នាំ ១៩៦២-៦៣ ក្រុមហ៊ុនចិននៅក្រុងភ្នំពេញ បានគ្រប់គ្រងពាណិជ្ជកម្មនាំចេញ-នាំចូលរបស់កម្ពុជាស្ទើរតែទាំងអស់ ។ ប៉ុន្តែគេអាចសង្កេតឃើញថា សម្រាប់កម្ពុជា (ផ្ទុយពីឥណ្ឌូចិនទាំងមូល)ភាពខុសប្លែកគ្នានេះ បានស្តែងឡើងយ៉ាងច្បាស់ជាងការពិតទៅទៀត ។ កាលមុនសម័យសង្គ្រាម ក្រុមហ៊ុនចិននៅក្រុងភ្នំពេញ ដឹកទំនិញទៅកាន់ក្រុងសូឡុង ដូចដែលពួកគេនាំទំនិញចេញទៅកាន់បរទេសនាឆ្នាំ ១៩៦២-៦៣។ សព្វថ្ងៃនេះ ដោយសារដំណើរការជាតូបនីយកម្មលើការនាំចេញ-នាំចូលសាជីវកម្មជនជាតិចិនត្រូវគេកម្រិតឲ្យនៅត្រឹមតែជាឈ្មួញកណ្តាលសម្រាប់ការលក់ដុំ និងលក់រាយ ដែលនាំចូលដោយភ្នាក់ងាររដ្ឋាភិបាលហើយប្រមូលទិញទំនិញក្នុងស្រុក ដែលនឹងនាំចេញដោយភ្នាក់ងាររដដែលនេះ ។

ប្រសិនបើគេមានការអង្កេតខ្វះនោះ គេអាចធ្វើការសន្និដ្ឋានជាទូទៅ ពីតួនាទីសេដ្ឋកិច្ចរបស់ជនជាតិចិនដែលការសន្និដ្ឋាននោះ នៅតែឆ្លុះបញ្ចាំងពីស្ថានភាពពិតទាំងនៅក្នុងសម័យបារាំង និងទាំងសម័យកម្ពុជាបច្ចុប្បន្ន ។

## ជនជាតិចិនក្នុងវិស័យកសិកម្ម

អ្នកនិពន្ធមួយចំនួនបានលើកឡើងថា ជនជាតិចិននៅកម្ពុជា បានចូលប្រលូកក្នុងវិសយកសិកម្មច្រើនជាងជនជាតិចិននៅក្នុងប្រទេសដទៃទៀត នៃតំបន់ឥណ្ឌូចិន ។ ដោយឡែកមានអ្នកខ្លះអះអាងថា ជនជាតិចិនមួយចំនួននៅកម្ពុជា បានក្លាយជាកសិករធ្វើស្រែ (គូឡេត ទំ.៤៦២)។ ដោយផ្អែកលើការប៉ាន់ស្មានផ្ទាល់ខ្លួន អ្នកនិពន្ធម្នាក់បានសន្និដ្ឋានថា ជនជាតិចិននៅកម្ពុជាចំនួនពាក់កណ្តាលរស់នៅតាមតំបន់ជនបទ នៅពេលដែល ជនជាតិចិនចំនួនច្រើនជាងនេះ នៅក្នុងប្រទេសផ្សេងទៀតនៃឥណ្ឌូចិនបារាំងរស់នៅក្នុងទីប្រជុំជន ។ សូម្បីតែសព្វថ្ងៃនេះមានជនជាតិចិនច្រើនជាង ៤០% កំពុងរស់នៅទីជនបទ ប៉ុន្តែមានចំនួនភាគរយតិចតួចប៉ុណ្ណោះ នៃជនជាតិចិនដែលបានបន្តការពាក់ព័ន្ធក្នុងវិស័យកសិកម្មនេះ ហើយពួកគេទាំងនោះកម្រធ្វើស្រែណាស់ ។ នៅកម្ពុជា សកម្មភាពកសិកម្មសំខាន់ៗដែលពួកគេធ្វើនោះ គឺការដាំម្រេច និងការធ្វើចម្ការបន្លែ ។ ជនជាតិចិនជាច្រើន ចូលចិត្តប្រកបរបរនៅក្នុងឧស្សាហកម្មស្រូវគ្រប់កម្រិតដូចជា៖ ការដួញដូរ ការកិន និងការដឹកជញ្ជូនស្រូវប៉ុន្តែមានជនជាតិចិនមួយចំនួនតូចប៉ុណ្ណោះ ប្រកបមុខរបរជាកសិករធ្វើស្រែនៅកម្ពុជា ។ អ្នកទាំងនោះគឺជាចិនខេះ មួយចំនួននៅខេត្តតាកែវ នឹងពួកកសិករចិននៅខេត្តបាត់ដំបង ដែលជាកូនចៅរបស់ចិនហុកកៀន ប៉ុន្តែពួកគេបានបន្សាំខ្លួន រស់នៅដូចជនជាតិកម្ពុជាដទៃទៀតនៅតាមភូមិដ្ឋានផ្សេងៗដែរ រហូតដល់សព្វថ្ងៃនេះ គេពិបាកនឹងនិយាយបានថាមួយណាជាជនជាតិចិនណាស់ ។ បើយោងតាមនិយមន័យដែលបានកំណត់ថា ជនជាតិចិន គឺជាអ្នកមានការចូលរួមក្នុងសហគមន៍ចិននោះ ពួកគេទាំងនោះប្រហែលជាមិនមែនជាជនជាតិចិនទេ ព្រោះពួកគេមិនបានចូលរួមឬស្ថិតនៅក្នុងសមាគមន៍ចិនឡើយ មិនត្រឹមតែប៉ុណ្ណោះកូនរបស់ពួកគេក៏មិនដែលបានចូលរៀនក្នុងសាលាចិនដែរ ។ ដូចច្នេះ គេត្រូវចាត់ទុកការរួមចំណែករបស់ជនជាតិចិន នៅក្នុងវិស័យពាណិជ្ជកម្មស្រូវទាំងមូល ថាជាសកម្មភាពជំនួញជាជាងសកម្មភាពកសិកម្ម ។ យើងត្រូវការតែការពិភាក្សាអំពីការដាំម្រេច និងការធ្វើចម្ការដំណាំ ដែលជាសកម្មភាពកសិកម្មចម្បងរបស់ជនជាតិចិន(មានជនជាតិចិនមួយចំនួនតូចដាំថ្នាំជក់ និងផ្កាឈូកនៅខេត្តកំពតហើយមានជនជាតិចិនម្នាក់ បានដាំកៅស៊ូចំនួនពីរបីអាក្នុងពេលថ្មីៗនេះ តែមិនទាន់បានប្រមូលផលនៅឡើយទេ) ។

## ចម្ការម្រេច

រហូតមកដល់សម័យសង្គ្រាមលោកលើកទី ២ កម្ពុជា គឺជាប្រទេសឈានមុខគេក្នុងការនាំចេញម្រេច ។ ម្រេចគឺជាទំនិញនាំចេញដ៏មានតម្លៃបំផុតរបស់កម្ពុជា ពេញមួយសម័យបារាំង (អានស្តាត ១៩៥២ និង ១៩៥៨, តារាង ២-៧) ។

ខ្ញុំបានគ្រាន់និយាយរួចមកហើយ អំពីរបៀបដែលជនជាតិចិនហៃណាំ បានក្លាយជាអ្នកដាំម្រេចធំជាងគេនៅកម្ពុជា បន្ទាប់ពីការតាំងលំនៅដ្ឋានរបស់ជនជាតិចិនម្នាក់ឈ្មោះម៉ាក់គុ នៅតំបន់ហាទៀងប្រទេសវៀតណាម។ ទោះបីជាជនជាតិខ្មែរធ្លាប់បានបេះផ្លែម្រេចព្រៃចាប់តាំងពីសម័យអង្គរក៏ដោយ ក៏តំបន់ផ្សេងទៀតនៃប្រទេសកម្ពុជាមិនសាកសមនឹងដាំដុះម្រេចទេ ហើយម្យ៉ាងទៀត តម្រូវការដើមទុនច្រើនសន្ធឹកសន្ធាប់ក្នុងការចាប់ផ្តើមធ្វើចម្ការម្រេច គឺឧបសគ្គរារាំងមិនឲ្យជនជាតិខ្មែរចូលប្រលូកក្នុងការប្រកបរបរនេះ ។ (ហ្គារី ទំ.១៣៣ និង ១៣៩ អេហ្វ ។ លើសពីនេះទៅទៀត ការងារដ៏លំបាក និងផ្ចិតផ្ចង់ក្នុងការបណ្តុះកូនម្រេច គឺជាមូលហេតុមួយទៀតដែលជនជាតិខ្មែរសម្រេចមិនជ្រើសរើសមុខរបរនេះ ។ ដើមម្រេចត្រូវតែនៅក្រោមម្លប់ស្ទើរតែពេញមួយឆ្នាំ ហើយកូនម្រេចត្រូវការស្រោចទឹក និងដាក់ជីជារៀងរាល់ថ្ងៃ ចំណែកផ្ការបស់វាត្រូវតែច្បូតយកចេញពីដើមដោយប្រុងប្រយ័ត្នបំផុត ក្នុងអំឡុងពេលពីរបីឆ្នាំដំបូង ។ ម្ចាស់ចម្ការម្រេចជនជាតិហៃណាំបានជួលពលករកុងត្រាពីកោះហៃណាំឲ្យធ្វើកិច្ចការទាំងអស់នេះ កិច្ចកុងត្រាសម្រាប់ពលករភាគច្រើនមានរយៈកាលកំណត់បីឆ្នាំ ។ ពលករទាំងនោះ មួយចំនួនធំនៅតែបន្តរស់នៅកម្ពុជា ដើម្បីធ្វើជាអ្នកជំនួញតូចៗ ឬបង្កើតចម្ការផ្ទាល់ខ្លួន (ហ្គារី ទំ.១៣៥) ។ ហេតុដូច្នេះហើយ ទើបខេត្តកំពតដែលពីមុនធ្លាប់ថិតនៅក្រោមការគ្រប់គ្រងរបស់ម៉ាកគុ និងកូនប្រុសរបស់គាត់ មានការប្រមូលផ្តុំទៅដោយជនជាតិហៃណាំ ជាពិសេសនៅតំបន់កំពង់ត្រឡាច ទូកមាស និងក្រុងកំពត ។

គេមិនបានដឹងទេថា នៅពេលណាដែលជនជាតិចិនហៃណាំ ចាប់ផ្តើមដាំម្រេចដំបូងនៅខេត្តកំពត ។ ថ្មីៗនេះ លោកហ្គារីបានសរសេរអំពីម្រេចកម្ពុជា ប៉ុន្តែគាត់មិនបានផ្តល់ភាពសុក្រឹតខាងផ្នែកប្រវត្តិសាស្ត្រ ហើយយើងមិនអាចពឹងផ្អែកលើកាលបរិច្ឆេទរបស់គាត់ ទាក់ទងនឹងរឿងម្រេចបានឡើយ[៥] ។ គាត់បានលើកឡើងថាមានការកត់ត្រាអំពីចម្ការតូចៗនៅកូស៊ាំងស៊ីននាឆ្នាំ ១៨៤០ (ហ្គារី ទំ.៣៤) ប៉ុន្តែគាត់បានថ្លែងបញ្ជិតបញ្ជៀងថា ម្រេចត្រូវបានគេដាំនៅតំបន់ហាទៀងក្នុងអំឡុងសតវត្សទី ១៨ ទៅវិញ ។ ក្នុងករណីណាក៏ដោយចម្ការទាំងឡាយត្រូវបានបង្កើតឡើងយ៉ាងហ្មត់ចត់ នៅពេលមហាអំណាចបារាំងមកដល់ ។ គេនាំម្រេចកម្ពុជាចេញទៅកាន់ប្រទេសចិន រីឯម្រេចកូស៊ាំងស៊ីនត្រូវនាំចេញទៅកាន់សិង្ហបុរី ទីនោះ គឺជាកន្លែងដែលម្រេចត្រូវគេដឹកជញ្ជូនបន្តទៅអឺរ៉ុបក្រោមស្លាក «ម្រេចសិង្ហបុរី («ផលិតផល និងពាណិជ្ជកម្មម្រេចនៅតណ្ឌូចិន» ៤៥០) ។ ការកាត់បន្ថយពន្ធលើទំនិញនាំចូលប្រទេសបារាំងនាឆ្នាំ ១៨៩១-២ បានបណ្តាលឲ្យមានកំណើនការនាំចេញគួរឲ្យកត់សម្គាល់ឆ្ពោះទៅកាន់ប្រទេសបារាំងដោយផ្ទាល់ (អានឌុយកាំប ១៨៩៤ ទំ.២៥) ។ ចាប់តាំងពីឆ្នាំ ១៨៩២ ការនាំចេញម្រេចកម្ពុជាបានកើនឡើងជាបន្តបន្ទាប់ពី ៥៩០ តោនទៅដល់ប្រហែល ៤.០០០ តោនមុនពេលសង្គ្រាមរវាងចិន និងជប៉ុន[៦]។ ចាប់តាំងពីពេលកើតសង្គ្រាមមក ផលិតផលម្រេចបានធ្លាក់ចុះគួរឲ្យកត់សម្គាល់ ហើយការនាំចេញបានធ្លាក់ចុះមកត្រឹម ១.៦០០ តោនសម្រាប់ឆ្នាំ ១៩៤៧ (ហ្គារី ទំ.១៤១) ។ លោកហ្គារីបានលើកឡើងថា មានហេតុផលបីយ៉ាងដែលនាំឲ្យមានការធ្លាក់ចុះដូច្នេះ÷ ទី (១) កង្វះខាតជីក្នុងពេលមានសង្គ្រាម បានធ្វើឲ្យដីនៅកំពតកាន់តែខ្សោះជីវជាតិ ។ (២) ការត្រួតត្រារបស់ជប៉ុនលើកោះហៃណាំ បានរារាំងមិនឲ្យមានពលករអន្តោប្រវេសន៍ចេញពីស្រុក។ (៣)សំខាន់បំផុតនោះគឺពពួកសត្វល្អិតចង្រៃប៉ារ៉ាស៊ីតបានបំផ្លាញដើមម្រេច(ហ្គារី ១៩៦៣ ទំ.១៣៨ (អាររយ ទំ.៩៦៣, ១៣៨)) ។

បន្ថែមពីលើហេតុផលទាំងនេះមានមូលហេតុពីរទៀត គឺ (៤)ដោយយោងទៅតាមអ្នកដាំម្រេចជាជនជាតិចិនហៃណាំផ្ទាល់ សកម្មភាពពួកចោរព្រៃ និងពួកឧទ្ទាមនៅខេត្តកំពតក្នុងកំឡុងសង្គ្រាមឥណ្ឌូចិនលើកទី១ បានធ្វើឲ្យអ្នកដាំដំណាំម្រេចជាច្រើនចាកចោលភូមិដ្ឋាន និងចម្ការដំណាំទៅទីក្រុងអស់រយៈពេលពីរបីឆ្នាំ ។ ដើមម្រេចស្រស់មិនមានអ្នកថែរក្សាទាំងនោះត្រូវខូចខាតអស់ ។ មូលហេតុទី (៥)គឺដោយសារតែតម្លៃនៃផ្លែម្រេចខ្មៅនៅភ្នំពេញបានធ្លាក់ចុះពីប្រហែល ៩០ រៀលក្នុង ១ គីឡូទៅតម្លៃប្រហែល ៥០ រៀលចាប់តាំងពីពេលសង្គ្រាមចាប់ផ្តើម ។

ការពិនិត្យលើស្ថិតិនៃការនាំចេញម្រេចបានបង្ហាញថា មានកម្រិតប្រែប្រួលខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ។ជាឧទាហរណ៍ ក្នុងកំឡុងពេលបីឆ្នាំជាប់គ្នា ១៩៥៨-៥៩-៦០ ការនាំចេញមានបរិមាណរៀងគ្នា ១.០០០-១.៤០០ និង ១.២០០តោន (ហ្គារី, ទំ.១៤១) ដែលការប្រែប្រួលនេះខុសគ្នា ៤០% រវាងឆ្នាំនីមួយៗ ។ លទ្ធភាពនៃការកើនឡើង និងធ្លាក់ចុះបែបនោះបង្ហាញឲ្យគេឃើញថា ការដាំដុះម្រេច គឺជារបរមួយដែលមានការប្រថុយប្រថានខ្លាំងណាស់ មានដូចការប្រថុយនឹងគ្រោះថ្នាក់បាត់បង់ដើមទុនលើការវិនិយោគធំៗ ទាំងហិរញ្ញវត្ថុនិងកម្លាំងពលកម្មជាដើម ។

មិនមានអ្វីគួរឲ្យចម្លែកទេ ដែលម្រេចគឺជាដំណាំគ្រប់គ្រងផ្តាច់មុខដោយជនជាតិចិនហៃណាំនៅក្នុងប្រវត្តិចម្ការម្រេចប្រទេសកម្ពុជា ។ លោកហ្គារីបានផ្តល់តារាងទិន្នន័យដែលនាំឲ្យគេយល់ខុស ពោលគឺតារាងនោះបង្ហាញថា សូម្បីតែនៅឆ្នាំ១៩៤២ ៨៥% នៃអ្នកដាំម្រេចជាជនជាតិកម្ពុជា ផលិតបានម្រេច ៥១% នៃរុក្ខជាតិមានទ្រើងដំណាលពេលដែលតួលេខសម្រាប់ឆ្នាំ ១៩៥៨ មានកសិករ ៨៦% ហើយផលិតបាន ៦៩% (ហ្គារី ទំ.១៣៥អេហ្វ) ។ ទោះជាយ៉ាងណាក៏ដោយ គេត្រូវតែចងចាំថា ច្បាប់ហាមឃាត់ជនជាតិចិនមិនឲ្យកាន់កាប់ទ្រព្យសម្បត្តិ បានអនុម័តឡើងនៅឆ្នាំ១៩២៩ ដូច្នេះហើយ ទើបមានជនជាតិចិនហៃណាំជាច្រើន បានទាមទារសញ្ជាតិកម្ពុជាតាមរយៈការរស់នៅកម្ពុជា និងមានដូនតាជាជនជាតិកម្ពុជា ។ ជនជាតិកម្ពុជាភាគច្រើនបំផុត ដែលប្រកបរបរធ្វើចម្ការម្រេចពីមុនជាជនជាតិចិន ហើយឥឡូវនៅតែជាជនជាតិចិនដដែល ទោះជានៅទសវត្សរ៍ចុងក្រោយមានចម្ការម្រេចខ្លះត្រូវគេជួលទៅឲ្យជនជាតិខ្មែរក៏ដោយ ។ ជនជាតិចិនហៃណាំ ដែលបានរស់នៅខេត្តកំពតអស់ប៉ុន្មានជំនាន់មកហើយ និងច្រើនមានម្តាយ ឬជីដូនជាជនជាតិខ្មែរ នៅតែត្រូវគេចាត់ទុកថាជាសមាគមចិន និយាយភាសាចិនហៃណាំនៅទូទាំងខេត្ត ។ អ្នកផ្តល់ព័ត៌មានទាំងអស់ទាំងនៅក្នុងចំណោមចិនហៃណាំ និងនៅក្នុង «នាយកដ្ឋានកសិកម្ម» បានយល់ស្របចំពោះភាពពិត ។ នៅកម្ពុជា ជនជាតិបារាំងមិនដែលពិពណ៌នាអំពីចម្ការម្រេចលើសពីទំហំពីរបីអាឡើយ («ស្ថានការណ៍អាណានិគមន៍អឺរ៉ុបនៅកម្ពុជា» ទំ.២៦៧, ដែននីរី ១៩៣១ ទំ.១៣៦,ហ្គារីទំ.១៣៥, រ៉ូប៊ីកាំង ទំ. ៣៦)។

## ចម្ការដំណាំ និងផ្លែឈើ

នៅជុំវិញក្រុងនីមួយៗ និងទីប្រជុំជនលក់ដូរនៅកម្ពុជា គេប្រទះឃើញមានចម្ការដំណាំ និងចម្ការផ្លែឈើដែលមានដាំដំណាំបន្លែបង្ការ និងផ្លែឈើសម្រាប់លក់នៅទីផ្សារក្នុងក្រុង ហើយស្ទើរតែគ្រប់ចម្ការទាំងអស់ មានជនជាតិចិនជាអ្នកដាំ ។ នាយកដ្ឋានកសិកម្មបានប្រាប់ឲ្យខ្ញុំដឹងថា មុនសម័យឯករាជ្យជនជាតិចិនគឺជាអ្នកដាំដុះបន្លែយ៉ាងសំខាន់ ប៉ុន្តែឥឡូវ ដោយសារទីក្រុងភ្នំពេញមានការរីកលូតលាស់យ៉ាងរហ័ស ជនជាតិខ្មែរជាច្រើនដែលរស់នៅជុំវិញទីក្រុង បានឈានទៅប្រកបរបរនេះដែរ ។ អ្នកផ្តល់ព័ត៌មានខ្លះបាននិយាយប្រាប់យើងថា មានចម្ការបន្លែដែលដាំដោយជនជាតិវៀតណាមដែរ បើយើងធ្វើដំណើរចុះតាមច្រាំងខាងកើត នៃទន្លេបាសាក់នៅខាងត្បូងក្រុងភ្នំពេញ

*ដែលជាតំបន់មួយមានដាំដំណាំច្រើនបំផុតសម្រាប់ក្រុងភ្នំពេញ យើងនឹងមានចំណាប់អារម្មណ៍ជាពិសេស នៅពេលឆ្លងកាត់ភូមិចិនដ៏វែងមួយ លម្អដោយយ័ន្តក្រដាសក្រហមបិទពីលើទ្វារ ដោយឃើញកូនចិនលេងនៅលើផ្លូវ នារីត្បាញក្រណាត់ដោយប្រើកីចិននៅលើរាលហាលមុខផ្ទះ[៧] ហើយមានសាលារៀនចិនមួយ និងវិហារចិនមួយ សម្រាប់បម្រើការក្នុងតំបន់ ។ នៅតាមច្រាំងខាងលិច កាត់តាមចម្ការផ្លែឈើតម្រង់ទៅទិសខាងត្បូងនៃ (ក្រុង) តាខ្មៅ គេនឹងមានការចាប់អារម្មណ៍ ប្រហាក់ប្រហែលគ្នានេះដែរ ។*

*ចម្ការដំណាំ ក៏ដូចជាចម្ការម្រេចដែរ តម្រូវឲ្យមានការចំណាយដើមទុនច្រើន ដើម្បីជួលកម្មករដាំដុះជាបន្តបន្ទាប់ និងមានការប្រថុយប្រថានខ្ពស់ ព្រោះថាផលិតផលអាចធាប់ស្អុយខូច ហើយដំណាំនៅតាមដងទន្លេ ក៏ងាយនឹងរងគ្រោះដោយសារទឹកជំនន់ដែរ ។ គេដាំដំណាំសម្រាប់លក់ មិនមែនសម្រាប់តែហូបចុកផ្ទាល់ខ្លួននោះទេ ទាំងបន្លែ និងម្រេចសុទ្ធតែជាដំណាំសម្រាប់លក់ខុសពីដំណាំស្រូវ ព្រោះផលិតផលស្រូវគេទុកសម្រាប់ហូបលើកលែងតែគេមានផលិតផលលើសប៉ុណ្ណោះ ដែលគេយកទៅលក់ ។*

*ដូចច្នេះហើយ ការពាក់ព័ន្ធរបស់ជនជាតិចិន ក្នុងវិស័យកសិកម្មអាចត្រូវបានគេចាត់ទុកថា ជាសកម្មភាពជំនួញដែលគេរំពឹងថា នឹងអាចទទួលប្រាក់ចំណេញពីការវិនិយោគ ។ លើសពីនេះទៅទៀត ចំនួនដ៏ច្រើននៃកម្លាំងពលកម្មសម្រាប់ដាក់ទុនធ្វើស្រែចម្ការមានលក្ខណៈដូចគ្នាទៅនឹងប្រភេទជំនួញនៅទីក្រុង ដែលជាទំនោររបស់ជនជាតិចិន នៅក្រៅប្រទេសដែរ ។ យើងនឹងឃើញពីលក្ខណៈនេះ នៅផ្នែកបន្ទាប់ទៀត ។*

## ជនជាតិចិន ក្នុងវិស័យពាណិជ្ជកម្ម

*គេមានការពិបាកណាស់ ក្នុងការស្វែងរកទិន្នន័យជាតួលេខ ស្តីពីតួនាទីជនជាតិចិននៅក្នុងវិស័យពាណិជ្ជកម្ម ទាំងពាណិជ្ជកម្មក្នុង និងក្រៅស្រុក ។ អ្វីដែលគេអាចយល់បាននោះ គឺថាមន្ត្រីកម្ពុជាមានការស្ទាក់ស្ទើរនឹងផ្តល់តួលេខបែបហ្នឹង ដោយសាររដ្ឋាភិបាលចង់បង្ហាញឲ្យគេឃើញ ពីការពឹងពាក់លើខ្លួនឯងក្នុងឋានៈជាប្រជាជាតិឯករាជ្យថ្មីមួយ ។ ម្យ៉ាងទៀត ការដែលរដ្ឋាភិបាលខ្វះនិយមន័យសម្រាប់កំណត់ជនជាតិចិន កាន់តែធ្វើឲ្យតួលេខមានលក្ខណៈមិនច្បាស់លាស់ និងគ្រាន់តែជាការប៉ាន់ស្មាន ពីតួនាទីរបស់ជនជាតិចិននៅក្នុងវិស័យជំនួញ នៅកម្ពុជាប៉ុណ្ណោះ ។*

*មុនសម័យសង្គ្រាមចិន និងជប៉ុន លោកខល្លីស៍បានប៉ាន់ស្មានថា ការវិនិយោគទុនសរុបរបស់ជនជាតិចិននៅឥណ្ឌូចិន មានទំហំធំទីពីរបន្ទាប់ពីបារាំង ប៉ុន្តែគាត់បានសារភាពថា មិនមានលទ្ធភាពផ្តល់ព័ត៌មានសុក្រឹតឡើយ ។ គាត់បានសន្និដ្ឋានថា ៖*

> ដោយផ្អែកលើចំនួនសមាជិក ប្រាក់កម្រៃគ្រួសារ សកម្មភាពសេដ្ឋកិច្ច និងការសិក្សាប្រៀបធៀបពីតួនាទីរបស់ពួកគេនៅក្នុងតំបន់ជិតខាង យើងមានអាចនិយាយបានថា ការវិនិយោគទុនសហគ្រិនរបស់ពួកគេមានតម្លៃ ២ កោដិលុយហ្វ្រង់របស់បារាំង ឬមានតម្លៃស្មើ ៨០ លានដុល្លារអាមេរិក ។ (ខល្លីស៍ ទំ.៨៥)

*នៅពេលនោះ ជនជាតិចិនប្រហែលមួយភាគបីនៅក្នុងតំបន់ឥណ្ឌូចិនទាំងមូល កំពុងរស់នៅក្នុងប្រទេសកម្ពុជាប៉ុន្តែ ទឹកប្រាក់ដែលពួកគេវិនិយោគនៅប្រទេសនេះ ទំនងជាមិនអាចគិតក្នុងសមាមាត្រនៃចំនួនខាងលើនោះទេ ។ សម្រាប់ជំនួញជនជាតិចិននៅកូស៊ាំងស៊ីន ទោះបីជាមានទំហំតិចជាងជំនួញនៅតុងកឹងក៏ដោយ ក៏ប្រហែលជាមានកម្រិតធំជាងជំនួញនៅកម្ពុជា ដែលភាគច្រើនមានតែតៀមលក់ឥវ៉ាន់តូចតាចនៅទីជនបទតែប៉ុណ្ណោះ ។*

ប្រសិនបើយើងឧបមាថា វិនិយោគទុននៅកម្ពុជាមានទំហំមួយភាគបួននៃចំណែកសរុបទាំងមូល នោះការវិនិយោគរបស់ជនជាតិចិន នៅកម្ពុជាមុនសម័យសង្គ្រាមគួរមានតម្លៃប្រហែលម្ភៃលានដុល្លារ ។

លោកសាស្ត្រាចារ្យ អ៊ូជីដា បានប៉ាន់ស្មានថា ចំនួនវិនិយោគទុនសរុបរបស់ជនជាតិចិននៅអាស៊ីអគ្នេយ៍នាឆ្នាំ ១៨៥៦ មានចំនួន ៥ ដង ច្រើនជាងចំនួនមុនសម័យសង្គ្រាម ដែលផ្តល់ដោយលោកខល្លីស៍ (អ៊ូជីដា ទំ.៥៩០) ។ យ៉ាងណាមិញ គេមិនអាចនិយាយថាកំណើនបែបនេះ កើតមានឡើងនៅគ្រប់ប្រទេសទាំងអស់ទេ ដោយសារប្រការមួយចំនួនដូចជា ភាពអាសន្ននៅប្រទេសម៉ាឡេស៊ី ការលំបាករបស់ជនជាតិចិននៅឥណ្ឌូណេស៊ី និងនៅវៀតណាមខាងត្បូង ការបិទវិនិយោគទុនបរទេសនៅតុងកឹង បានបណ្តាលឲ្យការវិនិយោគទុនមួយផ្នែកធំរបស់ជនជាតិចិន ផ្លាស់ប្តូរទៅកាន់តំបន់ស្ងប់ស្ងាត់ជាងនៅអាស៊ីអគ្នេយ៍ ។ ការចូលហ៊ុនមិនស្មើគ្នាក្នុងការវិនិយោគទុននៅប្រទេសកម្ពុជាកំឡុងពេលមួយទសវត្សរ៍ចុងក្រោយ បានបណ្តាលឲ្យមានការវិនិយោគទុនពីសំណាក់ជនជាតិចិនខ្ពស់ជាងគេនៅទីនោះ ជាជាងនៅប្រទេសដទៃទៀត ។ ដូចច្នេះដំណាលពេលដែលគេរង់ចាំការសិក្សាលម្អិត និងសុក្រឹតស្តីពីការវិនិយោគទុននៅក្នុងតំបន់ ខ្ញុំសូមប៉ាន់ស្មានថា ការវិនិយោគទុនរបស់ជនជាតិចិននៅកម្ពុជាមានទំហំប្រហែលពីមួយទៅពីររយលានដុល្លារអាមេរិកក្នុងឆ្នាំ ១៩៥៦ ។

ការប៉ាន់ស្មាន ទុនវិនិយោគ បានកើនឡើងទ្វេដងនៅកម្ពុជា ចាប់តាំងពីឆ្នាំ ១៩៥៦ នោះមិនមែនមិនសមហេតុផលទេ ទោះបីជាមានតែតួលេខស្តីពីផលិតផលជាតិសរុបសម្រាប់ឆ្នាំ ១៩៥៦ ក៏ដោយ សុចនិករនៃកំណើនមូលធន អាចប្រមូលបានពីស្ថិតិពាណិជ្ជកម្មក្រៅប្រទេស និងកំណើនឧស្សាហកម្ម ។ ចាប់តាំងពីឆ្នាំ ១៩៥៦ ដល់ ១៩៦១ តម្លៃសរុបនៃការនាំចូល និងការនាំចេញកើនជាង ៧០% ÷ គឺពី ៣.២៨០ លានរៀលដល់ ៥.៦១៥លានរៀល[៨] ។ គេអាចស្មានបានថា មានកំណើនយ៉ាងសម្បើមខាងផ្នែកពាណិជ្ជកម្មអន្តរជាតិ ក្នុងពេលនេះដែរចំនួនជំនួញទំនិញឧស្សាហកម្មបានកើនឡើងពី ១.១៧៨ ប្រភេទទៅ ១.៩០៣ ប្រភេទ គឺកើនឡើងជាង ៦០%(សូមមើលតារាងទី ១២)[៩] ។ដោយយោងតាមតួលេខនេះទុនវិនិយោគសរុបរបស់ជនជាតិចិននៅក្នុងប្រទេសកម្ពុជាប្រហែលជាមានតម្លៃពី ២ ទៅ ៤ រយលានដុល្លារ (ស្មើ ៧ ពាន់ទៅ ១៤ ពាន់ លានរៀល) ។

## ជំនួញស្រូវ

ការដាក់ទុនសរុបផ្នែកឧស្សាហកម្ម ចុះបញ្ជីដោយក្រសួងឧស្សាហកម្មដែលខ្ញុំគិតថា ជាការដាក់ទុនរបស់ជនជាតិចិនមានតម្លៃ ១៨.២០០.០០០ ដុល្លារ (៦៣៦.៣៦៥.០០០ រៀល) ក្នុងនោះទុនចំនួន ៤.៥០០.០០០ ដុល្លារ (១៥៧.៤១៥.០០០រៀល) ត្រូវបានវិនិយោគក្នុងផ្នែករោងម៉ាស៊ីនកិនស្រូវ (សូមមើលតារាង ១១ ស្តីពីការវិនិយោគទុនផ្នែកឧស្សាហកម្ម) ។ចំនួននេះ មានទំហំខុសឆ្ងាយពីទំហំវិនិយោគសរុប ផ្នែកពាណិជ្ជកម្មស្រូវ ។ ចំពោះការដឹកជញ្ជូននិងពាណិជ្ជកម្មស្រូវនៅគ្រប់កម្រិត ត្រូវការដើមទុនមួយចំនួន ដែលការវិនិយោគស្ទើរតែទាំងអស់នោះ ជារបស់ជនជាតិចិន ។ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាដែលបានពឹងផ្អែកយ៉ាងសំខាន់លើការនាំចេញត្រីស្រស់និងត្រីងៀត អស់ជាងមួយសតវត្សមកហើយនោះ ឥឡូវត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការនាំចេញស្រូវ[១០] ។

ភ្នាក់ងារទាំងអស់បានយល់ស្របថា ពាណិជ្ជកម្មស្រូវកម្ពុជាតែងតែត្រូវបានគ្រប់គ្រងដោយជនជាតិចិន ។ ពេលឆ្លងសតវត្សថ្មីនេះ រោងម៉ាស៊ីនកិនស្រូវរបស់ជនជាតិចិននៅក្រុងសៃហ្គន-សូឡុងបានកិនស្រូវនាំចេញពីកម្ពុជាទាំងអស់ ។ រហូតដល់ឆ្នាំ ១៩០៦ មួយភាគបីនៃស្រូវនាំចេញរបស់ក្រុងសៃហ្គនបានមកពីតំបន់ជុំវិញបឹង

ទន្លេសាប[១១] និងទន្លេមេគង្គ (ពិសេសខេត្តបាត់ដំបង និងមង្គលបុរី ទោះជានៅពេលនោះ តំបន់នេះជាផ្នែកមួយរបស់សៀមក៏ដោយ) ដែលជាតំបន់ដីមានដីជាតិសម្រាប់ដំនាំស្រូវ ។ ជនជាតិចិនបានបង្កើតតាមលំដាប់លំដោយនៃការធ្វើជំនួញស្រូវ ដែលស្ថិតនៅក្នុងកណ្ដាប់ដៃចិន ចាប់តាំងពីអ្នកប្រមូលទិញ-លក់ស្រូវតិចៗតាមជនបទ ដែលធ្លាប់ប្រមូលទិញស្រូវផ្ទាល់ពីវាលស្រែ អ្នកចែកចាយ និងអ្នកដឹកជញ្ជូន រហូតដល់រោងម៉ាស៊ីនសូឡុង ដែលផ្ទេរទៅឲ្យក្រុមហ៊ុននាំចេញបារាំងដឹកជញ្ជូនតាមកប៉ាល់ទៅបរទេស ។ ជារឿយៗអ្នកប្រមូលទិញ-លក់ស្រូវតូចតាចមានមុខងារជាភ្នាក់ងាររបស់ក្រុមហ៊ុនធំៗ ឬជាភ្នាក់ងាររបស់រោងម៉ាស៊ីនកិនស្រូវ ប៉ុន្តែជាញឹកញាប់ រោងម៉ាស៊ីនកិនស្រូវរបស់ជនជាតិចិនចូលចិត្តរកស៊ីជាមួយអ្នកជួញស្រូវឯករាជ្យ តាមកម្រិតផ្សេងៗ(វ៉ាង វិន យន់ ទំ.៣៧-៤១) ។

ចាប់តាំងពីសម័យឯករាជ្យមក វិស័យជួញដូរស្រូវនៅកម្ពុជាទទួលការប្រែប្រួលប្រពីរបែបយ៉ាងខ្លាំង ដែលការប្រែប្រួលទាំងនេះអាចមើលឃើញតាមរយៈកំណើនចំនួនរោងម៉ាស៊ីនកិនស្រូវជារៀងរាល់ឆ្នាំ (សូមមើលតារាងទី ១២) ។ ទោះបីជារោងម៉ាស៊ីនកិនស្រូវដំបូងបង្អស់នៅកម្ពុជា ត្រូវបានគេសាងឡើងចាប់តាំងពីឆ្នាំ ១៩២១ មកក៏ដោយ ផលិតផលស្រូវ នៅតែជាការនាំចេញដ៏សំខាន់មួយ រហូតដល់សង្គ្រាមឥណ្ឌូចិនលើកទី ២ និងសម័យកម្ពុជាទទួលបានឯករាជ្យ ។ នៅពេលនោះ រោងម៉ាស៊ីនកិនស្រូវនៅក្នុង និងជុំវិញទីក្រុងភ្នំពេញបានចាប់ផ្ដើមកិនស្រូវមួយចំណែកធំ នៃផលិតផលស្រូវនាំចេញ ។ ការប្រែប្រួលមួយទៀត បានកើតឡើងក្នុងអំឡុងប្រាំឆ្នាំចុងក្រោយ គឺនៅពេលដែលរោងម៉ាស៊ីនកិនស្រូវជាច្រើន បានបង្កើតឡើងនៅតាមខេត្តទាំងឡាយ ដោយសារតែរោងម៉ាស៊ីនកិនស្រូវទាំង ១១ នៅក្រុងភ្នំពេញ មិនមានសមត្ថភាពពេញលេញសម្រាប់កិនស្រូវទាំងអស់ក្នុងឆ្នាំ ១៩៦៣ និងនៅពេលដែលអង្ករត្រូវបានគេដឹកជញ្ជូន ពីបណ្ដាខេត្តទាំងឡាយសម្រាប់ការនាំចេញ ។ ចំនួនរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា បានកើនឡើងពី ៤៧ នៅឆ្នាំ ១៩៥១ ដល់ចំនួនជាង ២០០ នាឆ្នាំ ១៩៦១ នេះជាកំណើនជាង ២.៥០០% ក្នុងរយៈពេលតែដប់ឆ្នាំប៉ុណ្ណោះ ។ សព្វថ្ងៃនេះ មានជនជាតិចិនច្រើនជាងមុនប្រកបរបរកិនស្រូវ ក្រុមហ៊ុនខ្លះមានរោងម៉ាស៊ីនកិនស្រូវច្រើន ហើយលើសពីនេះទៅទៀត រោងកិនស្រូវធុនតូច ក៏មានការកើនឡើងច្រើនដែរ ដើម្បីផ្គត់ផ្គង់តម្រូវការក្នុងស្រុក តែមិនមែនដើម្បីកិនស្រូវនាំចេញនោះទេ ។ កសិករខ្មែរនាំយកស្រូវរបស់គេទៅកិននៅរោងកិនស្រូវតូចៗទាំងនេះ ដើម្បីជំនួសឲ្យទម្លាប់នៃការបុកស្រូវតាមគ្រួសារ ដែលពេលខ្លះនៅតែមានអនុវត្តន៍ នៅតាមទីជនបទជាច្រើនក្នុងប្រទេសកម្ពុជា ។

នៅកម្ពុជា គេដាំស្រូវជាចម្បងនៅតាមទំនាបលិចទឹក ជាជាងដាំនៅលើផ្ទៃដីដែលមានប្រព័ន្ធប្រលាយស្រោចស្រព ដូចច្នេះហើយ ទិន្នផលស្រូវត្រូវពឹងអាស្រ័យលើរបបទឹកភ្លៀង (រ៉ូប៊ីកាំង ទំ. ៣០៩) ។ ដោយសារតែស្រូវចំនួនមួយភាគប្រាំត្រូវគេនាំចេញ[១២] ការប្រែប្រួលដ៏តូចមួយ នៅក្នុងការប្រមូលផលសរុប អាចធ្វើឲ្យមានការប្រែប្រួលគួរឲ្យកត់សម្គាល់ នៅក្នុងចំនួនផលិតផលសម្រាប់លក់ ។ ដើម្បីទប់ទល់នឹងការខូចខាតនៅឆ្នាំដែលមិនបានទទួលទិន្នផលល្អ អ្នកចែកចាយស្រូវតូចៗតាមស្រុក តែងតែប្រកបរបររួមផ្សំដទៃទៀតក្រៅពីការជួញដូរស្រូវ ។ មុខរបរទាំងនោះមានដូចជា ការចងការប្រាក់ និងលក់ឥវ៉ាន់រាយជាដើម ។ សកម្មភាពទាំងនេះយកតម្រាប់តាមអ្នកជំនួញចិនក្រៅស្រុកដទៃទៀត ដែលនិយមប្រកបរបរច្រើនមុខ ជាជាងផ្ដោតអារម្មណ៍ខ្លាំងទៅលើមុខរបរតែមួយ ។ ដូចច្នេះជំនួញស្រូវ គឺគ្រាន់តែជាមុខរបរមួយ ក្នុងចំណោមមុខរបរជាច្រើនរបស់អ្នកជំនួញ មិនថាជំនួញនោះមានទំហំប៉ុណ្ណាឡើយ ។

## ការនាំចូល_ការនាំចេញ

ផ្នែកម្ខាងទៀតនៃសេដ្ឋកិច្ចពាណិជ្ជកម្មកម្ពុជា គឺការនាំចូលទំនិញឧស្សាហកម្ម ពីព្រោះរហូតមកដល់ពេលថ្មីៗនេះ សេដ្ឋកិច្ចកម្ពុជាមានទម្រង់មួយ ដែលគេហៅថា «សេដ្ឋកិច្ចអាណានិគម» (រ៉ូបឺកាំង ទំ. ៣១៩ ដេកុបប៊ី ទំ. ១៥២) ។ បើទោះបីជាសក្តានុពលឧស្សាហកម្មកំពុងកើនឡើង ជំហានរបស់រដ្ឋាភិបាលនាពេលថ្មីៗ បានដកការរឹតបន្តឹងពាណិជ្ជកម្មបរទេសឲ្យទៅភ្ជាក់ងាររដ្ឋាភិបាល ដែលអាចនឹងធ្វើឲ្យវិស័យឧស្សាហកម្មមានសន្ទុះកាន់តែខ្លាំងជាងមុនក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជាពឹងអាស្រ័យមួយផ្នែកធំ លើការនាំចូលទំនិញឧស្សាហកម្ម ។ ជារឿយៗទាំងការនាំចូល និងការនាំចេញ ត្រូវធ្វើឡើងដោយក្រុមហ៊ុនតែមួយ ពោលក្រុមហ៊ុននោះផ្គត់ផ្គង់ទំនិញនាំចូលដល់អ្នកលក់រាយបន្តផង និងប្រមូលទិញស្រូវ និងផលិតផលផ្សេងទៀតពីឈ្មួញ និងភ្នាក់ងារតាមស្រុក ។

ក្នុងចំនោមក្រុមហ៊ុននាំចូល-នាំចេញចំនួន ៣៤៦ ដែលចុះបញ្ជីក្នុងព្រឹត្តិបត្រពាណិជ្ជកម្មចិនប្រចាំឆ្នាំ ក្នុងឆ្នាំ ១៩៦៣ (ដូចជាក្រុមហ៊ុនដៀនពូចាយ សាំងយៀក ម៉ាវអ៊ី នៀនដៀន ទំ. ៧២-១២២) យ៉ាងហោចណាស់ក្រុមហ៊ុនចំនួន ២៦៧ ឬស្មើនឹង ៧៨% អាចត្រូវបានគេស្គាល់ថា ជាក្រុមហ៊ុនរបស់ជនជាតិចិន ដោយសារតែឈ្មោះក្រុមហ៊ុនទាំងនោះ[១៣] ។ ទោះជាក្រុមហ៊ុនធំៗភាគច្រើន គឺជាក្រុមហ៊ុនរបស់ពួកអឺរ៉ុប ប៉ុន្តែមុនពេលរដ្ឋាភិបាលអនុវត្តដំណើរជាតូបនីយកម្មលើផ្នែកពាណិជ្ជកម្មបរទេសនាឆ្នាំ ១៩៦៤ ជនជាតិចិនពិតជាមានឧត្តមភាព ក្នុងវិស័យនាំចេញ-នាំចូលប្រាកដមែន ។

## វិស័យពាណិជ្ជកម្មក្នុងស្រុក ឧស្សាហកម្ម និងការដឹកជញ្ជូន

ក៏ដូចជាទំនិញស្រូវ និងការនាំចូល-នាំចេញដែរ ជំនួញលក់រាយនូវទំនិញឧស្សាហកម្មស្ទើរតែទាំងអស់ត្រូវបានគ្រប់គ្រងដោយជនជាតិចិន ទាំងទំនិញនាំចូល និងទំនិញផលិតក្នុងស្រុក ត្រូវបាននាំទៅលក់នៅលើទីផ្សារតាមរយៈអ្នកលក់រាយជនជាតិចិននៅរាជធានី នៅតាមបណ្តាទីក្រុងដទៃទៀត និងសូម្បីតែនៅតាមភូមិដ្ឋានតូចៗក៏ដោយ ។ នៅឆ្នាំ ១៩៣៧ លោកវ៉ាងវ៉ិនយន់ បានប៉ាន់ស្មានថា បួនភាគប្រាំនៃពាណិជ្ជកម្មក្នុងស្រុក នៅក្នុងតំបន់ឥណ្ឌូចិនទាំងមូល ស្ថិតនៅក្នុងកណ្តាប់ដៃជនជាតិចិន (វ៉ាងវិនយន់ ទំ. ៤៤) ។ ទំហំសមាមាត្រអាចនឹងមានទំហំធំជាងនេះនៅក្នុងប្រទេសកម្ពុជា (ប្រហែល ៩០%) ចំណែកឯនៅតុងកឹង និងនៅអណ្ណាម ទំហំសមាមាត្រមានទំហំតូចជាងនោះឆ្ងាយណាស់ (អ៊ុំ ទំ. ១៥៣) ។ សព្វថ្ងៃនេះ ទោះបីជាអ្នកលក់រាយភាគច្រើនមានសញ្ជាតិកម្ពុជាតែគេនៅតែអាចនិយាយបានថា ជនជាតិចិនគ្រប់គ្រងលើជំនួញពាណិជ្ជកម្មចំនួន ៣៦.០០០ របស់កម្ពុជាស្ទើតែទាំងអស់[១៤] ។

ក្នុងចំណោមជំនួញឧស្សាហកម្មទាំង ៣.៣៤៩ ដែលចុះឈ្មោះក្នុងក្រសួងឧស្សាហកម្មនាឆ្នាំ ១៩៦២ ចំនួនប្រហែល ៣.៣០០ (ស្មើនឹង ៩៨%) ស្ថិតនៅក្នុងកណ្តាប់ជនជាតិចិន ទោះបីជាជំនួញធំៗបំផុតត្រូវគ្រប់គ្រងដោយរដ្ឋឬដោយបារាំងក៏ដោយ ។ ឧស្សាហកម្មទាំងនោះ ភាគច្រើនជារោងជាងហត្ថករ ឬឧស្សាហកម្មធុនតូច ការផលិតអាហារ ផលិតធ្យូង និងកូរស្ករជាដើម (សូមមើលតារាងទី ១១) ។ ក្នុងចំណោមនោះ ពួកគេប្រហែលជាលក់រាយដោយខ្លួនឯង (ឌែននរី ១៩៣១ ទំ. ៥) ។ ដូចច្នេះហើយ ភាពខុសគ្នារវាងជំនួញពាណិជ្ជកម្ម និងឧស្សាហកម្មមិនមានការបែងចែកច្បាស់លាស់នោះទេ ព្រោះថានៅឆ្នាំ ១៩៦២ មានការចេញលិខិតអនុញ្ញាតឲ្យធ្វើឧស្សាហកម្មចំនួនតែ ១.៧៦៣ ហើយក្រៅពីនោះ ជាលិខិតអនុញ្ញាតឲ្យធ្វើជំនួញ ។ នៅចុងឆ្នាំ ១៩៦៣ គោលនយោបាយរដ្ឋាភិបាលបានផ្លាស់ប្តូរ ដើម្បីបង្វែរប្រាក់ទុនពីការនាំចូលទាំងប្រថុយប្រថាននិងការនាំចូលទំនិញប្រណីតៗទៅជាផលិតកម្មក្នុងស្រុក ។ គោលនយោបាយថ្មី ទំនងជាបង្កើនការវិនិយោគវិស័យឧស្សាហកម្មរបស់ចិន និងកាត់បន្ថយការ

វិនិយោគលើវិស័យពាណិជ្ជកម្មបរទេស ប៉ុន្តែការប៉ាន់ស្មានពីការប្រែប្រួលបែបនេះហាក់ដូចជាធ្វើឡើងរហ័សពេកហើយ ។[១៥]

បើគេប្រៀបធៀបផ្នែកឧស្សាហកម្មរបស់ជនជាតិចិន និងជនជាតិផ្សេងក្រៅពីចិន នៅក្នុងប្រទេសកម្ពុជា គេនឹងឃើញភាពខុសគ្នាមួយចំនួន ដែលបានសង្ខេបនៅក្នុងតារាងទី ១៣ ។ ការវិនិយោគទុនផ្នែកឧស្សាហកម្មរបស់ជនជាតិចិន ទំនងជាផ្ដោតអារម្មណ៍លើផលិតផលដំបូងដូចជា (រោងម៉ាស៊ីនកិនស្រូវ រោងចក្រអារឈើ និងឡដុតឥដ្ឋ) និងផលិតផលអាហារ (ភេសជ្ជៈ ទឹកកក និងទឹកសណ្ដែក) ។ ដាក់ស្ដែងដំនួញឧស្សាហកម្មចិនមានទំហំតូច មានបុគ្គលិកប្រាំនាក់ជាមធ្យម ក្នុងខណៈពេលដែលឧស្សាហកម្មឯកជន ដែលមិនមែនជារបស់ជនជាតិចិនមានបុគ្គលិកចំនួន ១០៤ នាក់ជាមធ្យមក្នុងដំនួញនីមួយៗ ។ ចំណុចចុងក្រោយនេះ គឺថាការដាក់ទុនលើវិស័យឧស្សាហកម្មរបស់ជនជាតិចិនមានចំនួនតិចតួច៖ គឺ ៤០.៤០០ រៀល (៛១.១៥៤ ក្នុងម្នាក់ៗ) ចំណែកដំនួញឧស្សាហកម្មឯកជន ដែលមិនមែនជារបស់ចិនជាមធ្យមគឺ ១៥៨.៥០០ រៀល (៛៤.៥៣០ ក្នុងម្នាក់ៗ) ។

## វិស័យហិរញ្ញវត្ថុ និងឥណទាន

ទើបតែនៅក្នុងកំឡុងបីទសវត្សរ៍ចុងក្រោយនេះទេ ដែលជនជាតិចិនបានចាប់ផ្ដើមប្រលូកចូលក្នុងវិស័យធនាគារនៅកម្ពុជា ។ នៅឆ្នាំ ១៩៦៣ មានធនាគារចំនួន ៥ នៅក្នុងក្រុងភ្នំពេញ និងធនាគារ ២ ផ្សេងទៀត (ដោយមិនគិតបញ្ចូលទាំងសាខា) នៅក្នុងក្រុងផ្សេងទៀតមានជនជាតិចិនជាម្ចាស់[១៦] ។ គេមិនអាចប៉ាន់ស្មានបានទេនូវទំហំធនធានរបស់ធនាគារទាំងនេះ ហើយក៏មិនអាចស្មានបានថាធនធានរបស់ពួកគេមានប៉ុន្មានភាគ បើប្រៀបជាមួយទំហំធនធាន នៃធនាគារទាំងអស់នៅក្នុងប្រទេសទាំងមូល ។

នៅក្នុងវិស័យហិរញ្ញវត្ថុ និងឥណទានអ្វីដែលសំខាន់ជាងនេះនោះ គឺអ្នកចងការប្រាក់តូចតាចជាច្រើន និងអ្នកផ្ដល់ឥណទាននៅតាមភូមិស្រុក និងនៅតាមទីក្រុង ។ យើងបានលើកឡើងរួចមកហើយថា អ្នកដួញដូរស្រូវនៅតាមភូមិស្រុកឲ្យប្រាក់គេខ្ចីសម្រាប់ដាំដំណាំ ក៏ដូចជាផ្ដល់ឥណទានបន្តដល់កសិករខ្មែរ ហើយគ្មានវិធីណា ដែលគេអាចដឹងពីទំហំពិតប្រាកដនៃប្រតិបត្តិការហិរញ្ញវត្ថុទាំងនោះទេ ។ មន្ត្រីសំខាន់មួយរូប នៃរាជការិយាល័យសម្រាប់កិច្ចសហប្រតិបត្តិការ បានប្រាប់ខ្ញុំឲ្យដឹងថា ការិយាល័យរបស់គាត់ឥឡូវនេះមានតួនាទីសំខាន់ក្នុងផ្នែកឥណទានកសិកម្ម ជាងអ្នកចងការប្រាក់ឯកជន ដោយសារការិយាល័យនេះបានផ្ដល់ប្រាក់ឥណទានចំនួន ៤២០.០០០.០០០ រៀលក្នុងឆ្នាំ ១៩៦២ ។[១៧] នៅឆ្នាំ ១៩៥២ ការិយាល័យឥណទានប្រជាជន បានប៉ាន់ស្មានថា បីភាគបួននៃអ្នកប្រកបរបរកសិកម្មជាំផុះ មានជំពាក់បំណុលចំនួនជាមធ្យមប្រហែល ១.០០០ រៀលក្នុងម្នាក់ៗ ធ្វើឲ្យចំនួនជំពាក់សរុបកើនដល់ ៥០០.០០០.០០០ រៀល (ឌែលវីត ទំ. ៥១៩) ។ ប៉ុន្តែការសិក្សារបស់លោកឌែលវីត បានបង្ហាញពីទំហំទឹកប្រាក់ដែលគេជំពាក់ខុសគ្នាៗពីភូមិមួយទៅភូមិមួយទៀត ចំណែកបុគ្គលឯកជនម្នាក់ៗជំពាក់ចាប់ពីសូន្យដល់ ៧.០០០ រៀល (ដដែល ៥១៩-៥២១) ។ ផ្អែកលើលោកឌែលវីត ជាការសមរម្យណាស់ដែលគេប៉ាន់ស្មានថា ប្រាក់ជំពាក់សម្រាប់វិស័យកសិកម្មទាំងអស់មានចំនួនជាង ៥០០.០០០.០០០ រៀល ដែលក្នុងនោះម្ចាស់ហាង និងអ្នកចងការប្រាក់ជាជនជាតិចិនបានឲ្យគេខ្ចីចំនួនជាង ៣០០.០០០.០០០ រៀល (ស្មើនឹង ៨.៦០០.០០០ ដុល្លារ)[១៨] ។

## ម្ចាស់តៀមជនជាតិចិននៅតាមជនបទ

*ក្រៅពីផ្នែកខាងលើ គេមើលឃើញយ៉ាងច្បាស់ថា នៅថ្នាក់ភូមិ បុគ្គលម្នាក់ប្រកបមុខរបរផ្សេងៗជាច្រើន ក្នុងវិស័យសេដ្ឋកិច្ចជំនួញៈ លោកឌែលវីត ហៅរបរនោះថា «តៀមលក់ឥវ៉ាន់ក្នុងភូមិ»៖*

> ម្ចាស់តៀមលក់ឥវ៉ាន់ក្នុងភូមិ (ភាគច្រើនជាជនជាតិចិន) រស់នៅយ៉ាងជិតស្និទ្ធជាមួយកសិករ ។ តាមពិតទៅ គាត់បំពេញតួនាទីពីររួមគ្នា៖ គាត់ផ្គត់ផ្គង់កសិករនូវទំនិញសំខាន់ៗ (ហើយ)គាត់នាំយកផលិតផលកសិករទៅលក់នៅក្រៅប្រទេស ។ នៅក្នុងតៀមលក់ឥវ៉ាន់ទាំងនោះ មានរបស់របរសព្វគ្រប់ដែលកសិករត្រូវការភ្លាមៗដូចជា ៖ គ្រឿងបរិភោគនាំចូលពីបរទេសរួមមាន ទឹកដោះគោកំប៉ុង និងទឹកស៊ីអ៊ីវដែលគេខានមិនបាន ស្ករគ្រាប់ សម្លៀកបំពាក់បុរស ចានក្បាន និងគ្រឿងបិទបាំងកាយមានក្រមា សំពត់គ្រប់ប្រភេទ និងសារ៉ុង ថ្នាំជក់ក្នុងស្រុក ហើយជួនកាលមានបារី ត្រីងៀត និងត្រីឆ្អើរ ទឹកត្រី អំបិល ឈើគូស ប្រេងកាតសម្រាប់ចង្កៀង ស្បែកជើងឈើ ថូផើង ក្រឡ និងចង្ក្រានយកពីខេត្តកំពង់ឆ្នាំង ផ្លែកាំបិត កណ្ដៀវ ផាលនង្គ័ល អំបោសស្រកីដូង និងក្រណាត់អំបោះ កញ្ច្រែង ឬកញ្ជេរធ្វើពីត្រែងឬ ឬស្សីឧបករណ៍ស្ទូចត្រី (ពិសេសនៅតំបន់ខ្សត់ឬស្សី) ស្រា គ្រឿងក្រអូបថោកៗ គ្រឿងកែវ គ្រឿងអលង្ការ គ្រាប់អង្កាំ ។ល។ ផលិតផលទាំងប៉ុន្មានដែលរៀបរាប់ខាងក្រោយនេះ កម្រមានកសិករណាទិញណាស់ ទំនិញទាំងនោះលក់ដាច់ខ្លាំងនៅរដូវប្រមូលផល ។ នៅពេលពួកគេត្រូវការអ្វីមួយ កសិករមកសុំជំពាក់ពីម្ចាស់ហាង ពួកគេនឹងសងវិញនៅរដូវប្រមូលផល សងជាស្រូវ ជាពោត ជាថ្នាំជក់ ។ល។...

*ជារឿយៗម្ចាស់តៀមតែងផ្តល់មធ្យោបាយដឹកជញ្ជូនស្រូវ និងទំនិញផ្សេងទៀត ហើយពួកគេក៏ទិញទំនិញក្នុងស្រុកសម្រាប់យកមកលក់ក្នុងទីផ្សារដែរ ។ លោក ឌែលវីត បានបន្តទៀតថា ម្ចាស់តៀមក្នុងភូមិទាំងនេះ ជាញឹកញាប់តែងតែជាដេប៉ូរបស់ហាងជំនួញធំៗនៅភ្នំពេញ (ឌែលវីត ទំ.៥២៣) ។ គាត់ពន្យល់ថា ប្រព័ន្ធសេដ្ឋកិច្ចបែបនេះ មានដំណើរការយ៉ាងរលូន ដោយសារអ្នកជំនួញផ្គត់ផ្គង់ដល់កសិករ នូវទំនិញដែលពួកគេត្រូវការនៅក្នុងភូមិតែម្តង ដំណាលពេលដែលអ្នកជំនួញទាំងនោះ យកផលិតផលរបស់កសិករទៅលក់នៅលើទីផ្សារអន្តរជាតិ ពីព្រោះម្ចាស់តៀម នឹងផ្តល់ប្រាក់កម្ចីសម្រាប់ការប្រមូលផលណាដែលអាចលក់បាន (ឌែលវីត ទំ.៥១២)។ លោកឌែលវីត បានប៉ាន់ស្មានថាប្រហែល ១៨% នៃតម្លៃផលិតកម្មកសិកម្មរបស់កសិករខ្មែរ បានទៅលើកណ្តាប់ដៃអ្នកជំនួញចិន ដែលមានតម្លៃសរុបគិតជាប្រាក់ប្រហែល ៧៥០.០០០.០០០ រៀល (ប្រហែល ២១.៤០០.០០០ ដុល្លារ) (ឌែលវីត ទំ. ៥២៣) ។*

*ឌែលវីត សង្កត់ធ្ងន់ថា ម្ចាស់ហាងទាំងនោះជាជនជាតិចិន ហើយឥឡូវនៅតែជាជនជាតិចិនដដែល មិនថាពួកគេមានសញ្ជាតិអ្វីនោះទេ ។ ពួកគេជាជនជាតិចិនទាំងអស់ ពួកគេអនុវត្តន៍ប្រពៃណីគោរពជូនតាប្រារព្ធពិធីចូលឆ្នាំចិនជាជាងពិធីចូលឆ្នាំខ្មែរ ហើយពួកគេចូលចិត្តបញ្ចុះសាកសពជាជាងបូជា លើសពីនេះទៅទៀតពួកគេបញ្ជូនកូនចៅឲ្យទៅរៀននៅសាលាចិនបើអាចទៅរួច (ឌែលវីត ទំ.៥២២) ។ ម្ចាស់ហាងបែបនេះមាននៅគ្រប់ទីកន្លែងក្នុងទីជនបទកម្ពុជា ដោយបង្កើតតៀមនៅក្នុងភូមិ និងស្រុកដាច់ស្រយាលបំផុត ។ ឌែលវីតបន្តទៀតថា «បើមិនមានពួកគេ កសិករមុខជាជួបប្រទះបញ្ហាប្រកបរបរចិញ្ចឹមជីវិត លើកលែងតែនៅក្នុងតំបន់មួយចំនួន» (ឌែលវីត ទំ.៥២៣)។*

*អ្នកនិពន្ធផ្សេងទៀតដែលមិនសូវមានគំនិតលម្អៀងចំពោះជនជាតិចិន (សូម្បីតែលោកឌែលវីត ក៏មានគំនិតប្រកាន់ពូជសាសន៍ ចំពោះម្ចាស់តៀមជនជាតិចិនទាំងអស់នោះ) បានផ្តល់ព័ត៌មានគួរឲ្យតក់ស្លុតអំពីដំណើរ*

*ដែលជនជាតិចិនកេងប្រវ័ញ្ច លើកម្លាំងញើសឈាមជនជាតិខ្មែរ ។ ជាឧទាហរណ៍លោកម៉ូណូដ បានសរសេរអត្ថបទមួយស្ដីពី «កម្ពុជា» ថា ៖*

> ជនជាតិចិន គឺជាអ្នកដើរប្រមូលទិញស្រូវ ដែលជនជាតិខ្មែរកើបដាក់ជង្រុក ក្នុងតម្លៃមួយតាមចិត្តគេចង់បាន ហើយជារឿយៗ តម្លៃនោះទាបជាងតម្លៃធម្មតានៅលើទីផ្សារ ។ អាក្រក់ជាងនេះ គឺតៅដែលពួកគេយកទៅវាល់ស្រូវមានទំហំធំជាងទំហំតៅធម្មតា (ដែលធ្វើឲ្យកសិករខ្មែរកាន់តែមានការខាតបង់ច្រើន) ។ ទោះជាយ៉ាងនេះក្ដី ជនជាតិខ្មែរទាំងអស់នៅតែត្រូវគេកេងប្រវ័ញ្ចដដែល ។ ជារៀងរាល់ឆ្នាំ ពួកគេទទួលបានប្រាក់ចំណូលតិចជាងចំនួនដែលពួកគេសមនឹងទទួលបាន ។

*ទោះបីជាព័ត៌មាននេះ ជួយបំភ្លឺបន្ថែមពីទំនាក់ទំនងជាតិសាសន៍រវាងជនជាតិបារាំង និងជនជាតិចិនជាជាងឆ្លុះបញ្ចាំងពីសច្ចភាពពិតប្រាកដ ពីពាណិជ្ជកម្មតាមជនបទរបស់ជនជាតិចិន ក៏ព័ត៌មាននោះចង្អុលបង្ហាញថា ជនជាតិចិនជួនកាលបានផ្ដល់នូវទំនាក់ទំនងសេដ្ឋកិច្ចរវាងភូមិកសិករខ្មែរ ទៅនឹងពិភពខាងក្រៅ (សូមមើលផងដែរ នូវឌឺឡាព័រត៍ ទំ.៣០អេហ្វ, ឌឺឡាប្រុស ទំ.១៣២៨, ហេក ទំ.២៥៥, អ៊ី ទំ.១៥៨)។*

*កំឡុងពេលមានវិបត្តិសេដ្ឋកិច្ចឆ្នាំ ១៩៣០-៣៣ ស្ថាប័នសេដ្ឋកិច្ចចិនបានទទួលរងការប៉ះពាល់ជាច្រើន ។ បើយោងតាម ដែនន័រី ៖*

> នៅពេលដែលរចនាសម្ព័ន្ធពាណិជ្ជកម្ម ស្ថិតនៅក្រោមកណ្ដាប់ដៃជនជាតិចិន រចនាសម្ព័ន្ធពាណិជ្ជកម្មទាំងមូលនៅកម្ពុជាត្រូវខូចខាត ។ រចនាសម្ព័ន្ធនោះមិននៅសេសសល់ទេ ហើយរឿងបែបនេះ ក៏កើតមានឡើងនៅកូស៊ាំងស៊ីនដែរ ទោះបីជាមានផលប៉ះពាល់តិចតួចក៏ដោយ... ជនជាតិចិនភាគច្រើន ដែលធ្លាប់ធ្វើជំនួញផ្ដាច់មុខលើការកិនស្រូវ បានរលាយបាត់ទៅហើយ លើកលែងតែអ្នកជំនួញម្នាក់ ឬពីរនាក់ប៉ុណ្ណោះ ។ ជាឧទាហរណ៍ ក្នុងចំណោមអ្នកជំនួញបួននាក់ ដែលធ្វើជំនួញផ្ដាច់មុខលើការលក់ និងទិញស្រូវ មានតែម្នាក់ប៉ុណ្ណោះនៅរកស៊ីក្នុងសម័យអាណានិគម ហើយបើក្នុងចំណោម ១០ នាក់ដែលលក់គ្រឿងដែក និងក្រណាត់ មានប្រាំបួននាក់ទៅហើយដែលដួលរលំ (ដែនន័រី ១៩៣១. ទំ. ១៥៧) ។

*យើងធ្លាប់បានដឹងរួចមកហើយថា កំឡុងឆ្នាំ១៩៣០-៣៣ ជនជាតិចិនបានចាកចេញពីប្រទេសកម្ពុជាច្រើនជាងចំនួនជនជាតិចិនមកពីប្រទេសចិន ហើយនិន្នាការនេះ គ្រាន់តែឆ្លុះបញ្ចាំងពីការពិតដែលថា មានជំនួញជាច្រើនបានដួលរលំក្នុងអំឡុងពេលនោះ ។ ទាំងលោកដែនន័រី និងលោករ៉ូប៊ីកាំង មិនបានផ្ដល់ព័ត៌មានលម្អិតពីវិបត្តិនេះទេ ហើយក៏មិនបានចង្អុលបង្ហាញដែរថា តើផ្នែកណាដែលទទួលផលប៉ះពាល់ខ្លាំងបំផុតពីវិបត្តិខាងលើ ។ យ៉ាងណាមិញ គេអាចស្មានបានថា អ្នកជំនួញនៅទីក្រុង ដែលរកស៊ីទាំងប្រថុយប្រថានលើការនាំចូល និងការនាំចេញ ហើយដែលឆ្ងាយពីប្រភពធនធាន (ស្រូវ) នៅវាលស្រែ បានរងការវាយប្រហារធ្ងន់ធ្ងរ ជាងម្ចាស់តៀមលក់ឥវ៉ាន់នៅតាមជនបទដែលលក់ឥវ៉ាន់ចាំបាច់ដល់កសិករដោយដោះដូរជាមួយនឹងស្រូវ ។ ដោយសារតែម្ចាស់តៀមលក់ឥវ៉ាន់ នៅតាមជនបទទាំងអស់ជាចិនទាជីវ វិបត្តិនេះប្រហែលជាទីអវសាន នៃការគ្រប់គ្រងជំនួញរបស់ចិនកន្តាំង នៅក្នុងប្រទេសកម្ពុជា ហើយត្រូវជំនួសមកវិញដោយការកើនឡើង នៃជំនួញរកស៊ីរបស់ចិនទាជីវ ។ ខណៈពេលដែលជំនួញរបស់ចិនកន្តាំងបានដុះចេញពីក្រុងសូឡុង ពាណិជ្ជកម្មចិនទាជីវបានរីកឡើងធំទូលាយ ដោយចេញពី*

*បណ្ដាម្ចាស់តៀមលក់ដុំរាយនៅតាមជនបទ ដូចច្នេះហើយទើបចិនទាជីវមានមូលដ្ឋានរឹងមាំ ជាងចិនកន្ដាំងដែលត្រូវបានបំផ្លាញដោយវិបត្តិសេដ្ឋកិច្ចពិភពលោកនោះ ។*

## កម្លាំងពលកម្មចិននៅកម្ពុជា

*ការប៉ាន់ស្មានចំនួនពលករចិន ដែលធ្វើការក្នុងវិស័យផ្សេងៗ មានការពិបាកជាងការប៉ាន់ស្មានពីទំហំទឹកប្រាក់វិនិយោគទុនជនជាតិចិនទៅទៀត ។ ដោយសារសហគ្រាសជនជាតិចិន មានលក្ខណៈប្រហាក់ប្រហែលគ្នា គេមិនអាចបែងចែងឲ្យដាច់ពីគ្នារវាងនិយោជក និងនិយោជិកនៅក្នុងក្រុមហ៊ុន ដូចក្រុមហ៊ុនដែលយើងធ្លាប់បានឃើញនៅបស្ចិមប្រទេសនោះទេ ។ ពិសេសជាងនេះទៅទៀត និយោជិកជនជាតិចិនជាច្រើន ចាប់ផ្ដើមប្រកបមុខរបររបស់ខ្លួន ក្នុងខណៈពេលដែលពួកគេនៅកំពុងធ្វើការងារបម្រើគេ ព្រោះថា គោលដៅរបស់ជនជាតិចិននៅក្រៅប្រទេស គឺចង់ប្រកបមុខរបរដោយខ្លួនឯង (វីល្លៀម វីលមូតត៍ ១៩៦៣ ទំ.៣១៨) ។ មិត្តភក្ដិជនជាតិចិនរបស់ខ្ញុំម្នាក់ដែលធ្វើការជាអ្នករត់តុក្នុងភោជនីយដ្ឋានមួយកន្លែងនៅក្រុងភ្នំពេញ ១០ម៉ោងក្នុងមួយថ្ងៃ ៧ ថ្ងៃក្នុងមួយសប្ដាហ៍ នោះគាត់នៅមានហ៊ុនរកស៊ី នៅក្នុងភោជនីយដ្ឋានមួយទៀត និងជាដៃគូនៅក្នុងរោងពុម្ពមួយដែរ ។មិត្តភក្ដិខ្ញុំម្នាក់ទៀត គឺជាដៃគូរកស៊ីនៅក្នុងហាងកាត់សក់មួយ ដែលភរិយារបស់គាត់កំពុងធ្វើការ ក្នុងខណៈពេលដែលខ្លួនគាត់ កំពុងធ្វើជាអ្នកគិតប្រាក់នៅក្នុងភោជនីយដ្ឋានមួយ ក្រោយមកទៀត គាត់ធ្វើជាស្មៀននៅក្នុងក្រុមហ៊ុននាំចូលមួយ ។ គេពិបាកនឹងកំណត់ថា ក្រុមមនុស្សបែបនេះជាកម្មករ ឬក៏ជាអ្នកជំនួញ ចំពោះការកំណត់របស់ខ្ញុំ កម្មករគឺជាអ្នកដែលធ្វើការឲ្យក្រុមហ៊ុនដែលពួកគេមិនមានឥទ្ធិពលលើគោលនយោបាយគ្រប់គ្រង ប៉ុន្តែនិយមន័យនេះ ពិតជាមិនមានន័យពេញលក្ខណៈនោះឡើយ ។*

*ទោះបីជានៅក្នុងរបបបារាំង មានកម្មករតិចតួចជាងចំនួនកម្មករសព្វថ្ងៃក៏ដោយ ក៏ប្រហែលជាចំនួនសមាភាគកម្មករភាគច្រើន គឺជាជនជាតិចិន ហើយភាគរយនោះ ច្រើនជាងចំនួនភាគរយកម្មករចិនសព្វថ្ងៃ ក្នុងខណៈពេលនោះដែរកម្មករ ផែកប៉ាល់នៅក្រុងភ្នំពេញ គឺជាជនជាតិចិន ឬវៀតណាម ។ ជនជាតិចិនជាអ្នកអូសរទេះដៃកែវ ។ ចំណែកកម្មករសំណង់មានទាំងជនជាតិចិន ឬជនជាតិវៀតណាម ។ ទាំងនេះវាមានលក្ខណៈខុសពីតំបន់ជាច្រើនទៀតនៅអាស៊ីអាគ្នេយ៍ នៅក្នុងប្រទេសកម្ពុជា មានពលករចិនជាប់កុងត្រាតិចតួចណាស់ (រ៉ូប៊ីកាំង ទំ.៣៦) ។ នៅក្នុងចម្ការកៅស៊ូឯណោះវិញ អ្នកគ្រប់គ្រងជនជាតិបារាំងចូលចិត្តជួលកម្មករវៀតណាម ព្រោះកម្មករវៀតណាមយកថ្លៃឈ្នួលថោកជាង (ដែននីរ៍ ១៩៣១ ទំ.១៣៥) ហើយជារឿយៗ គេអាចរកកម្មករប្រភេទនេះបានយ៉ាងច្រើនពីស្ថាប័នព្រហ្មទណ្ឌ (បណ្ណសារដ្ឋាន,អេហ្វ ៨១ (២)) មានតែនៅក្នុងចម្ការម្រេចតែប៉ុណ្ណោះ ដែលគេប្រទះឃើញមានកម្មករចិនយ៉ាងច្រើន អាចច្រើនរហូតដល់មួយម៉ឺននាក់ៗ[១៩] ក្នុងសម័យបារាំងគ្រប់គ្រងទាំងមូល ចំនួនសរុបនៃពលករចិន ប្រហែលជាមានមិនលើសពីមួយម៉ឺនប្រាំពាន់នាក់ឡើយ ។ នៅក្នុងអត្ថបទមួយស្ដីពីការងារពលកម្មក្នុងដែនដីអាណានិគមបារាំង លោក ម៉ាន់ហ្គៀត បានសរសេរថា ជនជាតិចិននៅឥណ្ឌូចិន ផ្ដោតសំខាន់លើផ្នែកពាណិជ្ជកម្ម (ម៉ាន់ហ្គៀត ទំ.២៩៤ សូមមើលផងដែរនូវ អ៊ី ទំ.១៥៣) ។*

*ទោះបីជាចំនួនកម្មករចិន មានការកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងវិស័យឧស្សាហកម្មក៏ដោយ ក៏កម្លាំងពលកម្មចិន ប្រហែលជាមិនបានកើនឡើងចាប់តាំងពីសម័យបារាំងមក ។ មានហេតុផលបីយ៉ាង សម្រាប់បញ្ហានេះ (១) គឺលែងមានអន្តោប្រវេសន៍ចិន (ចូលមកស្រុកខ្មែរ) ចាប់តាំងពីឆ្នាំ ១៩៥២ ដែលនាំឲ្យកម្លាំងពលកម្មចិនធ្លាក់*

ចុះ ព្រោះគ្មានជនអន្តោប្រវេសន៍ក្រីក្រចូលមកបន្ថែម ។ ជនជាតិចិនជាច្រើន (ដែលកាលពីមួយទសវត្សមុនជាកម្មករ) បានចាប់ផ្តើមរកស៊ីផ្ទាល់ខ្លួន នៅក្នុងទីក្រុងដែលកំពុងរីកចម្រើន ។ (២) ការរឹតបន្តឹងផ្នែកផ្លូវច្បាប់ បានបណ្តាលឲ្យមានការជំនួសកម្មករចិនទាំងនោះ ដោយកម្មករជាជនជាតិខ្មែរ ។ ច្បាប់ឆ្នាំ ១៩៥៦ ដែលហាមប្រាមមិនឲ្យជនជាតិបរទេសធ្វើមុខរបរទាំង ១៨ មានប្រសិទ្ធភាពក្នុងការបណ្តេញកម្មករកេប៉ាល់ អ្នកបើកឡាន និងជាងកាត់សក់ចិនចេញពីការងារ ។ ពិសេសជាងនេះទៅទៀត ច្បាប់មួយដែលអនុម័តនៅឆ្នាំ ១៩៥៧ (តាមក្រមលេខ ២១២ នស) តម្រូវឲ្យមាននយោជិកសញ្ជាតិកម្ពុជាចំនួន ៧០% នៅក្នុងគ្រប់ក្រុមហ៊ុនទាំងអស់ (ជី អូ ស៊ី ១៩៥៧, ២៣៦៩)។ ដោយសារជនជាតិខ្មែរមិនទាន់មានជំនាញ តួយ៉ាងដូចជាការគ្រប់គ្រង ឬចុងភៅ ក្រុមហ៊ុនចិនជាច្រើនបានជួលខ្មែរឲ្យធ្វើកិច្ចការបន្ទាប់បន្សំ ដូចជាជុសជូត និងបោសសម្អាត ដើម្បីបំពេញឲ្យគ្រប់កូតា ។ (៣) មូលហេតុចុងក្រោយ គឺការរីកចម្រើនយ៉ាងឆាប់រហ័សនៃក្រុងភ្នំពេញ (ដែលមានចំនួនប្រជាជនពី ១០០.០០០ នាក់ទៅ ៥០០.០០០ នាក់ក្នុងរយៈពេល ១៥ ឆ្នាំ) បានទាក់ទាញជនជាតិខ្មែរ ពីទីជនបទមកប្រកបការងារធម្មតា ដូចជាការសាងសង់ និងការផ្គត់ផ្គង់សេវាកម្មក្នុងទីក្រុង ដែលកំពុងតែរីកលូតលាស់ ។ ប្រជាជនជាច្រើនងាកមករកមុខរបរដូចជាកម្មករកេប៉ាល់ និងអ្នកបោសសម្អាត ដែលបើកចំហសម្រាប់ពួកគេ តាមការរឹតបន្តឹងច្បាប់ ដូចដែលត្រូវបានគេរៀបរាប់ខាងលើ ។ ជនជាតិខ្មែរផ្សេងទៀត បានចាប់ផ្តើមក្លាយជាអ្នកជាក់ស៊ីក្លូ ដោយជួលស៊ីក្លូពីក្រុមហ៊ុនចិន និងជាក់តាមដងផ្លូវដើម្បីរកអ្នកជិះ ។ ពួកគេភាគច្រើនតែងទាក់ទងមកភូមិស្រុករបស់គេវិញ ដូច្នេះហើយទើបនាំឲ្យមានហូរចូលក្នុង ចំណោមយុវជនតាមបណ្តាខេត្តជិតខាងមកក្រុងភ្នំពេញ ។[២០] ចលនាបន្ទាស់ទីទាំងនេះ បណ្តាលឲ្យមានកម្លាំងពលកម្មខ្មែរនៅក្រុងភ្នំពេញប្រឈមនឹងគូលីចិន ដែលមិនមានភូមិដ្ឋានជាទីពំនាក់អាស្រ័យ ហើយមិនយូរប៉ុន្មាន ពួកចិនមិនអាចបំពេញការងារនោះបានតទៅទៀត ។

តារាងទី ១៤ ផ្តល់ការប៉ាន់ស្មានពីចំនួនកម្មករចិន ធ្វើការក្នុងផ្នែកផ្សេងៗនៃវិស័យសេដ្ឋកិច្ច ។ ការប៉ាន់ស្មានដែលអាចមានភាពត្រឹមត្រូវជាងគេ គឺការប៉ាន់ស្មានលើផ្នែកឧស្សាហកម្ម ជាវិស័យដែលគេផ្អែកលើតួលេខបុគ្គលិកដែលទទួលបានពីព្រឹត្តិបត្រនៃក្រសួងឧស្សាហកម្ម ។ ការប៉ាន់ស្មានចំនួនកម្មករចិនសរុបទាំងអស់នៅឆ្នាំ ១៩៦១ មានចំនួន ១៦.០០០ បូករួមនឹងក្រុមគ្រួសាររបស់ពួកគេ តួលេខនេះអាចប្រហែលជា ១៥% នៃចំនួនប្រជាជនចិនទាំងអស់ នៅក្នុងប្រទេសកម្ពុជា ។

## សន្និដ្ឋាន ៖ រចនាសម្ព័ន្ធវណ្ណៈជនជាតិចិន

ទោះបីជាការពិភាក្សាខាងលើជួយពន្យល់ច្បាស់ថា ទិន្នន័យដែលទាក់ទងនឹងមុខរបរ គ្រាន់តែជាទិន្នន័យប្រហាក់ប្រហែលក៏ដោយ ក៏គេមានចំណាប់អារម្មណ៍ជាទូទៅមួយចំពោះចំនួនជនជាតិចិន ពាក់ព័ន្ធនឹងការពិនិត្យខាងសេដ្ឋកិច្ចជាច្រើន ។ ចំណាប់អារម្មណ៍នេះ ត្រូវបានសង្ខេបដាក់ក្នុងតារាងទី ១៥ ។ ផ្នែកដែលមានបញ្ហាខ្វាំងបំផុតនៅក្នុងតារាងនេះ គឺចំនួនកម្មករជំនួញ ដោយសារហេតុផលរៀបរាប់ខាងដើមរួចមក ហើយអំពីការពិបាកក្នុងការកំណត់និយមន័យ (យ៉ាងម៉េចទៅដែលហៅថានយោជិក ឬនយោជក?) ។ យ៉ាងណាមិញ តួលេខនោះតំណាងឲ្យការប៉ាន់ស្មានចំនួនប្រជាជន ដែលពាក់ព័ន្ធនឹងការធ្វើជំនួញ តែមិនពាក់ព័ន្ធនឹងការគ្រប់គ្រងដើមទុនវិនិយោគទេ ។

យោងតាមតារាង និងឆ្លងតាមការពិភាក្សាខាងលើ យើងអាចទាញសេចក្តីសន្និដ្ឋានបានថា ចំនួនជនជាតិចិនជាច្រើន ពោលគឺជាង ៨០% ស្ថិតនៅក្នុងគ្រួសារអ្នកជំនួញ ។ បើសិនយើងបូកបញ្ចូលទាំងនយោជិក នោះមានន័យ

ថា ក្នុងចំណោមអ្នកជំនួញទាំងអស់នៅកម្ពុជា មានអ្នកជំនួញជាជនជាតិចិននោះប្រហែលជា ៩០% ដែលចំនួននោះប្រហែលជាស្មើ ៩៥% នៃជនជាតិចិនទាំងអស់ដែលរស់នៅកម្ពុជា ។ ដូច្នេះហើយ គេអាចនិយាយបានថា ជនជាតិចិនជាទូទៅ បង្កើតបានជាវណ្ណៈកណ្តាលនៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា ។

ភាពខុសប្លែកគ្នារវាងវណ្ណៈជំនួញនៅទីជនបទ និងនៅទីប្រជុំជន ជាប្រការសំខាន់បើគេយកចិត្តទុកដាក់លើស្ថាប័នសង្គមជនជាតិចិន ព្រោះថា ស្ថាប័នសង្គមមានទិដ្ឋភាពសង្គមផង និងសេដ្ឋកិច្ចផង ។ អ្នកជំនួញនៅជនបទហាក់ដូចជាមានភាពក្រីក្រជាង ពួកគេមានទំនោរ និងបន្សាំខ្លួនចូលវប្បធម៌ខ្មែររហ័សជាង ដោយពួកគេមានទំនោររៀបការជាមួយជាតិសាសន៍ខ្មែរញឹកញាប់ជាង ដែលពួកគេស្ទើរតែទាំងអស់នោះជាចិនទាជីវ ។ កត្តាទាំងអស់នេះមានឥទ្ធិពលយ៉ាងខ្លាំង លើស្ថាប័នសង្គមនៅទីជនបទ ។

ភាពខុសគ្នាខ្លាំងបំផុត ក្នុងចំនោមជនជាតិចិននៅទីប្រជុំជន (ក្រុមប្រជាជនសំខាន់ក្នុងការពិភាក្សានៅទីនេះ) គឺភាពខុសគ្នារវាងអ្នកជំនួញ និងកម្មករ ។ តាមតួលេខដែលយើងទទួលបាន ជាការប្រាកដណាស់ថា ក្នុងចំណោមប្រជាជនក្នុងទីក្រុងទាំងអស់ប្រហែលបីភាគបួន គឺស្ថិតនៅក្នុងវណ្ណៈអ្នកជំនួញ (៧២%) ។ ក្នុងសម័យបារាំង ចំនួនមេគ្រួសារដែលពាក់ព័ន្ធនឹងផ្នែកជំនួញមានតិចតួច ដោយសារតែជនជាតិចិនភាគច្រើនសន្និក ជាអ្នកផ្តល់កម្លាំងពលកម្មនៅទីប្រជុំជន ។ ទន្ទឹមនឹងនេះ គេគួរចង់ចាំថា មុនសម័យសង្គ្រាម ជាទូទៅកម្មករជនជាតិចិននៅទីក្រុងមិនយកក្រុមគ្រួសាររបស់ខ្លួន មករស់នៅជាមួយនៅប្រទេសកម្ពុជាទេ ដូចច្នេះហើយចំនួនប្រជាជន ដែលត្រូវគេចាត់ចូលជាវណ្ណៈកម្មករមានចំនួនតិចជាងសព្វថ្ងៃ ប៉ុន្តែគេមិនអាចរកស្ថិតិណាមួយ ដើម្បីបញ្ជាក់ពីបញ្ហានេះបានឡើយ ៕

## តារាងទី ១១ ជំនួញឧស្សាហកម្មឯកជននៅកម្ពុជា ១៩៦០–៦១

| សាខា | ជំនួញរបស់ជនជាតិចិន | | | ជំនួញផ្សេងក្រៅពីរបស់ជនជាតិចិន | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|
| | ចំនួន | ដើមទុន | បុគ្គលិក | ចំនួន | ដើមទុន | បុគ្គលិក | ចំនួន | ដើមទុន | បុគ្គលិក |
| រោងម៉ាស៊ីនកិនស្រូវ | ១០៩២ A | ១៥៧.៤១៥.០០០ | ៣៩០២ | ៥ B | ៥៨២.០០០ | ១៤ | ១០០៧ C | ១៥៨.០៧៧.០០០ | ៣៩១៦ |
| ការធ្វើផលិតផលដើមផ្សេង | ១៧១៥ | ៩៧.៨២៧.០០០ | ៧៣៧៧ | ៦ | ២៣៨.៥២០.០០០ | ១៧២២ | ១៧២១ | ៣៣៦.៣៤៧.០០០ | ៩០៩៩ |
| ផលិតផលអាហារ | ១៣៥ | ១៦៦.៨៣៦.០០០ | ១០១៤ | ២ | ១១៨.០០០.០០០ | ៣២៨ | ១៣៧ | ២៨៤.៨៣៦.០០០ | ១៣៤២ |
| ឧស្សាហកម្មកម្មន្តសាល | ៣០១ | ១៨២.៥៨៥.០០០ | ៣៦២៤ | ៩ | ៧០.២០៣.០០០ | ៣៤៣ | ៣១០ | ២៥២.៧៨៨.០០០ | ៣៩៦៧ |
| រោងពុម្ព និងគ្រឿងយន្ត | ៧០ | ៣១.៧០២.០០០ | ៧១៤ | ១១ | ១២.០០១១.០០០ | ១០៣៣ | ៨១ | ១៥១.៧១៣.០០០ | ១៧៤៧ |
| | ៣៣១៣ | ៦៣៦.៣៦៥.០០០ | ១៦៦៣១ | ៣៣ | ៥៤៧.៣១៦.០០០ | ៣៤៤០ | ៣៣៤៦ | ១១.៨៨៣.៧៦១.០០០ | ២០០៧១ |

A. ចំនួនសរុបពិតប្រាកដប្រហែលជា ១.០៩៦ (ចូរកត់សម្គាល់ពីតួលេខផ្សេងគ្នាក្នុងតារាង ១២)

B. ចំនួនសរុបពិតប្រាកដប្រហែលជា ១២

C. ចំនួនសរុបពិតប្រាកដប្រហែលជាជំនួញ ១.១០២, ដើមទុន ១៨៣.០០០.០០០, ៤.០៥០ បុគ្គលិក

ប្រភពឯកសារ: តារាងឧស្សាហកម្មធំ

## តារាងទី ១២ :ឧស្សាហកម្មឯកជនធំៗក្នុងកំឡុង ១២ ឆ្នាំនៅកម្ពុជា ១៩៥១–៦១

| ឆ្នាំ | រោងម៉ាស៊ីនកិនស្រូវ | រោងចក្រអារឈើ ប្រើម៉ាស៊ីន | រោងចក្រអារឈើ ប្រើកំលាំងមនុស្ស | រោងចក្រ ចម្រោះទឹកស្អាត | រោងចក្រស្បែកជើង កៅស៊ូ |
|---|---|---|---|---|---|
| **១៩៥១** | ៤៧ | ៨ | ១៧០ | ៨ | --- |
| **១៩៥២** | ៨២ | ១១ | ៩៤ | ៩ | --- |
| **១៩៥៣** | ១៣៦ | ១៣ | ១០១ | ៩ | --- |
| **១៩៥៤** | ២៧៧ | ១៥ | ១០៩ | ១២ | --- |
| **១៩៥៥** | ៥៤៣ | ២២ | ១៩៧ | ១២ | --- |
| **១៩៥៦** | ៦៧៣ | ២៥ | ២២២ | ១២ | --- |
| **១៩៥៧** | ៧៦៥ | ២៩ | ២៣៤ | ១២ | --- |
| **១៩៥៨** | ៩៣១ | ៤៦ | អត់ទិន្នន័យ | ១២ | ១ |
| **១៩៥៩** | ១០៥៧ | ៦៨ | អត់ទិន្នន័យ | ១២ | ៤ |
| **១៩៦០** | ១១៣០ | ៨២ | អត់ទិន្នន័យ | ១២ | ៦ |
| **១៩៦១** | ១២០៤ | ៨៤ | អត់ទិន្នន័យ | ១២ | ១៣ |
| **១៩៦៤** | ១៣២៤ | ២០៣ | អត់ទិន្នន័យ | អត់ទិន្នន័យ | អត់ទិន្នន័យ |

ប្រភពឯកសារ: អាន ស្តាត រ៉ែត្រូ (An. Stat. Retro) ១៩៣៧–៥៧, តារាង ៨–១, អាន ស្តាត រ៉ែត្រូ (An. Stat. Retro) ១៩៥៨–៦១, តារាង ៨–១ កម្ពុជា,៤, ទំ. ៤៧ ។

## តារាងទី ១៣ ចំនួនប្រាក់ដាក់ទុន និងចំនួនបុគ្គលិកក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ១៩៦១

| ផ្នែកនៃឧស្សាហកម្ម | ជំនួញរបស់ជនជាតិចិន ជាមធ្យម | | | ជំនួញមិនមែនជារបស់ជនជាតិចិន ជាមធ្យម | | |
|---|---|---|---|---|---|---|
| | ចំនួនប្រាក់ដាក់ទុន | ចំនួនបុគ្គលិក | ចំនួនទុន នៃអ្នកជំនួញម្នាក់ៗ | ចំនួនប្រាក់ដាក់ទុន | ចំនួនបុគ្គលិក | ចំនួនទុន នៃអ្នកជំនួញម្នាក់ៗ |
| រោងម៉ាស៊ីនកិនស្រូវ | ១៤៤.០០០ | ៣,៦ | ៤០.០០០ | ១១៦.៤០០ | ២,៨ | ៤១.៦០០ |
| ការផលិតផលដើម | ៥៨.០០០ | ៤,៣ | ១៣.៥០០ | ៣៩.៨០០.០០០ | ២៨៧,០ | ១៣៨.៦០០ |
| ការផលិតគ្រឿងអាហារ | ១.២៣៤.០០០ | ៧,៥ | ១៦៤.៥០០ | ៥៩.០០០.០០០ | ១៦៤,០ | ៣៦០.០០០ |
| ផលិតផលឧស្សាហកម្ម | ៦០៦.០០០ | ១២,០ | ៥០.៥០០ | ៧.៨០០.០០០ | ៣៨,១ | ២០២.៤០០ |
| រោងពុម្ព និងហាងម៉ាស៊ីន | ៤៥៣.០០០ | ១០,២ | ៤៤.៤០០ | ១០.៩១០.០០០ | ៩៣,៩ | ១១៦.២០០ |
| សរុបគ្រប់ផ្នែកទាំងអស់ | ២០២.០០០ | ៥,០ | ៤០.៤០០ | ១៦.៦០០.០០០ | ១០៤,៣ | ១៥៨.៥០០ |

## តារាងទី ១៤ ការប៉ាន់ស្មានចំនួនកម្មករចិន នៅកម្ពុជា ១៩៣៦ និង ១៩៦១

| ផ្នែកនៃឧស្សាហកម្ម | ១៩៣៦ | | | | ១៩៦១ | | | |
|---|---|---|---|---|---|---|---|---|
| | ចំនួន | %នៃកម្មករចិន | %នៃមនុស្សប្រុសពេញវ័យចិនA | %នៃកម្មករទាំងអស់ក្នុងផ្នែកនីមួយៗ | ចំនួន | %នៃកម្មករចិន | %នៃមនុស្សប្រុសពេញវ័យចិន B | %នៃកម្មករទាំងអស់ក្នុងផ្នែកនីមួយៗ |
| ឧស្សាហកម្ម | ១៥០០ | ១០% | ២% | ៧៥% | ៦០០០ | ៣៨% | ៦% | ៤៥% |
| គោដនីយដ្ឋាន និងសណ្ឋាគារ | ៧០០ | ៥% | ១% | ៩០% | ១៥០០ | ៩% | ១,៥% | ៩០% |
| វិស័យដឹកជញ្ជូន | ៨០០ | ៥% | ១% | ៨០% | ៥០០ | ៣% | ០,៥% | ២០% |
| ចំការដំណាំ C | ៨០០០ | ៥៣% | ១១% | ៦០% | ៥០០ | ៣% | ០,៥% | ២% |
| ជំនួញ | ៤០០០ | ២៧% | ៥% | ១០០% | ៧៥០០ | ៤៧% | ៧,៥% | ៩៥% |
| សរុប | ១៥០០០ | ១០០% | ២០% | ៧០% | ១៦០០០ | ១០០% | ១៦% | ៣២% |

A. ប៉ាន់ស្មានពីជំរឿនឆ្នាំ ១៩២១ ត្រឹមត្រូវ

B. ប៉ាន់ស្មានពីតំរូវជំរឿនឆ្នាំ១៩៦១

C. ប៉ាន់ស្មានថាមាន ៥.០០០ ពាន់នាក់ក្នុងចំការកៅស៊ូ និង ៨.០០០ នាក់ក្នុងចំការម្រេច នៅឆ្នាំ១៩៣៦ ។

# តារាងទី ១៤ វណ្ណៈសេដ្ឋកិច្ចក្នុងចំណោមជនជាតិចិន នៅកម្ពុជា ឆ្នាំ ១៩៦២–៣

| វណ្ណៈសេដ្ឋកិច្ច | ជនជាតិចិន | | ជនជាតិកម្ពុជាទាំងអស់ | | ជនជាតិចិនគិតជា%នៃប្រជាជនទាំងអស់ |
|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | |
| កសិករ និងអ្នកនេសាទ | --- | --- | ៤.៩៥០.០០០ | ៨៦% | --- |
| **ពលកម្មផ្នែក÷** | ៦៤.០០០ | ១៥,៥% | ២០៩.០០០ | ៤% | ៣១% |
| ឧស្សាហកម្ម | ២៤.០០០ | ៥% | ៥៤.០០០ | ១% | ៤៤% |
| ជំនួញ | ៣០.០០០ | ៧% | ៤២.០០០ | ១% | ៧១% |
| នៅជនបទ | ២.០០០ | ០,៥% | ១០២.០០០ | ២% | ២% |
| សេវាកម្ម A | ៨.០០០ | ៣% | ១១.០០០ | --- | ៧៣% |
| **ជំនួញនៅ÷** | ៣៥.៩០០០ | ៨៤% | ៣៧៩.០០០ | ៦,៥% | ៩៥% |
| ទីជនបទ | ១៧.៣០០០ | ៤១% | ១៨៣.០០០ | ៣% | ៩៥% |
| ទីប្រជុំជន | ១៨.៦០០០ | ៤៣% | ១៩៦.០០០ | ៣,៥% | ៩៥% |
| មុខរបរអាជីព និងការងាររដ្ឋាភិបាល | ២.០០០ | ០,៥% | ២០២.០០០ | ៣,៥% | ១% |
| **សរុប** | ៤២.៥០០០ | ១០០% | ៥.៧៤០.០០០ | ១០០% | ៧,៤% |

A. រួមបញ្ចូលទាំងកម្មករធ្វើការក្នុងគោជនីយដ្ឋាន

# ជំពូកទី ២

# សន្និសញ្ញាច្បាប់ និងលក្ខខណ្ឌក្នុងការកំណត់លក្ខណៈត្រឹមត្រូវស្របច្បាប់ របស់ជនជាតិចិននៅកម្ពុជា

*ដោយ វីល្លៀម. អ៊ី. វីលម៉ូតត៍*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "The Legal Status of the Chinese in Cambodia" ។

*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖* **ជនជាតិចិននៅកម្ពុជា** ។

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យប្រ៊ីធីសកូឡុំបៀ ។*

# CHAPTER 2:

## The Legal Status of the Chinese in Cambodia

William E. Willmott

(*The Chinese in Cambodia*)

**Copyright © 1967 by University of British Columbia**

បកប្រែដោយ ទូច សុពុទ្ធី

# ជំពូកទី ២

## សន្ធិសញ្ញាច្បាប់ និងលក្ខខណ្ឌក្នុងការកំណត់លក្ខណៈត្រឹមត្រូវ ស្រប ច្បាប់ របស់ជនជាតិចិននៅកម្ពុជា

*អស់ពេលជាយូរយារណាស់មកហើយ ដែលយើងនៅតែមានមន្ទិលសង្ស័យមិនដាច់ស្រេចមួយចំនួន ស្ដីពីស្ថានភាពក្នុងសង្គមរបស់ជនជាតិចិន ក្នុងការចូលមកជ្រៀតជ្រែកលើមុខនាទីមួយ ដែលមានឥទ្ធិពលគ្របដណ្ដប់លើផ្នែកសេដ្ឋកិច្ចនៃប្រទេសទាំងមូល ហើយពួកគេហាក់ដូចជាមិនដែលបានដាក់ឲ្យនៅក្រោមច្បាប់ដូចជនបរទេសដទៃទៀតនោះឡើយ[១] ។ ជនជាតិចិនទទួលបាននូវបុព្វសិទ្ធិពិសេសមួយចំនួន ដោយបានចាត់ទុកពួកគេថា ជាជនបរទេសផង និងជាប្រជាជនម្ចាស់ស្រុកផងក្នុងពេលតែមួយ នៅពេលដែលពួកគេបានចាត់ទុកខ្លួនឯងថាជាជនពិសេសមួយក្រុម (កូឡេត ទំ. ៤៦២, ហូហ្វេល) ។ សូម្បីតែបារាំង ដែលជាអ្នកព្យាយាមធ្វើការបែងចែក និងកំណត់ឲ្យមានលក្ខណៈត្រឹមត្រូវស្របច្បាប់តាមរយៈសន្ធិសញ្ញារបស់ខ្លួន ជាមួយនឹងប្រទេសចិនក្ដី ក៏មិនទទួលបានជោគជ័យជាផ្លែផ្កាអ្វីដែរ ចំពោះបំណងចង់ជម្រះឲ្យដាច់ស្រេច នូវមន្ទិលដូចដែលបានបរិយាយរួចមកហើយនោះ ។ ផ្ទុយទៅវិញបារាំងកាន់តែមានការច្របូកច្របល់ និងកាន់ច្រឡំច្រើនឡើងថែមទៀត ទៅលើសន្ធិសញ្ញានីមួយៗ ដែលខ្លួនបានចុះហត្ថលេខានោះ (ឡេវ៉ាស័រ ទំ. ៣៨) ។ រាល់សេចក្ដីប្រកាស អំពីស្របច្បាប់របស់ជនជាតិចិននីមួយៗ ទទួលលក្ខខណ្ឌបានជោគជ័យតែទៅលើការ ដែលធ្វើឲ្យកាន់តែប្រត្យក្សឡើងថែមទៀត នូវភាពផ្ទុយគ្នារវាងស្ថានភាពក្នុងសង្គមរបស់ជនជាតិចិនតាមរយៈអនុសញ្ញាអន្តរជាតិ និងស្ថានភាពដើម ដែលខ្លួនធ្លាប់មានពីមុនស្រាប់នៅក្នុងប្រទេសកម្ពុជាតែប៉ុណ្ណោះ ។*

*យើងអាចបែងចែកប្រវត្តិ នៃការកំណត់លក្ខខណ្ឌស្របច្បាប់របស់ជនជាតិចិន ជាបីសម័យកាលគឺ : សម័យមុនអាណានិគមបារាំង សម័យអាណានិគមបារាំង និងសម័យឯករាជ្យ ។ សម័យកាលទាំងបីនេះមិនត្រឹមតែមាននូវលក្ខណៈខុសប្លែកពីគ្នា ទៅលើដំណើរនៃការបង្កើតក្រមច្បាប់ចំពោះជនជាតិចិនប៉ុណ្ណោះទេ វាថែមទាំងបង្ហាញឲ្យឃើញថែមទៀត នូវនយោបាយផ្សេងៗ ដែលមានពាក់ព័ន្ធជាមួយនឹងជនជាតិចិន ។ មុនរបបគ្រប់គ្រងរបស់បារាំងមកលើព្រះរាជាណាចក្រកម្ពុជា ព្រះរាជាខ្មែរមានបំណងដាក់ប្រជាជនទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជាឲ្យនៅក្រោមអំណាច នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។ គំនិតនេះ គឺមានភាពផ្ទុយគ្នាយ៉ាងស្រលះពីបារាំង ព្រោះបារាំងបានអនុវត្តតាមនយោបាយនៃការកំណត់ទៅលើសហគមន៍ជនបរទេស ឲ្យដាច់ស្រឡះពីពួកម្ចាស់ស្រុកដើម ហើយថែមទាំងបង្កើតនូវក្រមច្បាប់យ៉ាងច្បាស់លាស់ ព្រមទាំងអាចធានាបាននូវការទទួលបានមកវិញផ្នែកហិរញ្ញវត្ថុ ដែលបានមកពីការប្រមូលពន្ធពិសេសទៅលើជនជាតិចិន ។ ចំណែកឯនៅសម័យដែលកម្ពុជាទទួលបានឯករាជ្យវិញ ដោយយោងទៅតាមហេតុផលជាច្រើននោះ រាជរដ្ឋាភិបាលកម្ពុជាបានត្រឡប់ទៅចាប់យកនយោបាយមួយយ៉ាងទូលាយ ដែលបានក្ដោបនូវរាល់លក្ខខណ្ឌទាំងឡាយ ស្ដីពីការកំណត់សញ្ជាតិកម្ពុជាទាំងអស់ ដែលមានពីមុនមកឡើងវិញ ។ យើងអាចមើលឃើញយ៉ាងច្បាស់ថា នាសម័យដែលគ្រប់គ្រងដោយបារាំង គឺមាននូវការបែងចែកយ៉ាងដាច់ស្រឡះពីគ្នារវាងជាតិសាសន៍នីមួយៗ ច្រើនជាងពេលសព្វថ្ងៃនេះ ក៏ប៉ុន្តែក្នុងសម័យនោះ បារាំងបង្កើតច្បាប់ទាំងនោះឡើងក្នុងគោលបំណងបម្រើដល់ផ្នែកសេដ្ឋកិច្ច និងប្រព័ន្ធគ្រប់គ្រងដោយប្រយោលទៅលើសង្គមទាំងមូល ជាជាងបំណង*

*ចង់កំណត់លក្ខខណ្ឌនៃច្បាប់យ៉ាងពិតប្រាកដនោះ ហើយប្រព័ន្ធនោះគេហៅថា ប្រព័ន្ធសហគមន៍ជាតិពន្ធុ ហៅជាភាសាបារាំងថា ប្រព័ន្ធកុងក្រេហ្គាស្យុង (congrégation system)*[២] ។

## ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិនមុនសម័យអាណានិគមន៍បារាំង

*នៅក្នុងព្រះរាជសារមួយរបស់ព្រះរាជានៃប្រទេសកម្ពុជា ព្រះបាទបរមរាជាទី ៥ (១៦៥៩-៧២) ផ្ញើរទៅកាន់បេសកទូតបារាំងនៅឯជ្រោយមលក្កា បានបង្ហាញឲ្យឃើញថា នៅចុងសតវត្សទី ១៧ ជនបរទេសទាំងអស់ ដែលរស់នៅលើដែនដីនៃប្រទេសកម្ពុជា គឺស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់ស្តេច(ប៊ែរណារដ៍ ហ្វ. ហ្គ្រោស៍លីយេ័រ ១៩៥៨ ទំ.១៥៥)។ជាមួយនឹងការកើនឡើងនូវចំនួនជនបរទេសក្នុងទីក្រុងភ្នំពេញ ច្បាប់នេះមើលទៅហាក់ដូចជាមិនទាន់មានប្រសិទ្ធភាពគ្រប់គ្រាន់ ក្នុងការគ្រប់គ្រងទៅលើក្រុមជាតិពន្ធុ (ជនជាតិ) ជាច្រើនដែលមានលក្ខណៈខុសប្លែកពីគ្នាពីក្រុមមួយទៅក្រុមមួយ ហើយថែមទាំងខុសប្លែកគ្នាពីជនជាតិខ្មែរនៅឡើយ ។ ហេតុដូច្នេះហើយវាមិនមែនជាការភ្ញាក់ផ្អើលអ្វីនោះទេ ដែលថា ក្រោយពីរាជ្យរបស់ព្រះបរមរាជា ភ្លាមនោះគេបានទទួលយកនូវប្រព័ន្ធមួយដែលអាចគ្រប់គ្រងទៅលើសហគមន៍ជនបរទេសដោយប្រយោលបាន មកអនុវត្តន៍នៅក្នុងប្រទេស ។ យើងអាចមើលឃើញភស្តុតាងទាំងនេះតាមរយៈច្បាប់ក្រមស្រុក ដែលបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការឡើងនៅរាជធានីឧត្តុង្គក្នុងឆ្នាំ ១៦៩៣*[៣] ។

*ច្បាប់កំពូលរបស់ប្រទេស ដែលនិយាយទាក់ទងទៅនឹងជនបរទេស គឺនៅត្រង់មាត្រាទី ១០០ នៃច្បាប់ក្រមស្រុក ហើយលោករេស៊ីដង់ស៊ុបពេរីយែរប្រចាំនៅប្រទេសកម្ពុជា គឺលោក រេស៊ីដង ស៊ុបពែរីយេ អាដេម៉ាដឡឺក្លែរ បានធ្វើការបកប្រែនៅក្នុងឆ្នាំ ១៨៩៨ ដែលមានខ្លឹមសារដូចតទៅ÷*

> មួយទៀតសោត បើលោកនឹងស្រដីឲ្យជា ចៅទា (មកពីពាក្យសៀម «ចៅមានន័យថា ម្ចាស់ និង ទាមានន័យថាកំពង់» ដូច្នេះចៅទាជាម្ចាស់កំពង់ ឬ ប្រធានក្រុមនេះឯង) លោកឲ្យរកបរទេស (ណាដែលចេះ)សព្វភាសា ទើបលោក(៤៣០) នឹងឲ្យស្រដីជា (តែងតាំង) ចៅហ្វាយពោះត្រា ឲ្យជាចៅហ្វាយពន្ធបៀ ឯចៅហ្វាយ ចៅទាសោត (៤៣១) ឲ្យលាវ (ជា) ចៅទាស្រដី (គ្រប់គ្រង) លើទូកលាវ ឲ្យយួន (ជា) ចៅទាស្រដីលើ គូលាយ (ប្រភេទទូកម្យ៉ាង)យួន ឲ្យចាម (ជា) ចៅទាស្រដីលើសំពៅចាម ឲ្យជ្វា(ជា) ចៅទាស្រដីលើសំពៅជ្វា ឲ្យចិន(ជា) ចៅជាស្រដីលើសំពៅ(៤៣៣) ចិន ឲ្យយីប៉ុន (ជប៉ុន) (ជា) ចៅទាស្រដីលើសំពៅ យីប៉ុន ឯសំពៅបារាំង (បើតាមលោក ហ្គ្រេហ្គូរី មីកាលៀន ថា ពាក្យដែលខ្មែរថាបារាំងនោះ គឺសំដៅលើជនជាតិ អេស្ប៉ាញញ៉ុល ឬ ព័រទុយហ្គេ) សំពៅអង់គ្រិស (អង់គ្លេស) នោះ (៤៣៤) ទោះកូន យីប៉ុនក្តី កូនចិនក្តី បើចេះស្រដីភាសាបារាំងហើយ សឹងឲ្យជាចៅទាឯបារាំង(៤៣៥) ឯងថាបើចេះស្រដីខ្មែរ ដឹងច្បាប់ខ្មែរ ឲ្យជាចៅទាបារាំងបាន ឯសំពៅក្លិង្គ សំពៅ(២៣៦) កុលា (មកពីភូមា) នោះ បើមានក្លិង្គ មានកុលា ចេះស្រដីខ្មែរ ដឹងច្បាប់ខ្មែរនោះ ឲ្យជាចៅទាបាន (២៣៧) បើគ្មានក្លិង្គកុលា សោតឲ្យជ្វាជាចៅទាបាន ឯចៅហ្វាយត្រា បើចិនឯណាចេះស្រដី (៤៣៨) ខ្មែរ ហើយដឹងច្បាប់ខ្មែរ សឹងឲ្យជាចៅហ្វាយត្រា ឯបារាំងនោះសោត ពុំដែលចិញ្ចឹម (៤៣៩) ឡើយ។ ឯចៅហ្វាយពន្ធបៀនោះសឹងចិនសុទ្ធ ស្រីដីជាចៅហ្វាយបៀ[៤] ។ (បកប្រែជាភាសាខ្មែរតាមរយៈក្រមស្រុកដោយ មីសែល អង់តែម្មល៍ )

*ចំពោះសិស្សដែលសិក្សាពីជនជាតិចិន គឺមានការចាប់អារម្មណ៍ទៅលើចំណុចចន្លោះប្រហោង ដែលគេមិន*

*បានលើកយកមកនិយាយនោះទៅវិញ ។ យើងគួរស្វែងយល់ថា តើថៅទាមាននាទីដើរប្រមូលពន្ធដារពីសមាជិកក្រុមរបស់ខ្លួនដែរឬទេ ។ យើងក៏គួរតែស្វែងយល់ឲ្យឃើញផងដែរថា តើគាត់មានការទាក់ទងយ៉ាងដូចម្ដេច ជាមួយនឹងរដ្ឋបាលនៃប្រទេសកម្ពុជា ថាតើគាត់ត្រូវរាយការណ៍ឲ្យនរណា ហើយថាតើគាត់គួរតែដើរតាមសច្ចាប័នបែបណា ដែលគួរឲ្យទុកចិត្តបាននោះ ។ យើងក៏គួរតែស្វែងយល់ពីតួនាទី និងបុព្វសិទ្ធិពិសេសរបស់ពួកគេ ក៏ដូចជាករណីយកិច្ចរបស់ពួកគេផងដែរ ពិសេសជាងនេះទៅទៀតនោះ យើងគួរតែស្វែងយល់ពីដំណើរ នៃការជ្រើសតាំងតំណែងថៅទា នេះថាតើសមាជិកនៃក្រុមរបស់គាត់ ជាអ្នកបោះឆ្នោតជ្រើសរើសគាត់ ឬក៏ព្រះរាជា ជាអ្នកតែងតាំងគាត់ ។ តាមរយៈដំណើរការនេះអាចបង្ហាញឲ្យយើងឃើញពីរចនាសម្ព័ន្ធផ្ទៃក្នុង របស់សមាគមន៍ចិននាពេលនោះបាន ។ រាល់ចម្ងល់ទាំងអស់ខាងលើនេះគ្មាននៅក្នុងច្បាប់នោះទេ ប៉ុន្តែអ្វីមួយដែលបង្ហាញឲ្យឃើញយ៉ាងច្បាស់នោះ គឺមានព្រះរាជានៃប្រទេសកម្ពុជាជាច្រើនអង្គ បានផ្ដួចផ្ដើមគំនិតឲ្យចេញជាប្រព័ន្ធគ្រប់គ្រងដោយប្រយោលឡើង ដែលតម្រូវឲ្យសមាជិកម្នាក់ មកពីសហគមន៍ជនបរទេសនីមួយៗ ទទួលខុសត្រូវលើផ្នែកច្បាប់ និងសណ្ដាប់ធ្នាប់ល្អក្នុងសហគមន៍របស់ពួកគេ ។ នេះ គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធសហគមន៍ជាតិពន្ធុ ដែលបានយកទៅធ្វើការកែច្នៃយ៉ាងល្អិតល្អន់ ដោយអាណាចក្រអណ្ណាមនៅចុងសតវត្សរ៍ទី ១៩ ហើយក្រោយមក បារាំងបានយកមកអនុវត្តជាផ្លូវការនៅពាសពេញតំបន់ឥណ្ឌូចិនទាំងមូល(៥) ។*

*លោក ង្វៀន គួកឌិញ ដែលជាអ្នកបានសិក្សា និងសរសេរយ៉ាងលម្អិតទៅលើប្រព័ន្ធសហគមន៍ជាតិពន្ធុរបស់ចិនតែនៅក្នុងតំបន់ឥណ្ឌូចិន បានជជែកវែកញែកឡើងថា តាមការពិតទៅ ច្បាប់ក្រមស្រុកនេះមិនបានបង្កើតឲ្យមានឡើង នូវការគ្រប់គ្រងដោយប្រយោលទៅលើជនជាតិចិននោះទេ ។ គាត់បានសរសេរនៅក្នុងកំណត់ចំណាំមួយ ពីមូលហេតុដែលគាត់ហ៊ានអះអាងថា ប្រទេសកម្ពុជាមិនមែនជាប្រទេស ដែលបារាំងយកគំរូតាមនោះទេ ។ កំណត់ចំណាំនោះមានសេចក្ដីដូចតទៅ ៖*

> ខ្ញុំចង់និយាយពីបញ្ហានៅក្នុងប្រទេសកម្ពុជា ដោយទុកករណីប្រទេសវៀតណាមមួយឡែកសិន ។ មុនសម័យបារាំងគ្រប់គ្រង នៅក្នុងប្រទេសកម្ពុជាមិនទាន់មានស្ថាប័ន ឬសង្គមចិន ដែលជាក្រុមពិសេស មានលក្ខណៈរៀបរយដូចនៅប្រទេសវៀតណាមនៅឡើយទេ ។ ដូច្នេះ ជនអន្តោប្រវេសទាំងអស់ ដែលរស់នៅក្នុងប្រទេសកម្ពុជា ត្រូវចាត់ទុកដូចជាប្រជាជនម្ចាស់ស្រុកដែរ ក្នុងវិស័យពន្ធដារ និងតុលាការ ។ បើប្រៀបធៀបទៅនឹងជនជាតិខ្មែរ ជនអន្តោប្រវេសចិនទាំងនោះ ត្រូវទទួលបង់ពន្ធលើខ្លួនគេម្នាក់ៗដូចជាជនជាតិខ្មែរដែរ សូម្បីតែអ្នកដែលធ្វើការក្បែរស្ដេចក៏ដោយ លើកលែងតែប្រជាកសិករខ្មែរចេញ ។ ក្នុងពេលមានករណីមានបទឧក្រិដ្ឋ ឬរដ្ឋប្បវេណី ឬការផាកពិន័យ ក៏ពួកគេទទួលការកាត់ទោសពីសំណាក់ចៅក្រម និងពីច្បាប់តែមួយ ដូចនឹងប្រជារាស្ត្រខ្មែរដែរបើសិនជាខុសគ្នានោះ គឺខុសតែទៅលើការចែងនៅក្នុងមាត្រាមួយចំនួន នៃពង្រាងច្បាប់សម្រាប់ជនបរទេស ដែលកំណត់ឲ្យជនបរទេសទាំងនោះគោរព និងអនុវត្តទៅតាមច្បាប់ ដែលមានតាមតំបន់ដែលពួកគេបានរស់នៅរៀងៗខ្លួន ក្រោមការគ្រប់គ្រងដោយផ្ទាល់របស់មេក្រុមមួយហៅថា «ថៅទា»តែប៉ុណ្ណោះ(៦) ។
> (អត្ថន័យបកប្រែជាខ្មែរ ដោយលោកថាច់ដេត និងលោក ហៀង សុខុម)

*យោងទៅលើភស្តុតាងខាងលើនេះ លោកង្វៀន ហាក់ដូចជាធ្វើការសន្និដ្ឋានរហ័សពេកថា ជនជាតិចិនបានរស់នៅយ៉ាងស្របច្បាប់ ក្រោមការគ្រប់គ្រងរបស់ព្រះរាជាខ្មែរ ដោយលោកមិនបានមើលទៅលើធាតុពិត ដែល*

មានចែងយ៉ាងច្បាស់ក្នុងច្បាប់ក្រមស្រុកត្រង់មាត្រាទី ៧ ថា ត្រូវចាត់ទុកជនជាតិចិនជាជនបរទេស ដែលន័យសេចក្តីមាននៅក្នុងសំណេររបស់លោក ឡេរ៉ាស៊័រ ជាបុគ្គលសំខាន់ម្នាក់ ដែលបានសិក្សាពីជនជាតិចិននៅក្នុងតំបន់ឥណ្ឌូចិន ។ លោក ផ្សៀន និយាយត្រូវ ក្នុងការដែលលោកអង្កេតមើលតែទៅលើបុគ្គលម្នាក់ៗ តែលោកហាក់ដូចជាមិនបានឃើញពីធាតុពិត ចំពោះសហគមន៍ជនជាតិចិនទាំងមូល ដែលត្រូវបានដាក់ឲ្យនៅក្រោមច្បាប់យ៉ាងដាក់លាក់មួយ ដោយបានដាក់ក្រុមជនជាតិមួយនេះទៅក្នុងប្រភេទមួយ ដែលខុសគ្នាទាំងរវាងជនជាតិខ្មែរផង និងសហគមន៍ជនបរទេសដទៃទៀតផង ។ យើងអាចនិយាយម្យ៉ាងទៀតថា បើទោះបីជាជនជាតិចិនអាចនឹងមានការងាយស្រួល ក្នុងការគេចផុតពីច្បាប់នេះក៏ដោយ យ៉ាងហោចណាស់ក៏មាននូវនិយមន័យមួយ ដែលកំណត់ឡើងដោយច្បាប់ ដែលបានកំណត់សម្រាប់ជនជាតិចិនឲ្យនៅផ្សេងតែឯង ខុសពីក្រុមដទៃទៀតដែរ ។

ជនជាតិចិន ក៏ដូចជាជនបរទេសដទៃទៀតដែរ គឺបានរួចផុតពីកំណែន ដែលជាទូទៅមានរយៈពេលបីខែក្នុងមួយឆ្នាំ សម្រាប់អ្នកដែលជាប់កំណែននោះ (អែម៉ូណីញេ ទំ.៤៣) ។ ក៏ប៉ុន្តែ អ្វីដែលមិនដូចនឹងជនបរទេសដទៃទៀតនោះគឺថា ជនជាតិចិនមានតួនាទីទទួលបន្ទុកលើផ្នែករដ្ឋបាលនៅក្នុងប្រទេសកម្ពុជា ។ មាត្រាទី ១០៣ នៃក្រមស្រុក បានផ្តល់នូវតួនាទីផ្នែកគ្រប់គ្រងកំពង់ផែនៅក្រុងភ្នំពេញឲ្យទៅកូនកាត់ចិន (ឡឺក្លែរ ១៨៩៨, ទំ. ១១៥) ។ ច្បាប់ដដែលនេះក៏បានលើកឡើងផងដែរថា ជនបរទេសអាចធ្វើជាចៅហ្វាយខេត្តបាន លុះណាបុគ្គលនោះកើតនៅក្នុងទឹកដីនៃប្រទេសកម្ពុជា និងអាចនិយាយភាសាខ្មែរបានស្ទាត់ (ឡឺក្លែរ ទំ.៩៩ មាត្រា ៤៤) តួយ៉ាងដូចជាជនជាតិចិនឈ្មោះ មូ ជឺ បានក្លាយទៅជាអភិបាលខេត្តក្នុងឆ្នាំ ១៧០៨ ហើយខ្មែរកាត់ចិនមួយរូបទៀតបានធ្វើជាចៅហ្វាយខេត្ត (ឧកញ៉ា) កំពត និងបានជួយដល់ព្រះបាទអង្គឌួង ឲ្យបានឡើងសោយរាជ្យសម្បត្តិនៅក្នុងឆ្នាំ ១៨៤១ (ឡឺក្លែរ ១៩០៧, ទំ. ៨៣៧)។

លើសពីនេះទៅទៀត ដូចដែលយើងបានដឹងនៅក្នុងជំពូកទី ៣ រួចមកហើយថា ព្រះរាជាខ្មែរបានប្រទានសិទ្ធិផ្តាច់មុខដល់ជនជាតិចិនទៅលើផ្នែកហិរញ្ញវត្ថុ គ្រឿងស្រវឹង និងនេសាទ ។ មាត្រាទី ១០៤ នៃច្បាប់ក្រមស្រុក បាននិយាយថា «រាល់ការប្រមូលពន្ធបៀទាំងឡាយ ត្រូវប្រគល់សិទ្ធិឲ្យជនជាតិចិន»[៧] (ឡឺក្លែរ ១៨៩៨ ទំ.១១៥)។

បើនិយាយពីផ្នែកច្បាប់ និងជម្លោះវិញ យើងឃើញមានភស្តុតាងដែលអាចបង្ហាញថា ជនជាតិចិនតែងដោះស្រាយជម្លោះរបស់ពួកគេដោយខ្លួនឯង ដោយមិនពឹងទៅលើតុលាការ នៃព្រះរាជាណាចក្រកម្ពុជាឡើយ ។ លើសពីនេះទៀត នៅពេលដែលបារាំងមកដល់ខេត្តកំពត ពួកគេបានកត់សម្គាល់ឃើញថា មេដឹកនាំសមាគមន៍ចិនដែលមានគេគោរពគ្រប់ៗគ្នានោះ គឺជាអតីតចោរសមុទ្រដើមកំណើត ហ៊ុកកៀន មានឈ្មោះថា មុនសុយ ដែលខ្លួនលោកផ្ទាល់បានព្យាយាមធ្វើអ្វីៗគ្រប់បែបយ៉ាង ដើម្បីឲ្យបានលេចមុខមាត់ឡើងក្នុងចំនោមប្រជាជនចិននៅតំបន់នោះ (ឡឺក្លែរ ១៩០៧ ទំ. ៨៣៩) ។

នៅមុនបារាំងគ្រប់គ្រងប្រទេស គេតែងចាត់ទុកជនជាតិចិនទាំងអស់ ដែលកើតនៅលើទឹកដីខ្មែរថាជាប្រជាជនកម្ពុជា ប្រសិនបើគេព្រមទទួលយកនូវវប្បធម៌ និងប្រពៃណីខ្មែរ (អ៊ីស៊ី ទំ.៣៤៨)។ កូនចិនកាត់ខ្មែរ គឺជាជនជាតិខ្មែរដោយស្វ័យប្រវត្តិ ដូចដែលលោកឡេរ៉ាស៊ឺបាននិយាយថា

> នៅទីនេះ ... ពួកកូនកាត់ចិនមិនអាចសំអាងខ្លួនជាសញ្ជាតិបរទេសនៅចំពោះព្រះភ័ក្ត្ររបស់ព្រះរាជាបានឡើយ[៨]

ជាក់ស្តែងយើងឃើញថា ជនជាតិចិនអាចមានសិទ្ធធ្វើជាម្ចាស់លើអចលនទ្រព្យផ្សេងៗ ប៉ុយ៉ាងហោចណាស់

ក៏ទទួលបាននូវសិទ្ធិអាស្រ័យផលដូចគ្នា នឹងប្រជាជនកម្ពុជាដែរ ។ មុនឆ្នាំ ១៩០៤ គ្រប់អចលនទ្រព្យទាំងអស់ គឺជារបស់ព្រះរាជាដែលគ្រងរាជសម្បត្តិ ហើយមិនអាចលក់ឲ្យជនបរទេសឡើយ ។ លើសពីនេះទៀតនោះ ព្រះរាជាអាចដកហូតយកអចលនទ្រព្យទាំងនោះបានគ្រប់ពេលវេលាទាំងអស់ (ឡេវ៉ាសឺ ទំ.១៣២) ។

សរុបមក យើងឃើញថា មុនពេលដែលបារាំងចូលមកដល់ក្នុងប្រទេសកម្ពុជា ជនជាតិចិនដែលមិនបានកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវស្ថិតក្រោមការគ្រប់គ្រងដោយច្បាប់ពិសេសដ៏ជាក់លាក់មួយ ប៉ុន្តែពួកគេទទួលបាននូវបុព្វសិទ្ធិពិសេសជាច្រើន ដែលជនបរទេសដទៃទៀតមិនដែលបានទទួល ។ ជនជាតិចិនដែលកើតនៅក្នុងប្រទេសកម្ពុជា អាចក្លាយទៅជាប្រជារាស្ត្រកម្ពុជា ដែលមានព្រះមហាក្សត្រកម្ពុជាជាអ្នកគ្រប់គ្រង បានដោយងាយ ដោយគ្រាន់តែទទួលយកនូវប្រពៃណីវប្បធម៌របស់កម្ពុជាតែប៉ុណ្ណោះ ។

## ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិនដៅសម័យអាណានិគមន៍បារាំង

ការជ្រៀតចូលរបស់បារាំងមកកាន់តំបន់ឥណ្ឌូចិនក្នុងឆ្នាំ ១៨៥៩ គឺបានទទួលការគាំទ្រពីជនជាតិចិន ដែលជាប្រជាជនម្ចាស់ស្រុក ជាអ្នកដែលបានសម្លឹងឃើញនូវលទ្ធផលល្អ ក្រោមរបបគ្រប់គ្រងរបស់បារាំង ដែលអាចផ្តល់ឲ្យពួកគេនូវស្ថិរភាព និងសណ្តាប់ធ្នាប់ល្អក្នុងតំបន់មួយ ដែលពីមុនសម្បូរទៅដោយការបះបោរ អំពើរប្លន់តាមផ្លូវសមុទ្រ និងការលួចប្លន់ (គូឡេត ទំ.៤៦)។ ផ្ទុយទៅវិញ បារាំងបានពឹងពាក់ទៅលើជនជាតិចិន ដោយចាត់ទុកថាជនជាតិចិន គឺជាអន្តរការី[៩] និងជាអ្នកឧបត្ថម្ភដល់កងទ័ពរបស់ពួកគេ ក៏ប៉ុន្តែនៅដើមឆ្នាំ ១៨៦២ ឧត្តមនាវីឯក បូណាដ ដែលជាទេសាភិបាលតំបន់ឥណ្ឌូចិនដំបូងគេ មើលឃើញថា ការគ្រប់គ្រងឲ្យកាន់តែជិតឡើងថែមទៀតទៅលើសហគមន៍ជនជាតិចិន គឺជាភាពចាំបាច់មួយ ។ ដូច្នេះហើយ ទើបបានជានៅក្នុងឆ្នាំបន្ទាប់គាត់ចាប់ផ្តើមនូវនយោបាយបង្កើនប្រាក់ចំណូលជាតិ តាមរយៈការដាក់ពន្ធពិសេសមួយទៅលើជនជាតិចិន ។ ដើម្បីរក្សាឲ្យបាននូវចំណូលទាំងនេះ លោក បូណាដ បានបង្កើតឡើងនូវប្រព័ន្ធគ្រប់គ្រងដោយប្រយោលមួយ ដល់ជនជាតិចិន តាមរយៈដំណើរនៃការបង្កើតច្បាប់ឡើងមកបន្តិចម្តងៗ ដោយប្រើរយៈពេលអស់ជាច្រើនឆ្នាំ ហើយនៅទីបញ្ចប់ក្នុងឆ្នាំ១៨៧១ លោកក៏បានដាក់ជនជាតិចិនគ្រប់ៗរូប ឲ្យស្ថិតនៅក្រោមប្រព័ន្ធសហគមន៍ជាតិពន្ធុ ដោយខានមិនបាន (ឡាហ្វាហ្គ៍ ទំ.៣៥-៤៤)។

ប្រព័ន្ធសហគមន៍ជាតិពន្ធុ ដែលបង្កើតឡើងដោយបារាំងនេះ គឺបារាំងយកគំរូដោយផ្ទាល់ ពីច្បាប់គ្រប់គ្រងជនជាតិចិននៅតំបន់អណ្ណាម ដែលមានប្រភពមកពីព្រះរាជតម្រិះរបស់អធិរាជ កៃ ឡុង នៅក្នុងឆ្នាំ ១៨១៤។

នៅក្នុងដំណើរនៃការវាយលុកទន្ទ្រានមកភាគខាងត្បូង ទៅក្នុងតំបន់ដីសណ្តទន្លេមេគង្គ (ដែលពីមុនមកជាផ្នែកមួយនៃអាណាចក្រខ្មែរ) អាណាចក្រ អណ្ណាម បានប្រឈមមុខទៅនឹងចំនួនប្រជាជនក្នុងតំបន់មួយ ដែលចម្រុះដោយក្រុមជនជាតិផ្សេងៗពីគ្នា ។ ជនអន្តោប្រវេសចិនដើរតួនាទីយ៉ាងសំខាន់មួយ នៅក្នុងដែនដីអាណានិគមមួយនេះ រាប់ចាប់តាំងពីឧត្តមសេនីយ៍ យ៉ាំង បានផ្តល់នូវការបម្រើរបស់ខ្លួនក្នុងឆ្នាំ១៦៧៩ មកម្ល៉េះ ។ នៅដើមសតវត្សរ៍ទី ១៩ ស្តេច កៃឡុង ជួបប្រទះនឹងបញ្ហា ក្នុងការគ្រប់គ្រងទៅលើចំនួនប្រជាជនចម្រុះពូជសាសន៍ទាំងនេះហើយក៏បានរកឃើញនូវគំនិតមួយ ដោយបង្កើតឲ្យមានឡើងនូវសមាគមន៍ជនជាតិចិន ដើម្បីដាក់ទៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល ។ ព្រះរាជបញ្ញារបស់ទ្រង់នៅក្នុងឆ្នាំ ១៨១៤ បានបង្កើតឲ្យមានឡើងនូវរដ្ឋបាលពិសេសមួយ សម្រាប់ជនជាតិចិន ដោយបានបែងចែកពួកគេទៅជាក្រុមៗ ដោយផ្អែកទៅលើទីកន្លែងកំណើតរបស់ពួកគេ (កាតាំង ហុក

គៀន ចិនខិ ហៃណាំ ហូចូវ គៀងចូវ) ហើយតម្រូវឲ្យពួកគេទាំងអស់ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់មេដឹកនាំពួកគេរៀងៗខ្លួន ។ ពួកមេដឹកនាំទាំងនេះ មាននាទីទទួលបន្ទុកខាងផ្នែកច្បាប់ និងគ្រប់គ្រងរៀបចំទៅលើកូនក្រុមរបស់ពួកគេ និងដើរតួរជាអន្តរការីរវាងពួកសមាជិកក្រុមទាំងនោះ និងរាជការ ក្នុងបញ្ហាទំនាក់ទំនង និងពន្ធដារ[១០] ។ បារាំងបានយករូបមន្តនេះមកប្រើប្រាស់តាមរយៈក្រឹត្យរបស់ខ្លួនមួយក្នុងឆ្នាំ ១៨៦៣ ប៉ុន្តែក្វាមៗក្រោយមក ចំនួនក្រុមបានថយមកនៅត្រឹម ៥ ក្រុមគឺ: ចិនកាតាំង ចិនហុកគៀន ចិនទាជីវ ចិនខិ និងចិនហៃណាំ (ផ្លូយិន ទំ.៤៥)។

ខុសពីនយោបាយដែលពួកគេបានប្រើនៅក្នុងតំបន់អណ្ណាម និង កូសាំងស៊ីន នោះបារាំងបានបង្ហាញនូវការចាប់អារម្មណ៍តិចតួច ទៅលើច្បាប់ផ្ទៃក្នុងសម្រាប់ប្រទេសកម្ពុជា នៅក្នុងកំឡុងពីរទសវត្សរ៍ដំបូង នៃរបបអាណាព្យាបាល ។ រហូតដល់ឆ្នាំ ១៨៨៤ នៅពេលដែលមានការបង្ខំឲ្យព្រះបាទនរោត្តមចុះហត្ថលេខាលើសន្ធិសញ្ញាផ្សេងៗទៅហើយ ទើបបារាំងចាប់ផ្តើមបង្កើតឲ្យមានជាច្បាប់ទម្លាប់ឡើង នៅក្នុងប្រទេសកម្ពុជា ។ ដំបូងឡើយព្រះបាទនរោត្តម ប្រហែលជាមានការរើងទទឹងមិនទទួលស្គាល់ចំពោះច្បាប់ឆ្នាំ ១៨៧១ ដែលតម្រូវឲ្យមានការបែងចែកប្រភេទអនិកជនជាតិអាស៊ីទាំងអស់[១១] ជាក្រុមៗ ជាពិសេសចំពោះជនជាតិចិន (និងជនជាតិវណ្ណា) នៅក្នុងតំបន់វណ្ណចិន ទើបទ្រង់ចេញរាជក្រឹត្យមួយនៅក្នុងខែ មេសា ឆ្នាំ ១៨៧៣ ដោយបានដាក់ជនជាតិអាស៊ី ដែលរស់នៅលើទឹកដីកម្ពុជាទាំងអស់ ឲ្យស្ថិតនៅក្រោមព្រះរាជបរិបាល (ការគ្រប់គ្រង) ដោយផ្ទាល់ពីព្រះរាជា (ឡេវ៉ាំស៊ី ៦៤) ។ ក្នុងការប្រឈមមុខជាមួយនឹងការគំរាមកំហែងរបស់បារាំង ដែលចង់ដករាជ្យសម្បត្តិពីទ្រង់ហើយប្រគល់ទៅឲ្យស្តេច ស៊ីសុវត្ថិនោះ ស្តេច នរោត្តម បានយល់ព្រមចុះហត្ថលេខា លើអនុសញ្ញាក្រុងភ្នំពេញមួយ នៅថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៨៨៤ ។ នៅក្នុងមាត្រាទី ១ នៃអនុសញ្ញានេះ បានបរិយាយយ៉ាងដាក់លាក់ថា ÷

> យើងព្រះចៅក្រុងកម្ពុជាធិបតី ព្រមទទួលស្គាល់ទាំងស្រុងលើកំណែទម្រង់ថ្មីផ្នែករដ្ឋបាល ផ្នែកច្បាប់ ផ្នែកហិរញ្ញវត្ថុ ក៏ដូចជាផ្នែកពាណិជ្ជកម្មរបស់សាធារណរដ្ឋបារាំង ដោយមើលឃើញថា យើងត្រូវតែធ្វើបែបនេះ ដើម្បីឲ្យការដាក់អាណាព្យាបាលរបស់បារាំងលើទឹកដីកម្ពុជា មានដំណើរការទៅបានល្អ និងទទួលបានជោគជ័យ[១២] ។

បន្ទាប់ពីបារាំងធ្វើការបង្ក្រាបទៅលើការបះបោរ ដែលប្រឆាំងនឹងច្បាប់ មិនសូវមានគេដឹងឮមួយនេះមកក្វាមៗនោះខ្លួនបានចាប់ផ្តើមធ្វើកំណែទម្រង់រដ្ឋបាលរបស់ប្រទេសកម្ពុជា ។ នៅក្នុងកំណែទម្រង់រចនាសម្ព័ន្ធពន្ធដារមួយនាឆ្នាំ ១៨៨៤ បារាំងបានយកច្បាប់ដែលខ្លួនបានបង្កើតសម្រាប់តំបន់វណ្ណចិនកាលពីមុន ដែលតម្រូវឲ្យជនជាតិចិនទទួលបន្ទុកបង់ពន្ធបន្ថែមនោះមកអនុវត្តនៅក្នុងប្រទេសកម្ពុជាតែម្តង(ឡាហ្វាហ្គ ៥៥) ។ ច្បាប់នេះពិតជាធ្វើឲ្យមានបញ្ហាយ៉ាងច្រើន ក្នុងស្ថានភាពមួយដែលមិនទាន់មានការបែងចែកច្បាស់លាស់ណាមួយ ដើម្បីដាក់កំហិតមិនឲ្យជនជាតិចិនមានសិទ្ធិចូលសញ្ជាតិកម្ពុជាដើម្បីបានរួចពន្ធ[១៣] ។

នៅគ្រានោះ បារាំងបានវាយប្រយុទ្ធជាមួយនឹងជនជាតិចិននៅក្នុងតំបន់តុងកឹង . ហើយនៅទីបញ្ចប់នៃសង្គ្រាម បានបង្កើតឲ្យមានសន្ធិសញ្ញា ទៀនសិន មួយឡើងមក ដោយបានចុះហត្ថលេខានៅថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ១៨៨៥ ។ នៅក្នុងឆ្នាំ ១៨៨៥ បារាំងបានបង្ខំព្រះបរមរាជវាំងចិនឲ្យផ្តល់នូវសិទ្ធិសម្រាប់ជនជាតិចិន និង គ្រួសាររបស់ពួកគេគ្រប់រូប អាចធ្វើដំណើរតាមកំពង់ផែរបស់បារាំង ដោយស្របច្បាប់ និងគ្មានការរករឿងអ្វីឡើយ (កាឡុក ទំ.៩១) ។ នៅក្នុងសន្ធិសញ្ញាទៀនសិន បារាំងបានចំណេញនូវការប្រើប្រាស់កំពង់ផែជាច្រើនកន្លែងរបស់

*ចិនសម្រាប់ការធ្វើពាណិជ្ជកម្ម ហើយជាការដោះដូចគ្នានោះ ពួកគេបានធ្វើកិច្ចព្រមព្រៀងមួយ ដែលសម្រេចថា នឹងដាក់ចូលបន្ថែមនូវឃ្លាដូចខាងក្រោមនេះ គឺនៅក្នុងកថាខណ្ឌទី ៣ នៃមាត្រាទីមួយ ÷*

> សម្រាប់ជនជាតិចិនជាអតីតទាហានចាស់ ឬជាអ្នកដែលមានកំណើតនៅអណ្ណាម និងកំពុងរស់នៅលើទឹកដីនៃប្រទេសអណ្ណាម ដោយក្តីសុខសាន្ត ដោយបានប្រកបរបរកសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម និងជាអ្នកដែលមានបុគ្គលិកលក្ខណៈ ឬអាកប្បកិរិយាសមរម្យ ដោយមិនធ្វើអ្វីឲ្យប៉ះពាល់ដល់សង្គមនោះ ពួកគេអាចមានសិទ្ធិផ្ទាល់ខ្លួន និងសិទ្ធិគ្រប់គ្រងទៅលើទ្រព្យសម្បត្តិរបស់ពួកគេ ប្រៀបដូចជាប្រជាជនម្ចាស់ស្រុកជាអ្នកដែលបារាំងបានគាំពារដែរ[១៨] ។ (បកប្រែជាភាសាខ្មែរដោយលោក ថាច់ ដេត)

*នៅឆ្នាំបន្ទាប់ គឺនៅក្នុងឆ្នាំ ១៨៨៦ ភាគីទាំងពីរបានយល់ព្រមគ្នាលើអនុសញ្ញាពាណិជ្ជកម្មមួយ ដែលបានកំណត់នៅក្នុងមាត្រាទី ១៦ ថា បើតាមផ្លូវច្បាប់ជនជាតិចិននៅក្នុងតំបន់អណ្ណាម គួរទទួលបាននូវការចាត់ទុកដូចជាជាតិសាសន៍ ដែលទទួលបាននូវក្តីអនុគ្រោះបំផុត (មីសែល ទំ.១៦) ។ លើសពីនេះទៅទៀត អនុសញ្ញានោះក៏បានបន្ថែមទៀតដែរថា គួរតែបង្កើតឲ្យមានស្ថានកុងស៊ុលរបស់ចិនមួយនៅក្នុងតំបន់តុងកឹង ប៉ុន្តែមួយឆ្នាំក្រោយមក ចិនបានយល់ព្រមផ្អាកការបង្កើតរបស់គេ ហើយរង់ចាំរហូតដល់ពេលណាដែលភាគីទាំងសងខាងសម្រេចចិត្តថា ពួកគេបានត្រៀមខ្លួនរួចជាស្រេច ទៅលើសកម្មភាពទាំងអស់នោះ (អារចាមបូដ ទំ.៨៦)។*

*គ្មានតម្រុយណាមួយអាចបង្ហាញឲ្យឃើញថា សន្ធិសញ្ញាទាំងនេះមានភាពខុសគ្នា ពីអ្វីដែលមាននៅក្នុងសន្ធិសញ្ញាចិន ជាមួយនឹងតំបន់តុងកឹងរបស់បារាំងឡើយ ហើយសន្ធិសញ្ញានេះ ហាក់ដូចជាអនុញ្ញាតឲ្យប្រើតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ បើទោះបីជាគេមិនបាននិយាយនៅក្នុងសន្ធិសញ្ញាយ៉ាងណាក៏ដោយ ។ ជាតុពិតទៅ បើតាមលោកនីកូឡាស យល់ថា សន្ធិសញ្ញាបែបនេះ មិនមែនប្រកាសឲ្យប្រើនៅក្នុងតំបន់តុងកឹងនោះទេ គឺគេប្រើតែនៅក្នុងប្រទេសបារាំងតែប៉ុណ្ណោះ ក៏ប៉ុន្តែច្បាប់នេះ ក៏បានរួមចំណែកដល់ការបង្កើតឡើងនូវច្បាប់មួយ ដែលមានលក្ខណៈសមស្របប្រើនៅក្នុងស្ថានការណ៍នោះដូច្នេះហើយ ទើបគេបន្តអនុវត្តច្បាប់នេះក្នុងសម័យបារាំង ក្នុងការធ្វើសន្ធិសញ្ញាផ្សេងៗ និងក្នុងការកំណត់បង្ហាញឲ្យឃើញថា ជនជាតិចិន គឺជាជនជាតិដើមម្ចាស់ស្រុក និងក្នុងពេលជាមួយគ្នានេះដែរ ក៏ជាជនជាតិដែលទទួលបាននូវក្តីអនុគ្រោះបំផុតដែរ ។*

*រហូតមកដល់ចុងឆ្នាំ ១៨៩១ ទើបបារាំងបែរការចាប់អារម្មណ៍របស់ខ្លួន ទៅលើការកំណត់និយមន័យស្របច្បាប់ ចំពោះសហគមន៍ជនជាតិចិននៅក្នុងប្រទេសកម្ពុជា ។ ព្រះរាជប្រកាសចុះកាលបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៨៩១ ដែលស្ទើរតែជាការចម្លងទាំងស្រុងចេញពីច្បាប់នៅតំបន់តុងកឹង ដែលបានអនុម័តកាលពីឆ្នាំកន្លងទៅ បានបង្ហាញឲ្យឃើញថា រាល់អនិកជនជាតិអាស៊ីទាំងអស់ លើកលែងតែ សៀម លាវ និងអណ្ណាមចេញ ត្រូវស្ថិតនៅក្រោមប្រព័ន្ធសហគមន៍ជាតិពន្ធុ ។ ការបែងចែកនេះរួមបញ្ចូលនូវជនជាតិចិន (ដែលមានច្រើនប្រភេទ) និង ជនជាតិតណ្ឌាស្ទើរគ្មានសល់ ។*

*ប្រព័ន្ធសហគមន៍ជាតិពន្ធុ បានផ្តល់នូវប្រសិទ្ធភាពខ្ពស់ជាងការគ្រប់គ្រងដោយប្រើច្បាប់ ទៅលើជនជាតិចិន ។ ជនអន្តោប្រវេសចិន មិនអាចចូលក្នុងប្រទេសកម្ពុជាបានទេ លុះត្រាណាមានការជ្រើសឲ្យចូលដោយប្រធានក្រុម ទៅក្នុងក្រុមសហគមន៍ជាតិពន្ធុណាមួយយ៉ាងសមរម្យ តាមប្រភេទជាតិពន្ធុរបស់គេជាមុនសិន ។ គ្មានជនជាតិចិនណាមួយ អាចធ្វើដំណើរពីខេត្តមួយទៅខេត្តមួយទៀត ដោយគ្មានលិខិតអនុញ្ញាតពីមេក្រុមដែលពាក់ព័ន្ធ*

ហើយក៏គ្មានជនជាតិចិនណាម្នាក់ អាចចាកចេញពីប្រទេសកម្ពុជា ដោយគ្មានលិខិតបញ្ជាក់ពីប្រធានក្រុម ដែលបញ្ជាក់ថា គេបានបំពេញបែបបទត្រឹមត្រូវ តាមច្បាប់រួចរាល់ហើយទៅលើកាតព្វកិច្ចបង់ពន្ធ ។ ប្រធានក្រុមនីមួយៗ មានភារៈទទួលខុសត្រូវលើការប្រមូលពន្ធពីកូនក្រុមរបស់ពួកគេ ហើយក៏មានភារៈរៀបចំតាមបញ្ជា(ជួយសម្រួល) ក្នុងចំនោមពួកគេ ប្រសិនបើមានការកោះហៅពីចៅក្រមរឺការកែនទាហាន ប្រធានក្រុមទាំងនោះក៏មានសិទ្ធិអំណាចស្របច្បាប់ ក្នុងការនិរទេសសមាជិកក្រុមរបស់គេណាម្នាក់ចេញបានដែរ ។ ប្រជាជនចិនគ្រប់រូបត្រូវតែកាន់កាតសម្គាល់ខ្លួនដែលបង្ហាញថា គេស្ថិតនៅក្នុងក្រុមណាមួយ នៃប្រព័ន្ធសហគមន៍ជាតិពន្ធុនោះ ។

យោងតាមសេចក្តីប្រកាសថ្ងៃទី ៦ ខែ ឧសភា ឆ្នាំ ១៨៩៨ រាល់ច្បាប់ដែលជាប់ទាក់ទងទៅនឹងជនជាតិចិននៅក្នុងតំបន់ឥណ្ឌូចិនទាំងអស់ នឹងក្លាយទៅជាច្បាប់ដែលអាចប្រើការបានជាទូទៅ រួមទាំងនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ដូច្នេះ ជនជាតិចិនទាំងនោះត្រូវដាក់ឲ្យស្ថិតនៅក្រោមច្បាប់ពាណិជ្ជកម្ម ដែលគេប្រើនៅស្រុកបារាំង និងនៅក្រោមច្បាប់ពាណិជ្ជកម្មឆ្នាំ ១៨៨០ របស់អណ្ណាម ។ លោករ៉េស៊ីដង់ ស៊ុបពែរីយែរ នៅទីក្រុងភ្នំពេញទទួលបានសិទ្ធិដូចគ្នាទៅនឹងកូឈួយ នៅតំបន់ឥណ្ឌូចិន ក្នុងការចាប់ឃុំឃាំង និងដកហូតទ្រព្យសម្បត្តិពីជនជាតិចិនទាំងនោះ ។

នៅក្នុងឆ្នាំ ១៩០៤ ស្តេចនរោត្តមបានប្រកាសបោះបង់សិទ្ធិគ្រប់គ្រងទឹកដីទាំងអស់ នៃព្រះរាជាណាចក្រ ហើយផ្ទេរសិទ្ធិគ្រប់គ្រងលើអចលនវត្ថុទៅដល់បារាំង នឹងស្ថិតនៅក្រោមច្បាប់របស់បារាំង ។ ច្បាប់នេះ ក៏បានអនុញ្ញាតឲ្យជនជាតិចិនមានសិទ្ធិទិញដី ដែលសិទ្ធិនេះមានការគាំទ្រពីសំណាកស្តេច ស៊ីសុវត្ថិ នៅក្នុងព្រះរាជប្រកាសរបស់ទ្រង់ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ១៩១៩ ។ ពីរឆ្នាំក្រោយមក នៅក្នុងសំបុត្រមួយផ្ញើទៅកាន់ទេសាភិបាលនៃតំបន់ឥណ្ឌូចិន លោករ៉េស៊ីដង់ស៊ុបពែរីយែរ បានបង្ហាញពីក្តីបារម្ភរបស់លោក ទៅលើការកើនឡើងនូវចំនួនជនជាតិចិន ដែលគ្រប់គ្រងលើអចលនវត្ថុនៅតាមតំបន់ទីក្រុង ឬទីប្រជុំជននានា ។ លោករ៉េស៊ីដង់ស៊ុបពែរីយែរ បានស្នើថា រដ្ឋាភិបាលបារាំងគួរតែធ្វើតាមនយោបាយរបស់ហុល្លង់នៅកោះជ្វា ក្នុងការទប់ស្កាត់ការលក់អចលនវត្ថុនៅតំបន់ទីក្រុង ឬទីប្រជុំជននានាឲ្យទៅប្រជាជនចិន ។ បន្ទាប់ពីបានទទួលយោបល់នេះមក លោកទេសាភិបាលបានធ្វើសេចក្តីប្រកាសមួយនៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩២៤ ថា មានតែប្រជារាស្ត្របារាំង ប្រជារាស្ត្រនៃប្រទេសដែលស្ថិតក្រោមអាណាព្យាបាលបារាំង និងអ្នកដែលនៅក្រោមការគាំពាររបស់បារាំង [១៥] ទេ ដែលមានសិទ្ធិអាចទទួលកាន់កាប់ដីធ្លីជាអចិន្ត្រៃយ៍បាន ហើយមិនអាចលក់ទៅឲ្យជនបរទេសបានឡើយ លើកលែងតែមានការអនុញ្ញាតពីរដ្ឋាភិបាល (នីកូឡា ទំ.១១៥) ។ (ច្បាប់នេះត្រូវប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩២៤) ។ ក្នុងនិក្ខេបបទថ្នាក់បណ្ឌិតមួយ របស់លោកនីកូឡា ឆ្នាំ ១៩៣៤ នៅសាកលវិទ្យាល័យប៉ារីស បានលើកឡើងថា ច្បាប់នេះបានប្រកាសឡើងដោយរំលោភច្បាប់នៅក្នុងប្រទេសកម្ពុជា ព្រោះគ្មានការអនុញ្ញាតពីព្រះរាជាខ្មែរ ហើយមានបំណងផ្តោតទៅលើជនជាតិចិនជាពិសេស ក្នុងការព្យាយាមផ្លាស់ប្តូរស្ថានភាពដើម ក្នុងសង្គមរបស់ពួកគេ ពីជនជាតិតែមួយដូចគ្នានឹងជនជាតិខ្មែរឲ្យទៅជាជនបរទេសវិញ (នីកូឡា ទំ. ១១៥ និង ទំ.១៤២) ។ នៅក្នុងព្រះរាជប្រកាសថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩២៩ ស្តេច មុនីវង្ស បានចេញព្រះរាជប្រកាសមួយ ដោយបង្ហាញពីក្តីបារម្ភរបស់ទ្រង់ ចំពោះការកាន់កាប់អចលនវត្ថុរបស់ជនជាតិចិននៅតាមជនបទៗ ទ្រង់មានព្រះរាជឱង្ការថា មានតែប្រជារាស្ត្រខ្មែរ ប្រជារាស្ត្របារាំង ប្រជារាស្ត្រខ្មែរ ដែលទទួលស្គាល់ដោយច្បាប់[១៦] និងអ្នកដែលបារាំងគាំពារ ឬក្រុមហ៊ុនទាំងឡាយណា ដែលភាគច្រើនបំផុតនៃភាគហ៊ុនរបស់ក្រុមហ៊ុន ជារបស់មនុស្សប្រភេទ ណាមួយក្នុងចំណោមមនុស្សទាំង ៤ ប្រភេទខាងលើនេះទេ ដែលមានសិទ្ធិអាចកាន់កាប់គ្រប់គ្រងលើដីធ្លីនៅតាមជនបទបាន(ដេ អូ ស៊ី ១៩២៩ ទំ.៣២–

៤៧) ។ ជាការពិត ទ្រង់បានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ នូវច្បាប់មួយដែលបានប្រកាសឡើងដោយប្រធានាធិបតីបារាំង នៅថ្ងៃទី ២៨ ខែមីនា ឆ្នាំ ១៩២៩ (ដេ អូ ស៊ី ១៩២៩, ទំ.១៣-៦៩) ។ ការអនុវត្តច្បាប់ទាំងនេះទៅលើជនជាតិចិន គឺផ្ទុយគ្នាទៅនឹងអនុសញ្ញាបារាំង-ចិននៅឆ្នាំ ១៨៨៦ ក៏ប៉ុន្តែរដ្ឋអំនាចអាណានិគមបានបញ្ចៀសបញ្ហាច្បាប់នេះ ដោយសំអាងទៅលើភាពខុសប្លែកគ្នារវាងពាក្យកាន់កាប់ (អនុសញ្ញាបានធានាចំពោះជនជាតិចិនថាសិទ្ធិកាន់កាប់ដីធ្លី) និងភាពជាម្ចាស់កម្មសិទ្ធ[១៧]។

ការហាមឃាត់ជនជាតិចិនមិនឲ្យកាន់កាប់ដីធ្លីបែបនេះ មានន័យថា អាជីពសព្វថ្ងៃរបស់ពួកគេ ក៏ត្រូវបានគេកម្រិតដែរ ផ្ទុយពីជនជាតិចិននៅប្រទេសម៉ាឡេស៊ី ជនជាតិចិននៅក្នុងប្រទេសកម្ពុជា មិនអាចគ្រប់គ្រងទៅលើធនធានរ៉ែ និងចម្ការកៅស៊ូឡើយ ។ មុខរបរទាំងពីរនេះ បានក្លាយទៅជាកម្មសិទ្ធផ្តាច់មុខរបស់បារាំង (រ៉ូប៊ីគ្វីន ទំ. ៣៦, ពួរសេល ១៩៥១, ទំ.២៣៣) ក៏ប៉ុន្តែក្រៅពីមុខរបរនេះជនជាតិចិនអាចចាប់យកមុខរបរដទៃទៀត ក្នុងប្រទេសកម្ពុជាបានដោយសេរី ។ ផ្ទុយពីជនបរទេសដទៃទៀតនោះជនជាតិចិនអាចអនុញ្ញាតឲ្យបោះពុម្ពកាសែត បង្កើតគ្រឹះស្ថានបោះពុម្ព សណ្ឋាគារ និងវង្គសាលផ្សេងៗ ជាពិសេសនោះ ជនជាតិចិន គឺជាជនបរទេសតែមួយគត់ ដែលបានអនុញ្ញាតឲ្យទទួលដេញថ្លៃ ទៅលើកិច្ចសន្យាផ្គត់ផ្គង់ដល់ផ្នែករដ្ឋបាលបារាំង ដូចជាការងារសាធារណៈ និងការផ្គត់ផ្គង់ដល់កងទ័ព និងអគ្គភាពសគ្គមស៊ីវិលនានា (ឡេវ៉ាស៊ឺ ទំ.១២២) ។ រឿងនេះក្រោយមកបានបង្កឲ្យមានជម្លោះជាច្រើន រវាងផលប្រយោជន៍ផ្នែកពាណិជ្ជកម្មរបស់បារាំង និងរដ្ឋបាលអាណានិគមបារាំងនៅក្នុងតំបន់ឥណ្ឌូចិន[១៨] ។

អនុសញ្ញាថ្មីមួយរវាងប្រទេសបារាំង និង សាធារណៈរដ្ឋចិន ដែលអនុសញ្ញាមានឥទ្ធិពលទៅលើជនជាតិចិននៅក្នុងប្រទេសកម្ពុជា ត្រូវបានចុះហត្ថលេខានៅក្នុងឆ្នាំ ១៩៣០ ។ ឆ្លងតាមរយៈបដិវត្តចិនឆ្នាំ ១៩១២ មក បារាំងព្យាយាមយ៉ាងខ្លាំង ក្នុងការចង់រក្សាឲ្យបាននូវកន្លែងរបស់ខ្លួន ដែលជាជាតិសាសន៍មួយដ៏ពេញនិយមបំផុត ហើយខ្លួនមានការព្រួយបារម្ភពីការចេះតែកើនឡើង នៃអំណាចរបស់អង់គ្លេសនៅក្នុងតំបន់គង់តុង ។ (ដោយមើលឃើញពីយុទ្ធនាការរបស់រដ្ឋាភិបាលគួងមីងតាងក្នុងឆ្នាំ១៩២៥-២៧) នៅភាគខាងជើងប្រទេសចិន បារាំងបានជឿទុកចិត្តថា រដ្ឋាភិបាលនេះអាចកាន់អំណាចយូរអង្វែងៗ រដ្ឋាភិបាលបារាំងបានព្រមបន្តធ្វើកិច្ចពិភាក្សាជាមួយនឹងរដ្ឋាភិបាលថ្មីនេះ គេបានយកចិត្ត និងជំរុញឲ្យបារាំងជួយគាំទ្រ តាមរយៈការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងពាណិជ្ជកម្ម ចិន-អាមេរិក ក្នុងឆ្នាំ ១៩៣៨ និង តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មក្រោយៗមកទៀតជាច្រើន ។ នៅក្នុងឆ្នាំដដែលនេះ ក៏មានការចុះហត្ថលេខាទៅលើសន្ធិសញ្ញាពាណិជ្ជកម្ម បារាំង-ចិនដែរ ។ នៅពេលជាមួយគ្នានោះ បារាំងក៏បានស្នើឲ្យមានការកែប្រែ នូវសន្ធិសញ្ញាចាស់ៗឡើងវិញ ដែលសំណើទាំងនោះត្រូវបានរដ្ឋាភិបាលចិនបដិសេធចោលនៅក្នុងឆ្នាំ ១៩២៨ ដោយសារមិនស្មើភាពគ្នា ។ កិច្ចពិភាក្សានេះ បានបន្តអស់រយៈពេលជាងមួយឆ្នាំ ដោយសារតែការអាក់ខានរបស់ភាគីចិនជាច្រើនដង ហើយនៅទីបញ្ចប់ ក៏ឈានដល់ការចុះកិច្ចព្រមព្រៀងលើសន្ធិសញ្ញា ណានគីង នៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ១៩៣០[១៩]។

តាមរយៈសន្ធិសញ្ញានេះ ជាថ្មីម្តងទៀត បារាំងបានយល់ព្រមឲ្យចិនដាក់ស្ថានកុងស៊ុលរបស់ខ្លួននៅទីក្រុងព្រៃនគរ (សៃហ្គន) និងក្រុង ហាណូយ ប៉ុសៃហ្គុង ហើយបានផ្តល់ឲ្យជនជាតិចិននៅក្នុងតំបន់ឥណ្ឌូចិន នូវសិទ្ធិនៃជាតិសាសន៍ ដែលទទួលបាននូវក្តីអនុគ្រោះបំផុតមួយ ។ ដោយយោងទៅលើរឿងនេះ គេបានសន្និដ្ឋានជាបណ្តោះអាសន្នថា ប្រព័ន្ធសហគមន៍ជាតិពន្ធុគឺលែងមានទៀតហើយ ហើយពេលខ្លះ គេបានចាត់ទុកជនជាតិចិនដូចជាជន

*ជាតិជប៉ុន ជាជនជាតិអាស៊ីដែលមានមុខមាត់ក្នុងសង្គមដូចជាពួកអឺរ៉ុប[២០] ។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរសារលិខិត ដែលប្រព្រឹត្តទៅក្នុងថ្ងៃតែមួយ ជាមួយនឹងថ្ងៃចុះហត្ថលេខានោះ បានផ្តល់ឲ្យមានការធានាមួយថា នឹងគ្មានការផ្លាស់ប្តូរណាមួយដល់ស្ថានភាពដើម ក្នុងសង្គមដែលមានមកស្រាប់របស់ជនជាតិនោះឡើយ ។ នៅក្នុងលិខិតរបស់បារាំងបាននិយាយថា (ឡេវ៉ាសឺ ៨៩)÷*

> ខ្ញុំមានកិត្តិយសនឹងបញ្ជាក់ជូនលោកថា រដ្ឋាភិបាលបារាំងរបស់យើងខ្ញុំ គ្មានបំណងនឹងដកហូតនូវបុព្វសិទ្ធិពិសេសពីជនអន្តោប្រវេសចិន ខណៈដែលពួកគេកំពុងតែមានស្រាប់ នាពេលបច្ចុប្បន្នក្នុងទឹកដីឥណ្ឌូចិននេះឡើយ [២១] ។
> (បកប្រែជាភាសាខ្មែរដោយ ថាច់ ដេត)

*ជាការពិតណាស់ដែលថា មានការព្រមព្រៀងគ្នាជាសម្ងាត់រវាងភាគីទាំងសង្ខាងទៅលើការបន្ថែមការបង់ពន្ធរបស់ជនជាតិចិន ដោយអាស្រ័យទៅលើបញ្ញត្តសិទ្ធិ ដែលពួកគេទទួលបាននោះ(ឡេវ៉ាសឺ ៩១)។*

*ពិតមែនថា កិច្ចព្រមព្រៀងអន្តរជាតិមួយនេះបានបង្ហាញយ៉ាងច្បាស់ពីសិទ្ធិ នៃជាតិសាសន៍មួយដែលទទួលបាននូវក្តីអនុគ្រោះបំផុតនៅក្នុងប្រទេសកម្ពុជា (និងនៅក្នុងតំបន់ឥណ្ឌូចិនទាំងមូល) ក៏ដោយ ក៏បារាំងនៅតែតម្រូវឲ្យជនជាតិចិនទទួលភារកិច្ចពិសេសមួយ នៃការបង់ពន្ធច្រើនជាងជនបរទេសដទៃទៀត និង ដាក់ជនជាតិចិនទាំងអស់ ឲ្យនៅក្រោមប្រព័ន្ធសហគមន៍ជាតិពន្ធុដដែល ។ ក្នុងរូបភាពបែបនេះគឺបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា គ្មានភាគីណាមួយចាប់អារម្មណ៍ចង់ធ្វើការផ្លាស់ប្តូរ ទៅលើភារកិច្ចរបស់ប្រជាពលរដ្ឋនោះឡើយ ។ រូបភាពបែបនេះបានផ្តល់នូវលក្ខណៈងាយស្រួលដល់ពាណិជ្ជករចិនដែលមានឥទ្ធិពល ក៏ដូចជាពាណិជ្ជករបារាំងដែរ ។ ម្យ៉ាងវិញទៀត រដ្ឋាភិបាល គួងមីងតាង ចាប់អារម្មណ៍ជាសំខាន់តែទៅលើបញ្ហាមោទនភាពជាតិ ជាជាងការធ្វើកំណែទម្រង់ (អាសមបួជ ទំ.៨៧) អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ គឺថា ការធ្វើសម្បទានរបស់បារាំង មានចែងនៅក្នុងឯកសារផ្លូវការនៃសន្ធិសញ្ញា ចំណែកឯការធ្វើសម្បទានរបស់ចិនវិញ មានតែនៅក្នុងកំណត់ចំណាំបន្ថែមហើយចំណុចជាច្រើនមិនបានចុះផ្សាយក្នុងពេលនោះឡើយ ។ លើសពីនេះទៅទៀតនោះ រដ្ឋាភិបាលចិនប្រហែលជាមើលឃើញថា ប្រព័ន្ធសហគមន៍ជាពន្ធុជាមធ្យោបាយដ៏ល្អមួយ ក្នុងការគ្រប់គ្រងទៅលើជនជាតិចិននៅក្រៅប្រទេស[២២]។*

*សូម្បីតែនៅមុនពេលមានការចុះហត្ថលេខាលើសន្ធិសញ្ញា ក៏លោករ៉េស៊ីដង់ស៊ុបពែរីយេប្រចាំនៅទីក្រុងភ្នំពេញ បានប្រកាសរួចទៅហើយនៅថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩២៩ ថា ពន្ធដែលបង់ដោយពួកអនិកជនជាតិអាស៊ី-ទាំងអស់ សម្រាប់ពាក្យដែលហៅថាពន្ធរាប់តាមចំនួនក្បាលរបស់មនុស្ស ឬការបង់លើការចុះបញ្ជី ចាប់ពីពេលនេះតទៅ ត្រូវហៅថាពន្ធសម្រាប់បុគ្គលម្នាក់ៗ នៃអនិកជនជាតិអាស៊ីវិញ ។ ចំណែកពាក្យដែលប្រើក្នុងច្បាប់ថា ការបង់ទៅលើផលដែលសម្រេចបាន ចាប់ពីពេលនេះតទៅ ត្រូវជំនួសដោយពាក្យថា ពន្ធលើផលចំណេញរបស់ពាណិជ្ជករដែលទទួលបានពីការផ្តល់សិទ្ធិពិសេសក្នុងសង្គម ។ ធាតុពិតទៅ ពាក្យថាពន្ធលើផលចំណេញរបស់ពាណិជ្ជករ ដែលទទួលបានពីការផ្តល់សិទ្ធិពិសេសក្នុងសង្គម ក្លាយជាគំរូផ្លូវការមួយ ដែលបានដាក់ទៅលើជនជាតិចិនខណៈពេលដែលជនបរទេសដទៃផ្សេងទៀត (ដូចជាជនជាតិឥណ្ឌា) នៅតែបន្តចាត់ទុកថា ជាអនិកជនជាតិអាស៊ីដដែលនោះ ។ ការផ្លាស់ប្តូរបែបនេះ ធ្វើឡើងតាមការទាមទារពីសំណាក់ជនជាតិចិន ឲ្យប្តូរទៅលើពាក្យទាំងឡាយណា ដែលខាងផ្នែករដ្ឋបាលបានប្រើ ហើយដែលជនជាតិចិនយល់ថា ជាពាក្យប្រមាថមើលងាយដក់ពួកគេនោះ ។*

ប៉ុន្តែ បើទោះបីជាពាក្យទាំងនោះបានផ្លាស់ប្តូរ ហើយយ៉ាងណាក៏ដោយ ក៏យើងនៅតែឃើញថា ជាការពិតទៅស្ថានភាពរបស់ប្រជាជនចិននៅតែដូចពីមុនដដែល គ្មានការផ្លាស់ប្តូរឡើយ ។ មានរដ្ឋអំណាចម្នាក់បាននិយាយថា ការសិក្សាទៅលើព្រឹត្តិបត្រផ្លូវការនៅក្នុងតំបន់ឥណ្ឌូចិន មួយដែលមានរយៈពេល ៦ឆ្នាំ បានបង្ហាញថា តាមរយៈសន្ធិសញ្ញា យើងមិនឃើញមានភាពខុសប្លែកគ្នា នៃស្ថានភាពរបស់ជនជាតិចិន នៅមុនពេលចុះហត្ថលេខានោះទេ (វិហ្ស៊ឺ ទំ.១៨៦) ។ តាមពិតទៅការប្រៀបធៀបទៅលើច្បាប់អន្តោប្រវេសន៍ពីរផ្សេងគ្នា ដែលបានប្រកាសឲ្យប្រើជាផ្លូវការនៅក្នុងឆ្នាំ ១៩៣៥-៦ ដើម្បីបែងចែកឲ្យដាច់រវាងជនជាតិចិន និងអនិកជនជាតិអស៊ី បានបង្ហាញឲ្យឃើញពីភាពខុសគ្នាដ៏ធំតែមួយគត់ គឺប្រព័ន្ធសហគមន៍ជាតិពន្ធុរបស់ចិន បានផ្តល់នូវលក្ខណៈស្របច្បាប់សម្រាប់បុគ្គលម្នាក់ៗ ជាលើដំបូង (ហ្ស៊ឺ អូ អ៊ី អេហ្វ ១៩៣៥ ទំ.៤០៩២-៩, ១៩៣៦ ទំ.៥០៣-៨)។

កិច្ចពិភាក្សាខាងលើ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា តារយៈសម័យដែលបារាំងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពក្នុងប្រទេសកម្ពុជា ពីឆ្នាំ១៨៨៤ ដល់ ១៩៥៣ ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិន ដែលជាប្រជាជនម្ចាស់ស្រុកក្នុងប្រទេស មានភាពស្រពេចស្រពិលមិនច្បាស់លាស់ ដោយផ្អែកទៅលើកន្លែងខ្លះនៅរវាងអនិកជនជាតិអឺរ៉ុប (ដោយរួមទាំងជនជាតិជប៉ុន) ផង និងប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រទេសកម្ពុជាខ្លួនឯងផង ។ ដោយមានគំនិតផ្ទុយស្រឡះពីស្តេចខ្មែរនោះ នយោបាយរបស់បារាំងបានប្តូរជាដាច់ខាត ទៅរកទិសដៅក្នុងការកំណត់ជនជាតិចិនជាជនបរទេស ជាដាច់កំណត់ថា ជាប្រជាជានដែលស្ថិតក្រោមការគ្រប់គ្រង ប៉ុន្តែមិនដែលដាក់ពួកគេទៅក្នុងស្ថានភាពមួយ ដូចគ្នានឹងក្រុមជនបរទេសដទៃទៀតនៅក្នុងប្រទេសឡើយ ។ ប្រព័ន្ធសហគមន៍ជាតិពន្ធុបានផ្តល់នូវមូលដ្ឋាននៃសញ្ញាណមួយចំពោះស្ថានភាពក្នុងសង្គម ដែលស្រពេចស្រពិល ។

ស្ថានភាពរបស់កូនចៅជំនាន់ក្រោយៗ ដែលរៀបការចម្រុះគ្នារវាងចិន និងខ្មែរ គឺកាន់តែមានភាពមិនច្បាស់លាស់ទៅទៀត បើយោងទៅលើគោលការណ៍ផ្សេងៗ ពីគ្នាស្តីអំពីការផ្តល់សញ្ជាតិ រវាងអាជ្ញាធរបារាំង និងអាជ្ញាធរចិននោះៗ ប្រទេសចិនតែងប្រើគោលការណ៍ផ្តល់សញ្ជាតិ តាមរយៈឈាមជ័រ ដែលមានន័យថាគ្រប់កូនចៅជំនាន់ក្រោយរបស់ចិនទាំងអស់ នៅតែជាជនជាតិចិនដដែល មិនថាគេកើតនៅទីណាក៏ដោយ (ឡេវ៉ាស៊ឺ ឡូ ទំ.៦៩, តេរ៉េ ទំ.៦០ និងសូមមើល ហ្វ្រេដមេន ១៩៥៥ ទំ.៤០៨) ។ គេបានដាក់គោលការណ៍នេះចូលទៅក្នុងច្បាប់ ដែលបានប្រកាសឲ្យប្រើជាផ្លូវការដោយរដ្ឋាភិបាល មាន់ជូ ក្នុងប្រទេសចិននៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩០៩ មានន័យសេចក្តីថា «អាចទាមទារយកសញ្ជាតិចិនបាន ចំពោះកូនចៅចិននៅក្នុង និងក្រៅប្រទេសទាំងឡាយណា ដែលមានឪពុកឬម្តាយជាជនជាតិចិន ដោយមិនគិតពីទីកន្លែងកំណើតរបស់គេឡើយ (វីល្មៀម វីលម៉ូត១៩៦១ ទំ. ១៤)។

មុនពេលដែលបារាំងត្រួតត្រាលើតំបន់អណ្ណាម ជនជាតិចិនកាត់អណ្ណាម ដែលស្គាល់ជាផ្លូវការថា មិញហ័ង (Minh Huong) ត្រូវបានគេបែងចែកឲ្យដាច់ចេញពីជនជាតិចិន និងជនម្ចាស់ស្រុក ។ ផ្ទុយទៅវិញ យើងឃើញថានៅសម័យមុនបារាំងត្រួតត្រា ប្រទេសកម្ពុជាបានកំណត់ថា អ្នកទាំងឡាយណាដែលកើតនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបានសញ្ជាតិកម្ពុជា ដោយមិនគិតថា គេជាកូនកាត់ ឬជាជនជាតិចិនឡើយ ។ ក៏ប៉ុន្តែនៅក្នុងសម័យបារាំង បារាំងបានធ្វើការកំណត់ដ៏តឹងរឹងមួយ(២៣) ទៅវិញ ។ នៅក្នុងឆ្នាំ ១៩០១ ស្តេចនរោត្តម បានប្រកាសថា គ្រប់ជនជាតិចិនទាំងឡាយណា ដែលមានឪពុក ឬម្តាយជាជនជាតិចិននោះ ពួកគេអាចនឹង ចុះឈ្មោះចូលក្នុងបញ្ជីបង់ពន្ធសម្រាប់សុំសញ្ជាតិកម្ពុជាបាន តែតម្រូវឲ្យពួកគេបោះបង់ចោលនូវសម្លៀកបំពាក់ និងម៉ូតសក់ចិនចេញ (តេរ៉េ ទំ.៦៦) ប៉ុន្តែច្បាប់របស់បារាំង មានទិសដៅផ្ទុយគ្នាស្រឡះពីនេះ ។ នៅក្នុងកំណែទម្រង់ពន្ធដារ

ឆ្នាំ ១៨៨៤ បានកំណត់ថា កុមារដែលមានឪពុកជាជនជាតិកម្ពុជា ត្រូវចាត់ទុកថាជាជនជាតិកម្ពុជា ប៉ុន្តែមិនបានបញ្ជាក់ពីកុមារដែលមានម្តាយជាជនជាតិកម្ពុជានោះទេ ។ ដោយហេតុនេះហើយ ទើបធ្វើឲ្យមានការសន្និដ្ឋានដោយស្វ័យប្រវត្តិមួយថា កុមារដែលមានឪពុកជាជនជាតិចិន គឺត្រូវបានបារាំងកំណត់ថា ជាជនជាតិចិនដោយស្វ័យប្រវត្តិតែម្តង (តេរ៉េ ទំ.៦៦) ។ បន្ទាប់មក ទើបមានការបញ្ជាក់យ៉ាងច្បាស់ នៅក្នុងច្បាប់រដ្ឋប្បវេណីរបស់កម្ពុជា ដែលបានប្រកាសជាផ្លូវការនៅក្នុងឆ្នាំ ១៩២០ ថា រាល់កូនកាត់ខ្មែរ-ចិនទាំងអស់ គឺជាជនជាតិចិន លើកលែងតែគេមានឈាមជ័រពីរភាគបីជាជនជាតិខ្មែរ ដែលពួកគេអាចទទួលយកសញ្ជាតិកម្ពុជាបាននៅចន្លោះអាយុពី ២១ ទៅ ២៦ ឆ្នាំ (ឡេវ៉ាស៊ឺ ទំ.៦៧) ។ នៅពេលដែលមានវិសោធនកម្មទៅលើច្បាប់នេះក្នុងឆ្នាំ ១៩៣៤ គេបានលុបចោលនូវសិទ្ធិក្នុងការទទួលយកសញ្ជាតិនេះ ហើយច្បាប់សញ្ជាតិកម្មរបស់កម្ពុជា បានប្រែទៅជាផ្តោតលើសញ្ជាតិកម្មបារាំងវិញដោយបាននិយាយថា ប្រសិនបើមនុស្សទាំងឡាយណា ដែលមានឪពុក ឬម្តាយមានសញ្ជាតិកម្ពុជា ហើយឪពុក ឬម្តាយ ម្ខាងទៀតជាជនជាតិបារាំង នោះជននោះត្រូវក្លាយទៅជាជនជាតិបារាំងដោយស្វ័យប្រវត្តិ (ដេ អូ ស៊ុ ១៩៣៤ ទំ.៣០៩) ។ ទាំងលោក ឡេវ៉ាស៊ឺ និងលោក តេរ៉េ យល់ឃើញថា ប្រព័ន្ធសហគមន៍ជាតិពន្ធុ ធ្វើឲ្យមានការលំបាកយ៉ាងខ្លាំង សម្រាប់កុមារដែលមានឪពុកជាជនជាតិចិន ក្នុងការទទួលបាននូវសញ្ជាតិកម្ពុជា ហើយជាការពិតណាស់ថា ជាទូទៅគេតែងចាត់ទុកកុមារទាំងនេះ ថាជាជនជាតិចិន (ឡេវ៉ាស៊ឺ ទំ.៦៦ និង ៦៩ តេរ៉េ ទំ.៧៦) ។ លើសពីនេះទៅទៀត ប្រព័ន្ធសហគមន៍ជាតិពន្ធុ ក៏ធ្វើឲ្យមានការរាំងស្ទះ ក្នុងការផ្តល់សញ្ជាតិកម្ពុជាដល់ជនជាតិចិន ដែលបានកើតនៅលើទឹកដីកម្ពុជា បើទោះបីជាជីដូនជីតារបស់ពួកគេជាច្រើនជំនាន់ បានកើតនៅក្នុងប្រទេសកម្ពុជាយ៉ាងណាក៏ដោយ [២៤]។

គេមិនបានលើយកបញ្ហាស្តីពីសញ្ជាតិកម្មកម្ពុជា មកពិភាក្សានៅក្នុងច្បាប់រហូតដល់ឆ្នាំ ១៩៤០។[២៥] នៅមុននេះការបាត់ខ្លួនដោយខុសច្បាប់របស់ជនជាតិចិន នៅក្នុងសង្គមកម្ពុជាជារឿងសមញ្ញមួយ ដែលតែងតែកើតឡើងជារឿយៗ ។ គ្រាន់តែនៅក្នុងឆ្នាំ ១៩៣៥ មានជនជាតិចិន ២.០០០ នាក់បានបាត់ខ្លួនចេញពីប្រព័ន្ធសហគមន៍ជាតិពន្ធុនៅក្នុងប្រទេសកម្ពុជា (ឡេវ៉ាស៊ឺ ទំ.១០៩) ។ នៅថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៤០ ស្តេច មុនីវង្ស បានប្រកាសជាផ្លូវការពីនិតិវិធីផ្តល់សញ្ជាតិកម្ពុជា ដែលតម្រូវឲ្យមានព្រះរាជក្រឹត្យទទួលស្គាល់សម្រាប់ករណីនីមួយៗ ។ និតិវិធីនេះតម្រូវឲ្យបេក្ខជនម្នាក់ៗ មានជាស្រេចនូវសំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍ និងលិខិតថ្កោលទោសចេញពីតុលាការ តែមិនបាននិយាយពីបុគ្គលិកលក្ខណៈភាពរបស់ឪពុកម្តាយ ឬសូម្បីតែការស៊ាំទៅនឹងភាសា និងប្រពៃណីវប្បធម៌របស់កម្ពុជានោះទេ (ប៊ី អេ ស៊ី ១៩៤០ ទំ. ១៥៣៣-៥)។

បញ្ហាទាក់ទងទៅនឹងការកាត់ក្តី ដែលមានតុលាការច្រើនប្រភេទចំពោះជនជាតិចិន នៅតែជាចម្ងល់នៅឡើយ ។ ជាយូរយារណាស់មកហើយ មុនពេលដែលបារាំងគ្រប់គ្រងអាណាចក្រខ្មែរ បានប្រកាន់ខ្ជាប់នូវអ្វីដែលអាចនិយាយបានថា ជាប្រព័ន្ធច្បាប់ដែលមានការចម្រើនលូតលាស់ និងយុត្តិធម៌មួយ (ប្លូឪណ្ឌ ទំ. ៩៨៤)ដែលបានដាក់ទៅលើជនជាតិចិន ក៏ដូចជាជនបរទេសដទៃផ្សេងទៀត ដែលរស់នៅលើទឹកដីខ្មែរ (នីកូឡា ទំ. ៨៨) ។ ក៏ប៉ុន្តែ បារាំងបានដើរតាមនយោបាយ នៃការផ្ដុំតាមតែអាចធ្វើទៅបាន នូវចំនួនដ៏ច្រើនលើសលប់ ឲ្យនៅក្រោមច្បាប់ និងយុត្តាធិការរបស់បារាំង (ហបហ្វូល ទំ. ៤៣) ដោយបង្កើតឲ្យមានតុលាការបារាំងមួយនៅទីក្រុងភ្នំពេញ ដែលអាចកាត់ក្តីលើគ្រប់រឿងក្តី ដែលកើតមានឡើងទាំងអស់ មិនថារឿងនោះកើតឡើងចំពោះប្រជារាស្ត្របារាំង ឬប្រជារាស្ត្រដែលស្ថិតនៅក្រោមការអាណាព្យាបាលបារាំង ឬបញ្ហានៃកិច្ចសន្យា ដែលស្ថិតនៅក្រោមយុត្តាធិការ

*របស់បារាំង (មីសែល ទំ.៥) ។ តាមរយៈព្រះរាជប្រកាសឆ្នាំ ១៨៩១ បានចែងថា រាល់អនិកជនជាតិអាស៊ីទាំងអស់នៅតែដោះស្រាយរឿងក្តីក្រោមតុលាការកម្ពុជាដដែល ដូច្នេះ ជនជាតិចិនក៏ស្ថិតនៅក្រោមការកាត់ក្តីពីតុលាការកម្ពុជាដែរ ដែលយ៉ាងហោចណាស់ក៏រូបភាពបែបនេះ នៅមានរហូតដល់ពេលដែលមានសន្ធិសញ្ញា ណានគីង ក្នុងឆ្នាំ ១៩៣០ ។ អត្ថន័យនៅក្នុងសន្ធិសញ្ញានេះ ពិតជាបានបង្ហាញពីការច្រានចោល លែងឲ្យមានតទៅទៀត នូវការដាក់ជនជាតិចិនឲ្យនៅក្រោមតុលាការសម្រាប់ជនម្ចាស់ស្រុក ហើយរដ្ឋាភិបាលវៀតណាមនៅទីក្រុងសៃហ្គន បានបង្ហាញពីការព្រួយបារម្ភជាច្រើន ទៅលើការកើនឡើង នូវឥទ្ធិពលដ៏ខ្លាំងរបស់ជនជាតិចិននៅក្នុងប្រទេសរបស់ខ្លួន ដោយពួកនេះបានគ្រប់គ្រងទៅលើផ្នែកសេដ្ឋកិច្ច ក៏ប៉ុន្តែរដ្ឋាភិបាលវៀតណាមលែងដាក់ពួកគេឲ្យនៅក្រោមច្បាប់តែមួយដូចគ្នា ទៅនឹងប្រជាជនដែលពួកគេបានកេងប្រវ័ញ្ចនោះទៀតហើយ (សម្រែករបស់ជនជាតិអាណ្ណាម ថ្ងៃទី ៨ ខែ មករា ឆ្នាំ ១៩២៩ ដកស្រង់ចេញពីអាស៊ីបារាំង ខែ មេសា ឆ្នាំ ១៩២៩ ទំ.១៣៣) ។ ការនិយាយបែបនេះនៅតែស្ថិតនៅក្នុងការខ្វែងគំនិតគ្នានៅឡើយ ព្រោះចំណុចនេះ ធ្លាប់មានគេលើកយកមកបង្ហាញរួចមកហើយ ដែលយ៉ាងហោចណាស់ ក៏មានអជ្ញាធរមួយបានរកឃើញថា តាមរយៈសន្ធិសញ្ញានេះ គឺគ្មានឃើញភាពខុសគ្នាគួរឲ្យកត់សម្គាល់ណាមួយឡើយ ។ ក៏ប៉ុន្តែ មានអ្នកជំនាញម្នាក់មកពីក្រសួងយុត្តិធម៌បានប្រាប់ខ្ញុំថា ជនជាតិចិន គឺស្ថិតនៅក្រោមការកាត់ក្តីរបស់តុលាការបារាំង នៅពេលដែលច្បាប់ស៊ីវិលរបស់ចិនត្រូវបានប្រើសម្រាប់ពួកគេនោះ ។ (អ្នកផ្តល់ព័ត៌មាននេះ បានទទួលស្គាល់ថា មានការធ្វើបែបនេះមែនរហូតមកដល់មុនឆ្នាំ ១៩៣០ ដែលយើងដឹងថាមិនគួរធ្វើបែបនេះ) ។ ប្រហែលជាការសម្របសម្រួលនៃគំនិតផ្ទុយទាំងនេះហើយ ដែលបានបង្ហាញអស់ជាង ៣០ ឆ្នាំហើយប្រហែលជាឈានទៅដល់គោលដៅមួយ តាមរយៈការស្នើឲ្យមានថា នៅពេលដែលជនជាតិចិនត្រូវបានកាត់ក្តីដោយប្រើប្រាស់ច្បាប់របស់ចិននៅក្នុងតុលាការបារាំងនោះ គឺជាពេលដែលចិនបានដាក់ស្ថានកុងស៊ុលមួយ នៅឯទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៤៦ រហូតដល់សម័យសង្គ្រាមដែលយ៉ាងហោចណាស់ ក៏ជនជនជាតិចិនស្ថិតនៅក្រោមការកាត់ក្តីរបស់តុលាការកម្ពុជាដែរ ។*

*ក៏ប៉ុន្តែ មិនថាតុលាការបែបណានោះទេ ក៏យើងនៅតែអាចមើលឃើញយ៉ាងច្បាស់ថា ក្នុងសម័យបារាំងនៅរាល់ពេលដែលពួកគេមានជម្លោះនៅក្នុងសហគមន៍របស់ពួកគេនោះ ជនជាតិចិនកម្រនឹងពឹងផ្អែកទៅលើប្រព័ន្ធតុលាការណាស់ ដោយសារតែគ្រប់ក្រុមទាំងអស់ សុទ្ធតែមានគណៈកម្មការផ្សះផ្សារជម្លោះ រៀងៗខ្លួន ។ ប្រសិនបើជម្លោះកើតឡើង រវាងជនជាតិចិនមកពីសហគមន៍ផ្សេងគ្នា ឬប្រសិនបើមានភាគីម្ខាងណា ចង់ធ្វើការតវ៉ាទៅលើការសម្រេចចិត្តពីគណៈកម្មការរបស់ពួកគេ ក្នុងករណីទាំងនេះ ត្រូវដាក់ឲ្យសម្រេចដោយគណៈកម្មការមួយ ដែលមានសមាជិកចំនួនដប់នាក់មកពីសហគមន៍ទាំង ៥ ដែលសហគមន៍នីមួយៗមានតំណាងពីរនាក់ ជាសមាជិកនៃគណៈកម្មការនេះ ។[២៦] ក្រុមប្រឹក្សាភិបាលដែលមានប្រធានក្រុមទាំង ៥ រូប និងអនុប្រធានក្រុម ៥ រូប នឹងចូលរួមប្រជុំគ្នានៅក្នុងទីក្រុងភ្នំពេញ ដើម្បីស្តាប់ពីបញ្ហានិរទេសខ្លួនរបស់សមាជិកក្រុមណាម្នាក់ ។[២៧]*

## ការកំណត់ន័យស្របច្បាប់របស់ជនជាតិចិននៅសម័យឯករាជ្យ

*ការកំណត់ន័យស្របច្បាប់សម្រាប់ជនជាតិចិន ដែលរស់នៅលើទឹកដីនៃប្រទេសកម្ពុជា មានការផ្លាស់ប្តូរយ៉ាងខ្លាំង ។ បើមើលឲ្យច្បាស់ទៅលើបន្ទាស់ប្តូរនេះ គ្មានអ្វីទាក់ទងទៅនឹងអនុសញ្ញាអន្តរជាតិនោះទេ ព្រោះប្រទេសកម្ពុជាមិនដែលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាសាធារណៈណាមួយ ជាមួយនឹងប្រទេសចិន ដើម្បីដាក់ជំនួសនូវសន្ធិ*

*សញ្ញាណានគីង ដែលបានធ្វើឡើងក្នុងឆ្នាំ ១៩៣០ នោះឡើយ ។*[២៨]

*នៅក្នុងសម័យឯករាជ្យ ទ្រង់ទ្រាយថ្មីមួយត្រូវបានបន្ថែមទៅនឹងចម្ងល់មួយថា ជនជាតិចិនឥឡូវនេះអាចចាត់ទុកថា ជាប្រជាជាតិរបស់សាធារណៈរដ្ឋចិនផង និងជាប្រជាជាតិរបស់សាធារណៈរដ្ឋប្រជាមានិតចិន ។ នៅពេលដែលប្រទេសកម្ពុជាទទួលបានឯករាជ្យក្នុងឆ្នាំ ១៩៥៣*[២៩] *នៅក្នុងទីក្រុងភ្នំពេញមានការបង្កើតស្ថានកុងស៊ុលជាតិនិយមចិនមួយ ប៉ុន្តែរដ្ឋាភិបាលនៃប្រទេសកម្ពុជា មិនដែលទទួលស្គាល់ស្ថានកុងស៊ុលនេះទេ ព្រោះថារដ្ឋាភិបាលកម្ពុជា មានទំនោរទៅខាងសាធារណៈរដ្ឋប្រជាមានិតចិនជាតិ ដែលក្រោយពីសន្និសីទទីក្រុងបានឌុង មកធ្វើឲ្យសម្តេចសីហនុ និងជូអេនឡាយត្រូវរូវគ្នា ហើយចំណងទាក់ទងមិត្តភាពបានវិវត្តកាន់តែស្និទស្នាលឡើងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋប្រជាមានិតចិន ក្រោយពេលដែលសម្តេចសីហនុ បានយាងទៅធ្វើទស្សនកិច្ចនៅប៉េកាំង ហើយ ជូអេនឡាយ បានមកធ្វើទស្សនកិច្ចនៅកម្ពុជា ព្រមទាំងបានធ្វើសន្ធិសញ្ញាផ្នែកសេដ្ឋកិច្ចមួយចំនួនជាមួយគ្នាទៀតផង ។*

*នៅពេលដែលរដ្ឋាភិបាលគួមីងតាង របស់ចិន នៅតែប្រើនយោបាយប្រកាសទាមទារយុត្តិធម៌នៅលើឆាកអន្តរជាតិ រដ្ឋាភិបាលថ្មីរបស់ក្រុង ប៉េកាំង បានប្រើនយោបាយមួយដោយមិនទទួលស្គាល់ពួក គួមីងតាង ដើម្បីការពារនូវការវាយប្រហាររបស់ពួកនេះ ដែលអាចកើតមានឡើងគ្រប់ពេលវេលា ជាក់ស្តែង យុទ្ធសាស្ត្រនេះផ្អែកលើគំនិតមួយ ដែលចោទថាពួកគួមីងតាង គឺជាពួកប្រតិកិរិយា ដែលតែងប្រឆាំងទៅនឹងបដិវត្តិ ហើយពួកនេះបានក្បត់ទៅនឹងប្រទេសជាតិរបស់ខ្លួន ដោយសារតែពួកគេរស់នៅក្រៅប្រទេស* (**សង្គ្រាមត្រជាក់ និងជនជាតិចិននៅបរទេស** *ទំ. ៥៨១) ។ ក្នុងពេលជំណាលគ្នានេះដែរ ប្រទេសចិនបានធ្វើការវាយប្រហារដោយពាក្យសម្តីសារជាថ្មីប្រឆាំងទៅនឹងរដ្ឋាភិបាលជាច្រើន នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បន្ទាប់មកក្នុងឆ្នាំ ១៩៥៤-៥ នៅពេលដែលរដ្ឋាភិបាលកណ្តាលរបស់ចិន ក្លាយទៅជាសន្សៀននយោបាយរបស់អាស៊ីនោះ ចិនបានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួន ដោយលើកទឹកចិត្តដល់ប្រជាជនចិននៅក្រៅប្រទេសទាំងអស់ ឲ្យធ្វើជាពលរដ្ឋល្អចំពោះប្រទេសជាតិរបស់ពួកគេ ។ នយោបាយនេះ គឺជាការពាំនាំ និងប្រកាសដោយ ជូអេនឡាយ ទៅកាន់ប្រជាជាតិចិនក្នុងទីក្រុងភ្នំពេញនៅខែធ្នូ ឆ្នាំ ១៩៥៦ (ចូស៊ី ទំ. ៨០៧) ។*[៣០]

*ទន្ទឹមនឹងពេលដែលមានបន្លាស់ប្តូរនយោបាយ របស់រដ្ឋាភិបាលចិនកណ្តាល ដែលមានភាពផ្ទុយគ្នាយ៉ាងស្រឡះពីនយោបាយរបស់រដ្ឋាភិបាល គួមីងតាង ច្បាប់ថ្មីរបស់ប្រទេសកម្ពុជា លើបញ្ហាសញ្ជាតិកម្ម ក៏បានប្រកាសឲ្យប្រើជាផ្លូវការនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៥៤ ដែរ ហើយក៏មានច្បាប់អន្តោប្រវេសន៍មួយ បានប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៥៦ ដែលបានកំណត់បង្ហាញជាថ្មីម្តងទៀត ពីស្ថានភាពរបស់ជាតិសាសន៍ចិនក្នុងប្រទេសកម្ពុជា ផ្ទុយពីនយោបាយរបស់បារាំង ដែលមានកត្តាជាច្រើនអាចកំណត់ថា ជាជនបរទេសនោះ ច្បាប់ថ្មីរបស់ប្រទេសកម្ពុជាទាំងនេះ បានត្រឡប់ទៅយកគោលការណ៍ចាស់របស់ប្រទេសកម្ពុជា ដែលជាច្បាប់មួយផ្តល់នូវភាពកាន់តែទូលាយឡើងសម្រាប់ជនបរទេស ដែលនៅទីបញ្ចប់ ច្បាប់នេះបានយកទាំងច្បាប់សញ្ជាតិ ដែលផ្អែកលើទីកន្លែងកំណើត* (Jus soli) *និងច្បាប់សញ្ជាតិ ដែលផ្អែកលើសញ្ញាតិរបស់មាតាបិតា មកប្រើ ។*

*គេបានកំណត់ការធ្វើសញ្ជាតិកម្មកម្ពុជាឡើង នៅក្នុងច្បាប់រដ្ឋប្បវេណីក្នុងឆ្នាំ ១៩២០ ប៉ុន្តែបានធ្វើវិសោធនកម្មដោយច្បាប់ឆ្នាំ ១៩៥៤ វិញ (ក្លែរូន ទំ.២៤) យោងតាមមាត្រាទី ២២ រាល់អ្នកណាដែលអាចរាប់ខ្សែលោហិតរបស់ខ្លួន ដែលយ៉ាងហោចណាស់មានឪពុក ឬម្តាយជាជនជាតិខ្មែរ ជននោះត្រូវចាត់ទុកថាជាជនជាតិខ្មែរ ដោយ*

*មិនគិតពីទីកន្លែងដែលគេបានកើតឡើយ ។ ក្នុងពេលដែលច្បាប់តែមួយនេះ បាននិយាយលម្អិតពីស្ត្រីកម្ពុជា ដែលបានរៀបការជាមួយនឹងជនបរទេស គឺមិនបានបាត់បង់នូវសញ្ជាតិកម្ពុជារបស់ខ្លួន បែបនេះមានន័យថា រាល់កូនកាត់តទាំងអស់ គឺជាជនជាតិកម្ពុជាចាប់ពីពេលនេះតទៅ (ក្លេរូន ទំ. ២៥) លើសពីនេះទៅទៀតក្នុងមាត្រាដដែលក៏បានបន្ថែមទៀតដែរថា រាល់អ្នកណាដែលកើតនៅក្នុងប្រទេសកម្ពុជា ដែលយ៉ាងហោចណាស់ឪពុក ឬម្តាយរបស់គេក៏កើតនៅលើទឹកដីកម្ពុជាដែរ នោះគឺចាត់ទុកថាជាប្រជាជនកម្ពុជា ។ មាត្រានេះចាប់អនុវត្តន៍ចំពោះកុមារទាំងឡាយណា ដែលកើតក្រោយថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៥៤ បើយោងតាមសារាចរដែលបានចុះផ្សាយនៅថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ១៩៥៥ ។*

*ឆ្លងតាមរយៈការពិភាក្សាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ច្បាប់ដែលកំណត់សម្រាប់ជនជាតិចិន គឺកាន់តែតូចចង្អៀតទៅនៅក្នុងពេលបច្ចុប្បន្ន ជាងកាលនៅសម័យបារាំង លើសពីនេះទៅទៀតនោះ ប្រហែលជាលែងមានព្រំដែនសម្រាប់ជនជាតិនេះ ព្រោះឥឡូវ មានមនុស្សជាច្រើនដែលកើតក្នុងគ្រួសារជនជាតិចិន មានសញ្ជាតិកម្ពុជា ដោយយោងតាមរយៈច្បាប់សញ្ជាតិដែលផ្អែកលើទីកន្លែងកំណើត ។ សព្វថ្ងៃនេះ មានគ្រួសារជាច្រើនដែលមានសមាជិកជាជាតិសាសន៍ទាំងពីរនេះ ។ នៅក្នុងគ្រួសារមិត្តភក្តិរបស់ខ្ញុំមួយ ជាគ្រួសារចិន ដែលឪពុករបស់គេកើតនៅលើទឹកដីកម្ពុជា ប៉ុន្តែបានចំណាយពេលក្នុងវ័យកុមារភាពរបស់គាត់ នៅក្នុងប្រទេសចិននោះ បុរសជាឪពុកនោះ គឺជាជនជាតិខ្មែរ នៅពេលដែលបងប្អូនប្រុសរបស់គាត់ពីរនាក់ទៀតនោះ គឺជាជនជាតិចិន បងប្អូនជីដូនមួយម្នាក់របស់មិត្តខ្ញុំ គឺជាជនជាតិចិន ដែលគេនោះមានឪពុកជាជនជាតិខ្មែរ ចំណែកឯកមិត្តខ្ញុំ និង ប្អូនប្រុសគាត់ពីរនាក់ទៀត គឺជាជនជាតិខ្មែរ ខណៈពេលដែលសមាជិករបស់គាត់ដទៃទៀត (ទាំងចាស់ជាង ទាំងក្មេងជាង, ទាំងប្រុស ទាំងស្រី) គឺជាជនជាតិចិន ។ បងប្អូនស្រីជនជាតិចិនរបស់ឪពុកមិត្តខ្ញុំ បានរៀបការជាមួយនឹងបុរសជនជាតិខ្មែរម្នាក់ ហើយកូនៗរបស់គាត់ លែងចាត់ទុកថាជានជនជាតិចិនទៀតហើយ ។ ក្នុងករណីគ្រួសារមួយខាងលើ ដែលមានពិត តែមិនមែនជាទូទៅបែបនេះ អាចនឹងក្លាយទៅជាឧបសគ្គមួយ ក្នុងការកម្រិតចំពោះកិច្ចពិភាក្សារបស់យើង អំពីជនជាតិចិនដែលបានកំណត់ដោយច្បាប់ទាំងនោះ ។*

*ច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៥៦ បានបង្ហាញនូវការផ្លាស់ប្តូរមួយចំនួនគួរឲ្យចាប់អារម្មណ៍ ទៅលើនិតិវិធីនៃច្បាប់នេះ ។ ជនជាតិចិន ត្រូវបានគេដាក់ឲ្យនៅក្រោមនិតិវិធី ដូចគ្នាមួយទៅនឹងជនអន្តោប្រវេសន៍ដទៃទៀត ក៏ប៉ុន្តែនៅពេលនោះស្ទើរតែគ្មានជនជាតិណាម្នាក់ ធ្វើអន្តោរប្រវេសន៍ចូលមកក្នុងប្រទេសឡើយ ។ នៅផ្នែកទី ២ ដែលកំណត់ទៅលើលក្ខខណ្ឌនៃប្រជាជនម្ចាស់ស្រុក ក៏មិនបានបែងចែកឲ្យដាច់រវាងជនជាតិចិន និងជនបរទេសដទៃទៀតដែរ ហើយអ្នកទាំងអស់គ្នា ត្រូវតែកាន់កាតសម្គាល់ខ្លួនម្នាក់មួយ ដែលកាតនេះត្រូវធ្វើថ្មីជារៀងរាល់ឆ្នាំ ហើយអ្នករាល់គ្នា ក៏ស្ថិតក្នុងការដាក់ទោស និងផាកពិន័យដូចគ្នា ។ មាត្រាទី ២៦ បានរៀបរាប់ពីមុខរបរចំនួន ១៨ ដែលបានហាមឃាត់ចំពោះជនបរទេសទាំងអស់ ដែលមានមួយចំនួនធំត្រូវបានជនជាតិចិនកាន់កាប់កាលពីអតីតកាល (សូមមើលទំព័រ ៤៦ សម្រាប់ការពិភាក្សាមួយពីទ្រង់ទ្រាយនៃច្បាប់នេះ) ។ ការផ្តល់នូវលក្ខណៈពិសេសមួយចំនួនចុងក្រោយដល់ជនជាតិចិន គឺនៅក្នុងមាត្រាទី ៣៧ ដែលមានដូចខាងក្រោម (ជេ អូ ស៊ុ ១៩៥៦ ទំ. ៧៩៨) ÷*

> មុននឹងមានសន្និសញ្ញា ដែលយល់ព្រមជាមួយនឹងប្រទេសដែលពាក់ព័ន្ធ ជនបរទេសដែលបានមកតាំងលំនៅនៅក្នុងអាណាចក្រកម្ពុជា និងបានរួបរួមគ្នាជាសហគមន៍រួចហើយ នៅតែស្ថិតក្រោមច្បាប់ ដែលមានសុពលភាពក្នុងពេលបច្ចុប្បន្ននេះតទៅទៀត សម្រាប់ដំណើរការ និងសណ្តាប់ធ្នាប់សង្គមរបស់ពួកគេ ។[៣១] អត្ថន័យជាភាសាខ្មែរដោយលោក ថាច់ ដេត

អនុប្រយោគខាងលើនេះមាននៅក្នុងពង្រៀងច្បាប់មួយ ដែលធ្វើឡើងដោយស្តេច សីហនុ ផ្ទាល់ នៅពេលដែលទ្រង់គង់នៅជានាយករដ្ឋមន្ត្រី ។ អនុប្រយោគ ខាងលើ ហាក់ដូចជាបានបង្ហាញឲ្យដឹងថា ព្រះរាជានៅពេលនោះដូចជាបានដឹងមុនថា នឹងមានកិច្ចព្រមព្រៀងលើអនុសញ្ញាជាមួយនឹងប្រទេសចិន និងប្រទេសឥណ្ឌា ។ អនុសញ្ញានេះ នឹងមិនអាចកើតមានឡើងទេ ប្រសិនបើពួកគេមិនរក្សានូវការសម្ងាត់នោះទេ ។

ច្បាប់សញ្ជាតិកម្មឆ្នាំ១៩៥៤គ្មានប្រតិសកម្មទេ ។ បើតាមច្បាប់ ចំពោះជនជាតិចិន ដែលកើតនៅក្នុងប្រទេសកម្ពុជាមុនថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ១៩៥៤ ហើយចង់ប្តឹងទាមទារយកសញ្ជាតិកម្ពុជា គាត់ចាំបាច់ត្រូវតែបំពេញឲ្យបានតាមនូវចំណុចបន្ថែមដែលតម្រូវឲ្យមាន គឺយ៉ាងហោចណាស់ឪពុក ឬម្តាយរបស់គេមានសញ្ជាតិកម្ពុជា ។ យើងអាចនិយាយបានម្យ៉ាងទៀតថា ប្រសិនបើជនជាតិចិនទាំងឡាយណា ដែលបានកើតនៅក្នុងប្រទេសកម្ពុជាមុនថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ១៩៥៤ ចង់ធ្វើការប្តឹងទាមទារសញ្ជាតិកម្ពុជា អ្នកនោះយ៉ាងហោចណាស់ ក៏ជាជនជំនាន់ទីពីរដែលបានកើត និងរស់នៅលើទឹកដីនេះ ហើយត្រូវបង្ហាញថាយ៉ាងហោចណាស់គេមានជីដូន ឬជីតាម្នាក់មានសញ្ជាតិកម្ពុជា ។ ការសុំសញ្ជាតិកម្ពុជា ពួកចិនហៅជាភាសាចិនថា ហ្ស៊ួន ជី ដែលមានន័យថាដូរសញ្ជាតិ ។

ចំពោះជនជាតិចិនដែលមិនមានសញ្ជាតិកម្ពុជានោះ ពួកគេហៅបែបបទនៃការចូលសញ្ជាតិថា «រុជី» ដែលមានន័យថាចូលសញ្ជាតិ ។ តម្រូវការ និង ដំណើរការនៃការចូលសញ្ជាតិ គឺបានកំណត់នៅក្នុងច្បាប់មួយដែលប្រកាសឡើងដោយស្តេច នរោត្តមសីហនុ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៥៤ (ដេ អូ ស៊ី ១៩៥៤ ទំ. ៣៥៣៥-៧)។ តាមរយៈច្បាប់នេះ រាល់ជនបរទេសទាំងឡាយណា ដែលមានអត្តចរិត អាកប្បកិរិយា និងសីលធម៌ល្អ ហើយបានរស់នៅក្នុងប្រទេសកម្ពុជាតិចបំផុត ៥ ឆ្នាំ (ពីរឆ្នាំ ប្រសិនបើកើតនៅលើប្រទេសកម្ពុជា ឬរៀបការជាមួយនឹងជនជាតិកម្ពុជា អាចនឹងដាក់ពាក្យសុំសញ្ជាតិកម្ពុជាបាន ។ ក្នុងច្បាប់ដើមតម្រូវឲ្យមានចំណេះដឹងផ្នែកភាសាឲ្យបានគ្រប់គ្រាន់ប៉ុន្តែក្នុងវិសោធនកម្មច្បាប់ថ្មីក្នុងឆ្នាំ១៩៥៩ (៣៥៧-អិន អេសទំ. ២៦ តុលា ១៩៥៩) បានប្តូរតម្រូវការនេះ ទៅជាលទ្ធភាព ដែលអាចនិយាយភាសាខ្មែរស្ទាត់ និងបង្ហាញឲ្យឃើញថា ខ្លួនមានចរិតមារយាទ ប្រពៃណីទំនៀមទម្លាប់គ្រប់គ្រាន់ ដូចនឹងប្រជាជនកម្ពុជាដែរ (ក្លៃវ៉ុន) ។

ផ្ទុយគ្នាពីប្រទេសវៀតណាម ដែលជនជាតិចិនមិនដែលសប្បាយចិត្ត នឹងទទួលយកនូវច្បាប់ផ្តល់សញ្ជាតិវៀតណាមឆ្នាំ១៩៥៦ ដល់ជនទាំងឡាយ ណាដែលកើតនៅលើទឹកដីវៀតណាមនោះ ប្រទេសកម្ពុជាអាចបង្កើតច្បាប់ឡើងមក ដោយមិនបានធ្វើឲ្យមានប្រតិកម្ម ពីសំណាកប្រជាជនចិននៅលើទឹកដីរបស់ខ្លួនឡើយ ។ មួយផ្នែកនៃរឿងនេះ គឺដោយសារតែមេដឹកនាំជនជាតិចិននៅក្នុងប្រទេសកម្ពុជា ស្ថិតនៅក្នុងដំណាក់កាលមិនច្បាស់លាស់ ហើយមួយផ្នែកទៀត ក៏អាចកើតឡើងបានដែរ ដោយសារតែច្បាប់នៅមានលក្ខណៈចន្លោះប្រហោងនៅឡើយ ក្នុងការសម្គាល់ទៅលើជនជាតិចិន ដែលមានសញ្ជាតិចិនទាំងនោះ ។ ទោះបីជាយ៉ាងណាក៏ដោយ ជនជាតិចិនបានមើលឃើញថា ដើម្បីប្តឹងទាមទារយកសញ្ជាតិកម្ពុជា ក្រោមច្បាប់ឆ្នាំ ១៩៥៤ ពួកគេត្រូវបង់ប្រាក់ក្នុងចំនួនដ៏ក្រៃលមួយ ពួកគេតែងត្អូញត្អែរពីតម្លៃនៃការប្តូរសញ្ជាតិនេះ ។ នៅក្នុងឆ្នាំ ១៩៦២ តម្លៃក្នុងការប្តូរសញ្ជាតិគឺ ២៣.០០០ រៀល ប៉ុន្តែនៅខែ កុម្ភៈ ឆ្នាំ១៩៦៣ គឺបានឡើងដល់ ២៦.០០០ រៀល (ស្មើនឹង ៧៥០ ដុល្លារអាមេរិក) លុយនេះ គឺបង់ឲ្យអ្នករត់ការ ធ្វើបែបបទសុំសញ្ជាតិ ។ មានអ្នកផ្តល់ព័ត៌មានជាច្រើនបានអះអាងថា ចាំបាច់ត្រូវតែមានចំនួនលុយដ៏ច្រើនមួយ ព្រោះមានជនជាតិចិនភាគតិចណាស់ ដែលអាចជាប់លើផ្នែកភាសា ដែលជាវិញ្ញាសាមួយតឹងរឹងបំផុត លុះណាតែអ្នកនោះបង់លុយឲ្យទើបជាប់ ។ (៣២)

ដូចនៅក្រោមសម័យបារាំងដែរ ជនបរទេសទាំងឡាយនៅក្នុងប្រទេសកម្ពុជា គ្មានសិទ្ធិកាន់កាប់ ឬសាងសង់លើដីធ្លីទាំងនៅទីក្រុង និងជនបទ បើយោងទៅតាមច្បាប់មួយ ដែលប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ១៩៥៨ ដោយសម្តេច នរោត្តម សុរាម្រិត (ហ្សឺ អូ អ៊ី ១៩៥៨,ក្រម ទំ.២៥៤) ច្បាប់នេះបានចែងថា អចលនទ្រព្យទាំងឡាយ អាចលក់ឲ្យបានតែចំពោះប្រជាជនកម្ពុជា ឬក្រុមហ៊ុនដែលមានប្រជាជនកម្ពុជាជាម្ចាស់ ហើយមានកិច្ចសន្យារយៈពេល ៩៩ ឆ្នាំ ប្រសិនបើជួលទៅឲ្យជនបរទេស ។

បើមើលការកាត់ក្តីនៅតុលាការ ចំពោះជនជាតិចិន គឺទាមទារមិនឲ្យមានប្រព័ន្ធតុលាការពីរផ្សេងគ្នាតទៅទៀតឡើយ ហើយជនបរទេសគ្រប់រូប ត្រូវស្ថិតនៅក្រោមតុលាការកម្ពុជា (ម៉ូរីសទំ. ១៦) ដោយមានការលើកលែងតែចំពោះអ្នកណា ដែលមានអភ័យឯកសិទ្ធិផ្នែកការទូត ។ អ្នកជំនាញផ្នែកច្បាប់ នៅក្រសួងយុត្តិធម៌ម្នាក់បាននិយាយប្រាប់ខ្ញុំដោយត្រង់ថា សម្រាប់ជនជាតិចិន ដែលមានសញ្ជាតិចិនទាំងនោះ គួរតែកាត់ក្តីឲ្យបានសមរម្យដោយប្រើប្រាស់ច្បាប់របស់ជនជាតិចិន ប៉ុន្តែក្រសួងមិនបានដាក់ច្បាប់រដ្ឋប្បវេណីរបស់សាធារណៈរដ្ឋប្រជាមានិតចិន ហើយពួកគេក៏មិនអាចប្រើប្រាស់ច្បាប់របស់សាធារណៈរដ្ឋចិនដែរ ព្រោះប្រទេសកម្ពុជាលែងទទួលស្គាល់ក្រុមទាំងពីរនេះតទៀតហើយ ។

ច្បាប់ពាណិជ្ជកម្មរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៥០ បានក្លាយជាទុន ក្នុងការបង្កើតឲ្យមានតុលាការពាណិជ្ជកម្មឡើងមក ជាមួយនឹងការកាត់ក្តីជុំវិញជម្លោះរវាងពាណិជ្ជករ និងពាណិជ្ជករ ។ ស្ថាប័នតុលាការនេះ មានតុលាការបីរូប ក្នុងនោះមានពីររូបជាអ្នកដែលទទួលបានការជ្រើសតាំង ដោយការបោះឆ្នោតពីសំណាក់ពាណិជ្ជករ ដែលមានប័ណ្ណរកស៊ីត្រឹមត្រូវតាមច្បាប់ (ក្លេរូន ១៩៦២ ទំ.២៤៩) ក៏ប៉ុន្តែដោយសារពាណិជ្ជករកម្ពុជាមានចំនួនតិចពេក ស្ថាប័នតុលាការនេះ នៅមិនទាន់បានបង្កើតនៅឡើយទេ ហើយរាល់រឿងក្តីដែលទាក់ទងទៅនឹងផ្នែកពាណិជ្ជកម្ម គឺត្រូវដោះស្រាយតាមរយៈតុលាការស៊ីវិល (ម៉ូរីស ទំ.២៨) ។

ជាការពិតដែលថា គន្លឹះសំខាន់ដែលធ្វើឲ្យមានភាពខុសគ្នា ក្នុងការកំណត់ស្ថានភាពស្របច្បាប់របស់ជនជាតិចិន គឺដោយសារការការសាបសូន្យទៅ នៃប្រព័ន្ធសហគមន៍ប្រមូលផ្តុំ ។ របបគ្រប់គ្រងរបស់ប្រព័ន្ធនេះ គឺបានខូចខ្ទីទៅ ជាមួយនឹងលំហូរចូលដ៏ច្រើនសន្ធឹកសន្ធាប់ឥតគណនា នៃចំនួនជនអន្តោប្រវេសចិន បន្ទាប់ពីមានសង្គ្រាមរវាងចិន និងជប៉ុន ។ អំណាចរបស់ប្រធានក្រុមគ្រប់រូប ត្រូវកាត់បន្ថយគួរឲ្យកត់សម្គាល់ ជាមួយនឹងការបញ្ចូលថ្មីនូវបណ្តុំនៃពន្ធអាករមួយ សម្រាប់ជនជាតិចិនក្នុងឆ្នាំ ១៩៥៤ ។ ច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៥៦ ធ្វើឲ្យមាននូវដែនកំណត់ដល់បណ្តាពួកប្រធានសហគមន៍ តាមរយៈការអនុញ្ញាតិ ឲ្យមានចលនាដោយសេរីមួយនៅទូទាំងផ្ទៃប្រទេស ដោយអនុញ្ញាតឲ្យជនអន្តោប្រវេសន៍ទាំងអស់ មានសិទ្ធិកាន់អត្តសញ្ញាណប័ណ្ណដែលអាចយកជាការបាន និងដកហូតសិទ្ធិអំណាច នៃការនិរទេសសមាជិកក្រុម ចេញពីប្រធានក្រុមវិញ ។ នៅទីបញ្ចប់ តួនាទីរបស់ប្រធានក្រុមត្រូវបានសាបរលត់នៅក្នុងឆ្នាំ១៩៥៨[៣៣] ក្នុងពេលនោះហើយ ដែលជនជាតិចិនទទួលបាននូវអត្តសញ្ញាណស្របច្បាប់មួយដូចនឹងជនបរទេសដទៃទៀតដែរ ហើយក៏មានមនុស្សជាច្រើន អាចប្តឹងទាមទារសញ្ជាតិកម្ពុជាបាន ។

## សេចក្តីសន្និដ្ឋាន

តាមរយៈការពិភាក្សាវែកញែកពីខាងដើមមក បានបង្ហាញឲ្យឃើញនូវភាពខុសប្លែកគ្នាយ៉ាងច្រើន ជុំវិញបញ្ហានៃការកំណត់និយមន័យស្របច្បាប់ចំពោះជនជាតិចិន នៅរវាងសម័យមុនអាណានិគមបារាំង ឬសម័យអាណានិគមបារាំង

និងសម័យបច្ចុប្បន្ន ។ ជាការពិតណាស់ថា គោលគំនិតផ្សេងៗគ្នា ជួយជំរុញឲ្យមាននូវការតាក់តែងច្បាប់ជាច្រើន ក្នុងកំឡុងពេលខុសៗគ្នា ។ នៅក្រោមរបបបារាំងគ្រប់គ្រង ពេលដែលជនជាតិចិនត្រូវបានគ្រប់គ្រងដោយប្រព័ន្ធសហគមន៍ជាតិពន្ធុ និងនៅពេលដែលបារាំងមើលឃើញថា ជនជាតិចិន គឺជាប្រភពចំនូលផ្ទាល់មួយ ចំពោះរដ្ឋបាលអាណានិគមនោះ ច្បាប់ហាក់បីដូចជាបានផ្តល់ នូវលទ្ធភាពជាច្រើនដល់ជនជាតិចិន ក្នុងការកំណត់និយមន័យស្រប ច្បាប់សម្រាប់ពួកគេ ។ សព្វថ្ងៃនេះ ច្បាប់ជាច្រើនមានទំនោរទៅរក លក្ខណៈកាន់តែទូលាយឡើង នៅជុំវិញបញ្ហាផ្តល់សញ្ជាតិកម្ពុជា ដល់បណ្តាប្រជាជនដែលមានកំណើតនៅលើទឹកដី នៃប្រទេសកម្ពុជាទាំងមូល ដូច្នេះតាមរយៈច្បាប់នេះ បានបន្ថយនូវចំនួនជនជាតិចិនយ៉ាងច្រើន ។ ដំណើរការបែបនេះ គឺអនុវត្តន៍តាមព្រះរាជតម្រិះក្សត្រអង្គមុនៗ មុនពេលដែលបារាំងចូលលុកលុយប្រទេសកម្ពុជានោះ ក៏ប៉ុន្តែ នៅពេលដែលប្រព័ន្ធសហគមន៍ជាតិពន្ធុបានជួយបម្រើដល់ច្បាប់សម័យបារាំង ហើយលក្ខខណ្ឌកំណត់ពូជសាសន៍ (ឬជាតិពន្ធុ) មានសភាពស្ទើរតែត្រឹមត្រូវ ១០០% នោះជនជាតិចិនបានចូលសញ្ជាតិខ្មែរជាច្រើននាក់ ក៏ប៉ុន្តែចំនួនពិតប្រាកដ ឬសូម្បីតែតម្លៃប៉ាន់ស្មានមួយ ពិបាកនឹងទទួលបានពិតប្រាកដណាស់ (សូមមើលឧប្បសម្ព័ន្ធទី១) ។ រឿងនេះ អាចបង្ហាញតាមរយៈភាពពិតក្នុងគ្រួសាររបស់ពួកគេ ដែលមានបញ្ចូលគ្នាទាំងជាតិសាសន៍ចិន និងខ្មែរ ។ ដំណើរការចូលសញ្ជាតិជាផ្លូវការបានលេចឡើងប្រៀបដូចជាបាតុភូតដ៏ថ្មីសន្ធាងមួយនៅក្នុងប្រទេសកម្ពុជា ដែលទើបតែចាប់ផ្តើមមានឡើងក្នុងឆ្នាំ ១៩៤០។ ចាប់តាំងពីទទួលបានឯករាជ្យមក ច្បាប់ក្នុងការកំណត់ទៅលើជនជាតិចិន គឺកាន់តែជាក់ច្បាស់ឡើងថែមទៀត ប៉ុន្តែពួកគេបានក្លាយទៅជាមុខសញ្ញាមួយ ដែលត្រូវទទួលចំណាយក្រៅផ្លូវការកាន់តែច្រើនឡើងៗ ។

ការកំណត់ព្រំដែនដើម្បីទប់ទល់ទៅនឹងការទិញ និងគ្រប់គ្រងលើអចលនវត្ថុរបស់ជនជាតិចិន បានធ្វើឡើងជាលើកដំបូងនៅក្នុងឆ្នាំ ១៩២០ ហើយបានបន្តរហូតមកដល់សព្វថ្ងៃនេះ តាមរយៈច្បាប់មួយដែលបានអនុម័តឡើងនៅឆ្នាំ ១៩៥៨ (ច្បាប់នេះបានលេចឡើងមក នៅក្រោយពេលទទួលបានឯករាជ្យបានពីរបីឆ្នាំ ក្នុងពេលដែលជនបរទេសមានសិទ្ធិអាចទិញអចលនវត្ថុបាននោះ) លើសពីនេះទៅទៀត នៅកំឡុងឆ្នាំ ១៩៥៦ ច្បាប់បានហាមឃាត់ជនជាតិចិនមិនឲ្យប្រកបរបរចំនួន ១៨ មុខ។

ចំណុចចុងក្រោយ គឺលើកលែងតែសម័យកាលមួយបន្ទាប់ពី (ហើយក៏ប្រហែលជានៅអំឡុងពេល) សង្គ្រាមរវាងជប៉ុន និងចិនចេញនោះ ជនជាតិចិនត្រូវស្ថិតនៅក្រោមច្បាប់របស់ប្រទេសកម្ពុជា ដែលគ្រប់គ្រងដោយតុលាការរបស់ប្រទេសកម្ពុជា រួមជាមួយនឹងកំណត់ចំណាំជាពិសេសមួយ ដែលមានការជជែកវែកញែកគ្នាជាច្រើន នៅក្នុងសម័យអាណាព្យាបាលបារាំង ដែលថា បើភាគីជម្លោះទាំងសង្ខាងជាជនជាតិចិន ពួកគេត្រូវដោះស្រាយនៅក្រោមគណៈកម្មការ នៃប្រព័ន្ធសហគមន៍ជាតិពន្ធុ ៕

# ជំពូកទី ៣

## ស្ថាប័នសង្គម នៃសហគមន៍ចិននៅកម្ពុជា

*ដោយ វីល្លៀម. អ៊ី. វីលម៉ូតត៍*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "Social Organization of the Chinese Community" ។
*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖* **ជនជាតិចិននៅកម្ពុជា** ។
*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យប្រ៊ីធីសកូឡុំបៀ* ។

# CHAPTER 3:

## Social Organization of the Chinese Community

William E. Willmott
(*The Chinese in Cambodia*)

**Copyright © 1967 by University of British Columbia**

បកប្រែដោយ ថុល-ឌីណា

# ជំពូកទី ៣
# ស្ថាប័នសង្គមនៃសហគមន៍ចិននៅកម្ពុជា

នៅក្នុងជំពូកទីពីរ យើងបានរៀបរាប់រួចមកហើយ អំពីលក្ខណៈផ្សេងៗគ្នារបស់ជនជាតិចិននៅកម្ពុជា រួមមានដូចជា រូបរាងខាងក្រៅ ភាសា ការគិត និងការគោរពជំនឿសាសនា ដែលលក្ខណៈទាំងអស់នេះ គឺជាសញ្ញាណសម្រាប់ក្រុមមួយទាក់ទងទាក់ទងជាមួយក្រុមផ្សេងទៀត ។ ប៉ុន្តែ អត្តសញ្ញាណវប្បធម៌របស់ជនជាតិចិនទាំងមូល ស្ថិតនៅលើមូលដ្ឋានច្បាស់លាស់ ដែលស្ថែងឡើងតាមរយៈស្ថាប័នសង្គមរបស់សហគមន៍នោះ ។ លក្ខណៈទាំងអស់នោះមានដូចជាភាសា និងពិធីសាសនា ពឹងផ្អែកមួយផ្នែកធំលើស្ថាប័នសង្គមនេះ ។

ជនជាតិខ្មែរ បានចាត់ទុកជនជាតិចិនទានាថា ជាជាតិសាសន៍តែមួយក្រុមដូចៗ គ្នារាប់ចាប់តាំងពីអ្នកតាំងលំនៅបានចាកចេញពីប្រទេសចិន មកដល់ស្រុកខ្មែរដំបូង ។ ប៉ុន្តែ រហូតមកទល់ពេលថ្មីៗនេះជនជាតិចិនខ្លួនឯងដែលរស់នៅក្រៅប្រទេស សង្កត់ធ្ងន់លើការបែងចែកវប្បធម៌រវាងក្រុម (ចិន) និយាយភាសាផ្សេងៗ ជាជាងសង្កត់ធ្ងន់លើអត្តសញ្ញាណជាជនជាតិចិន ។ នៅតណ្ហចិន ការបែងចែកទាំងនេះត្រូវបានពង្រឹង និងជំរុញឲ្យបន្តមានពេញមួយសម័យ ដែលបារាំងកាន់កាប់ តាមរយៈការព្រមព្រៀងផ្លូវច្បាប់ ដែលគេហៅឈ្មោះថា ប្រព័ន្ធសហគមន៍ជាតិពន្ធុ។ ប្រព័ន្ធនេះ បានបែងចែកជនជាតិចិនជាប្រាំក្រុម មានដូចជា ចិនទាជីវ ចិនកាតាំង ចិនហុកកៀន ចិនខិ និងចិនហៃណាំ ។ ដូច្នេះ សមាគមន៍ចិនមានរចនាសម្ព័នប្រាំ ដែលមានការទាក់ទងជាមួយគ្នាតាមរយៈរូបភាពផ្សេងៗ ប៉ុន្តែរូបភាពទាំងនោះ អាចត្រូវបានគេមើលឃើញថាជាប្រព័ន្ធសង្គម ដែលគេពុំងាយនឹងពិនិត្យឃើញ ។ ក្រុមនិយាយភាសាមួយ គឺជាតំណាងសម្រាប់ទាក់ទងពាណិជ្ជកម្ម ការជ្រើសរើសគូរស្រករ រៀបអាពាហ៍ពិពាហ៍ និងជាមួយរដ្ឋបាល ។

ជាមួយការលេចឡើងនូវស្មារតីជាតិនិយម ដែលពួកគេមានចំពោះស្រុកចិន សហគមន៍ចិនក្រៅស្រុកនៃបណ្តាប្រទេសភាគច្រើន បានទទួលស្គាល់អំពីការឯកភាពវប្បធម៌ នៅកំលុងដំណាច់សតវត្សរ៍នេះ ។[១] ដូចដែលខ្ញុំបានលើកឡើងរួចមកហើយថា នៅក្នុងប្រទេសកម្ពុជា ដំណើរការបែបនេះត្រូវបានពន្យារពេល ដោយសារប្រព័ន្ធសហគមន៍ជាតិពន្ធុ ។ ដោយឡែក រហូតមកដល់ឆ្នាំ ១៩៥៦ ជាពេលដែលលោក ជូអេនឡាយ បានមកធ្វើទស្សនកិច្ចនៅកម្ពុជាជាលើកដំបូង ជនជាតិចិននៅភ្នំពេញជាច្រើន បានបោះបង់ចោលនូវភក្តីភាពដោយឡែកៗពីគ្នា ដោយបែរមករួមសម្តែងភក្តីភាពជាសាកល ចំពោះសហគមន៍ចិនទាំងមូល ។

នៅក្រោមការគ្រប់គ្រងរបស់បារាំង សមាគមចាំបាច់ទាំងឡាយណា ដែលគេស្គាល់ថាហ៊ុយកន (ដែលត្រូវបានកំណត់ដោយប្រព័ន្ធសហគមន៍ជាតិពន្ធុ ហើយសមាគមន៍នីមួយៗឱបក្រសោបលើក្រុមភាសារួមមួយ)គឺជាអ្នកផ្តល់រចនាសម្ព័ននយោបាយ សម្រាប់ស្ថាប័នសង្គមចិននៅតាមមជ្ឈមណ្ឌលធំៗក្នុងប្រទេសកម្ពុជា ។ សព្វថ្ងៃនេះដូចគ្នានឹងសមាគមន៍ចិនក្រៅប្រទេស ភាគច្រើនសមាគមន៍ស្ម័គ្រចិត្ត គឺជាអ្នកផ្តល់នូវគ្រោងឆ្អឹងនយោបាយផងនិងអត្តសញ្ញាណវប្បធម៌មួយចំណែកធំផង ។[២] សម្រាប់ជនជាតិចិន ១៣៥.០០០នាក់នៅក្រុងភ្នំពេញខ្ញុំបានទទួល

ព័ត៌មានថា មានសមាគមស្ម័គ្រចិត្តចំនួន ១១៥ ។ សមាគមភាគច្រើន ត្រូវបានបង្កើតតាំងពីចុងបញ្ចប់នៃសង្គ្រាមចិនជប៉ុន ពោលគឺចាប់តាំងពីការបញ្ចប់ការប្រើប្រាស់ប្រព័ន្ធសហគមន៍ជាតិពន្ធុ ចំពោះរចនាសម្ព័ន្ធរបស់សមាគមចិន ។ ចំណែកមជ្ឈមណ្ឌលតូច ដែលមានប្រជាជនចិនតិច មានសមាគមន៍តិចតាមហ្នឹងដែរ ប៉ុន្តែនៅគ្រប់សមាគមចិនទាំងអស់ យ៉ាងហោចណាស់ ក៏យើងអាចឃើញមានសាលារៀនមួយ និងក្លឹបកីឡាមួយដែរ ។

គេអាចចាត់ប្រភេទសមាគមចិននៅកម្ពុជាជាពីរប្រភេទ ដោយឈរលើមូលដ្ឋាននៃសកម្មភាពដឹកនាំ គឺ ក្រុមបុរាណ និងក្រុមទំនើប ។

សមាគមក្រុមបុរាណ គឺជាសមាគមទាំងឡាយណា ដែលមានលំនាំទៅរកតម្លៃចិនបុរាណ ។ សមាគមទាំងនេះ ព្យាយាមបញ្ចុះបញ្ចូលឲ្យមានកក្តីភាពចំពោះប្រទេសចិន ដែលមានកាលពី ៣០ ឆ្នាំមុន ឬក៏យូរជាងនេះ ។ ខ្ញុំហៅពួកគេថា «បុរាណនិយម» ជាជាងហៅថា «បុរាណ» ពីព្រោះតែសមាគមទាំងនេះ មិនមានលក្ខណៈបុរាណនៅក្នុងសង្គមចិនមុនសហសម័យទេ តែទិសដៅរបស់ពួកគេ មានលក្ខណៈបែបប្រពៃណី ។ សមាគមក្រុមបុរាណនៅក្នុងប្រទេសកម្ពុជា រួមបញ្ចូលទាំងក្រុមត្រកូលខ្សែស្រឡាយសមាគមក្នុងស្រុក គណៈកម្មាធិការរៀបចំបុណ្យសពល្ខោន និងក្រុមសម្តែងផ្សេងទៀត ។ សមាគមទាំងនេះ រើសសមាជិកពីក្នុងចំណោមមនុស្សចាស់ៗដែលកើតនៅស្រុកចិន ហើយពួកគេយកចិត្តទុកដាក់ជាចម្បងលើការអភិរក្សប្រពៃណី បុណ្យទាន និងសិល្បៈចិនបុរាណ ។

សមាគមក្រុមទំនើប ធ្វើសកម្មភាពទាំងឡាយឆ្ពោះទៅរកតម្លៃជាសាកល ។ សមាគមទាំងនោះមានដូចជាមន្ទីរពេទ្យចិន សមាគម កីឡា និងសាលារៀន ហើយការបំពេញការកិច្ចរបស់សមាគមទាំងនេះ គឺសម្រាប់ជាប្រយោជន៍ដល់សហគមចិនទាំងមូល ។ តួនាទីរបស់ពួកគេមានភាពច្បាស់លាស់ជាង ប៉ុន្តែមានការពាក់ព័ន្ធច្រើនទៅនឹងជីវិតនៅស្រុកខ្មែរ ច្រើនជាងការអភិរក្សប្រពៃណីចិន ។

សមាគមមួយចំនួនទៀត មានទាំងលំនាំបុរាណនិយមផង និងទំនើបនិយមផង ។ សមាគមទាំងនោះរួមមានសមាគមបីនៃក្រុមនិយាយភាសាផ្សេងគ្នា (សមាគមហ៊ុយកន) និងសមាគមសង្គមជួយគ្នា លៀនយូវ ដែលជាក្រុមធំជាងគេនៅមានវត្តមានដល់សព្វថ្ងៃ ។ សមាគមទាំងនោះ ជ្រើសរើសសមាជិកតាមបែបចន្លៀតចន្លល់ និងកក្តីភាពតែមានសកម្មភាព កាន់តែទូលាយ និងមានការចូលរួមផ្ទាល់នៅក្នុងស្ថាប័ននយោបាយនៃសហគមន៍ចិនទាំងមូល ។

ការពិភាក្សាបន្តស្តីពីស្ថាប័នសង្គម មានការទាក់ទងច្រើនជាមួយក្រុងភ្នំពេញ ដោយសារទីនេះជាបេះដូងរបស់សមាគមចិននៅកម្ពុជា ។ ខ្ញុំនឹងពិនិត្យយ៉ាងសង្ខេប ពីស្ថាប័នសង្គមរបស់ប្រជុំតូចៗនៅផ្នែកបន្ទាប់នៃជំពូកនេះ ។

## សមាគមស្ម័គ្រចិត្ត

សមាគមភាសាមានឥទ្ធិពលខ្លាំងណាស់ នៅក្រោមប្រព័ន្ធសហគមន៍ជាតិពន្ធុ ដោយសារសមាគមទាំងនេះអាចរារាំងដល់ការបង្កើតសមាគមភាសាដ៏ទៃទៀត ។ (វ៉ីលម៉ុត ១៩៦៤ ទំ.២៥៦-៨) ។ នៅក្នុងស្ថានភាពបច្ចុប្បន្នសមាគមទាំងនោះមិនមានឥទ្ធិពលបែបនោះទៀតទេ ហើយសារៈសំខាន់នៃក្រុមនិយាយភាសាចិនទាជីវ និងកាតាំងក៏បានធ្លាក់ចុះ ។ សមាគមរបស់ចិនកាតាំងត្រូវរលាយទាំងស្រុង ក្នុងពេលដែលសមាគមរបស់ចិនទាជីវសព្វថ្ងៃមិនមានអ្វីក្រៅពីគណៈកម្មាធិការកិត្តិយសរបស់អ្នកជំនួញ ដែលគ្រប់គ្រងវិហារចិនទាជីវនោះទេ ។ ប៉ុន្តែនៅក្នុង ចំណោមក្រុមចិនហៃណាំ ចិនខែ និងចិនហុកកៀន សមាគមហ៊ុយកន នៅតែជាសមាគមដែលមានឥទ្ធិពលដដែលដែលសកម្មភាពរបស់សមាគមនេះ មិនត្រឹមតែមើលថែវិហារ និងបញ្ចុះសពប៉ុណ្ណោះទេ តែរួមបញ្ចូលទាំងការ

គ្រប់គ្រងសាលារៀន គ្រប់គ្រងអន្តរជំនួយ និងដោះស្រាយជម្លោះរវាងសមាជិកទៀតផង ។

សមាគមត្រកូល បានវិវឌ្ឍន៍នៅក្នុងក្រុមចិនទាជីវចាប់តាំងពីឆ្នាំ ១៩៥៩ មកម៉្លេះ គឺនៅពេលដែលសាលាក្រុងភ្នំពេញបញ្ជាឲ្យឈូសម៉ុង (ផ្លូវខ្មោច) ចិនបួនកន្លែងចេញ សម្រាប់សាងសង់ផ្លូវពង្រីកក្រុង ។ ការមិនពេញចិត្តជាមួយគម្រោងការរបស់គណៈកម្មាធិការរៀបចំសពទាជីវ ក្នុងការរៀបចំអដ្ឋិធាតុ ដែលគ្មានអត្តសញ្ញាណនៅក្នុងផ្នូររួម បានបណ្តាលឲ្យក្រុមពាណិជ្ជករ ដែលមានត្រកូលដូចគ្នា សាងផ្នូរសែស្រឡាយរបស់ពួកគេ ។ ការគាំទ្រចំពោះសកម្មភាពបែបនេះ បានបង្កើតឲ្យមានសមាគមសែស្រឡាយបន្ថមកទៀត ដែលរហូតមកដល់ឆ្នាំ ១៩៦៣ មានឈ្មោះត្រកូលចំនួនប្រាំបី ដែលគេប្រើជារឿយៗនៅទីក្រុងភ្នំពេញ ។[៣] សមាគមទាំងនេះ តែងតែប្រារព្ធពិធីបុណ្យនៅកន្លែងផ្នូរសែស្រឡាយរបស់ពួកគេ ក្នុងពេលវេលាសមគួរណាមួយ (ជាទូទៅត្រូវបានគេស្គាល់ថាពិធីបុណ្យឆេងម៉េង) ឬក៏ពិធីរៀបចំជប់លៀងប្រចាំឆ្នាំ និងជ្រើសរើសមន្ត្រីណា ដែលដើរតួនាទីជួយសង្គ្រោះ និងសម្រុះសម្រួលដល់សមាជិកទាំងឡាយ ។

សមាគម ផ្តោតទៅលើឈ្មោះតំបន់ មានតែក្នុងចំណោមពួកចិនកាតាំងទេ[៤] សមាគមបែបនេះមានចំនួន ១៥ ដែលចុះឈ្មោះទទួលសមាជិករបស់ពួកគេ ពីក្នុងចំណោមចិនកាតាំង ដោយឈរលើប្រភពកំណើតដើមជាសៀន ឬក៏សៀង ។ ពួកគេមានភារៈរៀបចំបញ្ចុះសព និងថែមទាំង ហើយដើរតួជាអ្នកថែរក្សាសុខុមាលភាព និងផ្សះផ្សារនៅក្នុងចំណោមសមាជិករបស់ពួកគេ[៥] ដូចសមាគមត្រកូលដែរ ពួកគេទទួលរ៉ាប់រងរៀបចំបុណ្យសព រៀបចំពិធីជប់លៀង ប្រចាំឆ្នាំ និងជ្រើសរើសមន្ត្រី ។ មានតែសមាគមមួយនេះទេ ដែលមានទីតាំងនៅក្នុងសង្គមចំណែកសមាគមផ្សេងទៀត រៀបចំសកម្មភាពរបស់ខ្លួននៅក្នុងវង្វង់ពាណិជ្ជកម្ម នៃមន្ត្រីរបស់ពួកគេតាមរបៀបផ្ទាល់គ្នា ។[៦]

រហូតដល់ទីអវសាននៃប្រព័ន្ធសហគមន៍ជាតិពន្ធុ ក្រុមភាសានីមួយៗរក្សាទីកប់សពមួយនៅជិតទីក្រុងភ្នំពេញ ដែលគ្រប់គ្រងដោយអនុគណៈកម្មាធិការរបស់សមាគមនីមួយៗ ។ សព្វថ្ងៃ ទីកប់សពធំៗចំនួនពីរដំណើរការនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការ ដែលមានស្វ័យភាពផ្ទាល់ខ្លួន និងដំណើរការដោយខ្លួនឯងបាន ដូច្នេះហើយ គេអាចចាត់ទុកគណៈកម្មាធិការនោះថា ជាសមាគមអ្នកស្ម័គ្រចិត្តបែបប្រពៃណីផងដែរ ។ គណៈកម្មាធិការនេះមានភារៈដឹកជញ្ជូន និងរៀបចំសកម្មភាពបុណ្យទានសំខាន់ៗរបស់ចិន មានដូចជាបុណ្យឆេងម៉េង ឬបុណ្យធុងយ៉ាងរបស់ចិនកាតាំង ។

សព្វថ្ងៃនេះ សមាគមដែលមានសារៈសំខាន់ជាងគេ គឺក្លឹបកីឡា (ធីអ៊ីហ៊្វួយ) ដែលកាលឆ្នាំ ១៩៦២ មានចំនួន ៣១ នៅភ្នំពេញ ។ ក្នុងចំណោមសមាគមទាំងអស់នេះ មានសមាគមពីរត្រូវបានបង្កើតចាប់តាំងពីឆ្នាំ ១៩៥៦ ហើយចំនួនសមាជិកមានចាប់ពីចំនួន ៥០ ទៅ ៣០០ នាក់ ។ បើទោះបីជាសកម្មភាពកីឡាទាំងនេះ ស្ថិតនៅជុំវិញតុកីឡាដ៏សំខាន់របស់ជនជាតិចិន មានដូចជាពីងប៉ុង និងតាពាងបាល់ស្កេត ក៏ក្លិបទាំងនោះមានរួមបញ្ចូលសកម្មភាពផ្សេងៗច្រើនទៀតដូចជា តន្ត្រី ល្ខោន ប្រដាល់ របាំប្រពៃណី អក្សរសាស្ត្រ និងការអប់រំយុវវ័យ ហើយភាគច្រើន សកម្មភាពកីឡាទាំងនោះ នៅតែអាចជួយសម្រួលដល់សុខុមាលភាព នៃសមាជិកពួកគេបានដែរ ។

បើទោះបីជាក្លឹបទីអ៊ីហ៊្វួយ ត្រូវបានគេអះអាងថាជាក្លឹបសម្រាប់យុវជនក៏ដោយ ប៉ុន្តែក្លឹបនេះ ក៏មានការចូលរួមពីសំណាក់មនុស្សចាស់តាមរបៀបផ្សេងៗជាច្រើន ។ អ្នកខ្លះចូលរួមនៅក្នុងក្រុមតន្ត្រី ឬក៏ក្រុមល្ខោន ។ សំខាន់ជាងនេះទៅទៀត ក្លឹបនីមួយៗមានក្រុមប្រឹក្សាភិបាលរបស់អ្នកជំនួញ ដែលចូលរួមចំណែកគាំទ្រដល់ប្រាក់ចំណូល

របស់ក្លឹប ជាមួយការរួមវិភាគទាន ដែលប្រមូលបានពីក្នុងចំណោមសហសេវិករបស់ពួកគេ ។ ក្លឹបកីឡាមួយចំនួនទទួលបានការជួយគាំទ្រពីក្រុមបែបនេះមានដូចជាកាសែត និងសមាគមសកម្មហ៊ុយកន ចំនួនបី ។

ទន្ទឹមនឹងការកើនឡើងនូវក្លឹបកីឡា គេក៏ឃើញមានការកើនឡើង នូវចំនួនសាលារៀនចិនយ៉ាងច្រើន ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះនៅភ្នំពេញដែរ ។[៧] នៅឆ្នាំ ១៩៦២ មានសាលារៀនចិនប្រហែល ២០០ នៅក្នុងប្រទេសកម្ពុជា ដែលប្រហែល ៥០ សាលាស្ថិតនៅទីក្រុងភ្នំពេញ ហើយបើប្រៀបធៀបជាមួយជំនួញផ្សេងទៀត សាលារៀនចិនភាគច្រើននៅភ្នំពេញ ដំណើរការក្រោមរូបភាពរកប្រាក់កម្រៃ ។ ប៉ុន្តែមានសាលារៀនចិនប្រមាណ ១២ ដំណើរការតាមរយៈក្រុមប្រឹក្សាសាលា ហើយសាលាទាំងអស់នេះ ពឹងផ្អែកលើវិភាគទានហិរញ្ញវត្ថុពីក្នុងចំណោមអ្នកគាំទ្រផ្សេងទៀត ។

មន្ទីរពេទ្យចិន បានកើតឡើងនៅភ្នំពេញតាំងពីឆ្នាំ ១៩០៦ មកម្ល៉េះ គឺនៅពេលដែលសមាគមហ៊ុយកនទាំងប្រាំបានរួមគ្នាបង្កើតឡើង ។ នៅមុនពេលបញ្ចប់ប្រព័ន្ធសហគមន៍ជាតិពន្ធុ មន្ទីរពេទ្យនេះ ដំណើរការតាមរយៈក្រុមប្រឹក្សាតំណាងឲ្យសមាគមហ៊ុយកនទាំងប្រាំ ។ នៅឆ្នាំ ១៩៦១ សមាគមមួយ ដែលគេហៅថាគណៈកម្មាធិការមន្ទីរពេទ្យ សម្រាប់ផ្តល់ការព្យាបាលត្រូវបានបង្កើតឡើង ដើម្បីជួយទ្រទ្រង់មន្ទីរពេទ្យ ។ គណៈកម្មាធិការនេះ មានការចូលរួមពីសំណាក់ពាណិជ្ជកររាប់ពាន់នាក់ ដែលជួយបរិច្ចាគប្រាក់ជាប្រចាំ ។ នោះ គឺជាសមាគមពាណិជ្ជករចិនធំបំផុតនៅភ្នំពេញ ។ គណៈកម្មាធិការមន្ទីរពេទ្យ បានជ្រើសរើសសមាជិកក្រុមប្រឹក្សាចំនួន ១៥ នាក់ ដើម្បីគ្រប់គ្រងមន្ទីរពេទ្យដោយផ្ទាល់ ហើយសមិទ្ធផលនៃមន្ទីរពេទ្យនេះ គឺជានិមិត្តរូបនៃការខិតខំប្រឹងប្រែងសហប្រតិបត្តិការដ៏ធំធេងរបស់សមាគមចិនទាំងមូល ។

ក្រៅពីសមាគមរបស់ក្រុមភាសាតូចបី (ភាសាចិនហៃណាំ ភាសាចិនខែ ភាសាចិនហុកកៀន) សមាគមសង្គមជួយគ្នាទៅវិញទៅមក ឈ្មោះលៀនយ៉ូវ ក៏អាចចាត់ថ្នាក់ជាសមាគមមួយ ដែលរួមបញ្ចូលទាំងទិសដៅឆ្ពោះទៅរកបែបប្រពៃណី និងបែបទំនើប ។ នេះប្រហែលជាសមាគមសំខាន់ជាងគេ កើតឡើងនៅពេលប្រព័ន្ធសហគមន៍ជាតិពន្ធុបានបញ្ចប់ ។ សមាគមនេះ បានរីកដុះដាលឡើង ដើម្បីឆ្លើយតបទៅនឹងភាពលំបាកវេទនា របស់គ្រួសារពលករចិនទាដីវ ដែលភាគច្រើនជាជនអន្តោប្រវេសថ្មីៗ មករស់នៅតំបន់អនាធិបតេយ្យ ហើយងាយទទួលរងអគ្គីភ័យក្នុងរដូវប្រាំង ។ ស្ថានភាពរបស់ពួកគេ កាន់តែយ៉ាប់យ៉ឺនឡើងដោយសារច្បាប់អន្តោប្រវេសន៍ឆ្នាំ ១៩៥៦ ដែលដាក់បម្រាមមិនឲ្យជនបរទេសធ្វើការងារ ១៨ ប្រភេទ និងហេតុដែលធ្វើឲ្យពួកគេ ត្រូវប្រឈមនឹងបញ្ហាលំបាកទាំងអស់ជាមួយគ្នា ។ ក្រៅពីការគ្រប់គ្រងសកម្មភាពជួយគ្នាទៅវិញទៅមក សមាគមនេះបានដំណើរការសាលារៀនចំនួនបី ក្លឹបកីឡាចំនួនមួយ និងក្រុមសម្តែងផ្សេងទៀត ។ បើទោះជាសមាជិកភាព មិនត្រូវបានកំហិតដោយក្រុមភាសា ក៏សកម្មភាពរបស់ក្លឹបទាំងនេះ ពាក់ព័ន្ធនឹងសមាជិកជាយុវវ័យរាប់ពាន់នាក់ ដែលភាគច្រើនគឺជាចិនទាដីវ ។

## អត្តសញ្ញាណវប្បធម៌

សមាគមចិននៅក្រុងភ្នំពេញ ត្រូវទទួលខុសត្រូវចំពោះសកម្មភាពធំៗ ដែលធ្វើឲ្យគេ (ចិន) ខុសពីប្រជាជនដទៃទៀតនៅក្នុងទីក្រុង ទាំងការអប់រំ និងពិធីបុណ្យផ្សេងដែលបានបំពេញតួនាទីនេះ ។

មានក្មេងប្រហែលពីរម៉ឺននាក់ បានចូលរៀននៅសាលាចិននៅភ្នំពេញ នេះជាចំនួនច្រើនជាងពាក់កណ្តាលនៃចំនួនជនជាតិចិន ដែលមានអាយុពី ៥ ទៅ១៥ ឆ្នាំ[៨] សាលាទាំងនេះ មានគ្រូចំនួន ២២៥ នាក់ ។ ដោយសារ

មានសំពាធយ៉ាងខ្លាំង ពីព្រោះតែការទទួចចង់បានការអប់រំរបស់ជនជាតិចិនសាលារៀននីមួយៗ តែងមានសិស្សច្រើនហួសចំណុះ រីឯគ្រូវិញ ទទួលបានប្រាក់ខែតិចតួច ហើយគ្រូភាគច្រើននៅក្មេង និងមិនមានការបណ្តុះបណ្តាលត្រឹមត្រូវ ។ នៅសាលាបង្រៀនចិនកុកងឺ[៩] គេប្រើសៀវភៅដែលមានប្រភពដើមនៅហុងកុង និងសិង្ហបុរី ។

ជោគជ័យរបស់សាលា ក្នុងការរក្សាអត្តសញ្ញាណវប្បធម៌ចិន ត្រូវបានបង្ហាញតាមរយៈវិសាលភាពនៃការបង្រៀនភាសាចិនកុកងឺ នៅភ្នំពេញ ។ មនុស្សម្នាទាំងឡាយ តែងតែស្តាប់ឮការសន្ទនាជាភាសាកុកងឺ ពិសេសក្នុងចំណោមយុវជន ហើយនៅក្នុងហាងលក់ដូរ ជួនកាលក៏មានការសន្ទនាជាភាសាចិនកុកងឺដែរ ប៉ុន្តែភាសាទាជីវមានការប្រើញឹកញាប់ជាង ។ ការបង្ហាញមួយទៀត គឺការចេញផ្សាយកាសែតជាភាសាចិន នៅក្នុងទីក្រុង ក្នុងចំណោមការសែតទាំង ១៣ ដែលបោះពុម្ពនៅទីក្រុងភ្នំពេញនាឆ្នាំ ១៩៦២-៣ មានកាសែតជាភាសាចិនចំនួនប្រាំ ហើយមានអ្នកអានប្រហែលប្រាំភាគប្រាំមួយ ។[១០] ខ្ញុំប៉ាន់ស្មានថា ជារៀងរាល់ថ្ងៃ មានយុវជនចិនប្រហែលពាក់កណ្តាលអានកាសែតចិន យ៉ាងហោចណាស់ក៏មួយច្បាប់ដែរ ។ មនុស្សជាច្រើនអានកាសែតបីទៅបួនច្បាប់ក្នុងមួយថ្ងៃ តួយ៉ាងដូចជាមិត្តភក្តិខ្ញុំម្នាក់ ដែលធ្វើការនៅភោជនីយដ្ឋាន គាត់អានកាសែតមួយច្បាប់ ដើម្បីដឹងពីព័ត៌មាន ហើយអានកាសែតពីរច្បាប់ទៀត ដើម្បីតាមដានប្រលោមលោកភាគ ។

ក៏ដូចជាការអប់រំដែរដែលជំនឿសាសនារបស់ជនជាតិចិន បានធ្វើឲ្យសមាគមនៃជនជាតិនេះ មានលក្ខណៈខុសពីប្រជាជនដទៃទៀតនៅក្រុងភ្នំពេញ ។ ប៉ុន្តែនៅក្នុងចំណោមជនជាតិចិននៅកម្ពុជា ជំនឿរបស់ពួកគេភាគច្រើនមានលក្ខណៈជាបុគ្គលនិយម ឬក៏គ្រួសារនិយម[១១] សូម្បីតែនៅរដូវសែនផ្នូរ គឺពេលដែលគ្រួសារ ដែលមានសមាជិកច្រើន នាំគ្នាធ្វើដំណើរទៅកាន់កន្លែងបញ្ចុះសព ដើម្បីបោសសម្អាតផ្នូរ និងធ្វើពិធីសែនក៏ដោយ ក៏ពិធីនោះកើតឡើងក្នុងលក្ខណៈបុគ្គល ឬគ្រួសារដែរ ។ (ជាឧទាហរណ៍) ពិធីឆ្លងវ័យ ដូចជាពិធីបង្កក់កូន និងអាពាហ៍ពិពាហ៍មិនមានការទាក់ទងជាមួយសមាគមណាមួយទេ បើទោះបីពិធីបុណ្យសព តែងមានការពាក់ព័ន្ធជាមួយសមាគមដែលអ្នកស្លាប់ធ្លាប់ជាសមាជិកក៏ដោយ ។ នៅពេលមានពីធីបុណ្យសំពះព្រះខែចិន រោងទេវតាត្រូវបានគេដាក់នៅមុខតូបចិន ហើយក្រុមគ្រួសារនីមួយៗ ប្រារព្ធពិធីនេះរៀងៗខ្លួន ដោយដាក់រោងទេវតាលម្អដោយពន្លឺនៅរានហាល ឬក៏នៅជិតបង្អួច ។ ពិធីបុណ្យភាគច្រើន មិនមានលក្ខណៈជាសាធារណៈ ខ្លាំងដូចពិធីបុណ្យនេះទេ ។

លើកលែងតែពិធីបុណ្យចូលឆ្នាំចិន មួយគត់ ដែលមិនឆ្លុះបញ្ចាំងពីលក្ខណៈគ្រួសារនិយម របស់ជនជាតិចិន ។ ពិធីបុណ្យចូលឆ្នាំចិន មានការដង្ហែរក្បួនតាមផ្លូវចំនួនពីរថ្ងៃ ដែលធ្វើឲ្យស្ទះចរាចរណ៍ និងទាក់ទាញអ្នកទស្សនាបានយ៉ាងច្រើន នៅក្នុងពេលនេះ គ្រប់សមាគម និងក្លឹបទាំងអស់ មានដូចជា ក្លឹបកីឡាក្រុមម៉ុងសាយក្លឹបតន្ត្រី ។ល។ សុទ្ធតែបានចូលរួម ។

បីល្ងាចមុនពេលដង្ហែរក្បួន គេសម្តែងល្ខោនចិននៅមុខវិហារចិន ។ នៅក្នុងក្បួនដង្ហែរ គេឃើញមានក្បួនដង្ហែរ ៨០ មកពីវិហារផ្សេងៗ ដែលភាគច្រើនមានក្បួនហែរអ្នកតាផង ហែរកាត់តាមគ្រប់ផ្លូវពាណិជ្ជកម្មធំៗ ភាគច្រើន ក្បួនហែរទាំងនេះ ជាក្បួនហែរអ្នកតារបស់ជនជាតិយួន ប៉ុន្តែការហែរទាំងនេះ ត្រូវបានកំណត់យ៉ាងច្បាស់ថា ជាព្រឹត្តិការណ៍របស់ជនជាតិចិន ។ មិនមានជនជាតិយួនណាម្នាក់មានជាប់ពាក់ព័ន្ធ និងការរៀបចំគណៈកម្មាធិការដែលសម្រាំងចេញពីសមាគមចិនផ្សេងៗទេ ។ គណៈកម្មាធិការនេះ ស្នើសុំការអនុញ្ញាតពីអាជ្ញាធរក្រុង ដើម្បីប្រារព្ធពិធីដង្ហែរក្បួនផ្សេងៗបើកផ្លូវសម្រាប់ហែរក្បួន និងផ្តល់ជាបដាធំនៅខាងមុខក្បួនដង្ហែរ ។ ពិធីបុណ្យចូលឆ្នាំចិន គឺជាព្រឹត្តិការណ៍បុណ្យធំជាងគេ របស់សហគមន៍ចិនទាំងមូល ។

## របងាសម្ព័ន្ធនយោបាយ

ស្ដែងចេញពីការពិភាក្សារបស់ខ្ញុំ ស្ដីអំពីឋានៈរបស់ជនជាតិចិននៅក្នុងសង្គមកម្ពុជា គេអាចនិយាយថា សហគមន៍ចិនមិនបានគ្រប់គ្រងរាល់ទិដ្ឋភាពជីវិតសង្គម របស់ជនជាតិចិនឡើយ តែទោះយ៉ាងណាក៏ដោយ ក៏ជាការសំខាន់ណាស់ក្នុងការស្វែងយល់ពីរចនាសម្ព័ន្ធនយោបាយ នៅក្នុងសហគមន៍ចិន ។ សម្រាប់អ្វីដែលជាផលប្រយោជន៍ ពួកគេត្រូវតែប្រមូលផ្ដុំគ្នា ហើយការបង្កើតគោលនយោបាយ និងការអនុវត្តត្រូវឈរលើបញ្ហាដែលពាក់ព័ន្ធទៅនឹងសហគមន៍ចិនទាំងមូល ។ តាមការពិនិត្យរបស់ខ្ញុំ សមាគមស្ម័គ្រចិត្តជាអ្នករៀបចំរចនាសម្ព័ន្ធនេះ ដែលមិនខុសអ្វីពីសហគមន៍ចិន នៅក្រៅប្រទេសដទៃទៀតឡើយ ។

សមាគមផ្សេងទៀត មានអន្តរទាក់ទងគ្នាតាមរយៈបណ្ដាញចាក់ស្រេះមួយ នៃបណ្ដាមន្ត្រី (សមាគម) ដូចគ្នាច្រើនទៅនឹងអ្វីដែល ស្គីននឺរ បានសង្កេតឃើញនៅទីក្រុងបាងកក (ស្គីននឺរ ១៩៥៨ទំ.២០០-២២៦)។ ពាណិជ្ជករចិនតែងតែធ្វើការជាមួយនឹងសមាគមលើសពីមួយ ដើម្បីផ្ដល់ជាផ្លូវទំនាក់ទំនង និងឥទ្ធិពល ។ ដូច្នេះគេអាចនិយាយពីរចនាសម្ព័ន្ធសមាគមមួយ ដែលក្នុងនោះ សមាគមទាំងឡាយមានចំណងទាក់ទងជាមួយគ្នា ហើយក្នុងសមាគមនីមួយៗអាចរៀបចំតាមឋានានុក្រម អាស្រ័យទៅតាមអំណាចមេដឹកនាំរបស់ពួកគេ ។[១២]

ថ្នាក់កំពូលនៃរចនាសម្ព័ន្ធសមាគមនេះ គឺក្រុមប្រឹក្សាមន្ទីរពេទ្យចិន ដែលសមាជិកទាំង ១៥ រូប គឺជាមនុស្សមានឥទ្ធិពល នៅក្នុងចំណោមក្រុមភាសាទាំងប្រាំ ហើយពួកគេក៏បានចូលរួមជាមួយមេដឹកនាំ ក្នុងសមាគមផ្សេងទៀត ដែលយ៉ាងហោចណាស់ក៏ ២០ សមាគម (ឬក៏ប្រហែលជាលើសនេះទ្វេដង) រួមមានដូចជា សមាគមសង្គមលៀនយ៉ូវ សាលាធំៗ ក្លឹបកីឡាធំៗ និងសមាគមហ៊ុយកនទាំងអស់ ។ ក្នុងឋានៈជាតំណាងឲ្យសហគមន៍ចិនទាំងមូលមេដឹកនាំទាំងនេះ ដើរតួជាអ្នករៀបចំបដិសណ្ឋារកិច្ច មន្ត្រីជាន់ខ្ពស់ ដែលអញ្ជើញមកពីប្រទេសចិន និងធ្វើជាតំណាងនៅចំពោះមុខអាជ្ញាធរ នៃរាជរដ្ឋាភិបាលកម្ពុជា ។ ពួកគេសកម្មក្នុងការរៀបចំពិធីបុណ្យចូលឆ្នាំចិន ហើយពួកគេ ក៏បម្រើតួនាទីជាមជ្ឈមណ្ឌលទាក់ទង និងផ្ដល់ការណែនាំសម្រាប់សមាគមចិនទាំងអស់ ។ ក្នុងចំណោមពួកគេ ខ្ញុំមិនអាចញែកឲ្យដាច់ថា នរណាម្នាក់ជាមេដឹកនាំធំជាងគេបានទេ ។

ឧទាហរណ៍ពីភាពជុនជាបមួយ ស្ដីពីប្រតិបត្តិការរបស់រចនាសម្ព័ន្ធនយោបាយនេះ នៅពេលដែលខ្ញុំកំពុងនៅភ្នំពេញ គឺចំពេលដែលមានទស្សនកិច្ចរបស់ប្រធានាធិបតី លី សាវជី មកប្រទេសកម្ពុជា ។ គេផ្ដល់ព័ត៌មានតិចតួចណាស់ពីដំណើរទស្សនកិច្ចនេះ ពីព្រោះអាជ្ញាធរកម្ពុជា មានការព្រួយបារម្ភណ៍ពីសុវត្ថិភាពរបស់ភ្ញៀវ ។ ដូច្នេះសមាគមចិនមានពេលវេលាតិចជាង ៥ ថ្ងៃ ដើម្បីរៀបចំពិធីស្វាគមន៍ ។ នៅពេលនោះ គណៈកម្មាធិការទូទៅមួយត្រូវបានបង្កើតឡើង ជាមួយអនុគណៈកម្មាធិការ មានភារៈរៀបចំចុះឈ្មោះគណៈប្រតិភូ ផ្សព្វផ្សាយ ហិរញ្ញវត្ថុ និងធ្វើសហប្រតិបត្តិការជាមួយរាជការ ។ល។ នៅពេលដែលប្រធានាធិបតី លី សាវជី បានមកដល់ផ្លូវនានានៅក្នុងទីក្រុងភ្នំពេញត្រូវឈរហែរហម និងស្រែកស្វាគមន៍ ដោយជនជាតិចិន ដែលអ្នកទាំងអស់នោះ ភាគច្រើនត្រូវបានចែកជាក្រុមតាមសមាគមរបស់ពួកគេ ហើយឲ្យឈរនៅតាមកន្លែង ដែលគណៈកម្មាធិការបានរៀបចំរួចជាស្រេច ។ ពួកគេកាន់ទង់ជាតិពណ៌ ហើយអ្នកខ្លះទៀតកាន់បដា ពាក្យស្លោក ដែលរៀបចំដោយគណៈកម្មាធិការ ។ ប្រការសំខាន់នោះ គឺថា គណៈកម្មាធិការរៀបចំព្រឹត្តិការណ៍នេះសុទ្ធមានរួមបញ្ចូលសមាជិកមន្ទីរពេទ្យ ១៤ ឬ ១៥ នាក់ ដែលភាគច្រើនកាន់តំណែងកំពូល ។

## ស្ថាប័នសង្គមរបស់ជនជាតិនៅតាមទីក្រុងតូចៗ

សមាគមចិននៅបាត់ដំបង កំពង់ចាម និងកំពត ដែលមានចំនួនលើសពី ២០.០០០ បានបង្ហាញពីរចនាសម្ព័ន្ធសង្គមស្រដៀង នឹងក្រុងភ្នំពេញ បើទោះជាមានទ្រព្យធនតូចក៏ដោយ ប៉ុន្តែសមាគមចិននៅតាមទីក្រុងតូច បានប្រឈមមុខជាមួយបញ្ហាផ្សេងៗ ខុសពីបញ្ហាដែលសមាគមធំៗបានប្រឈម ។ ជនជាតិចិនដែលនៅតាមទីប្រជុំជនតូចៗមានចំណងទាក់ទងល្អ ជាមួយប្រជាជនខ្មែរជាងជនជាតិចិននៅទីក្រុង នេះក៏ដោយសារតែអតិថិជនរបស់ពួកគេភាគច្រើនជាជនជាតិខ្មែរ ហើយពួកគេភាគច្រើន មានការទាក់ទងកាន់តែល្អជាមួយមន្ត្រីស៊ីវិលខ្មែរ ។ លើសពីនេះទៅទៀត ជនជាតិចិននៅក្នុងទីប្រជុំជនតូចៗ តែងតែមានក្រុមភាសាមួយរួមគ្នា ។ នៅក្នុងលក្ខខណ្ឌបែបនេះ សហគមន៍ចិនមានសាមគ្គីភាព ជាងសហគមន៍នៅភ្នំពេញ ។

ដូចដែលគេប៉ាន់ស្មាន ចំនួនសមាគមចិននៅតាមទីប្រជុំជនតូចៗ នៅមានកំណត់ ។ នៅក្នុងសហគមន៍ដែលមានជនជាតិចិនរាប់ពាន់នាក់ គេតែងតែរកឃើញសាលារៀនចិន និងក្លឹបកីឡាមួយ ឬពីរ ។ សមាគមទាំងនេះពឹងផ្អែកលើក្រុមមេដឹកនាំមួយចំនួនតូច ដែលគ្រប់គ្រងអន្តរជំនួយ និងដោះស្រាយបញ្ហាជំនួយផងដែរ មេដឹកនាំទាំងនេះ ធ្វើការងារតាមរយៈក្រុមប្រឹក្សាសាលា ដែលបម្រើជានីតិប្រតិបត្តិ សម្រាប់សហគមន៍ចិនទាំងមូល ។ នៅក្នុងក្រុងភាគច្រើន មេដឹកនាំកំពូលអាចញែកបានយ៉ាងងាយ ដោយសារតែពួកគាត់ត្រូវបានជនជាតិទាំងអស់ទទួលស្គាល់ ។ គាត់ដើរតួនាទីជាយានដ៏សំខាន់ សម្រួលដល់ការទាក់ទងរវាងជនជាតិចិន និងរដ្ឋបាលក្នុងស្រុក ។ ពីព្រោះតែមានទ្រព្យធនតូច និងឯកលក្ខណៈហើយ សហគមន៍នៅតាមក្រុងតូចៗ អាចពឹងផ្អែកលើទំនាក់ទំនងក្រៅផ្លូវការ ច្រើនជាងសហគមន៍នៅភ្នំពេញ ។

ចំណងទាក់ទងរវាងមេដឹកនាំចិននៅក្នុងសហគមន៍ នៃទីប្រជុំជនតូចៗជាមួយនឹងរចនាសម្ព័ន្ធនយោបាយចិន នៅទីក្រុងភ្នំពេញ ទំនងអាស្រ័យជាចម្បងលើការទាក់ទងសេដ្ឋកិច្ចរវាងក្រុមហ៊ុនផ្សេងៗ ។ ការទាក់ទងរវាងស្ថាប័ននឹងស្ថាប័ននោះ មិនទាន់មានលក្ខណៈច្បាស់លាស់ទេ ។

## សន្និដ្ឋាន

នៅពេលនេះបើទោះជាការសិក្សារបស់ខ្ញុំ ពីស្ថាប័នសង្គមរបស់ជនជាតិចិន ហាក់មានភាពប្រញាប់ប្រញាលក៏ដោយ ក៏ការសិក្សានេះបានបង្ហាញថា គេមិនអាចសង្កេតឃើញមានជនជាតិចិននៅកម្ពុជាប្រមូលផ្តុំគ្នា រវាងបុគ្គលទាំងឡាយនោះទេ ។ សហគមន៍ជនជាតិ គឺជាស្ថាប័នដែលកំណត់ និងដឹកនាំសកម្មភាពប្រព្រឹត្តទៅរបស់បុគ្គលនីមួយៗ ក្នុងកាលៈទេសៈផ្សេងៗ ។ បេះដូងនៃស្ថាប័ននេះ គឺជារចនាសម្ព័ននយោបាយ ដែលមានបណ្តាញមួយរួបរួមសមាគមន៍ស្ម័គ្រចិត្តដ៏ច្រើន បើទោះជាតួនាទីនៃសមាគមនីមួយៗ អាចមានដែនកំណត់ក៏ដោយ ក៏សមាគមន៍ទាំងនេះ បានភ្ជាប់ការទាក់ទងគ្នាតាមរយៈសមាជិកធ្វើការ ដើម្បីជាមធ្យោបាយក្នុងការទាក់ទង និងគ្រប់គ្រង ពេញសហគមន៍ចិនទាំងមូល ។

គំនិតដើមរបស់ ហ្វ៊ីនីវល ស្តីពីសង្គមចម្រុះជាតិសាសន៍ បានច្រានចោលគំនិតដែលថា ក្រុមជនជាតិនីមួយៗបង្ហាញនូវរចនាសម្ព័ន្ធសង្គមមួយ ។ គាត់បានពិពណ៌នាអំពីសង្គមមួយ ដែលបុគ្គលនីមួយៗ មិនមានភក្តីភាពចំពោះក្រឹត្យក្រុមសហគមន៍ ដែលអាចធ្វើឲ្យខាតផលប្រយោជន៍សេដ្ឋកិច្ចផ្ទាល់របស់ពួកគេ នេះក៏ដោយសារតែមានការបែងចែកក្រុមជាតិសាសន៍ ហើយរាល់ការទាក់ទងទាំងអស់ គឺជាផ្នែកសេដ្ឋកិច្ច ។ ប្រសិនបើមាននរណាម្នាក់បង្ហាញ

*អំពីគំនិតដែលថា ជនជាតិនីមួយៗបានរៀបចំផ្ទៃក្នុងរបស់ខ្លួន ដោយមានរចនាសម្ព័ន្ធនយោបាយឋានានុក្រមវណ្ណៈ និងបង្ហាញពីសាមគ្គីភាពនោះ ទស្សនៈសង្គមចម្រុះជាតិសាសន៍ អាចត្រូវគេកែលម្អតម្រូវឡើងវិញ ដើម្បីយកមកអនុវត្តន៍ឲ្យបានត្រឹមត្រូវ នៅក្នុងស្ថានភាពតំបន់អាស៊ីអាគ្នេយ៍ ។ ឥឡូវនេះ កិច្ចការដែលយើងត្រូវធ្វើ គឺងាកទៅកែលម្អទ្រឹស្តីនេះឡើងវិញ ៕*

# ជំពូកទី ៤

## ការលេចឡើង និងការរួបរួមនៃក្រុមវរជន

*ដោយ វីល្លៀម. អ៊ី. វីលម៉ូតត៍*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* “Emerging and Merging Elites in Cambodia” ។

*អត្ថបទនេះ ដកស្រង់ចេញពីសៀវភៅ ៖* **ជនជាតិចិននៅកម្ពុជា** ។

*រក្សាសិទ្ធិ គ.ស. ១៩៦៧ ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យប្រ៊ីធីសកូឡុំបៀ ។*

# CHAPTER 4:

## Emerging and Merging Elites in Cambodia

William E. Willmott

(*The Chinese in Cambodia*)

**Copyright © 1967 by University of British Columbia**

បកប្រែដោយ វង់ សុធារ៉ា

# ជំពូកទី ៤
# ការលេចឡើង និងការរួបរួមនៃក្រុមទាវជន

*ក្នុងអត្ថបទជាច្រើន ខ្ញុំបានលើកយកនូវគំនិតដែលយល់ឃើញថា «គេអាចនិយាយបានយ៉ាងសាមញ្ញថា ប្រទេសកម្ពុជា ជាសង្គមចម្រុះមួយ» មកជជែកវែកញែក ដោយផ្អែកលើនិយមន័យកាន់តែលម្អិតជាងនេះ ។ ជនជាតិចិន មិនត្រឹមតែបង្កើតសហគមន៍ជាតិពន្ធុមួយ ដាច់ដោយឡែកប៉ុណ្ណោះទេ គេថែមទាំងបានបង្កើតយ៉ាងឆាប់រហ័ស នូវវណ្ណៈសេដ្ឋកិច្ចមួយ គឺវណ្ណៈឈ្មួញកណ្ដាល ។ តាំងពីមុនសម័យអាណានិគមបារាំងមកម៉្លេះ ដែលជនចិនបានក្លាយទៅជាឈ្មួញកណ្ដាល នៅចន្លោះពួកកសិករ និង ពួកអភិជនរួចជាស្រេចទៅហើយ ពោល គឺពួកគេជាអ្នកដួលដីស្រែពីស្ដេច ជាអ្នកប្រមូលពន្ធដារថ្វាយស្ដេច និងជាអ្នករៀបចំធ្វើពាណិជ្ជកម្មស្រូវ និងត្រីសាច់ផ្សេងៗ ដោយបានធ្វើឲ្យរាជវាំងទទួលបាននូវប្រាក់ចំណូលយ៉ាងក្រាស់ក្រែល ។ ក្នុងសម័យអាណានិគមបារាំង ពួកគេនៅតែជាឈ្មួញកណ្ដាលដដែល ហើយសព្វថ្ងៃនេះពួកគេថែមទាំងមានឥទ្ធិពលគ្របដណ្ដប់លើបណ្ដាអ្នកជំនួញ និងឧស្សាហករណ៍តូចតាចទាំងឡាយ នៅទូទាំងប្រទេសទៀតផង ។*

*បញ្ញត្តិនៃពាក្យសង្គមចម្រុះ មានសារៈសំខាន់ណាស់ចំពោះការវិភាគបែបសង្គមវិទ្យា នៅពេលដែលការវិភាគនេះ ផ្ដោតការចាប់អារម្មណ៍កាន់តែច្រើនឡើង ទៅលើការទាក់ទង ឬការប្រាស្រ័យទាក់ទងគ្នារវាងក្រុមជាតិពន្ធុនានានោះ ប៉ុន្តែលោក ហ្វឺនីវ៉ល មិនទាន់ទទួលយកការយល់ឃើញ បែបនេះបានទាំងស្រុងនៅឡើយទេ ។ ក្នុងជំពូកចុងក្រោយនេះ មានការពិភាក្សាលើទិដ្ឋភាពពីរនៃទំនាក់ទំនងជាតិពន្ធុ គឺហេតុផល និងកត្តាដែលជំរុញឲ្យជនជាតិចិន ចាប់អារម្មណ៍ទៅលើការធ្វើជំនួញ និងការលេចឡើងនៃស្រទាប់វរជនចិនកាត់ខ្មែរនៅក្នុងស្រទាប់កំពូល នៃរចនាសម្ព័ន្ធឋានៈសង្គមរបស់កម្ពុជា ។ ជំពូកនេះនឹងបញ្ចប់ដោយធ្វើការពិភាក្សាលើឥទ្ធិពលនៃរចនាសម្ព័ន្ធសង្គម ទៅលើគោលនយោបាយ និងស្ថិរភាពរបស់រដ្ឋាភិបាលកម្ពុជា ដែលអាចជាទុនមួយ សម្រាប់ការវិភាគបែបសង្គមវិទ្យា ក្នុងការប្រើប្រាស់បញ្ញត្តិ សង្គមចម្រុះ ។*

## ចំណាប់អារម្មណ៍របស់ជនជាតិចិនក្នុងការធ្វើពាណិជ្ជកម្ម

*នៅក្នុងសេចក្ដីផ្ដើម ខ្ញុំបាននិយាយថា សហគមន៍ជនជាតិចិននៅកម្ពុជា ចាប់កំណើតជាមួយនឹងដំណើរចេះតែកើនឡើង នៃការធ្វើពាណិជ្ជកម្មក្រៅប្រទេស ក្នុងកំឡុងសតវត្សរ៍ទី ១៥ ។ ចាប់តាំងពីពេលនោះមក ជនជាតិចិនបានក្ដោបក្ដាប់ នូវរាល់សកម្មភាពពាណិជ្ជកម្មស្ទើរតែទាំងអស់ ហើយប្រការដែលគ្មានកសិករជាតិចិន និងមានវត្តមានកម្មករជាតិចិនដ៏តិចតួចបំផុតនៅកម្ពុជា ក៏ដូចជាការដែលគ្មាននូវស្រទាប់អ្នកជំនួញជនជាតិខ្មែរ គឺទាមទារឲ្យមានការពិនិត្យពិចារណារកហេតុផល ។*

*ក្នុងសៀវភៅមួយរបស់លោកអាលីវស៍ និយាយថា ពួកចិនចូលមកកាន់អាស៊ីអាគ្នេយ៍តាមរបៀបពីរប្រភេទខុសពីគ្នា ÷ ១)-នៅក្នុងតំបន់ដែលមានប្រជាជនប្រកបរបរកសិកម្មច្រើន (ឧទាហរណ៍ដូចជាកោះជ្វា) ជនជាតិចិនបានចូលទៅកាន់តំបន់នោះ ក្នុងឋានៈជាអ្នកជំនួញ ពីព្រោះតែពួកគេគ្មានដីធ្លីសម្រាប់ធ្វើកសិកម្ម ។ ២)-ប៉ុន្តែនៅ*

ក្នុងតំបន់ដែលមិនសូវមានប្រជាជនច្រើន (កោះបរ័ណេអូ ម៉ាឡាយ៉ា) ជនជាតិចិនតាំងលំនៅលើតំបន់ទាំងនោះក្នុងឋានៈជាអ្នកស្រែចម្ការ និងអ្នកជីករ៉ែ ។ របៀបតាំងលំនៅទាំងពីរបែបនេះ គេឃើញកើតមាននៅក្នុងប្រទេសកម្ពុជា ។[១] នៅតំបន់ជម្រកស្រូវនៃអាងទន្លេសាប និងទន្លេមេគង្គ ជនជាតិចិនបានបោះទីតាំងរស់នៅក្នុងជីវភាពជាអ្នកលក់ដូរ និងអ្នកចងការប្រាក់ ដោយប្រមូលផ្ដុំគ្នាជាពិសេសនៅភ្នំពេញ ។ នៅតំបន់មិនសូវសម្បូរមនុស្សដូចជាខេត្តកំពត ដែលមានសណ្ឋានដីខ្ពស់ផុតពីទឹកជំនន់ ជនជាតិចិនតាំងទីលំនៅក្នុងតំបន់ជនបទ ដើម្បីដាំដំណាំម្រេច ។

លក្ខណៈសម្បត្តិសេដ្ឋកិច្ចសំខាន់បំផុតរបស់ «កសិករ» ចិននៅកម្ពុជា គឺការរស់នៅក្នុងការដាំដុះធញ្ញជាតិសម្រាប់លក់ ជាពិសេសសម្រាប់ទីផ្សារ ដើម្បីយកលុយមកទិញអាហារប្រចាំថ្ងៃ ។[២] ក្នុងន័យម្យ៉ាងទៀត សូម្បីតែចិននៅស្រុកស្រែចម្ការ ក៏ត្រូវភ្ជាប់ខ្លួននឹងរបរដួញដូរដែរ ដែលជាការខុសគ្នាឆ្ងាយ ពីកសិករជនជាតិដើមក្នុងស្រុក ឬកសិករចិននៅក្នុងប្រទេសចិន ព្រោះពួកគេដាំដំណាំ ដើម្បីតែផ្គត់ផ្គង់ជីវភាពគ្រួសារ និងយ៉ាងច្រើនគេមានគោលដៅទីពីរ គឺដើម្បីទិញរបស់ចាំបាច់នានាសម្រាប់ជីវភាពប៉ុណ្ណោះ ។ (នៅកម្ពុជា មានតែជនជាតិចិន ដែលក្លាយជាអ្នកធ្វើស្រែនៅខេត្តបាត់ដំបងប៉ុណ្ណោះ ដែលបង្ហាញនូវការដាក់ចិត្តកាយធ្វើខ្លួនជាប្រជាជាតិខ្មែរ សម្របខ្លួនតាមមជ្ឈដ្ឋានដែលពួកគេរស់នៅ) ។ និយាយឲ្យងាយស្ដាប់ទៅគឺថា គ្មានកសិករសង្គមចម្រុះនៅក្នុងកម្ពុជាទេ ។[៣]

គំនិតដែលថា សន្តិភាពក្នុងសង្គមចម្រុះរបស់កម្ពុជា ពឹងផ្អែកលើវត្តមានរបស់មហាអំណាចអាណានិគមបារាំង ត្រូវលោកបណ្ឌិត ម៉ូរីស ហេប្ប លើកឡើងមុនលោក ហ្វីនីវ៉ែលទៅទៀត ។ ក្នុងស្នាដៃរបស់គាត់នៅឆ្នាំ ១៩២៨ លោក ហេប្ប បានលើកឡើងថា បើទុកជាពួកគេមានអរិយធម៌ខ្ពង់ខ្ពស់ក៏ដោយ ក៏ពួកជនជាតិចិនមានសារៈប្រយោជន៍ណាស់ នៅក្នុងរបបអាណានិគម ដរាបណារដ្ឋបាលអាណានិគមដាក់ការត្រួតពិនិត្យលើពួកគេដោយតត់មត់ (ហេប្ប ទំ. ២៥១) ប៉ុន្តែថា ទាំងលោក ហេប្ប និងទាំងលោក ហ្វីនីវ៉ែល បានពន្យល់ចំណុចនេះមិនបានច្បាស់លាស់ដូចគ្នា ដោយសារកត្តាដែលថា សង្គមចម្រុះនៅកម្ពុជា បានកើតមានយ៉ាងហោចណាស់ពីរសតវត្សរ៍ មុនការមកដល់របស់បារាំង ហើយយើងមិនដែលឃើញមានអំពើហិង្សា ឬទាំងព្រឹត្តិការណ៍មិនល្អណាមួយកើតឡើងឡើយ[៤] ច្បាស់ណាស់ គេត្រូវតែរកឲ្យឃើញ នូវការពន្យល់កាន់តែល្អ ពីសារជាតិនៃសាមគ្គីភាពក្នុងសង្គមចម្រុះ។

ខ្ញុំបានលើកឡើងថា ការពន្យល់មួយផ្នែក គឺផ្អែកលើរចនាសម្ព័ន្ធសង្គម នៃបំណែកជាតិពន្ធុនីមួយៗក្នុងសង្គមចម្រុះ កត្តាសំខាន់មួយទៀត គឺទំនាក់ទំនងសេដ្ឋកិច្ច ដែលពួកគេផ្ទាល់ជាប់ជំពាក់ជាមួយសហគមន៍ជាតិពន្ធុខុសៗពីគ្នា ។ ទោះបីការពិតថា សង្គមចម្រុះអាចខ្វះនូវការរួមចំណែកខាង «ឆន្ទៈសង្គម» ដូចដែលលោក ហ្វីនីវ៉ែលបានលើកឡើង ក៏សារជាតិនៃចំណងសេដ្ឋកិច្ច រវាងពួកពាណិជ្ជករជាតិចិន និងកសិករខ្មែរ ទាមទារឲ្យមាននិរន្តរភាព និងការពន្យល់បន្ថែម ក្នុងន័យដើម្បីផលប្រយោជន៍ទាំងសងខាង ។ បើគ្មានពាណិជ្ជករទេ កសិករក៏គ្មានប្រភពធនធានជាផលិតផលផ្សេងៗពីរោងចក្រ ដែលជាតម្រូវការចាំបាច់ដែរ ហើយបើគ្មានកសិករទេ អ្នកជំនួញក៏គ្មានអតិថិជន សម្រាប់ទិញទំនិញរបស់គាត់ដែរ ថែមទាំងគ្មានអ្នកផ្គត់ផ្គង់ផលកសិកម្ម សម្រាប់គាត់យកទៅលក់នៅទីក្រុងដែរ ។ ជាងនេះទៀត ការចាត់ចែងឲ្យខ្ចីបុលប្រាក់ ដោយផ្អែកលើមូលដ្ឋានទុកចិត្តគ្នាជាពិសេស ដែលភាគីទាំងពីរមិនដែលក្បត់គ្នា បានចងពួកគេមិនឲ្យបែកចេញពីគ្នាបាន (រ៉េដ ទំ.១៥០) ។ យើងអាចនិយាយម្យ៉ាងទៀតថា ទំនាក់ទំនងសេដ្ឋកិច្ច រវាងក្រុមអ្នកមានមុខងារដាក់លាក់ទាំងឡាយ បង្កើតនូវប្រយោជន៍រួមគ្នា ដែលចងក្រងសង្គមជាច្រើនជាមួយគ្នា ដោយមិនទាក់ទងនឹងសម្ពាធពីខាងក្រៅ របស់មហាអំណាចអាណានិគម បង្ខំឲ្យពួកគេរស់នៅដោយស្ងប់ស្ងៀមនោះទេ ។

*គំនិតនេះ បានពង្រីកក្នុងអត្ថបទថ្មីមួយ របស់លោកសាស្ត្រាចារ្យ ឺវីធីម ដែលថា ភាពខុសគ្នាខាងវប្បធម៌ មិនអាចពន្យល់អំពីភាពតានតឹងក្នុងសង្គមចម្រុះ និងអំពីការកេងប្រវ័ញ្ចសេដ្ឋកិច្ច នៃក្រុមជាតិពន្ធុមួយ ដោយក្រុមមួយទៀត ដែលនាំឲ្យកើតជម្លោះនោះទេ ។ ជាការពិត ការសិក្សាអំពីប្រវត្តិសាស្ត្ររបស់អាស៊ីអាគ្នេយ៍ លេចចេញនូវការលើកឡើងថា ជម្លោះរវាងជាតិពន្ធុមួយ ជាមួយនឹងជាតិពន្ធុមួយទៀត បានកើតឡើងនៅពេលណាមានវណ្ណៈសេដ្ឋកិច្ចស្រដៀងគ្នាច្រើន នៅក្នុងក្រុមជាតិពន្ធុទាំងពីរ ក្នុងការប្រកួតប្រជែងដោយផ្ទាល់រវាងពួកគេទាំងសងខាង (ឺវីធីម ១៩៦៤ ទំ. ៧៦)។ នៅកោះជ្វា សំនួនវោហារនៃមនោសញ្ចេតនា និងព្រឹត្តិការណ៍ហិង្សាប្រឆាំងពួកចិនកើតឡើងនៅពេលវណ្ណៈជ្វាថ្នាក់កណ្តាលបានចាប់កំណើតឡើង និងនៅពេលឯកទេសនីយកម្មជាប្រពៃណីរបស់ជាតិពន្ធុបានរលាយសាបសូន្យអស់ និយាយឲ្យខ្លីទៅ គឺថា នៅពេលរចនាសម្ព័ន្ធបានចាប់ផ្តើមផ្លាស់ប្តូរ ពីប្រភេទឧត្តមគតិនៃសង្គមចម្រុះដូចដែលបានពិពណ៌នាដោយហ្វឺនីវ៉ល ។[៥] ស្ថិតក្នុងស្ថានភាពបែបនោះ វត្តមាននៃកងទ័ពអាណានិគមអាចរារាំងអំពើហិង្សាបាន ក៏ប៉ុន្តែជាញឹកញាប់ ចលនាប្រឆាំងនឹងជនជាតិចិនមួយ អាចជាផលប្រយោជន៍របស់មហាអំណាចអាណានិគមដែរ ។ ដោយហេតុដូច្នេះហើយ ទើបគេបានលើកទឹកចិត្តឲ្យវាកាន់តែរីកដុះដាលឡើង ជាឧទាហរណ៍ នៅក្នុងប្រទេសហ្វីលីពីន អំឡុងសតវត្សរ៍ទី ១៩ ពួកអេស្ប៉ាញពិតជាសប្បាយចិត្តណាស់ ពេលឃើញជនជាតិហ្វីលីពីន បង្ហាញនូវអាកប្បកិរិយាមិនចូលចិត្តជនជាតិចិននោះ (វិយបឺក១៩៦២ ទំ. ២៧៦)។ បាតុកម្មប្រឆាំងជនជាតិចិន នៅសៃហ្គន ក្នុងឆ្នាំ ១៩១៩ និងនៅកំពង់ផែហៃហ្វុង ក្នុងឆ្នាំ ១៩២៧ យ៉ាងហោចណាស់មានការគាំទ្រដាក់ម្ខាំងចិត្តដោយដោយពួកបារាំង ដែលមានបំណងចង់ឲ្យពួកពាណិជ្ជករយួន បំបាក់សេដ្ឋកិច្ចពួកចិនដែលបានក្តាប់នៅទូទាំងឥណ្ឌូចិន និងកាត់បន្ថយខ្លះ នៅតុងកឹង ។[៦] ជាការពិតណាស់ថា ការប្រៀបធៀបជាមួយប្រទេសវៀតណាម នាំឲ្យគេកត់សម្គាល់នូវហេតុផលសេដ្ឋកិច្ចថា ហេតុអ្វីក៏ជម្លោះបែបនេះមិនបានកើតមានឡើងនៅកម្ពុជារវាងពួកខ្មែរ និងចិន បញ្ហានេះបានចង្អុលបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ដោយសារតែនៅកម្ពុជាគ្មានវណ្ណៈខ្មែរថ្នាក់កណ្តាលមួយសោះ ។*

*ទ្រព្យសម្បត្តិភាគច្រើនរបស់ពួកយួននៅឥណ្ឌូចិន បានមកពីការធ្វើម្ចាស់ដីធ្លី ។ សម្រាប់ ៨០% នៃដីស្រែចម្ការស្ថិតនៅក្នុងដៃពួកកុម្មី នៅខណៈដែលមានតែកសិករម្នាក់ ក្នុងចំណោមម្ចាស់ដីតូចតាចបួននាក់ ដែលគាត់ធ្វើចម្ការ (ហ្យាកូបឺ ទំ. ១៦០) ។ ផ្ទុយទៅវិញ នៅកម្ពុជា កសិករ ៩៥% គឺជាអ្នកដាំដុះដំណាំលើដីធ្លីរបស់ខ្លួន ( ទំ. ១៥៧) ហើយមានប្រជារាស្ត្រតិចតួចណាស់ ដែលមានដីកម្មសិទ្ធិធំជាងទំហំ ដែលគេអាចដាំដុះបានដោយខ្លួនឯង ។[៧] កង្វះវណ្ណៈកុម្មីនៅកម្ពុជា អាចបណ្តាលមកពីមូលហេតុមួយចំនួន រួមទាំងកត្តាដែលថា វាលស្រែភាគច្រើនជាវាលទំនាបលិចទឹកច្រើនជាងវាលស្រែដីគោក ដែលប្រើប្រព័ន្ធធារាសាស្ត្រ ហើយដីទាំងអស់នោះជារបស់ម្ចាស់តែម្នាក់ គឺស្តេច ។ រហូតដល់ឆ្នាំ ១៩០៤ កត្តាមួយទៀតនោះ គឺថា យើងតែងតែឃើញមាន នូវដីកសិកម្មមិនបានដាំដុះគ្រប់គ្រាន់នៅក្នុងតំបន់មានដីវជាតិ ដែលបានរារាំងដល់ការអភិវឌ្ឍន៍ទីផ្សារដីដាំដំណាំសកម្មមួយ ។ ទោះបីជាមានហេតុផលយ៉ាងនេះក៏ដោយ ក៏នៅមានខ្មែរប៉ុន្មាននាក់ដែរ ដែលក្លាយជាអ្នកមានទ្រព្យសម្បត្តិហូរហៀរដោយភាពជាម្ចាស់ដី ។ ដូចដែលលោក ដែលវើរ បានសរសេរថា «អ្នកមាននៅកម្ពុជា គឺជាពាណិជ្ជករ មិនមែនម្ចាស់ដីធ្លីនោះទេ» (ឌែលវើត ទំ. ៤៩៨) ។ ជាលទ្ធផល លើកលែងតែពួកអភិជនមួយក្តាប់តូចចេញនោះ គឺមានតែពួកចិនប៉ុណ្ណោះ ដែលមានដើមទុនដើម្បីចូលប្រលូកក្នុងអាជីវកម្មជំនួញ ហើយចំពោះពួកអភិជន គឺពេញចិត្តក្នុងការបង្កើនចំណូលទ្រព្យសម្បត្តិរបស់ខ្លួន តាមរយៈពួកឈ្មួញចិន ជាជាងដើរតួនាទីជំនួសពួកគេ ។*

ហេតុផលទីពីរ ចំពោះកង្វះវណ្ណៈខ្មែរថ្នាក់កណ្ដាល ស្ថិតនៅលើសារជាតិនៃការគ្រប់គ្រងរបស់អាណានិគម អំឡុងពេលបារាំងដាក់អាណាព្យាបាលលើកម្ពុជា ។ ដោយសាររដ្ឋការបារាំង និយមប្រើបុគ្គលិកយួនជាជាងខ្មែរ និងដោយសារតែកម្ពុជាមិនបានបង្កើតនូវវណ្ណៈ នៃអ្នកបម្រើរាជការជាជនជាតិខ្មែរ ដែលជាអ្នកមានកម្រិតវប្បធម៌ខ្ពស់គ្រាន់បើជាងកសិករ និងដោយឡែក ពួកគេមួយចំនួនបានឲ្យតម្លៃចំពោះបស្ចិមប្រទេសរួចជាស្រេចទៅហើយ ចង់ ឬមិនចង់ក៏ដោយ ក៏ធ្វើឲ្យពួកគេត្រូវឃ្លាតឆ្ងាយពីរបបអាណានិគមដែរ ។ មិនមែនជាការចៃដន្យនោះទេ ដែលថាប្រទេសកម្ពុជាទទួលបានឯករាជ្យរបស់ខ្លួន តាមរយៈការខិតខំប្រឹងប្រែងទាមតែឯងមួយ ដឹកនាំដោយព្រះបាទនរោត្តម សីហនុ ដោយខុសគ្នាទាំងស្រុង បើប្រៀបធៀបជាមួយនឹងប្រទេសឥណ្ឌូនេស៊ី និងវៀតណាម ដែលការតស៊ូទាមទារឯករាជ្យពីពួកអាណានិគម ផ្ដើមចេញពីការដឹកនាំរបស់ពួកឈ្មួញកណ្ដាលចិន ដែលជនម្ចាស់ស្រុកមិនពេញចិត្តទាំងអស់នេះឯង (វើធើម ១៩៦២ ទំ. ៥-៨, ឡែនកាស្ទើ ទំ. ៦៦)។ លើសពីនេះទៅទៀតនោះ យើងឃើញថា គ្មានខ្មែរអ្នកជាតិនិយមណាម្នាក់មានសញ្ចេតនាប្រឆាំងជនជាតិចិន ដូចដែលបានសម្ដែង និងបញ្ជាក់យ៉ាងច្បាស់តាមរយៈសេចក្ដីថ្លែងការ អ្នកជាតិនិយមនៅក្នុងប្រទេសជាច្រើន នៅអាស៊ីអាគ្នេយ៍នោះ ។[៨]

បន្ទាប់មក ដោយសារប្រវត្តិសាស្ត្រដាក់លាក់របស់ខ្លួន កម្ពុជាបានបង្កើតនូវសង្គមមួយ ដែលគ្មានវណ្ណៈខ្មែរមួយប្រកួតប្រជែងនឹងវណ្ណៈពាណិជ្ជកម្មចិន ។ ខ្ញុំបានពិភាក្សាតាមក្រោយលោក វើធីម ថា ទំនាក់ទំនងយ៉ាងជិតស្និទ្ធជាសាច់ញាតិ ដែលបានទទួលរវាងពួកខ្មែរ និងចិន មានការពាក់ព័ន្ធនឹងកង្វះ នៃការប្រកួតប្រជែងគ្នានោះឯង ។ ចំណុចសំខាន់ចម្បង ដែលមិនបណ្ដាលឲ្យមានជម្លោះរវាងខ្មែរ និងក្រុមជាតិពន្ធុចិន គឺដោយសារតែពន្ធុកនៃវជេនចិនកាត់ខ្មែរ ។

## វជេនចិនកាត់កម្ពុជា

អត្រាខ្ពស់បំផុតនៃអាពាហ៍ពិពាហ៍ឆ្លងជាតិពន្ធុ បានក្លាយជាភាពទូទៅ សម្រាប់ពេលខ្លះរវាងពួកពាណិជ្ជករចិនដ៏មានទ្រព្យសម្បត្តិនៅទីក្រុងភ្នំពេញ និងពួកអភិជនកម្ពុជា ។ ដោយសារគំនិតជាតិនិយមខ្មែរ មិនបានពាសបាត់លើមនោសញ្ចេតនាប្រឆាំងចិន ល្បាយនេះត្រូវបន្តរហូតដល់បច្ចុប្បន្នរវាងពួកអ្នកមានជាតិចិន និងពួកមន្ត្រីថ្នាក់ខ្ពស់ក្នុងជួររដ្ឋាភិបាល ដែលភាគច្រើនរួមមានពួកចិនកាត់ខ្មែរ ក្នុងកម្រិតខុសៗគ្នានៃភាពលាយចម្រុះ ។ លើសពីនេះទៅទៀត គ្មានបុគ្គលណាម្នាក់នៅក្នុងចំណោមមន្ត្រីថ្នាក់ណាមួយ ត្រូវគេបង្ខំដោយហេតុផលនយោបាយ ដើម្បីឲ្យសម្រេចចិត្តជ្រើសរើស រវាងភក្ដីភាពនៃក្រុមជាតិពន្ធុនានា ដាក់ស្ដែង ដូចជាក្នុងករណីពេលខ្លះ និងចំពោះបញ្ហាមួយចំនួនតូចនៅប្រទេសថៃបច្ចុប្បន្ន (ស្គីន ណឺ ១៩៥៧ ទំ. ២៤២ និងទំ. ២៤៩)។

នៅឆ្នាំ ១៩៦៣ បុរសអ្នកមានជាច់គេ ៩ នាក់នៅកម្ពុជា ដែលគេបានរាយការណ៍ គឺទាំងអស់សុទ្ធសឹងជកចេញពីចំណោមជនជាតិចិន មាន ៧ នាក់ជាចិនទាជីវ និង ២ នាក់ជាចិនហុកគៀន ។[៩] ចិនហុកគៀនទាំងពីរនាក់ និងយ៉ាងហោចណាស់ចិនទាជីវ ៣ នាក់ មានកំណើតនៅក្នុងប្រទេសកម្ពុជា ហើយយ៉ាងហោចណាស់ ៧ នាក់ក្នុងចំណោមនោះ គឺជាពលរដ្ឋខ្មែរ ។ ពួកគេទាំង ៩ នាក់នោះ គឺជាបុរសមានទ្រព្យសម្បត្តិស្ដុកស្ដម្ភ និងជាអ្នកជំនួញសកម្ម នៅក្នុងចំណោមអ្នកឈានមុខគេ ខាងសេដ្ឋកិច្ចដ៏មានអំណាចបំផុតនៅក្នុងប្រទេស ។ ពួកគេមានឱកាសច្រើន ដើម្បីបង្កើតរូបមន្តនៃគោលនយោបាយសេដ្ឋកិច្ច ដែលមានឥទ្ធិពលទៅលើសហគមន៍ជនជាតិចិនទាំងអស់ ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេក៏មានការទាក់ទងផ្លូវការបន្តិចបន្តួច ដល់រចនាសម្ព័ន្ធនយោបាយនៃ

សហគមន៍នោះ ។ សម្រាប់បញ្ហានេះ មានតែបុរសម្នាក់គត់ក្នុងចំណោមទាំង ៩ នាក់ បានដាក់ការិយាល័យខ្លួននៅក្នុងសមាគមចិនមួយចំនួន នៅពេលខ្ញុំនៅទីនោះ ។

នេះមិនមែនមានន័យថា បុរសអ្នកមានទាំងនោះ មិនមែនចិននោះទេ ពួកគេតែងតែធ្វើអំណោយជាប្រចាំដល់មន្ទីរពេទ្យចិន និងដល់បុព្វហេតុជនជាតិចិនដទៃទៀត ។ ពួកគេទាំងអស់គ្នានិយាយភាសាចិនយ៉ាងហោចណាស់មួយភាសា ហើយកូនៗរបស់ពួកគេ ត្រូវបញ្ជូនទៅរៀននៅតាមសាលាភាសាចិន ។ ពិតណាស់ ពួកគេភាគច្រើនកាន់កាប់តំណែងកំពូលៗ ដូចជាសមាជិកនៃក្រុមប្រឹក្សាភិបាលរបស់សាលា មុនពេលសង្គ្រាមចិន-ជប៉ុន ផ្ទុះឡើង ។ ប៉ុន្តែចាប់តាំងពីកម្ពុជាបានឯករាជ្យ នៅក្នុងករណីមួយចំនួន ពិសេសនៅពេលមានសង្គ្រាម ពួកគេបានជ្រើសរើសយកការស្ថិតនៅក្រៅរចនាសម្ព័ន្ធនយោបាយ របស់សហគមន៍ចិន ដើម្បីពង្រីកអំណាចរបស់ខ្លួននៅក្នុងពិភពដ៏ទូលាយមួយ គឺពួកគេជាសមាជិករបស់ក្រុមវណ្ណៈខ្មែរថ្នាក់ខ្ពស់ថ្មីមួយ ។

គេគិតថា វណ្ណៈជាន់ខ្ពស់នៅក្នុងកម្ពុជាមានពីរក្រុម ហើយក្រុមទាំងពីរខុសពីគ្នា ដោយចំណងទាក់ទងរបស់ពួកគេ នៅក្នុងរចនាសម្ព័ន្ធនយោបាយផ្លូវការរបស់ប្រទេស ។ ពួកវរជនសេដ្ឋកិច្ច រួមមានអ្នកមានចិនកាត់ខ្មែរ ដែលខ្ញុំបានបញ្ជាក់ពីខាងដើម ។ ជាលក្ខណៈពិសេស ពួកសេដ្ឋីចិនកាត់ខ្មែរទាំងនេះមិនបានចូលរួមនៅក្នុងបញ្ហានយោបាយជាផ្លូវការទេ ទោះបីពួកគេខ្លះបានទទួលការលើកសរសើរ និងផ្តល់កិត្តិយសហើយពួកគេជាច្រើននាក់ បានធ្វើអំណោយសាធារណៈយ៉ាងទូលំទូលាយ ចំពោះគម្រោងការរបស់រដ្ឋ បែបដូចជាមន្ទីរពេទ្យនានា និងខាងសិក្សាអប់រំក៏ដោយ ក៏មានតែមនុស្សម្នាក់គត់ ជាមេដឹកនាំសភាពាណិជ្ជកម្ម ។

មាននូវក្រុមវរជននយោបាយមួយដែរ ដែលចូលរួមចំណែកដោយផ្ទាល់ ក្នុងនយោបាយកម្ពុជា ក្នុងឋានៈជាមន្ត្រីស៊ីវិលជាន់ខ្ពស់ ជាអនុប្រធានសភាជាតិ ជានាយទាហាននៃកងយុទ្ធពលខេមរភូមិន្ទ និងជាអ្នកគ្រប់គ្រងក្រុមហ៊ុនរដ្ឋទាំងឡាយ ក្រុមហ៊ុនខេមរាជគោជនាល័យ ដែលគ្រប់គ្រងសណ្ឋាគារ និងផ្ទះសំណាក់រដ្ឋ ។ ពួកវរជននយោបាយទាំងនេះ មានពួកកូនកាត់ចិនកម្ពុជាជាច្រើននាក់ដែរ ។ចំណងទាក់ទងយ៉ាងស្អិតល្មួតក្នុងលក្ខណៈមិត្តភាព សាច់ញាតិ និងចំណងសាមគ្គីភាព រវាងក្រុមវរជនទាំងពីរប្រភេទនេះ ធ្វើឲ្យគេមិនអាចបែងចែកឲ្យដាច់ស្រឡះពីគ្នាបាន ហើយជាក់ស្តែង អាចធ្វើឲ្យក្រុមទាំងពីរបង្កើតនូវឥទ្ធិពលគួរឲ្យកត់សម្គាល់បាន ។

ហេតុដូច្នេះ គេអាចនិយាយបានថា វណ្ណៈចិនកាត់កម្ពុជាជាន់ខ្ពស់មួយប្រភេទនេះ អាចចាត់ទុកថា មានឋានានុក្រមសង្គមនៅក្រោមតែរាជវង្សានុវង្សខ្មែរតែបន្តិចប៉ុណ្ណោះ បើនិយាយពីឥទ្ធិពល និងកិត្យានុភាពរបស់ពួកគេនៅកម្ពុជា វណ្ណៈជាន់ខ្ពស់នេះ បានដើរតួជំនួសទាំងសងខាង គឺទាំងពួកអ្នកដឹកនាំជាតិពន្ធុចិន ដែលត្រួតត្រាសហគមន៍ចិន នៅអំឡុងពេលរបបលក្ខន្តិកៈសហគមន៍ជាតិពន្ធុ និងទាំងសហគមន៍បារាំង ដែលបានត្រួតត្រាដែន នៃអំណាចជាតិអស់ជិតមួយសតវត្សរ៍មកនោះ ។ សម្រាប់ពួកចិនដែលមានចំណាប់អារម្មណ៍នឹងចាប់យកអំណាច បានពង្រីកសង្វៀនព្រំដែនដ៏តូចចង្អៀត នៃការទាក់ទងក្នុងសមាគមចិន ឲ្យកាន់តែធំឡើងៗ ទៅក្នុងវិស័យនយោបាយជាតិរបស់ប្រទេសកម្ពុជា ។

## សង្គមចម្រុះ និងគោលនយោបាយ

ការវិភាគលើសង្គមចម្រុះនៃកម្ពុជា មានសារៈសំខាន់ខាងទ្រឹស្តីចំពោះសង្គមវិទូ ដូចដែលខ្ញុំបានចង្អុលបង្ហាញនៅក្នុងសេចក្តីផ្តើម ថាវាមានសារៈសំខាន់ ខាងលំហាត់អនុវត្តន៍ ដើម្បីស្វែងយល់អំពីព្រឹត្តិការណ៍នៅក្នុងតំបន់អាស៊ី

អាគ្នេយ៍ ដែលអាចចង្អុលបង្ហាញតាមរយៈការអនុវត្តគោលនយោបាយពីរ ដើម្បីបំភ្លឺពីរចនាសម្ព័ន្ធសង្គមកម្ពុជា គឺជាតូបនីយកម្ម និងអព្យាក្រឹត ។

នៅខែធ្នូឆ្នាំ ១៩៦៣ សម្ដេច សីហនុ បានប្រកាសយ៉ាងតក់ក្រហល់ នូវការធ្វើជាតូបនីយកម្មខាងធនធានទាំងអស់ និងពាណិជ្ជកម្មក្រៅប្រទេស ។ មូលហេតុជំរុញឲ្យមានចំណាត់ការនេះ គឺដោយសារតែបញ្ហាសេដ្ឋកិច្ច ។ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា នៅអនុវត្តន៍តាមលំអាន «អាណានិគម» នៅឡើយ ដោយការនាំចេញវត្ថុធាតុដើម និងផលិតផលកសិកម្ម ដើម្បីទូទាត់ជាមួយការនាំចូលមកវិញ នូវផលិតផលសម្រេចចេញពីរោងចក្រ នៃបណ្ដាប្រទេសអភិវឌ្ឍន៍ ។ តុល្យភាពមិនគួរឲ្យសាទរ បានលេចឡើងពីសកម្មភាពពាណិជ្ជកម្មនេះ ដោយសារទទួលបានលទ្ធផលត្រឹមតែតម្លៃមួយភាគប្រាំ នៃបរិមាណតម្លៃទំនិញនាំចូល(ដេល្វៀម ដែលម៉ូត ១៩៦៤, ទំ. ៣៣) ដើម្បីធ្វើឲ្យសេដ្ឋកិច្ចរបស់ប្រទេសកាន់តែប្រសើរឡើង ចាំបាច់ណាស់ គេត្រូវបង្វែរមូលធនពីរបរជំនួញមកប៉ាន់ប្រមាណលទ្ធផល នៅក្នុងការអភិវឌ្ឍឧស្សាហកម្មវិញ ហើយជាតូបនីយកម្មលើវិស័យធនាគារ និងពាណិជ្ជកម្ម គឺជាបំណងចុងក្រោយគេបង្អស់ ។

ដោយសារវេណទាន និងពាណិជ្ជកម្ម ទាំងក្នុង និងក្រៅប្រទេស ស្ថិតនៅក្នុងកណ្ដាប់ដៃពួកអាណិកជនចិនច្រើនជាងគេ នាំឲ្យការធ្វើជាតូបនីយកម្មលេចឡើង ក្នុងរបៀបប្រឆាំងនឹងផលប្រយោជន៍របស់ពួកអ្នកជំនួញ ភាគច្រើនដែលជាជនជាតិចិន ប៉ុន្តែ ក៏មានមួយភាគបួននៃពាណិជ្ជករចិនទាំងនេះដែរ ដែលមិនបានធ្វើការប្រឆាំងនោះ ។ ការពន្យល់អំពីការយល់ព្រមរបស់ពួកចិន ចំពោះគោលនយោបាយសេដ្ឋកិច្ចថ្មី ត្រូវមើលទៅលើផលប្រយោជន៍របស់ពួកជនជាតិចិនដ៏មានអំណាច ដែលហៅថា សេដ្ឋវរជន ឬវរជនសេដ្ឋកិច្ច ។ ទំហំនៃការចូលរួមដ៏ធំ អាចធ្វើឲ្យពួកគេទាំងនេះមានសិទ្ធិពេញលេញ ក្នុងការត្រួតត្រាលើការិយាល័យនានា នៅក្នុងក្រុមហ៊ុនថ្មីរបស់រដ្ឋ ខាងពាណិជ្ជកម្មក្រៅប្រទេស ដើម្បីធានាឲ្យបានថា ភ្នាក់ងារថ្មីទាំងនេះ អាចរកប្រាក់ចំណេញឲ្យប្រទេសជាតិបានដូចជាក្រុមហ៊ុនចាស់ៗដទៃផ្សេងទៀត ដែលមានក្នុងប្រទេស ។ ជាងនេះទៀត ពួកគេទាំងនេះភាគច្រើន បានធ្វើការវិនិយោគរួចជាស្រេច នូវចំណែកបន្ទាប់បន្សំនៃមូលធនរបស់ពួកគេ ទៅក្នុងរបរខាងដីធ្លី និងផ្ទះ ឬអចលនទ្រព្យ និងផលិតកម្មលើផ្នែកជាច្រើននៃសេដ្ឋកិច្ច ដែលមិននៅក្រោមឥទ្ធិពលរបស់គោលនយោបាយថ្មី ។ ចំណុចចុងក្រោយ គឺដោយសារអត្ថិភាព នៃរចនាសម្ព័ន្ធនយោបាយរបស់សហគមន៍ចិន និងចំណងទាក់ទងរបស់ពួកគេជាមួយនឹងរចនាសម្ព័ន្ធនេះ វរជនសេដ្ឋកិច្ចចិនកាត់កម្ពុជា មានឥទ្ធិពលទៅលើសហគមន៍ចិនដទៃទៀត ឲ្យទទួលយកការសម្រេចចិត្តខាងលើ ដោយអាចប្រឆាំងបាន ។

គោលនយោបាយការបរទេសរបស់កម្ពុជា គឺជាប្រទេសមួយប្រកាន់យកអព្យាក្រឹតភាព អស់រយៈពេលមួយទសវត្សរ៍ ។ ការអនុម័តយកជំហរអព្យាក្រឹតភាព និងការថែរក្សាយ៉ាងមានៈក្នុងកាលៈទេសៈប្រឈមមុខចំពោះសម្ពាធយ៉ាងធ្ងន់ធ្ងរ ពីប្រជាជាតិដែលមានអំណាចខ្លាំងជាង ត្រូវគេលើកយកទៅវិភាគពិស្ដារ នៅក្នុងការសិក្សាផ្សេងទៀតជាច្រើន ។[១០] ការគាំទ្រនៅក្នុងចំណោមខ្មែរភាគច្រើន មានការទាក់ទងនិងភាពស្មោះត្រង់ដ៏ខ្លាំងក្លារបស់ពួកគេ ចំពោះព្រះប្រមុខរដ្ឋរបស់ខ្លួន គឺសម្ដេច សីហនុ និងមួយចំណែកទៀត ដោយសារបាតុភាពសក្ដិសិទ្ធិក្នុងការថែរក្សាឯកភាពជាតិ (ដេល្វៀម ដែលម៉ូត ១៩៦៤ ទំ. ៣៤-៦) ។ ការគាំទ្រ មាននៅក្នុងចំណោមមួយក្រុមតូច ប៉ុន្តែក្រុមចិនដ៏មានសារៈសំខាន់ខាងសេដ្ឋកិច្ច បានបន្សាំខ្លួនក្នុងការប្រតិបត្តិយ៉ាងយូរអង្វែង ។ រឿងរ៉ាវទាំងប៉ុន្មាននេះ គេមិនបានពន្យល់ តាមរយៈកត្តាដែលកម្ពុជាមានស្ថិរភាពនយោបាយ ខុសគ្នាពីកន្លែងដទៃទៀតនៅក្នុងតំបន់

អាស៊ីអាគ្នេយ៍ទេ  តាមពិត ស្ថិរភាព គឺជាឱកាសដ៏ល្អសម្រាប់របរជំនួញ ។

ក្រុមជនភាគតិចចិនមួយចំនួនតូចនៅកម្ពុជា តែងប្រកាន់យកមោទនភាពដ៏ក្លៀវក្លា តាមព្រឹត្តិការណ៍បដិវត្តរួមរបស់ប្រទេសចិននៅឆ្នាំ ១៩៤៩ ។ កិច្ចស្វាគមន៍លោកប្រធានាធិបតី លីវ ចាវជី តាមរយៈជនជាតិចិននៅកម្ពុជា គឺជាការចង្អុលបង្ហាញតូចមួយ នូវមោទនភាពនេះ ។ កាសែតចិននៅភ្នំពេញ (លើកលែងតែកាសែតគួមីតាងចេញ) រៀងរាល់ថ្ងៃ តែងពោលកោតស្ញប់ស្ញែង គ្រប់ទិដ្ឋភាពនៃការអនុវត្តរបស់ចិន  ហើយអ្នកទេសចរចិនជាច្រើនត្រឡប់ពីប្រទេសចិនវិញ  ដោយនាំមកជាមួយនូវរឿងរ៉ាវគួរឲ្យអបអរសាទរ ចំពោះសមិទ្ធផលនៅទី នោះ ។ ក្នុងពេលជាមួយគ្នានោះ យើងឃើញថា ប្រាំបីនាក់ក្នុងចំណោមចិន ១០ នាក់នេះ គឺជាអ្នកជំនួញ ហើយសូម្បីតែកម្មករមួយចំនួន  ក៏មានក្តីប្រាថ្នាធ្វើជាមូលធនិកតូចមួយ ដោយការបើកក្រុមហ៊ុនផ្ទាល់ខ្លួនរបស់គេដែរ  ។  តាំងពីអ្នកលក់ដូរតូចតាច នៅជនបទរហូតដល់ថៅកែស្រូវអង្ករធំៗនៅទីក្រុង  ពួកគេមិនដែលសប្បាយចិត្តទៅនឹងការស្តាបនានៅកម្ពុជា  ជារបបមួយដែលនាំឲ្យមានសេដ្ឋកិច្ចកាន់តែរីកចម្រើន ឬមានការប្រែប្រួលសង្គមនោះទេ គឺពួកគេលើកតម្កើងតែប្រទេសចិនប៉ុណ្ណោះ ។ ការចាកចេញរបស់ពួកចិនរាប់ម៉ឺននាក់ ពីប្រទេសវៀតណាមនៅឆ្នាំ ១៩៥៥ នៅពេលមានចំនួនកើនឡើងយ៉ាងជាក់ស្តែង ដែលពេលនោះ ប្រទេសវៀតណាមមានការបែងចែកអស់មួយខណៈ រវាងសេដ្ឋកិច្ចកុម្មុយនីស្តនៅភាគខាងជើង និងម្ខាងទៀតនៅភាគខាងត្បូង មានមូលដ្ឋានបង្អែកលើក្រុមហ៊ុនឯកជន  គឺជាភស្តុតាងនៃការពិតនេះ ។

ជនជាតិចិនដែលនៅឯនាយសមុទ្រ បានស្ថិតនៅក្នុងស្ថានភាពផ្ទុយគ្នាមួយ  គឺខណៈពេលដែលពួកគេប្រាថ្នាចង់សម្តែងនូវសន្តានចិត្តសទ្ធាជ្រះថ្លា និងការលើកតម្កើងមាតុប្រទេសរបស់ខ្លួន នោះពួកគេនឹងមិនអាចសម្រេចបំណងទៅអនាគត ក្នុងការរស់នៅក្រោមរបបមួយ នៃប្រទេសដែលគេកំពុងរស់នៅនោះឡើយ ។ វត្តមាននៃអព្យាក្រឹតភាពស្និទ្ធនឹងចិនរបស់កម្ពុជា អាចអនុញ្ញាតឲ្យពួកគេ បង្ហាញនូវសន្តានចិត្តរបស់គេចំពោះប្រទេសគេ និងឲ្យពួកគេសម្រេចបំណងទៅអនាគតរបស់ពួកគេបាន ។ ដូច្នោះហើយ ទើបមានហេតុផលល្អមួយសម្រាប់ពួកចិននៅកម្ពុជា ក្នុងការគាំទ្រសម្តេច សីហនុ ៕

# ជំពូកទី ៥

# ការធ្លាក់ចុះនៃសម្ព័ន្ធភាពរវាងចៅហ្វាយនាយ_អ្នកពឹងពាក់ និងបម្រែបម្រួលសង្គម នៅតំបន់អាស៊ីអាគ្នេយ៍ជនបទ

*ដោយ ជេមស៍ ស៊ី. ស្កត់*

*ច្បាប់ដើមនៃអត្ថបទនេះ សរសេរជាភាសាអង់គ្លេស ក្រោមចំណងជើងថា៖* "The Erosion of Patron – Elient Bonds and Social Change in Rural Southeast Asia" ។

*អត្ថបទនេះដកស្រង់ចេញពីព្រឹត្តិបត្តិ ៖* **សិក្សាអាស៊ី** *ទំព័រ ៥-៣៧ ។*

*រក្សាសិទ្ធិ គ.ស. ១៩៧៣*

## CHAPTER 5:

"The Erosion of Patron – Elient Bonds and Social Change in Rural Southeast Asia"
James C. Scott
*(Journal of Asian Studies 1973, 5-37, )*

**Copyright © 1973 Journal of Asian Studies**

បកប្រែដោយ វង្ស ម៉េង

# ជំពូកទី ៥

# ការធ្លាក់ចុះនៃសម្ព័ន្ធភាពរវាងចៅហ្វាយនាយ_អ្នកពឹងពាក់[១] និងបម្រែបម្រួលសង្គម នៅតំបន់អាស៊ីអាគ្នេយ៍ជនបទ

មានការបកស្រាយតិចតួចបំផុត ពីរបបនយោបាយនៅតាមទីជនបទក្នុងតំបន់អាស៊ីអាគ្នេយ៍ (ការបកស្រាយរបស់នរវិទូជាច្រើន) អនុលោមទៅនឹងអ្វីដែលយើងអាចហៅបានថា ជាគំរូសកម្មភាព «ចៅហ្វាយនាយ-អ្នកពឹងពាក់» ឬ «សាមគ្គីភាពគ្នារវាងថ្នាក់លើ និងថ្នាក់ក្រោម»។[២] នៅក្នុងទម្រង់ចៅហ្វាយនាយ-អ្នកពឹងពាក់ទោះតិច ឬច្រើន ពួកចៅហ្វាយនាយផ្ទាល់របស់គេ គឺជាអ្នកតំណាង ពួកកសិករ នៅក្នុងនយោបាយក្នុងស្រុក ឬតំបន់[៣]។ ការប្រកួតប្រជែងផ្នែកនយោបាយ អាស្រ័យទៅលើសមត្ថភាពនៃក្រុមរបស់គេ ហើយក្រុមប្រកួតប្រជែងទាំងនោះ គឺជាបណ្តាញនៃចៅហ្វាយនាយ-អ្នកពឹងពាក់ ដែលមានលក្ខណៈស្រដៀងគ្នាយ៉ាងខ្លាំង ពីមួយក្រុមទៅមួយក្រុមនៅក្នុងល្បាយនៃវណ្ណៈក្នុងសង្គម ។ ចំពោះកសិករ ចំណងទាក់ទងក្នុងសង្គមដ៏សំខាន់ គឺជាចំណងទាំងឡាយណាដែលផ្សារភ្ជាប់ពួកគេទៅនឹងពួកចៅហ្វាយនាយ ឬអ្នកធំ ហើយចំណងទាក់ទងទាំងនេះ ហាក់ដូចជាបានកាត់បន្ថយនូវចំណងទាក់ទងដ៏សំខាន់មួយទៀត ក្នុងសង្គមរវាងវណ្ណៈកសិករដូចគ្នា ។ ក្នុងទម្រង់ជាទូទៅមួយ ដែលស្រដៀងគ្នាទៅនឹងរបបសក្តិភូមិនិយម នៃបណ្តារដ្ឋអឺរ៉ុបខាងលិចដែរនោះ វណ្ណៈកសិករបានភ្ជាប់ការទាក់ទងជាមួយពួកវណ្ណៈកុម្មីតាមចំណងភក្តីភាព ហើយពួកវណ្ណៈកុម្មីនោះ បានបង្កើតជាក្រុមអ្នកចូលរួមយ៉ាងសកម្ម ក្នុងរបបនយោបាយមួយ ដែលគ្រប់គ្រងតាមឋានានុក្រមមួយច្បាស់លាស់ ដោយក្រុមមនុស្សមួយក្តាប់តូច ។

ជាប្រការល្អមួយ ដែលមានលេចឡើងមកនូវគំរូនៃកិច្ចសហការរួមគ្នាទៅវិញទៅមករវាងវណ្ណៈ និងវណ្ណៈ ប៉ុន្តែគំរូនេះ ហាក់ដូចជាមិនសូវមានឥទ្ធិពលប៉ុន្មានទេ នៅគ្រប់ពេលដែលទំនាក់ទំនងរវាងកសិករ និងកុម្មីមានការប្រេះឆា ។ យើងឃើញថា នៅតំបន់អាស៊ីអាគ្នេយ៍មុនសម័យអាណានិគម ការប្រេះឆាបែបនេះតែងកើតមានឡើងជាពិសេស នៅអំឡុងពេលដែលប្រជាកសិករជួបប្រទះនឹងគ្រោះមហន្តរាយផ្សេងៗដូចជា ការប្រមូលផលមិនបាន និងសង្គ្រាម នោះគឺជាពេលមានការប៉ះទង្គិចគ្នារវាងការទាមទារចង់រស់របស់ប្រជាកសិករ និងការព្យាយាមគ្រប់មធ្យោបាយដើម្បីបានចំណូល និងកម្លាំងពលកម្មរបស់ពួកកុម្មី ។

យ៉ាងណាមិញនៅអំឡុងសម័យអាណានិគម នៅតាមតំបន់ដាក់លាក់មួយចំនួន ការបែកបាក់នៃចំណងទាក់ទងរវាងវណ្ណៈ និងវណ្ណៈ បានកើតមានឡើងនៅពាសពេញផ្ទៃតំបន់ទាំងមូលតែម្តង គឺមិនមែនកើតឡើងតែនៅតាមភូមិស្រុកតូចៗមួយចំនួននោះទេ ។ រឿងនេះ បានចាប់ផ្តើមឡើងនៅមុន ឬក្នុងអំឡុងទស្សវត្សរ៍ ឆ្នាំ ១៩២០ និងឆ្នាំ១៩៣០ នៅតាមបណ្តាតំបន់មួយចំនួនដូចជា: ឡូហ្សិនកណ្តាល ភូមាភាគខាងត្បូង និងនៅតាមតំបន់ដីសណ្តមេគង្គ និងដីសណ្តតុងកឹង ដែលជាថ្នាលបណ្តុះការបះបោររបស់ប្រជាកសិករ ក្នុងទម្រង់ផ្សេងៗជាច្រើន ។ ក្នុងស្ថានភាពបែបនេះជារឿយៗប្រជាកសិករតែងប្រឆាំងតទល់យ៉ាងរឹងទទឹង តែងធ្វើការប្តឹងផ្តល់ រត់គេចខ្លួន ឬប្រព្រឹត្តអំពើឆក់ប្លន់ និងលួចដុតបំផ្លាញជាដើម ។ ក៏ប៉ុន្តែនៅតំបន់មួយចំនួន មានការក្រោកឡើងប្រឆាំងដ៏សម្បើម តួយ៉ាងដូចជាពួកឧទ្ទាមសាយាសាន នៅប្រទេសភូមា ក្រុមកសិករញេអាន និងហាទៀងនៅ ប្រទេសវៀតណាម ចលនាសាក់ដាល នៅប្រទេសហ្វីលីពីន ឬនៅឆ្នាំ ១៩២៦-២៧ នៅកោះជ្វាខាងលិច និងនៅស៊ូម៉ាត្រា ដែលតំបន់

ទាំងនេះ សុទ្ធសឹងតែមានការពាក់ព័ន្ធទៅនឹងមនោគមន៍វិជ្ជាខាងផ្នែកសាសនា និងអ្នកជាតិនិយម ហើយលើសពីនេះ ជាពិសេសនោះ គឺការចោទសួររបស់កសិករពាក់ព័ន្ធនឹងរឿងពន្ធដារការប្រើប្រាស់ដីធ្លី និងការបែងចែកការប្រមូលផល ។ល។ រឿងឈឺចាប់ និងអយុត្តិធម៌ដូចៗគ្នាជាច្រើន បានផ្តល់ជាមូលដ្ឋានដល់ការបះបោរក្រោយសង្គ្រាមលោកលើកទី ២ ដល់អ្នកសង្គមនិយមទង់ក្រហមស នៅប្រទេសភូមា ក្រុមបះបោរវៀតមិញក្រុមហ៊ុកបាឡាហាប់ និងក្រុមបះបោរម៉ៃឌែន ប្រទេសឥណ្ឌូនេស៊ី ។ លើសពីនេះទៅទៀត នៅផ្នែកខ្លះនៃតំបន់អាស៊ីអាគ្នេយ៍ ប្រព័ន្ធចៅហ្វាយនាយ–អ្នកពឹងពាក់ នៃការពួតដៃគ្នារបស់កសិករ–គហបតី បានប្តូរទៅជាទម្រង់នៃភាពជាសត្រូវរវាងវណ្ណៈទៅវិញ ។

បើមើទៅលើទ្រឹស្តីជាទូទៅ យើងនឹងមានចម្ងល់ថា «តើអ្វីជាមូលដ្ឋាននៃរចនាសម្ព័ន្ធចៅហ្វាយនាយ–អ្នកពឹងពាក់ ហើយថា តើពួកគេបាត់បង់អានុភាពសីលធម៌ នៃការគោរពនេះយ៉ាងដូចម្តេច?» ចម្លើយមួយសម្រាប់សំណួរនេះ គឺគ្រាន់តែអាចផ្តល់ជាផ្នែកមួយនៃការវិភាគដោយភ្ជាប់គ្នា រវាងនយោបាយចៅហ្វាយនាយ–អ្នកពឹងពាក់នៅទីជនបទ និងទម្រង់មូលដ្ឋានវណ្ណៈនៃសកម្មភាពរបស់កសិករតែប៉ុណ្ណោះ ។ បើទោះបីជា សម្ព័ន្ធភាពនៃចៅហ្វាយនាយអ្នកពឹងពាក់ ដែលមានពីមុនមកអាចនឹងបាត់បង់សក្តានុពលភាពក្តី ក៏ទំនាក់ទំនងថ្មីតាមឋានានុក្រមពីធំមកតូច អាចភ្ជាប់កសិករទៅនឹងអ្នកនយោបាយ មន្ត្រីរាជការ ឬអ្នកត្រួតត្រានៅតាមទីជនបទ ហើយបានផ្តល់សេវាសំខាន់ៗ ចាំបាច់ជាច្រើនដល់សម្ព័ន្ធភាពចាស់ ។ នៅពេលដែលសម្ព័ន្ធភាពនៃសហប្រតិបត្តិការរវាងវណ្ណៈ និងវណ្ណៈមិនអាចកើតមានឡើង នោះពួកវណ្ណៈចៅហ្វាយនាយ ដែលបាត់បង់ឥទ្ធិពលភាពរបស់ខ្លួន អាចនឹងធ្វើអ្វីគ្រប់យ៉ាងដើម្បីរក្សាអំណាចរបស់ខ្លួន ដើម្បីទទួលបាននូវការផ្គាប់ចិត្ត និងគោរពដូចមុន ចំណែកឯប្រជាកសិករវិញ ប្រហែលជាត្រូវបែងចែកទៅជាក្រុមៗដោយយោងតាម តំបន់ សាសនា និងជាតិពន្ធុរបស់ពួកគេរៀងៗខ្លួន ហើយការធ្វើបែបនេះអាចទប់ស្កាត់កុំឲ្យមាននូវការរីកកាន់តែធំឡើងៗនៃចំណងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរបស់ពួកវណ្ណៈថ្នាក់ក្រោមដូចគ្នា ។ មិនថាការបាត់បង់ឥទ្ធិពលរបស់ពួកក្តុម្ពីអាចមានឥទ្ធិពលទៅដល់សកម្មភាពនៃវណ្ណៈកសិករ ឬយ៉ាងណានោះទេ ក៏ការសិក្សានេះ មិនបានយកកត្តាជុំវិញ និងការរារាំងនានាមកនិយាយដែរ ព្រោះកត្តាទាំងនេះ មិនអាចធ្វើបានក្នុងទំហំនៃការសិក្សាដ៏តូចនេះឡើយ ។

នៅពេលនេះខ្ញុំចង់ពន្យល់ថា ហេតុអ្វីបានជាសម្ព័ន្ធភាពសង្គមយ៉ាងរឹងមាំមួយ នៅតំបន់អាស៊ីអាគ្នេយ៍ ដែលផ្តុំគ្នាឡើងរវាងកសិករ និងគហបតី មានទំនោរទៅរកការបែកបាក់នៅក្នុងអំឡុងសម័យអាណានិគម ជាពិសេស នៅតាមតំបន់ដីទំនាបដែលគេកាន់កាប់ផ្ទាល់នោះ ។ ដោយមើលទៅលើប្រសិទ្ធភាពនៃការបែងចែកសង្គម ការលក់ដូរផលដំណាំ ដែលដាំសម្រាប់តែបរិភោគក្នុងគ្រួសារ និងការរីកលូតលាស់នៃរដ្ឋបាលអាណានិគម ទៅលើចំណងទាក់ទងទូទៅនៃវណ្ណៈនៅតាមទីជនបទ នោះអាចបង្ហាញឲ្យឃើញបានថា ហេតុអ្វីបានជាទំនាក់ទំនងមួយដែលវណ្ណៈកសិករធ្លាប់មានកិច្ចសហប្រតិបត្តិការល្អនឹងគ្នា ហើយថែមទាំងមានសក្តានុពលភាពទៀតនោះ ប្រែក្លាយយ៉ាងលឿនទៅជាករណីមិនមានភាពស្មើគ្នា ឬការកេងប្រវ័ញ្ចទាំងស្រុងមួយ ។

ខាងក្រោមនេះ គឺជាការសង្ខេបត្រួសៗនៃការអះអាងរបស់ខ្ញុំ ៖

១. ជាប្រការមួយអាចទទួលយកបាន ក្នុងការបង្ហាញពីទំនាក់ទំនងរវាងកសិករ និងពួកគហបតីម្ចាស់ដីថា ជាទំនាក់ទំនងនៃការដោះដូរគ្នាទៅវិញទៅមកតាមឋានានុក្រមរវាងអ្នកធំ និងអ្នកតូចមួយ ដែលក្នុងនោះការប្រែប្រួលនៃឥទ្ធិពលរបស់ពួកគហបតី ទាក់ទងដោយផ្ទាល់ទៅនឹងការប្រែប្រួលតុល្យភាពទំនិញ និងសេវាកម្មជាលក្ខណៈពាណិជ្ជកម្មរវាងពួកគេ ហើយនឹងការដោះដូរទាំងមូល ។ ខណៈពេលដែលតុល្យភាព នៃការដោះដូរមិន

អាចកម្រិតចំនួនបានច្បាស់លាស់ រួមមានទាំងទំនិញ និងសេវាកម្ម និងការផ្តល់សេវាដែលមិនអាចកំណត់បរិមាណបានដូចជា ការការពារនោះ ជាទូទៅគេអាចដឹងបានថា នៅក្នុងអំឡុងពេលមួយ តើតុល្យភាពនៃការដោះដូរមានទិសដៅតម្រង់ទៅណា ហើយគេក៏អាចមើលឃើញច្បាស់ដែរថា តើមានចំណុចត្រង់ណាមួយដែលបានដើរខុសពីទិសដៅមេនេះ ។[៨]

២. ឥទ្ធិពល ឬអំណាចស្របច្បាប់របស់ចៅហ្វាយនាយ គឺមិនមែនជាសមីការស្មើជាមួយនឹងតុល្យភាពនៃការដោះដូរដ៏ងាយស្រួលមួយនោះទេ ហើយមាននូវធាតុសំខាន់ៗ ឬចំណុចពិសេសៗជាក់លាក់ជាច្រើន នៅក្នុងតុល្យភាពដែលបង្កឲ្យមាននូវការផ្លាស់ប្តូរយ៉ាងខ្លាំងទៅលើឥទ្ធិពល ឬអំណាចស្របច្បាប់នេះ ។ កសិករ ឬអ្នកពឹងពាក់មានគំនិតបុរាណមួយ ដែលប្រាថ្នាចង់បានត្រឹមតែសុវត្ថិភាពផ្លូវកាយ និងជីវិតដ៏សាមញ្ញមួយតែប៉ុណ្ណោះ ។ការគិតបែបនេះ មានឫសគល់មកពី «សីលធម៌សេដ្ឋកិច្ចបែបបិតុនិយម» របស់វណ្ណៈកសិករ ហើយគន្លឹះសំខាន់នៃបញ្ញត្តិកម្មនេះ គឺយុត្តិធម៌ និងសមធម៌[៩] ។ ប្រសិនបើចំណុចតូចៗខាងលើ ដែលតម្រូវឲ្យមាននៅក្នុងចំណងនៃការដោះដូរទាំងនេះត្រូវបំផ្លាញ នោះអំណាច ឬឥទ្ធិពលដែលមានពីមុនរបស់ពួកវណ្ណៈចៅហ្វាយនាយនឹងត្រូវកាត់ផ្តាច់ ហើយនឹងជំរុញឲ្យវណ្ណៈកសិករប្រកាន់យកនូវគំនិតមួយ ដើម្បីប្រឆាំងជាមួយនឹងពួកគហបតីម្ចាស់ដី ។

៣. នៅក្នុងន័យរួមមួយ តុល្យភាពនៃការផ្តល់ឲ្យ ហាក់ដូចជាពឹងផ្អែកយ៉ាងខ្លាំងទៅលើស្ថានភាពចរចារ របស់ភាគីទាំងសង្ខាង ថាតើទំហំដែលអ្នកពឹងពាក់ត្រូវការចៅហ្វាយនាយនោះ ច្រើនជាងចៅហ្វាយនាយត្រូវការអ្នកពឹងពាក់វិញកម្រិតណា? យើងអាចនិយាយម្យ៉ាងទៀតថា ស្ថានភាពចរចារនៃភាគីនីមួយៗ បានទទួលឥទ្ធិពលយ៉ាងខ្លាំងពីបម្រែបម្រួលនៃរចនាសម្ព័ន្ធដូចជា កង្វះខាតដី បន្លាស់ប្តូរពីការធ្វើកសិកម្មសម្រាប់គ្រួសារទៅជាកសិកម្មសម្រាប់លក់ដូរ ការពង្រីកអំណាចរបស់រដ្ឋ និងកំណើនប្រជាជន ។

៤. លក្ខណៈពិសេសនៃរចនាសម្ព័ន្ធជាក់លាក់ នៅតំបន់អាស៊ីអាគ្នេយ៍មុនសម័យអាណានិគម ហាក់ដូចជាបានកម្រិតនូវទំហំនៃការពឹងពាក់គ្នារបស់មនុស្សម្នាក់ៗ និងហាក់ដូចជាបានការពារមិនឲ្យតុល្យភាពនៃការដោះដូរលម្អៀងទៅតែខាងចៅហ្វាយនាយតែម្ខាង ។ មានកត្តាបីគឺ ១).ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃយន្តការសង្គមដ៏សម្បូរបែប ដែលអាចកើតមានឡើងបានពីក្រុមញាតិសន្តាន និងភូមិដ្ឋាន ២).ការលេចឡើងនូវបញ្ហាដីមិនទាន់មានកម្មសិទ្ធិច្បាស់លាស់ និង ៣).អវត្តមាននៃឥទ្ធិពលដ៏ខ្លាំងពីខាងក្រៅ ទៅអ្នកកាន់អំណាចក្នុងស្រុកដែល-ជាលក្ខខណ្ឌធ្វើឲ្យពួកវណ្ណៈកសិករទទួលបាននូវការធានាដ៏តិចតួចបំផុត។

៥.បន្លាស់ប្តូរសេដ្ឋកិច្ច និងនយោបាយ ដែលស្ថិតនៅក្រោមរបបអាណានិគម បានបំបាត់ចោលទាំងស្រុងនូវវិសាលភាពនៃការដោះដូរ និងស្ថានភាពចរចាររបស់កសិករ ជាពិសេសនៅតាមតំបន់វាលទំនាប ដែលទទួលរងនូវឥទ្ធិពលជាច្រើនពីរដ្ឋបាលអាណានិគម និងពីទីផ្សារកសិកម្ម ។

ក. ចំណុចទី ១ គឺ ការបែងចែកសង្គម បានប្តូរទម្រង់ដ៏ធំ និងរីកសាយនៃការដោះដូរច្រើនរបស់បុគ្គលម្នាក់ៗ ទៅជាប្រព័ន្ធនៃចំណងទាក់ទងជាផ្នែកៗ និងកាន់តែតូចចង្អៀតឡើងជាមួយនឹងមុខងារជាក់លាក់ ដោយឡែកៗពីគ្នារបស់ពួកគហបតី ។

ខ. ចំណុចទី ២ គឺ ការរីកចម្រើនផ្នែករដ្ឋបាលអាណានិគម កាន់តែធ្វើឲ្យកសិករត្រូវការកាន់តែខ្លាំងនូវការពារ និងឥទ្ធិពល ខណៈពេលដែលពួកអាណានិគមប្រើប្រាស់ច្បាប់ និងធ្វើជាខ្នងបង្អែកឲ្យពួកគហបតីដែលជាឱកាសជំរុញឲ្យពួកនេះច្រានចោលនូវគំនិតយោបល់របស់អ្នកស្រុក ហើយកាន់តែកេងប្រវ័ញ្ចអ្នកស្រុកថែមទៀត ។

គ. ចំណុចចុងក្រោយ គឺការធ្វើពាណិជ្ជកម្មនៅក្នុងវិស័យកសិកម្ម បានពង្រឹងនូវអំណាចតថ្លៃរបស់ពួកគហបតី

ម្ចាស់ដីជាមួយនឹងវណ្ណៈកសិករ ។ ការឡើងចុះនៃទំនិញទីផ្សារ បានធ្វើឲ្យកសិករកាន់តែត្រូវការធានាឲ្យបាននូវការរស់រានមានជីវិត នៅពេលដែលមានការចាប់អារម្មណ៍ខ្លាំងទៅលើដី និងកំណើនប្រជាពលរដ្ឋ បានធ្វើឲ្យមានម្ចាស់ទាមទារកាន់ច្រើន តែផ្ទុយទៅវិញពួកគេផ្តល់ឲ្យអ្នកជួលដី និងកម្មករនូវសេវាកម្មកាន់តែតិច ។ អំណាច ឬតួនាទីរបស់អ្នកពឹងពាក់កាន់តែសាបរលាបទៅ ដោយសារតែគ្មានដីទំនេរនៅសល់ ហើយម្យ៉ាងទៀតគឺដោយសារតែការបាត់បង់ទៅនៃធនធានសាធារណៈ (បឹង ព្រៃ វាលស្មៅ...) ព្រោះតែឥទ្ធិពលជាប្រពៃណីរបស់ភូមិ ដើម្បីធានាឲ្យបាននូវភាពស្មើគ្នាក្នុងការប្រើប្រាស់ធនធានទាំងនេះ កាន់តែមិនអាចផ្តល់ឲ្យដល់សមាជិកគ្រប់ៗរូបបាន ។

៦. បំណែងចែកនៅជនបទ កាន់តែធ្វើឲ្យមានការបែកខ្ញែករវាងអ្នកផលិតឯករាជ្យ និងអ្នកផលិតដែលត្រូវពឹងពាក់គេ នៅពេលដែលតុល្យភាពនៃការដោះដូរ ឃ្លាតកាន់តែឆ្ងាយចេញពីវណ្ណៈកសិករ ។ សម្រាប់ថ្នាក់ក្រោម ការធានាការពារពីសង្គមដែលត្រូវតែមានសម្រាប់មនុស្សម្នាក់ៗ បានបាត់បង់អស់ទៅហើយ ពិសេសចំពោះអ្នកដែលស៊ីឈ្នួលធ្វើស្រែចម្ការ ដើម្បីទទួលប្រាក់កម្រៃបន្តិចបន្តួច ។ ជាលទ្ធផល នៅពេលណាដែលមានលេចឡើងនូវបម្រែបម្រួលសង្គមបែបនេះច្រើនជាងគេ ពេលនោះ ជាពេលដែលពួកគហបតីម្ចាស់ដីបាត់បង់នូវអំណាច ឬឥទ្ធិពលរបស់ខ្លួនលើអ្នកស្រុករបស់គេ ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងឃើញថាការបាត់បង់នូវឥទ្ធិពល ឬអំណាចនេះគឺជាវិបត្តិនយោបាយដែលអាស្រ័យទៅលើកត្តាមួយចំនួនដូចជា ១).កម្រិតពេញលេញនៃសុខមាលភាពរបស់កសិករ ២).លទ្ធភាពរបស់អ្នកស្រុកក្នុងការរួបរួមគ្នា និង ៣).អំណាចក្នុងការបញ្ជា ឬគ្រប់គ្រងរបស់ពួកគហបតី ។

## ចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់

*មុនពេលលើកឡើងថា តើចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ធ្លាក់ចុះយ៉ាងណានោះ? យើងគួរតែមើលត្រួសៗទៅលើលក្ខណៈខុសប្លែកគ្នា នៃទម្រង់ដែលពឹងគ្នាទៅវិញទៅមកមួយនេះជាមុនសិន ។*

*ទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់ ដែលជាទម្រង់នៃការដោះដូរគ្នារវាងមនុស្សពីរក្រុម ប្រហែលជាអាចនិយាយបានថា ជាករណីពិសេសមួយនៃចំណងទាក់ទងរវាងមនុស្សពីរនាក់ ដោយរួមបញ្ចូលនូវឧបករណ៍នៃមិត្តភាពមួយ ដែលក្នុងនោះបុគ្គលមានស្ថានភាពសេដ្ឋកិច្ចខ្ពស់ (ចៅហ្វាយនាយ) ប្រើប្រាស់នូវឥទ្ធិពល និងធនធានរបស់គេផ្ទាល់ដើម្បីផ្តល់ការការពារ និងផលប្រយោជន៍ដល់មនុស្សថ្នាក់ទាប (អ្នកពឹងពាក់) ហើយអ្នកពឹងពាក់ត្រូវផ្តល់ទៅឲ្យពួកគហបតីវិញនូវការគាំទ្រ និងជំនួយជាទូទៅ រួមទាំងសេវាផ្ទាល់ខ្លួន សម្រាប់ចៅហ្វាយនាយ ។ លក្ខណៈពីរយ៉ាងនៃបណ្តុំចៅហ្វាយនាយ-អ្នកពឹងពាក់តម្រូវឲ្យបញ្ជាក់នៅក្នុងបរិបទនេះ គឺមូលដ្ឋានមិនស្មើគ្នា និងភាពបត់បែនទៅគ្រប់ទីកន្លែងនៃប្រព័ន្ធនេះ គឺជាប្រព័ន្ធនៃការដោះដូររបស់បុគ្គលម្នាក់ៗ ។ កត្តាទាំងពីរឃើញមានយ៉ាងប្រាកដនៅក្នុងភាពចំណុះនៃសក្តិភូមិ និងនៅក្នុងការទាក់ទងរវាងចៅហ្វាយថ្នាក់ខ្ពស់ និងអ្នកជួលដីរបស់គាត់ក្នុងផ្នែកសេដ្ឋកិច្ចផ្អែកលើកសិកម្មប្រពៃណីដែលជាទំនាក់ទំនងស្តែងឲ្យឃើញ នូវគំរូដើមនៃចំណង ចៅហ្វាយនាយ-អ្នកពឹងពាក់ ។*

*ក្នុងលក្ខណៈជាយន្តការសង្គមមួយ សម្ព័ន្ធភាពចៅហ្វាយនាយ-អ្នកពឹងពាក់ មិនមែនជាទម្រង់មួយដែលទំនើបនោះទេ ហើយក៏មិនមែនជាទម្រង់បុរាណមួយសុទ្ធសាធដែរ ។ ដើម្បីឲ្យងាយយល់ និងមិនគិតទៅលើបរិបទរបស់វា នោះគំរូនៃការទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ មានលក្ខណៈសម្គាល់បែបបុរាណ តែនៅពេលគំរូនៃការទាក់ទងនេះ រក្សាលក្ខណៈប្រពៃណីដោយឡែក នោះចំណងបែបថ្មីមានលក្ខណៈទូទៅ ។ ចំណងទាក់ទងនេះអាច*

*សាយភាយយ៉ាងទូលំទូលាយ និងមានលក្ខណៈពិសេស ហើយជាមួយគ្នានោះ ចំណងទាក់ទងបែបទំនើបនេះមានសភាព ល្អិតល្អន់ និងជាក់លាក់ ។ ប៉ុន្តែទោះជាមានលក្ខណៈបែបបុរាណក៏ដោយ ចំណងទាក់ទងនៃចៅហ្វាយនាយ-អ្នកពឹងពាក់ បានផ្តល់ឲ្យនូវរូបមន្តនៃការប្រមូលផ្តុំបុគ្គលម្នាក់ៗ ដែលមិនមែនជាសាច់ញាតិ ឬបក្សពួកនឹងគ្នា ព្រមទាំងដើរតួរជាអ្នកការពារឲ្យបានរឹងមាំ នូវការរួមបញ្ចូលគ្នារវាងថ្នាក់លើ និងថ្នាក់ក្រោម ។ ចំណងថ្មីនេះមិនអាចលុបបំបាត់ចោលនូវលក្ខណៈបុរាណបានទាំងស្រុងឡើយ ប៉ុន្តែគេបានវិភាគឃើញថា ចំណងនេះគឺជាសម្ព័ន្ធសង្គមមួយដែលអាចនឹងមានឥទ្ធិពលខ្លាំងក្នុងលក្ខខណ្ឌមួយ ហើយអាចនឹងត្រូវទាត់ចោលក្នុងលក្ខខណ្ឌមួយផ្សេងទៀត ។*

## សមាសភាពនៃការដោះដូរ

*នៅពេលដែលមានការរីកសាយភាយឡើង នូវគំនិតនៃការជួយគ្នាទៅវិញទៅមក នោះការដោះដូរទំនិញ និងសេវាកម្ម រវាងចៅហ្វាយនាយ និងអ្នកពឹងពាក់បានឆ្លុះបញ្ចាំងឲ្យឃើញពីតម្រូវការរបស់ភាគីម្ខាងៗ ។ ធាតុមួយចំនួននៃការដោះដូរអាចរាប់បាន តែធាតុមួយចំនួនទៀតមិនអាចរាប់ ឬវាស់វែងបានទេ ដូច្នេះហើយរាល់ការវាស់វែងទៅលើតុល្យភាពនៃការដោះដូរ ត្រូវតែពិនិត្យមើលទៅលើចំណុចទាំងពីរនេះ ទោះបីជាគ្មានក្បួនណាមួយដែលអាចវាស់វែង និងកាត់សេចក្តីឲ្យបានត្រឹមត្រូវ ទៅលើប្រភេទសេវាកម្មដ៏សម្បូរបែបទាំងនោះយ៉ាងណាក្តី ក៏គេបានដើរតាមវិធីដ៏សាមញ្ញមួយ ដែលព្យាយាមបរិយាយពីប្រភេទនៃការដោះសំខាន់ៗ ។*[៦]

## ការផ្តល់ឱ្យរបស់ចៅហ្វាយនាយទៅកូនចៅ

### មធ្យោបាយមូលដ្ឋាននៃការចិញ្ចឹមជីវិត

*នៅក្នុងផ្នែកកសិកម្មជាច្រើន យើងឃើញថាសេវាចាំបាច់មួយនេះរួមមាន ÷ ការផ្តល់ឲ្យមាននូវស្ថិរភាពការងារ ការផ្តល់ដីសម្រាប់ដាំដុះ ហើយប្រហែលជារួមបញ្ចូលទាំងការផ្តល់ជាគ្រាប់ពូជ សម្ភារៈការជួយរកទីផ្សារ ការពិគ្រោះយោបល់ផ្នែកបច្ចេកទេស ។ល។*

### ការធានាមិនឲ្យមានវិបត្តិលើការចិញ្ចឹមជីវិតប្រចាំថ្ងៃ

*ជាទូទៅ គេរំពឹងទុកថាចៅហ្វាយនាយនឹងផ្តល់ប្រាក់កម្ចីឲ្យទាន់ពេល នៅពេលណាដែលពួកកសិករជួបប្រទះនឹងវិបត្តិសេដ្ឋកិច្ច និងជួយនៅក្នុងករណីណាដែលមានឈឺថ្កាត់ ឬឧបទ្ទវហេតុផ្សេងៗ ឬជួយផ្គត់ផ្គង់អ្នកដែលមកពឹងពាក់ខ្លួន នៅឆ្នាំណាដែលមិនសូវទទួលបានទិន្នផលល្អនោះ ។ ហេតុនេះ ចៅហ្វាយនាយជាអ្នកធានាឲ្យបាននូវលំនឹងនៃភាពដែលអាចរស់បានមួយ ដល់អ្នកពឹងពាក់គាត់តាមរយៈការប្រមូលយកនូវការខាតបង់ផ្សេងៗ (ការខាតបង់ក្នុងការបង្កបង្កើនផល ឬក៏ការខាតបង់ប្រាក់ចំណូល) ដែលអាចធ្វើឲ្យពួកគេ (កសិករ) ជួបគ្រោះមហន្តរាយនៅក្នុងការរស់នៅ ។*

### ការការពារ

*នៅអឺរ៉ុបនាសម័យសក្តិភូមិ ការការពារអាចមានន័យថា ជាការការពារដោយប្រើកងកម្លាំងប្រដាប់អាវុធ ឬជាការសន្យាចំពោះការសងជំនួសអ្នកដែលមកពឹងពាក់ ។ នេះមានន័យថា ដាវខែលរបស់អ្នកពឹងពាក់ ដើម្បីទប់ទល់*

ទៅនឹងគ្រោះថ្នាក់របស់បុគ្គលម្នាក់ៗ (ការលួចប្លន់ សត្រូវផ្ទាល់ខ្លួន) ក៏ដូចជាការពារទប់ទល់នឹងគ្រោះថ្នាក់សាធារណៈ (យោធា មន្ត្រីខាងក្រៅ តុលាការ អ្នកទារពន្ធ) ។

### ឈ្មួញកណ្ដាល និងឥទ្ធិពល

ប្រសិនបើចៅហ្វាយនាយការពារកូនចៅរបស់គាត់ ឲ្យរួចផុតពីការបំផ្លិចបំផ្លាញមកពីមជ្ឈដ្ឋានខាងក្រៅ គាត់ក៏អាចប្រើប្រាស់អំណាច និងឥទ្ធិពលរបស់គាត់នេះក្នុងការទាញយកប្រយោជន៍ពីអ្នកខាងក្រៅ ដើម្បីផ្ដល់ទៅឲ្យកូនចៅរបស់គាត់ផងដែរ ។ ការការពារ គឺជាការកិច្ចរបស់គាត់ ក្នុងការទប់ទល់ជាមួយអ្នកខាងក្រៅ ចំណែកឯឈ្មួញកណ្ដាល ជាតួនាទីឈ្លានពាននិយមរបស់គេ ។

### សេវារួមចំពោះចៅហ្វាយទាំងអស់

នៅក្នុងផ្ទៃក្នុង ក្រុមចៅហ្វាយនាយអាចសម្ដែងឡើង នូវតួនាទីបែបសេដ្ឋកិច្ចប្រមូលផ្ដុំ ។ ពួកគាត់ប្រហែលជាដឹកនាំ និងទំនុកបម្រុងដោយផ្ដល់ជាប្រាក់សប្បុរសធម៌ និងបរិច្ចាគដីសម្រាប់ឲ្យសហគមន៍ប្រើប្រាស់ ព្រមទាំងផ្ដល់នូវសេវាសាធារណៈនៅក្នុងស្រុក (ដូចជា សាលារៀន ផ្លូវថ្នល់តូចៗ និង អគារសម្រាប់សហគមន៍ប្រើប្រាស់) ហើយថែមទាំងជាអ្នកទទួលរ៉ាប់រង លើដំណើរទស្សកិច្ចរបស់មន្ត្រីរដ្ឋាភិបាល និងឧបត្ថម្ភដល់ពិធីបុណ្យផ្សេងៗក្នុងភូមិ ។ ក្នុងការដោះស្រាយជាមួយនឹងអ្នកខាងក្រៅ ពួកចៅហ្វាយនាយអាចធ្វើការរួមគ្នាសម្រាប់អ្នកភូមិ ដូចនូវអ្វីដែលចៅហ្វាយនាយពិតប្រាកដមួយរូប អាចធ្វើសម្រាប់អ្នកពឹងពាក់របស់គាត់ដែរ ។ នេះមានន័យថា ពួកគេអាចការពារសហគមន៍ពីមជ្ឈដ្ឋានខាងក្រៅ មិនថាពីរដ្ឋអំណាច ឬការលួចប្លន់នោះឡើយ ហើយ ពួកគេអាចធ្វើឲ្យសហគមន៍ទទួលបាននូវផលប្រយោជន៍កាន់តែច្រើនឡើង តាមរយៈការធានាឲ្យបាននូវការងារ និងសេវាសាធារណៈនានា ការយោគយល់ខាងរដ្ឋបាល ប្រាក់កម្ចីសម្រាប់សហគមន៍ និងជំនួយកសិកម្ម ។ល។

### ការផ្ដល់ឱ្យពីសំណាក់កូនចៅចំពោះចៅហ្វាយនាយ

ការផ្ដល់ឲ្យនូវទំនិញ និងសេវាកម្មពីកូនចៅទៅចៅហ្វាយនាយ គឺមានការលំបាកក្នុងការកំណត់ណាស់ ព្រោះថាជាទូទៅកូនចៅបានផ្ដល់នូវកម្លាំងពលកម្ម និងភាពប៉ិនប្រសព្វរបស់ខ្លួន ទៅក្នុងគ្រោងការរបស់ចៅហ្វាយនាយ តាមជំនាញរៀងៗខ្លួន ។ កត្តាចាំបាច់មួយចំនួនរួមមាន សេវាកម្មពលកម្ម (ជាទូទៅ គឺជាការងារកសិកម្ម) សេវាបន្ថែម (ឧទាហរណ៍ ការផ្គត់ផ្គង់ទឹក និងអុសឲ្យដល់ចៅហ្វាយនាយ សេវាក្នុងផ្ទះផ្ទាល់ខ្លួន អំណោយជាម្ហូបម្ហាម្ដងម្កាលហើយ ជាពិសេសនោះ គឺការសម្ដែងនូវភាពស្មោះត្រង់ ក្នុងនាមជាសមាជិកនៃក្រុមបក្សពួករបស់ចៅហ្វាយនាយ ។

## ការពឹងពាក់អាស្រ័យ និង ភាពស្របច្បាប់[៧]

សំណួរសំខាន់មួយចំពោះទំនាក់ទំនងនៃវណ្ណៈ នៅទីជនបទក្នុងប្រព័ន្ធចៅហ្វាយនាយ-អ្នកពឹងពាក់នោះ គឺថាតើអ្នកពឹងពាក់យល់យ៉ាងណា ចំពោះទំនាក់ទំនងពឹងពាក់អាស្រ័យនោះ តើគេចាត់ទុកថា ជាចំណុចដំបូងដែលនាំឲ្យមានកិច្ចសហប្រតិបត្តិការ និងផ្ដល់នូវឥទ្ធិពល ឬអំណាចឲ្យទៅគេ ឬក៏យល់ថា ជាចំណុចដំបូងដែលនាំឲ្យមានការកេងប្រវ័ញ្ច ។ បញ្ហានៅទីនេះ គឺថាការធ្វើតាមគេ និងភាពសមរម្យស្របច្បាប់ គឺមានភាពខុសប្លែកគ្នាបើយោងតាមការវិភាគ[៨] ។ បើយោងទៅលើការបកស្រាយរបស់លោកបារីងថុនម័រ ស្ដីពីការកេងប្រវ័ញ្ចថា ជាកម្មវត្ថុនៃបាតុ

កូតមួយ ទោះបីជាតិចក្តី ច្រើនក្តីនោះ ខ្ញុំជឿថា នៅក្នុងបរិបទមួយដែលមានជាប់ពាក់ព័ន្ធទៅនឹងរឿងដីស្រែចម្ការ យើងអាចបង្ហាញពីការប្រែប្រួលនៃអំណាច ឬឥទ្ធិពលស្របច្បាប់ ឬបង្ហាញពីការទទួលស្គាល់ថាវណ្ណៈថៅហ្វាយ-នាយជាអ្នកដើរតួរយ៉ាងសំខាន់ ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរទៅលើតុល្យភាពនៃការដោះដូរលើទំនិញ និងសេវាកម្ម ទាំងចំពោះបុគ្គលម្នាក់ៗ និងសហគមន៍ទាំងមូល នៅរវាងវណ្ណៈទាំងពីរនេះ ។(៩)

ជាការពិតណាស់ថា សញ្ញាណតុល្យភាពគឺមានភាពស្មុគស្មាញបន្តិច នៅពេលដែលយើងជជែកវែកញែក នៅទីនេះពីបញ្ហាតុល្យភាព ជាមួយនឹងបរិបទនៃភាពមិនស្មើគ្នាខាងអំណាច និងធនធាន ។ ការចាប់អារម្មណ៍នៅទីនេះ គឺមិនសំដៅថា តើការដោះដូរនេះមានភាពលម្អៀងទៅម្ខាងនោះ ឬយ៉ាងណានោះទេ ប៉ុន្តែ ត្រូវមើលថាតើលម្អៀងកម្រិតណា ទើបជាការសំខាន់ ។

សម្រាប់អ្នកពឹងពាក់កត្តាសំខាន់នៃការវាយតម្លៃ គឺជាផលធៀបនៃសេវាកម្មដែលគាត់ទទួលបាន ទៅនឹងសេវាកម្មដែលគាត់បានផ្តល់ឲ្យ ។ បើតម្លៃដែលគាត់អាចទទួលពីថៅហ្វាយនាយមានទំហំកាន់តែធំ និងច្រើនជាងបើប្រៀបធៀបជាមួយតម្លៃ ដែលគាត់ត្រូវតែផ្តល់ទៅឲ្យថៅហ្វាយនាយវិញ នោះកសិករនឹងមើលឃើញថា ថៅហ្វាយនាយគួរតែអាចទទួលអំណាច ឬឥទ្ធិពលរបស់ខ្លួនដោយស្របច្បាប់ ។ នៅទីនេះយើងត្រូវតែមានការពិចារណាដោយប្រុងប្រយ័ត្នបំផុត លើទម្រង់ទាំងមូលនៃការជួយគ្នាទៅវិញទៅមក ដែលកសិករបានអនុវត្តន៍ និងភាពលំបាកក្នុងការរៀបចម្ការដាំដុះ និងការបែងចែកគ្រាប់ពូជ ។ ទោះបីជាទស្សនៈស្តីពីតុល្យភាពនៃការដោះដូរដែលយកមកប្រើនៅទីនេះ មិនអាចកម្រិតចំនួនបានដោយផ្ទាល់ក៏ដោយ ក៏ជារឿយៗយើងអាចមើលឃើញយ៉ាងប្រាកដបានទាំងទៅលើទិសដៅ និងទាំងទៅលើទំហំប្រហាក់ប្រហែល នៃការផ្លាស់ប្តូរនៅក្នុងទម្រង់ជាក់លាក់មួយ(១០) ។

និយាយឲ្យខ្លីទៅអំណះអំណាងដែលបានបង្ហាញនៅទីនេះ គឺថាអារម្មណ៍របស់កសិករ ទាំងបុគ្គលម្នាក់ៗ និងសហគមន៍ទាំងមូលចំពោះគហបតីម្ចាស់ដី មានទិសដៅដ៏សំខាន់មួយ ហើយមិនមែនជាបញ្ហាធម្មតានៃរឿងមនោ-សិការ និងមនោគមវិជ្ជាឡើយ ។ គេអាចនិយាយឲ្យកាន់តែស៊ីជម្រៅថែមទៀតថា កសិករមានសញ្ញាណដែលមិនអាចបកស្រាយបានមួយចំនួន ដែលទាក់ទងទៅនឹងតុល្យភាពនៃការដោះដូរ ថាតើអ្វីដែលជាតម្លៃក្នុងការជំរុញឲ្យពួកគេទទួលយក នូវសេវារបស់ពួកថៅហ្វាយនាយ ហើយដែលថាខ្លឹមសារនៃកម្មវត្ថុនៃការប្រែប្រួលក្នុងតុល្យភាពដទៃៗផ្សេងទៀត អាចមានជាប់ពាក់ព័ន្ធទៅនឹងការប្រែប្រួល ឥទ្ធិពល ឬអំណាចក្នុងការទាក់ទងនៃការដោះដូរ ។

## ភាពស្មុគស្មាញ និងថេរភាព

ប្រសិនបើអំណាច ឬឥទ្ធិពលរបស់ថៅហ្វាយនាយចំពោះកូនចៅ នៅក្នុងតុល្យភាពនៃការដោះដូរ គឺជាសមីការស្មើមួយនោះ ដំណើរការរបស់យើងច្បាស់ជាទៅមុខយ៉ាងងាយជាមិនខាន ។ ប៉ុន្តែ ពហុភាពនៃអត្តសញ្ញាណមនុស្ស និងលក្ខណៈប្រែប្រួលនៃតម្រូវការរបស់មនុស្ស បានធ្វើឲ្យរូបមន្តដែលងាយស្រួល ឬសាមញ្ញមួយក្លាយទៅជារូបមន្តមួយ ដែលគេមិនអាចយល់បានទៅវិញ ។ លក្ខណៈសម្បត្តិ ឬការកែប្រែជាមូលដ្ឋានពីរ ហាក់ដូចជាចាំបាច់ដើម្បីយកមកបង្កើតជាឧបករណ៍សម្រាប់ធ្វើការវិភាគ ដែលអាចឆ្លុះបញ្ចាំងនូវទំនាក់ទំនងដែលកាន់តែសាំញ៉ាំខ្លាំងឡើងនៅពេលដែលរឿងមួយនេះ ក្លាយទៅជារឿងមួយដែលកាន់តែរញ៉េរញ៉ៃនោះ ។ ជាពិសេស គំរូដ៏ងាយស្រួលមួយនេះបានបង្ហាញឲ្យឃើញនូវការរេឥទ្ធិពលនៃការប្រែប្រួលភ្លាមៗ នៅក្នុងតុល្យភាពនៃការជួយគ្នាទៅវិញទៅមកទៅលើឥទ្ធិពលស្របច្បាប់របស់ថៅហ្វាយនាយ និងបង្ហាញឲ្យឃើញថា វត្តមាននៃភាពខុសប្លែកគ្នាលើផ្នែក

វប្បធម៌ និងរូបបី ដែលនៅពីក្រោយការរងឥទ្ធិពល និងមានការប្រែប្រួល មិនឋិតថេរ ។

## ការបែកចាក់នៃស្ថិរភាពក្នុងការដោះដូរ

នៅក្នុងបរិបទដីធ្លីដែលមានស្ថិរភាពនោះ ទំនាក់ទំនងអំណាចរវាងកសិករ និងគហបតី អាចបង្កើតនូវបទដ្ឋាននៃការជួយគ្នាទៅវិញទៅមកមួយ ដែលជាកញ្ចប់ស្តង់ដារមួយនៃសិទ្ធិក្នុងការជួយគ្នាទៅវិញទៅមក ក៏ដូចជាកាតព្វកិច្ច ដែលតម្រូវឲ្យមាននូវកម្លាំងសីលធម៌ផ្ទាល់មួយ ។ បទដ្ឋានទាំងនោះ (ដែលបានផ្តល់ឲ្យនូវការការពារ និងសុវត្ថិភាពជាមូលដ្ឋានដល់អ្នកពឹងពាក់) នឹងប្រឆាំងយ៉ាងដាច់ខាត ចំពោះការបែកបាក់ទាំងឡាយណាដែលគំរាមកំហែងទៅដល់កម្រិត នៃផលប្រយោជន៍របស់កសិករ ។ ការខិតខំភ្លាមៗក្នុងការតម្រែតម្រង់បទដ្ឋានទាំងនេះនឹងត្រូវគេចាត់ទុកថាជាការរំលោភបំពានមួយលើកាតព្វកិច្ចជាប្រពៃណី របស់ចៅហ្វាយនាយ ។ នេះ គឺជាការបំពានមួយខាងផ្នែកសីលធម៌ដែលនាំឲ្យមានការចងកំហឹងពីសំណាក់ពួកកសិករ ។ ហេតុនេះហើយ ទើបរាល់តុល្យភាពនៃការដោះដូរ ដែលមានកម្រិតលើសពីលើកិច្ចព្រមព្រៀងនោះ កសិករទទួលយកនូវឥទ្ធិពលរបស់ពួកម្ចាស់ដី ។ ប៉ុន្តែនៅពេលមានការប្រែប្រួលដ៏តិចតួចណាមួយបានខិតចេញពីតុល្យភាពនៃការព្រមព្រៀង ដែលអាចនឹងកាត់បន្ថយនូវផលប្រយោជន៍របស់ប្រជាកសិករនោះហេតុការណ៍នេះហាក់ដូចជាបានបញ្ឆេះឲ្យកើតមានឡើង នូវការតស៊ូដ៏ឃោរឃៅ ។

ការការពារនូវការដោះដូរជាលក្ខណៈប្រពៃណី របស់កសិករនៅក្នុងករណីបែបនេះ គឺគ្មានសញ្ញាណណាមួយដែលបង្ហាញពីការរាថយឡើយ ។ ជាការពិតណាស់ គេតែងមានការភ័យខ្លាចលើដំណើរនៃការធ្វើឲ្យមានតុល្យភាពឡើងវិញមួយ អាចជាទង្វើនៃការប្រឆាំងតទល់នឹងពួកគេទៅវិញ ឧទាហរណ៍យ៉ាងសាមញ្ញបំផុតមួយ ទាក់ទងទៅនឹងស្ថានភាពបែបនេះ គឺការបះបោររបស់ពួកកសិករនៅអង់គ្លេស នាទសវត្សរ៍ឆ្នាំ ១៨៣០ នៅពេលដែលកម្មករកសិដ្ឋានបានទាមទារឲ្យរក្សានូវទម្លាប់ជាប្រពៃណីក្នុងស្រុក ក្នុងការជួល និងផ្តល់ការងារ ហើយប្រឆាំងទៅនឹងការកែលម្អផ្នែកពាណិជ្ជកម្មរបស់ពួកម្ចាស់ដី ។[១១] ប្រសិនបើវណ្ណៈចៅហ្វាយនាយគិតថា អំណាចនៃការចរចារជាមួយកូនចៅកសិករកាន់តែយ៉ាប់យ៉ឺនទៅៗនោះ ឧទាហរណ៍ ដូចជាស្ថានភាពមួយនៃការទាក់ទងគ្នាទៅវិញទៅមកនៅសតវត្សរ៍ទី ១៨ រវាងពួកអភិជននៅជនបទនៃប្រទេសបារាំង និងពួកកសិករ ដែលបម្រើឲ្យវិស័យពាណិជ្ជកម្មនោះយើងឃើញថា គួរតែជាពួកអភិជនទាំងនោះទេដែលជាអ្នកទាមទារការការពារទៅលើបទដ្ឋានជាប្រពៃណីមិនមែនពួកកសិករទាំងនោះឡើយ ។ រឿងនេះផ្ទុយទៅវិញនោះ ក៏ព្រោះថាជារឿយៗការធ្វើពាណិជ្ជកម្មខាងផ្នែកកសិកម្ម តែងប្រឆាំងទៅនឹងផលប្រយោជន៍របស់កសិករ ដូច្នេះហើយយើងឃើញវណ្ណៈកសិករជាទូទៅជាអ្នកការពារសិទ្ធ និងកាតព្វកិច្ចជាប្រពៃណីប្រឆាំងនឹងការធ្លាក់ចុះ ហើយជាអ្នកទាមទារឲ្យមានការស្តារឡើងវិញ នូវស្ថានភាពដែលធ្លាប់មានពីមុនមក ។

## សិទ្ធិសង្គមជាមូលដ្ឋាន

ចំពោះអ្នកពឹងពាក់ គោលបំណងសំខាន់នៃកិច្ចសន្យារវាងចៅហ្វាយនាយ-អ្នកពឹងពាក់ ក៏ដូចជាគោលសំខាន់ចំពោះភាពស្របច្បាប់នៃកិច្ចសន្យានោះ គឺជាការផ្តល់នូវការធានាផ្នែកសង្គមជាមូលដ្ឋាននៃការចិញ្ចឹមជីវិត និងសុវត្ថិភាព ។ ប្រសិនបើនៅពេលដែល កិច្ចព្រមព្រៀងពាណិជ្ជកម្មមានសភាពកាន់តែយ៉ាប់យ៉ឺន ល្មមអាចនឹងគម្រាម

កំហែងដល់សិទ្ធិសង្គមដែលជាប្រភពដ៏ចម្បងនៃទំនាក់ទំនង និងការគោរព នោះយើងអាចមើលឃើញថា អ្នកពឹងពាក់នឹងចាត់ទុកទំនាក់ទំនងនោះថា មានភាពអយុត្តិធម៌ និងកេងប្រវ័ញ្ច ។ ពេលនោះភាពស្របច្បាប់លែងជាសមីការស្មើមួយនៃទំនាក់ទំនងរវាងចៅហ្វាយនាយ-អ្នកពឹងពាក់ នៅក្នុងតុល្យភាពនៃការដោះដូរទៀតហើយ ។ ជំនួសមកវិញ យើងសង្កេតឃើញមានចំណុចចាប់ផ្តើមជាច្រើន សម្រាប់អ្នកពឹងពាក់ ដែលការបាត់បង់ភាពស្របច្បាប់ត្រូវបានធ្វើឡើងយ៉ាងឆាប់រហ័ស និងពិតប្រាកដ ។ គ្មានការសង្ស័យទេដែលថា ចំណុចចាប់ផ្តើមមានទិដ្ឋភាពវប្បធម៌ មួយដោយសារតែចំណុចទាំងនេះពឹងផ្អែកជាចាំបាច់ ចំពោះការបំពេញឲ្យបាននូវវប្បធម៌ដ៏តូចបំផុតនៃសុភាវធម៌ឧទាហរណ៍ដូចជាការថែទាំឪពុកម្តាយចាស់ៗ ការប្រារព្ធពិធីបុណ្យវប្បធម៌ជាដើម ប៉ុន្តែចំណុចទាំងនេះក៏មានវត្ថុបំណងផងដែរ ដូចជា ការមានដីគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារ ការមានជំនួយគ្រប់គ្រាន់នៅពេលពួកគេមានជំងឺ ឬគ្រោះថ្នាក់ផ្សេងៗ និងការការពាររាងកាយប្រឆាំងនឹងមជ្ឈដ្ឋានខាងក្រៅ ។ ទំនាក់ទំនងនៃការពឹងផ្អែកដែលផ្តល់ឲ្យនូវការធានាតូចតាចទាំងនេះ នឹងរក្សាទុកនូវស្នូលនៃភាពស្របច្បាប់ ប៉ុន្តែអ្នកដែលបដិសេធចោលនូវសិទ្ធទាំងនេះ គឺជាអ្នកបំពានដល់ស្តង់ដារកាតព្វកិច្ច ដូច្នេះពួកគេបាត់បង់នូវគន្លឹះសំខាន់របស់ខ្លួន ក្នុងការទាមទារឥទ្ធិពលស្របច្បាប់ដែរ ។

នៅក្នុងសង្គមដែលវណ្ណៈកសិករ និងវណ្ណៈតូចតាចថ្នាក់ក្រោមភាគច្រើនមិនចង់រំពឹង ហើយមិនត្រូវគេចាត់ទុកថាជាផ្នែកមួយនៃកិច្ចការរដ្ឋាភិបាលខាងផ្នែកនយោបាយនោះ ការរំពឹងទុកដែលគ្មានលាយលក្ខណ៍អក្សរ ចំពោះអ្នកមិនចូលរួមដែលជាវណ្ណៈតូចតាច កម្រិតអប្បបរមានៃការចិញ្ចឹមជីវិត និងការការពារមួយ ត្រូវធានាដោយអភិជនដែលជាវណ្ណៈនយោបាយ ។ បន្ទាប់មកទៀត ចំណុចស្នូលនៃការជួយគ្នាទៅវិញទៅមកក្នុងសម្ព័ន្ធចៅហ្វាយនាយ-អ្នកពឹងពាក់ គឺជាការដោះដូរនៃសេចក្តីគោរព និងការផ្គាប់ចិត្តរបស់អ្នកពឹងពាក់ នៅក្នុងការឆ្លើយតបទៅនឹងចៅហ្វាយនាយ ចំពោះការផ្តល់ឲ្យនូវសិទ្ធិសង្គមដ៏តិចតួច ។ នៅពេលដែលការធានាទាំងអស់នេះ ត្រូវបានខូចរចនាសម្ព័ន្ធនៃការមិនរួមបញ្ចូលវណ្ណៈកសិករនោះបាត់បង់ធាតុសំខាន់នៃភាពស្របច្បាប់របស់ខ្លួន ។ សម្រាប់ចៅហ្វាយ-នាយ ការដួលរលំនៃការធានាទាំងអស់នោះ នឹងគំរាមកំហែងដល់ជំហររបស់គាត់ នៅក្នុងចំណោមកូនចៅរបស់ខ្លួន ។ ប៉ុន្តែ ទំហំដ៏ធំធេងនៃការបាត់បង់នូវការធានាបែបនេះ អាចគំរាមកំហែងដល់ភាពស្របច្បាប់ជារួមរបស់វណ្ណៈចៅហ្វាយនាយទាំងមូល ។

## តួនាទី ឬជំហែងអាស្រ័យលើការចរចារ

តុល្យភាពក្នុងការដោះដូរពិសេសមួយ នៅក្នុងទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់ ច្បាស់បញ្ជាក់ឲ្យឃើញពីតួនាទី ឬជំហែងដែលអាស្រ័យនឹងការចរចាររបស់ក្រុមទាំងពីរៗ ករណីនេះ គឺយើងត្រូវមើលថា តើអ្នកពឹងពាក់ត្រូវការចៅហ្វាយនាយ ច្រើនជាងចៅហ្វាយនាយត្រូវការអ្នកពឹងពាក់ក្នុងកម្រិតណាទៅ ។ ចៅហ្វាយនាយ គឺជាអ្នកមានអំណាចនៅពេលដែលគាត់អាចត្រួតត្រា ទៅលើមុខទំនិញ និងសេវាដែលសំខាន់ៗ ចំបាច់សម្រាប់ចិញ្ចឹមជីវិតដែលនៅកន្លែងដទៃទៀត របស់ទាំងនេះស្ថិតនៅក្នុងភាពមិនឋិតថេរនោះ ។ ប៉ុន្តែ ប្រសិនបើគ្មានការទាមទារចង់បាននូវដីដែលអាចបង្កបង្កើនផលបាន និងប្រសិនបើកសិករអាចត្រលប់ទៅពឹងក្រុមសាច់ញាតិ ឬបក្សពួករបស់គេឲ្យជួយការពារ ហើយពួកគេអាចទៅពឹងអ្នករកស៊ីចងការ ដើម្បីខ្ចីលុយបានវិញនោះការពំនាក់អាស្រ័យរបស់អ្នកពឹងពាក់លើចៅហ្វាយនាយ គឺហាក់ដូចជាមិនសូវមានទេ ។ ចំពោះភាគីខាងក្រុមអ្នកពឹងពាក់វិញ ប្រហែលជា

អាចស្ថិតនៅក្នុងជំហរដ៏ប្រសើរជាងមុន ប្រសិនបើសមាជិកនៃពួកគហបតី គិតថាចាំបាច់ត្រូវតែបង្កើត និងគាំពារក្រុមអ្នកដែលមកពឹងពាក់ខ្លួននោះ ។[១២] កត្តាសំខាន់ៗមួយចំនួន ដែលមានការជជែកកន្ទងមកបានលើកឡើងថា តម្លៃក្នុងការបង្កើតក្រុមអ្នកពឹងពាក់មានដូចជា: តម្រូវការដើម្បីធានា ឲ្យមានកម្លាំងពលកម្មជាអចិន្ត្រៃយ៍ និងគួរឲ្យទុកចិត្តបាន នៅពេលដែលតម្លៃឈ្នួលលើកម្លាំងពលកម្មមិនសមល្មម ទៅនឹងទំហំនៃការទារតម្រូវការការផ្គត់ផ្គង់កម្លាំងពលករ ច្រើនគួរសម ដើម្បីការពារតំបន់ត្រួតត្រារបស់ពួកចៅហ្វាយនាយ ឬនៅក្នុងពេលថ្មីៗនេះកើតមាននូវតម្រូវការនៃការបោះឆ្នោតគាំទ្រមតិដើម្បីទទួលជោគជ័យទៅលើការគ្រប់គ្រងធនធានក្នុងស្រុក ។

ប៉ុន្តែកត្តាទាំងនេះ ប្រហែលជាការធានាដ៏ប្រសើរបំផុតមួយ ជាជាងកត្តាពីខាងក្រៅផ្សេងទៀត សម្រាប់ពួកចៅហ្វាយនាយ ក្នុងការប្រកាន់យកនូវរាល់លក្ខខណ្ឌនៃការដោះដូរទាំងឡាយណា ដែលធ្វើឲ្យគេមានឥទ្ធិពលក្នុងចំណោមអ្នកពឹងពាក់ ។ ប្រសិនបើគាត់ពឹងអ្នកក្រៅដូចជាប៉ូលិស តុលាការ ឬកំយោធា មកធ្វើជាខ្នងបង្អែកដើម្បីការពារអំណាចត្រួតត្រារបស់ខ្លួនលើធនធានក្នុងស្រុកនោះ គេអាចនឹងប្រើឥទ្ធិពលរបស់ខ្លួននៅក្នុងតំបន់បានក្នុងកម្រិតមួយតិចតួចប៉ុណ្ណោះ ។ ផ្ទុយទៅវិញ ប្រសិនបើគ្រឹះនៃអំណាចរបស់គេ គឺជាអ្នកស្រុកក្នុងតំបន់គេផ្ទាល់ ហើយប្រសិនបើគេត្រូវការអ្នកគាំទ្រដែលស្មោះត្រង់នឹងខ្លួន ដើម្បីការពារ និងធ្វើឲ្យអំណាចនៃការគ្រប់គ្រងទៅលើធនធានក្នុងស្រុករបស់ពួកគេមានសុពលភាពនោះ គេនឹងទទួលបាននូវផលចំណេញយ៉ាងស្របច្បាប់មួយ គឺផលចំណេញដែលអាចរក្សាបាននូវឥទ្ធិពល ឬអំណាចរបស់ខ្លួនពីសំណាក់ពួកអ្នកគាំទ្រទាំងនោះ។

ការពិភាក្សាខាងក្រោម នឹងបង្ហាញពីបណ្តុំនៃស្ថានភាពក្នុងការចរចាររបស់អ្នកពឹងពាក់ ដែលផ្អែកយ៉ាងខ្លាំងទៅលើកត្តាដែលពាក់ព័ន្ធគ្នាមួយចំនួនដូចជា កាន់កាប់ដីធ្លី កំណើនប្រជាជន និងការពង្រីកនៃអំណាចរបស់រដ្ឋ ។

## ស្ថានភាពទូទៅ នៃភាពជាចៅហ្វាយជាយជាសម័យបុរាណ

ប្រពៃណីរបស់អាស៊ីអាគ្នេយ៍ គឺជាអាហារូបត្ថម្ភមូលដ្ឋានសម្រាប់ដំណើរវិវឌ្ឍន៍ នៃចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ ។ ដូចជានៅអឺរ៉ុបសម័យសក្តិភូមិដែរ រដ្ឋមានសភាពទន់ខ្សោយ ហើយជាទូទៅ មិនអាចធានាសុវត្ថិភាព ឬទ្រព្យសម្បត្តិរបស់បុគ្គលម្នាក់ៗនៅក្នុងព្រំដែនរដ្ឋនោះបានទេ ។ អំណាចដែលមានឥទ្ធិពល ជាអំណាចនៅក្នុងស្រុក ហើយអំណាចនៅក្នុងស្រុកជាអំណាចស្វយ័តដ៏ធំ ។ ជាពិសេស នៅក្នុងរដ្ឋឥណ្ឌានីយកម្ម (រដ្ឋដែលទទួលឥទ្ធិពលពីឥណ្ឌា) ទស្សនៈគ្រប់គ្រងបែបរាជានិយម និងអំណាចគឺជារឿងបុគ្គល និងជាឥទ្ធិពលទាក់ទាញជាជាងការិយាធិបតេយ្យ និងស្ថាប័ន ។[១៣] ដូច្នេះហើយ អាជ្ញាធរតាមអាណត្តិដែលនៅក្មេងខ្ចីទោះជាបានសម្រេចគោលបំណងហើយក្តី បើអាជ្ញាធរនេះមានបំណងធ្វើឲ្យអំណាចផ្ទាល់របស់ខ្លួនមានភាពស្របច្បាប់ លុះណាតែអ្នកថែរក្សានៅក្នុងស្រុកបង្ហាញនូវភាពស្មោះត្រង់ចំពោះអំណាចកណ្តាល និងបំពេញកង្វះខាតផ្នែកពន្ធអាករ ឬកំសេវារបស់រដ្ឋាភិបាលផ្សេងៗដែលទាមទារ ។ អ្នកមានតំណែង មានឥទ្ធិពលជាចៅហ្វាយនាយទៅលើអ្នកតាមហែហមរបស់គាត់ច្រើនជាងអ្នករដ្ឋបាល ។

ប្រសិនបើអំណាចកណ្តាល (ព្រះរាជា ឬរដ្ឋាភិបាល) មិនបានផ្តល់ឲ្យនូវយន្តការមួយដែលមានប្រសិទ្ធភាពដើម្បីការពារ និងរក្សាសុវត្ថិភាពទេនោះ ផ្នែកដ៏តូចៗជាច្រើននៃប្រពៃណីនឹងមិនមានភាពគ្រប់គ្រាន់ពេញលេញឡើយ ។ នៅកន្លែងដែលក្រុមសាច់ញាតិសហការគ្នា និងរចនាសម្ព័ន្ធភូមិដែលមានភាពស្អិតរមួតនោះ (ដូចដែលបានអនុវត្តន៍ក្នុងកម្រិតមួយចំនួននៅប្រទេសវៀតណាម និងកោះជ្វាជាដើម) នៅទីនោះ ចំណងទាក់ទងតាមឋានានុ

ក្រុមពីធំមកតូចបានកាត់បន្ថយ ។ ប៉ុន្តែ សូម្បីតែនៅក្នុងតំបន់បែបនេះក្តី ក៏ចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ នៅតែត្រូវបានគេប្រើយ៉ាងទូលំទូលាយ ដើម្បីជំនួសឲ្យយន្តការសែស្រលាយ និងភូមិនៅពេលអវត្តមានការរៀបចំតំបន់ និងអំណាចសាធារណៈរបស់រាជាណាចក្រដ៏ធំទាំងនោះ ។

លក្ខណៈនៃចំណងទាក់ទងជាប្រពៃណីរបស់ចៅហ្វាយនាយ-អ្នកពឹងពាក់នៅតំបន់អាស៊ីអាគ្នេយ៍មានភាពខុសៗគ្នាយ៉ាងច្រើនពីសម័យមួយទៅសម័យមួយ និងពីតំបន់មួយទៅតំបន់មួយទៀត ។ ចំណងទាក់ទងទាំងនោះប្រហែលជាត្រូវគេបង្កើត និងបង្កប់នៅក្នុងប្រព័ន្ធជាន់ថ្នាក់ដ៏ធំទូលាយ នៅក្នុងរាជាណាចក្របែបប្រពៃណីរបស់សៀម ភូមា និងនៅរដ្ឋ ក្រាតុង នៃកោះជ្វា ។ នៅប្រទេសថៃ និងភូមាពួកអភិជនដែលមានមូលដ្ឋាននៅក្នុងស្រុកត្រូវបានគេប្រគល់សិទ្ធិឲ្យទទួលយកសេវាកម្មពីគ្រួសារកសិករមួយចំនួន ទិញដោយគ្រួសារ ទាំងនោះជាច្រើនជំនាន់ ។[១៤] ប្រព័ន្ធបន្ទាប់បន្សំមួយដែលគ្រប់គ្រងព្រៃចាដី នៅកោះជ្វាមានលក្ខណៈច្រើនដូចគ្នា ។ទោះបីជាអាចនឹងមានកំហុស ទៅលើការប៉ាន់ស្មានជ្រុលពីភាពមាំមួន ឬភាពជាប់លាប់ក៏ដោយ ក៏ការរៀបចំបែបនេះមានសភាពនឹងហ្នរ ឬមាំទាំជាងរចនាសម្ព័ន្ធអាជ្ញាធរថ្នាក់ស្រុកនៅរដ្ឋម៉ាឡេ លូហ្សិន ឬអាណាចក្រតណ្ហូនេស៊ីនៅតាមតំបន់ឆ្នេរសមុទ្រ ។ មកដល់ចំណុចនេះតួនាទីរដ្ឋអំណាចកណ្តាល ហើយនិងលំដាប់ថ្នាក់ជាប្រពៃណី គឺជារឿងមួយដ៏សាមញ្ញ នៅពេលដែលការអេះអាងចំពោះអាជ្ញាធរ ពឹងផ្អែកទៅលើសមត្ថភាពផ្ទាល់ខ្លួនម្នាក់ៗរបស់អ្នកស្រុកដើម្បីប្រមែប្រមូលនូវអ្នកគាំទ្រដ៏រឹងមាំ ជាហេតុទទួលបាននូវការទទួលស្គាល់ពីមេដឹកនាំល្បីប្រចាំតំបន់ ក្នុងនាមជាភ្នាក់ងាររបស់ពួកគេ ។ ចំណុចចុងក្រោយ នៅក្រៅដែនអាណាចក្រ ក្នុងពេលដែលមានភាពច្របូកច្របល់ ឬការធ្លាក់ចុះនៃសន្តិវង្ស ក៏ដូចជា នៅតាមតំបន់ខ្ពង់រាបខ្វះដែរ បណ្តាញចៅហ្វាយនាយ-អ្នកពឹងពាក់ ត្រូវគេរៀបចំដោយរចនាសម្ព័ន្ធមិនទៀងទាត់ នៅជុំវិញដំណើរពាណិជ្ជកម្ម ការហូតពន្ធលើផ្លូវពាណិជ្ជកម្ម ឬអំពើលួចប្លន់ ។ យើងអាចនិយាយដោយយុត្តិធម៌បានថា កាលណាស្ថិតនៅកាន់តែជិតទៅនឹងអំណាចកណ្តាល តាមរយៈវប្បធម៌ក្តី ភូមិសាស្ត្រក្តី និងឋានៈ នោះសាច់រឿងនៃកិច្ចសន្យាចៅហ្វាយនាយ-អ្នកពឹងពាក់នឹងកាន់តែមានកម្រិតច្រើនឡើង និងកាន់តែជាក់លាក់ត្រឹមត្រូវខាងផ្នែកវប្បធម៌ ។ កាលណាយើងនៅកាន់តែឆ្ងាយពីអំណាចកណ្តាល ដូចនៅតំបន់ដាច់ស្រយាលវប្បធម៌ខាងក្រៅ និងនៅតាមតំបន់ដែលផ្តោតសំខាន់ទៅលើឋានានុក្រមនៃសង្គម នោះចំណងចៅហ្វាយនាយ-អ្នកពឹងពាក់ គឺអាចកើតមានឡើងបានតិចតួច ហើយលើសពីនេះ គឺមានសភាពបត់បែន ។

សារៈសំខាន់ និងប្រសិទ្ធភាពនៃចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ត្រូវតែមានការប្រែប្រួលពីសម័យកាលមួយទៅសម័យកាលមួយ និងពីកន្លែងមួយទៅកន្លែងមួយ ។ ប្រហែលជាមានន័យច្បាស់លាស់ដល់ការគិតពីរចនាសម្ព័ន្ធចៅហ្វាយនាយ-អ្នកពឹងពាក់ ជាការពង្រីក ឬបង្រួមជាច្រើនលើកច្រើនសារ ដូចគ្នាទៅនឹង លោកលិចធ៍ពិពណ៌នាអំពីការប្រែប្រួលសង្គមកាឈីន នៅចន្លោះទម្រង់ក្រុមអ្នកភូមិតូចៗដែលយកទម្រង់នៃសាច់ញាតិជាមូលដ្ឋាន និងប្រព័ន្ធមេប្រចាំតំបន់ ។[១៥] កាលៈទេសៈដែលអំណោយផលដល់សេដ្ឋកិច្ច បានបើកឱកាសឲ្យមានការរីកចម្រើនច្រើនឡើងៗ នៃចំណងទាក់ទងបន្ថែមនៃចៅហ្វាយនាយ-អ្នកពឹងពាក់ ដែលក្រោយមករលត់រលាយទៅវិញ ឬមិនមានការរីកចម្រើនតទៅទៀតនៅក្នុងស្ថានការលំបាកនោះ ។

កត្តាសំខាន់ស្តីអំពីទំនាក់ទំនងជាប្រពៃណី របស់ចៅហ្វាយនាយ-អ្នកពឹងពាក់ នៅក្នុងតំបន់នោះ គឺថាប្រភពឬធនធានសម្រាប់ការចរចាររបស់អ្នកពឹងពាក់ បានការពារតុល្យភាពនៃការដោះដូរឲ្យឃ្លាតចាកឆ្ងាយ ពីផលប្រយោជន៍របស់ពួកចៅហ្វាយនាយ ។ ក្រៅពីតម្រូវការផ្នែកសុវត្ថិភាពរបស់អ្នកពឹងពាក់ យើងឃើញថាលក្ខណៈជាក់

លាក់នៃទម្រង់បែបបុរាណ បានធានាដល់អ្នកពឹងពាក់នូវកម្រិតអប្បបរមានៃការជួយគ្រួលប់មកវិញប៉ុណ្ណោះ ។ ដែនកំណត់នៃលទ្ធភាពរបស់ចៅហ្វាយនាយ ក្នុងការគាបសង្កត់ទៅលើអ្នកពឹងពាក់អាចអាស្រ័យនឹង (១) លទ្ធភាពនៃសេស្រឡាយ និងវចនាសម្ព័ន្ធភូមិ ក្នុងការជំនួសដល់មុខងារចៅហ្វាយនាយមួយចំនួន (២) ដីធ្លីដែលមិនមានអ្នកកាន់កាប់ ដែលអាចឲ្យអ្នកពឹងពាក់គៀសខ្លួនទៅនៅតំបន់ដីទំនេរទាំងនោះបាន និង (៣) អសមត្ថភាពរបស់រដ្ឋបាលកណ្តាល ដែលមានការខ្វះខាតទាំងកម្លាំង និងភាពដាប់លាប់ខាងការថែរក្សា និងធានាដល់មុខដំណែងនៃវរជននៅតាមតំបន់ ឬវិមជ្ឈការអំណាចតាមតំបន់ ។ សុវត្ថិភាពនៅពេលដែលគ្មានបទបញ្ជា ដែលមានប្រសិទ្ធភាពយន្តការសង្គមជាច្រើនផ្សេងទៀត ដែលដើរតួរជាភ្នាក់ងារការពារថែរក្សា និងជំរុញឲ្យមានការរីកចម្រើននោះគឺជាក្រុមសាច់ញាតិអ្នកភូមិ ឬអ្នកភូមិតូចៗ និងទំនាក់ទំនងទ្វេភាគីរបស់ចៅហ្វាយនាយ-អ្នកពឹងពាក់ ។ បើទោះបីជា បុគ្គលភាគច្រើនជាប់ជំពាក់ជំពិនទៅនឹងក្រុមទាំង ៣ ខាងលើយ៉ាងណាក្តី ប្រសិនបើការធានាផ្នែកសង្គមរបស់អ្នកភូមិ និងសេស្រលាយកាន់តែមានប្រសិទ្ធភាពឡើងនោះ សារៈសំខាន់ផ្នែកសង្គមនៃទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់កាន់តែមានភាពថយចុះដាលំដាប់ទៅដែរ ។ ទំនាក់ទំនងនីមួយៗមានចំណុចខ្លាំង និងចំណុចខ្សោយដោយឡែកៗពីគ្នា ហើយអំណះអំណាងមានព្រំដែនបានបង្ហាញថា សង្គមដែលកាន់តែមានភាពស៊ាំញ៉ាំ សារៈសំខាន់នៃទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់នឹងកាន់តែមានការកើនឡើងដែរ[១៦] ។ ទាំងនេះ គឺព្រោះតែភាពស៊ាំញ៉ាំបានបង្ហាញនូវកំណើននៃតម្រូវការទំនាក់ទំនងខាងផ្នែកសេដ្ឋកិច្ច និងនយោបាយក្រៅពីបណ្តាញសេស្រលាយ និងអ្នកភូមិរបស់ខ្លួន ។ សង្គមដែលកាន់តែមានភាពស៊ាំញ៉ាំ ក៏បានផ្តល់ផលលើសដោយសារឋានៈសមរម្យ និងទ្រព្យធនយូរអង្វែងមានមូលដ្ឋាននៅលើការដោះដូរវាងចៅហ្វាយនាយ-អ្នកពឹងពាក់ ។ ហេតុនេះហើយយើងអាចគិតទុកជាមុនថា តួនាទីនៃវចនាសម្ព័ន្ធចៅហ្វាយ-អ្នកពឹងពាក់គួរតែមានភាពខ្លាំងក្លានៅតំបន់វាលទំនាប ដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងប្រព័ន្ធរដ្ឋបាល និងវប្បធម៌នៃអាណាចក្រតំបន់វាលទំនាប និងមានតួនាទីតូចតាចនៅក្នុងតំបន់ដាច់ស្រយាល ។

នៅក្នុងបែបផ្សេងៗជាច្រើន ទំនាក់ទំនងសេស្រលាយ គឺជាបណ្តាញសុវត្ថិភាពដ៏ស្អិតរមួតនឹងអាចពឹងផ្អែកបានបំផុត ។ នេះប្រហែលដោយសារតែបណ្តាញនេះ គឺជាបណ្តាញតែមួយគត់ដែលផ្តល់ឲ្យតាមរយៈរូបរាងសាច់ឈាម ។ ទំនាក់ទំនងនេះ គឺជាគំរូដ៏ល្អបំផុតនៃសាមគ្គីភាពសម្រាប់ការការពារ ។[១៧] យើងអាចនិយាយដោយគ្មានការសង្ស័យថាចំណុចស្នូលនៃប្រសិទ្ធភាពរបស់ប្រព័ន្ធសេស្រលាយមួយនេះ គឺជាមុខងារដើមដែលជាឧបករណ៍សងសឹកបង្ហូរឈាមសម្រាប់សមាជិករបស់គេ ។ នៅក្នុងតំបន់ដែលអ្នកភូមិ និងសេស្រលាយ គឺជាសហគមន៍ដូចជាសហគមន៍នៅតំបន់ខ្ពង់រាបមួយចំនួន ឬនៅកន្លែងដែលក្រុមសាច់សាលោហិតកាន់កាប់ទៅលើដីធ្លី និងធនធានជាច្រើនផ្តាច់មុខ នោះតួនាទីក្នុងផ្នែកសហប្រតិបត្តិការ និងការពាររបស់ប្រព័ន្ធនេះមានកម្រិតអតិបរមា ។

ប៉ុន្តែក្រុមសាច់ញាតិតែមួយនោះ កម្រជាមូលដ្ឋាននៃសហគមន៍ ដែលអាចផ្គត់ផ្គង់ខ្លួនដោយខ្លួនឯងណាស់ ។ ហេតុផលសំខាន់មួយចំពោះភាពមិនគ្រប់គ្រាន់នេះ គឺលក្ខណៈតូចចង្អៀតរបស់ប្រព័ន្ធមួយនេះ ។[១៨] ឧទាហរណ៍ដូចជា នៅក្នុងការសិក្សារបស់លោកឡមែនស្តីអំពីសង្គមស៊ីន បានបង្ហាញថា នៅក្នុងកាលៈទេសៈផ្សេងៗគ្នាជាច្រើនដូចជា «តម្រូវការសម្រាប់ការរស់នៅ នៅពេលដែលមានកង្វះខាតស្បៀងអាហារ តម្រូវការក្នុងការលោះខ្លួនឯង ឬបងប្អូន តម្រូវការដើម្បីបង់ការផាកពិន័យដោយច្បាប់ប្រពៃណី ឬបំណងប្រាថ្នារបស់ជនរងគ្រោះពីការប្រយុទ្ធបង្ហូរឈាម ក្នុងការស្វែងរកនូវទីជម្រកសុវត្ថិភាព» បានជំរុញឲ្យប្រជាជនស៊ីនជាច្រើនដាក់ខ្លួនគេផ្ទាល់ស្ថិត

នៅក្រោមការការពាររបស់មនុស្ស ដែលមិនមែនជាសាច់ញាតិ ឬសែស្រឡាយរបស់ខ្លួន ។[១៩] នៅក្នុងករណីនេះភាពក្រីក្របំផុតនៃសង្គមស៊ីន ប្រហែលជាបានចូលរួមចំណែកដល់ការកើនឡើងនៃវណ្ណៈចៅហ្វាយនាយ ដោយហេតុថា នៅពេលដែលតម្រូវការម្ដងម្កាលដើម្បីបង្កើតក្រុមដែលមានឱនភាព តែពោរពេញដោយថាមពលបានប្រគល់អំណាចកាន់តែខ្លាំងទៅក្នុងកណ្ដាប់ដៃមនុស្សទាំងនោះដែលពួកគេបានរៀបចំវាយប្រហារទៅលើការធ្វើដំនួញ និងសកម្មភាពធក់ប្លន់ ។ នៅតំបន់វាលទំនាប ដាកន្លែងដែលការប្រាស្រ័យទាក់ទងគ្នាជាមួយមនុស្សដែលមិនមែនជាសាច់ញាតិ ឬសែស្រឡាយក្លាយទៅរឿងទូទៅមួយនោះ តម្រូវការយន្តការការពារផ្សេងទៀតមានភាពកាន់តែច្បាស់ឡើង ។

ជាទូទៅ ភូមិបុរាណនៅតំបន់អាស៊ីអាគ្នេយ៍បានដើរតួរនាទីជាប្រវត្តិសាស្ត្រមួយយ៉ាងសំខាន់ជាអង្គសាមគ្គី និងសន្តិសុខ ។ យើងអាចឃើញពីវត្តមាននៃសមូហភាព ឬការផ្តុំគ្នាតាមរយៈការបង្ហាញនៅតាមកន្លែងសក្ការៈបូជា និងពិធីបុណ្យរបស់អ្នកភូមិ ក៏ដូចជានៅក្នុងការការពារប្រឆាំងនឹងការឈ្លានពានពីខាងក្រៅ នៅក្នុងការិយាល័យឃុំ និងអាគាររបស់សហគមន៍ និងនៅក្នុងសម្ពាធប្រតិបត្តិការអនុវត្តច្បាប់ទម្លាប់ នៃការជួយគ្នាទៅវិញទៅមកនៅក្នុងមូលដ្ឋាន ។ សាមគ្គីភាពរបស់អ្នកភូមិ គឺជាចំណុចដ៏គួរឲ្យចាប់អារម្មណ៍បំផុត នៅក្នុងការដោះស្រាយជាមួយអ្នកខាងក្រៅ ប៉ុន្តែគេក៏ធ្លាប់ឃើញមានអនុវត្តន៍សាមគ្គីភាពនេះនៅក្នុងកិច្ចការក្នុងភូមិដែរ ។[២០]

គ្រប់ក្រុមគ្រួសារទាំងអស់នៅក្នុងភូមិមានគោលបំណងរួមគ្នា នៅក្នុងការទាក់ទងជាមួយនឹងរដ្ឋអំណាចកណ្ដាល និងខេត្ត ដូចជា : ការប្រាថ្នាកាត់បន្ថយពន្ធអាករ បញ្ហាសេវាកម្មរដ្ឋាភិបាល និងបញ្ហាសេវាផ្សេងៗទាញយកដោយអាជ្ញាធរពីខាងក្រៅដែលបំផ្លាញធនធានសម្រាប់បម្រើសេចក្តីត្រូវការ និងការប្រើប្រាស់នៅក្នុងភូមិ ។ ជាការពិតយើងសង្កេតឃើញថា អ្នកភូមិមានស្វាមីភក្តិទៅលើប្រព័ន្ធវប្បធម៌ដ៏ទូលំទូលាយ និងការប្រមូលពន្ធដោយស្របច្បាប់របស់អំណាចកណ្ដាល ។[២១] ប៉ុន្តែការអះអាងបែបនេះ កើតមាននៅក្រោយពេលដែលអ្នកភូមិអាចមានលទ្ធភាពរស់បានដោយខ្លួនឯង ប៉ុន្តែទោះជាយ៉ាងនោះក្តី ក៏អ្នកភូមិមិនអាចគេចចេញពីបន្ទុកដ៏ច្រើនសន្ធឹកសន្ធាប់ដែលមាននោះដែរ ។ ជាការពិត យើងអាចឃើញយ៉ាងប្រាកដនូវបំណងទាំងនោះ តាមរយៈភាពបរាជ័យរបស់បទដ្ឋានជាប្រពៃណីក្នុងការកត់ត្រាអ្នកភូមិទៅក្នុងបញ្ជី នៅប្រទេសវៀតណាម ដើម្បីកាត់បន្ថយពន្ធសរុបដែលកំណត់ដោយអំណាចកណ្ដាល ។ នៅកោះជ្វា មានចលនាល្បីថា «គំរូនៃការជំទាស់តវ៉ា ជាមួយនឹងការិយាធិបតេយ្យក្រុងរបស់ពួកជ្វា»[២២] ហើយយើងក៏ឃើញមាននៅក្នុងការអនុវត្តជាទូទៅមួយ ក្នុងការបែងចែកនូវតនាទីដ៏មានប្រសិទ្ធភាពចំពោះការដឹកនាំរបស់ភូមិ និងអ្នករដ្ឋការថ្នាក់ទាបៗពីមួយទៅមួយ ។

ភូមិបុរាណនៅតំបន់អាស៊ីអាគ្នេយ៍ អាចធានាការចិញ្ចឹមជីវិតដល់ប្រជាពលរដ្ឋទាំងមូលបាន នៅពេលណាដែលអាច ។ សម្ពាធសង្គមដូចជា ការជេរណ្ដើមគ្នា និងការច្រណែនឈ្នានីស ឬការចោទប្រកាន់ថាមានអំពើអាបធ្មប់សម្ពាធបែបនេះប្រព្រឹត្តទៅដោយលាក់កំបាំង ដើម្បីបំបាក់សេចក្តីប្រាថ្នាដែលបានរត់លឿនជាងអ្នកភូមិ ។ ពិតណាស់ថា អ្នកដែលមានលទ្ធភាពប្រសើរជាងកម្រិតមធ្យមបន្តិចបន្តួច ត្រូវគេគាបសង្កត់ឲ្យចែករំលែកទ្រព្យសម្បត្តិដើម្បីឧបត្ថម្ភពីធីបុណ្យផ្សេងៗ ដូចជា ពិធីបុណ្យសាសនា ការងារសហគមន៍ ឬជាការស្នើសុំខ្ចីប្រាក់ជាកិត្តិយស មិនសងវិញ ។[២៣] យន្តការមិនផ្លូវការទាំងនេះ (គួរឲ្យចាប់អារម្មណ៍បំផុតនៅកោះជ្វា និងតំបន់តុងកឹង) មានបន្ថែមទៀតដូចជា ការប្រើប្រាស់ដីសហគមន៍សម្រាប់ជួយដល់អ្នកមេម៉ាយ និងអ្នកភូមិទុគ៌តទាំងឡាយ ។

ដូច្នេះដូចជាក្រុមសែស្រឡាយដែរ អ្នកភូមិបានផ្តល់ការធានាបន្តិចបន្តួចខាងការការពារ និងសុវត្ថិភាព

សម្ពារៈចំពោះសមាជិករបស់គេ ។ ទង្វើបែបនេះមានប្រសិទ្ធភាពខ្លាំងនៅកន្លែងណាដែលការតាំងទីលំនៅ នៅជិត និងជាប់ៗគ្នា ។ នៅពេលណាដែលគេបើកចំហភូមិហើយ ឱកាស និងធនធានជាច្រើនដែលមានតម្លៃសម្រាប់អ្នកភូមិ ត្រូវអ្នកក្រៅគ្រប់គ្រងអស់នោះ អ្នកភូមិដូចគ្នាមិនអាចជួយគ្នាដូចមុនៗបានទេ ពួកគេត្រូវពឹងពាក់អ្នកខាងក្រៅដោយផ្ទាល់ ឬតាមរយៈការដឹកនាំអ្នកភូមិដោយមានភ្ជាប់ទំនាក់ទំនងជាមួយខាងក្រៅ ។

ការធានាបន្តិចបន្តួចរបស់សាច់ញាតិ និងអ្នកភូមិ កម្រអាចលុបបំបាត់ចោលនូវតម្រូវការចំណងទាក់ទងថៅហ្វាយនាយ-អ្នកពឹងពាក់ណាស់ ។ ប៉ុន្តែពួកគេ (សាច់ញាតិ និងអ្នកភូមិ) ពិតជាបានជួយដល់អ្នកពឹងពាក់ក្នុងការកម្រិតនូវព្រំដែន នៃឥទ្ធិពលចរចាររបស់ពួកថៅហ្វាយនាយ ។ ជាជម្រើសនៅពេលមានការប្រែប្រួល ពួកគេបានដំណើរការខ្សែរយៈសង្គមសំខាន់មួយ ជាពិសេសនៅក្នុងសហគមន៍ស្វ័យតរបស់កសិករ ដែលអាចចិញ្ចឹមជីវិតរស់ដោយខ្លួនឯងបាន ដើម្បីផ្តល់សេវាកម្មមួយចំនួនដូចទៅនឹងអ្វី ដែលថៅហ្វាយនាយអាចផ្តល់ឲ្យ ។ អាស្រ័យហេតុនេះពួកគេមិនត្រឹមតែកំណត់ទៅលើកម្រិតនៃអតុល្យភាព ក្នុងការដោះដូរនៅក្នុងប្រពន្ធ័ថៅហ្វាយនាយ-អ្នកពឹងពាក់នីមួយៗប៉ុណ្ណោះទេ ថែមទាំងកំណត់ទៅលើសារៈសំខាន់នៃឋានៈអ្នកពឹងពាក់ នៅក្នុងសហគមន៍ទាំងមូលផងដែរ ។

ចំណុចដ៏ធំមួយផ្សេងទៀត ដែលបានរាំងដល់ទម្រង់នៃការកេងប្រវ័ញ្ចពីចំណងទាក់ទង ថៅហ្វាយនាយ-អ្នកពឹងពាក់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍បុរាណ គឺជាលទ្ធភាពនៃការប្រើប្រាស់ដី ដែលអាចដាំដំណាំបានដោយសេរី ។ ករណីនេះ កើតឡើងជាពិសេសនៅក្នុងតំបន់ធ្វើកសិកម្មចល័ត ជាតំបន់មួយដែលការវិនិយោគទៅលើតំបន់ដីសម្បទាននៅមានទំហំតូច ឬជាតំបន់ដែលកសិករនៅមានភាពងាយស្រួល ក្នុងការផ្លាស់ប្តូរកន្លែងដាំដុះទៅកាន់តំបន់ដីថ្មីនៅពេលដែលគេមិនពេញចិត្តនឹងកន្លែងចាស់ ហើយពួកគេប្រហែលជាអាចនឹងសម្រេចចិត្តតាំងទីលំនៅលើតំបន់ដីថ្មីនោះថែមទៀតផង ។ តំបន់ដីទំនាបដែលមានប្រពន្ធ័ធារាសាស្រ្តស្រោចស្រព គឺជាតំបន់មានតម្លៃដែលធ្វើឲ្យមានការទាក់ទាញក្នុងការវិនិយោគជាងតំបន់ដទៃទៀត ហើយប្រហែលជាមានការលំបាកខ្លាំងក្នុងការចង់កាប់ឆ្ការរានព្រៃយកដី ។ ក៏ប៉ុន្តែ សូម្បីតែនៅក្នុងតំបន់ទាំងនេះក៏ដោយ ក៏ករណីនៃ «ការធ្វើដំណើរទៅកាន់តំបន់ភ្នំ»ដើម្បីលួចបង្ក (ឬចាប់យកដីព្រៃ) ឬដើម្បីធ្វើកសិកម្មពនេចរទាំងនេះ គឺជម្រើសជាប្រពៃណីសម្រាប់កសិករ ដែលក្រីក្រគ្មានលទ្ធភាព ។ បើនិយាយអំពីការគ្រប់គ្រងដីធ្លី បែបប្រពៃណីដែលគេយកមកប្រើប្រាស់ នៅតំបន់ដីមិនសូវសម្បូរដីវជាតិ ក៏មិនបានបង្កឲ្យមានបញ្ហាជាស្វ័យប្រវត្តិ ដែលធ្វើឲ្យប្រជាកសិករក្រីក្រតោកយ៉ាកត្រូវការពឹងពាក់ទៅលើពួកថៅហ្វាយនាយដើម្បីរស់នោះដែរ ។ ការគ្រប់គ្រងកម្លាំងពលកម្មរបស់មនុស្ស គឺមានសារៈសំខាន់ជាងការគ្រប់គ្រងដីធ្លី និងអគារ ដែលតម្រូវឲ្យមានការការពារច្រើនជាងដីធ្លី ។ បើទោះបីជា មានការផ្លាស់ទីពីសហគមន៍ដែលមានស្រាប់ទៅតំបន់ដីថ្មី មិនសូវផ្តល់ការលំបាកដល់អ្នកពឹងពាក់យ៉ាងណាក្តី ក៏អត្ថិភាពនៃដីដែលទំនេរ គឺជាគោលការណ៍មូលដ្ឋាននៃសេចក្តីសុខ និងសេរីភាពរបស់កសិករក្នុងសម័យមុនអាណានិគមនៃតំបន់អាស៊ីអាគ្នេយ៍ ។

ចំណុចសំខាន់ចុងក្រោយស្តីពីការជះឥទ្ធិពល ទៅលើស្ថានភាពនៃការចរចាររបស់អ្នកពឹងពាក់នៅក្នុងតំបន់អាស៊ីអគ្នេយ៍ក្នុងសម័យមុនអាណានិគមនោះ គឺការផ្តល់ (បែងចែក) អំណាចដល់មូលដ្ឋាន ដែលជារឿយៗមិនព្រមឲ្យថៅហ្វាយនាយស្វែងរកជំនួយពីខាងក្រៅនោះ ។ នេះមានន័យយ៉ាងសមញ្ញថា មេដឹកនាំក្នុងស្រុកម្នាក់កម្រនឹងទៅរកពឹងផ្អែកលើឥទ្ធិពល ឬច្បាប់ខាងក្រៅដើម្បីជួយការពារខ្លួនឯងណាស់ ជំនួសមកវិញទ្រព្យសម្បត្តិនិងតួនា

ទីរបស់គាត់ បានធ្វើឲ្យអំណាចរបស់គាត់មានសុពលភាពឡើង ដោយសារតែឥទ្ធិពលស្របច្បាប់ដែលគាត់ទទួលបានពីសហគមន៍ផ្ទាល់ ។ ប្រសិនបើគាត់មិនអាចទាក់ទាញ នូវចំនួនមនុស្សមួយភាគធំនៃសហគមន៍ ដែលគាត់គឺជាអ្នកផ្តល់ផលប្រយោជន៍ឲ្យពួកអ្នកមកពឹងពាក់ ឬប្រសិនបើគាត់មិនអាចទទួលបាននូវក្រុមអ្នកគាំទ្រគាត់គ្រប់គ្រាន់ទេនោះ គាត់ច្បាស់ជាជួបនឹងគ្រោះថ្នាក់ជាមិនខាន ។[២៤]

ដូច្នេះចំណុចសំខាន់នៃការបែងចែកឡើងវិញរបស់ភូមិ គឺថាសកម្មភាពនេះអាចដំណើរការទៅបាន ក៏អាស្រ័យទៅនឹងស្ថានភាពនៃអំណាចក្នុងស្រុក ។[២៥] អ្នកមានលុយត្រូវអ្នកភូមិបង្ខំឲ្យទទួលរាប់រង ក្នុងការធ្វើពិធីបុណ្យផ្សេងៗប្រចាំភូមិ និងជាអ្នកដែលធ្វើអំណោយខាងផ្នែកសាសនាច្រើនជាងគេ ហើយក៏ជាអ្នកផ្តល់ប្រាក់កម្ចី និងប្រាក់ជំនួយផ្សេងៗ ។ល។ អ្នកមាននោះប្រើប្រាស់ទ្រព្យសម្បត្តិផ្ទាល់ខ្លួនបន្តិចបន្តួច ដើម្បីដូរយកមកវិញនូវភាពល្បីល្បាញ ឬកិត្យានុភាព តែយ៉ាងហោចណាស់ក៏គាត់បានផ្តល់ឲ្យអ្នកដទៃនូវសុខុមាលភាពខ្លះៗដែរ យោងតាមទង្វើទាំងនេះ គាត់បានក្លាយទៅជាចៅហ្វាយនាយដ៏មានឥទ្ធិពលម្នាក់ដោយឯកឯង ហើយថែមទាំងមានអ្នកនៅចាំហែហមបម្រើថែមទៀតផង ។ ស្វ័យភាពនៃភូមិដ្ឋានបែបបុរាណនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានធ្វើឲ្យអំណាច ឬឥទ្ធិពលស្របច្បាប់ក្នុងតំបន់មានតម្លៃដ៏អស្ចារ្យបំផុតមួយ និងបានជួយឲ្យចៅហ្វាយនាយគោរព ឬប្រកាន់ខ្ជាប់នូវបទដ្ឋានជាប្រពៃណីនៃការជួយគ្នាទៅវិញទៅមក ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ ។

អ៊ីចឹងយើងឃើញថា អំណាចតថ្លៃបែបបុរាណរបស់អ្នកពឹងពាក់ មាននូវចំណុចខ្លាំងមួយចំនួន ។ តាមន័យនេះសហគមន៍ និងក្រុមសែស្រឡាយគឺជាអ្នកប្រកួតប្រជែងជាមួយនឹងពួកចៅហ្វាយនាយ ក្នុងការផ្គត់ផ្គង់សេវាកម្មដូចៗគ្នាជាច្រើន ដូច្នេះគេអាចការពារមិនឲ្យចៅហ្វាយនាយក្លាយទៅជាអ្នកលក់ផ្តាច់មុខ ដែលអាចក្រឡុកតម្លៃស្រេចនឹងចិត្ត ។ ការផ្គត់ផ្គង់ដីធ្លីយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើរតួនាទីជំនួសឲ្យអ្នកពឹងពាក់ក្នុងការស្កាត់ចៅហ្វាយនាយមិនឲ្យមានការរើងទទឹង ក្នុងការព្យាយាមបន្ថោកនូវតម្លៃទិន្នផល ដែលកសិករផលិតបាន ។ ចំណុចចុងក្រោយគឺថាភាពទន់ខ្សោយរបស់រដ្ឋធ្វើឲ្យពួកចៅហ្វាយនាយតាមតំបន់ ឬស្រុកមានការប្រុងប្រយ័ត្នក្នុងការបង្កើតនូវអំណាច ឬឥទ្ធិពលតូចតាចតាមតំបន់របស់ខ្លួន ។

# ការប្រែប្រួលនៃការធាក់ទង់ក្នុងការពឹងពាក់

ប្រវត្តិនៃការទាក់ទងវណ្ណៈកសិករនៅតំបន់អាស៊ីអាគ្នេយ៍នៅមិនទាន់មានគេសរសេរជាលាយលក្ខណ៍អក្សរនៅឡើយទេ សូម្បីតែនៅក្រោយពេល ដែលមានការរីកសាយភាយឡើងយ៉ាងគំហុក នូវប្រភពឯកសារដើមនៃប្រវត្តិសង្គមនៅថ្នាក់តំបន់ និងខេត្តយ៉ាងណាក្តី ។ ក៏ប៉ុន្តែយើងអាចពន្យល់បានថា ហេតុអ្វីបានជាបន្លាស់ប្តូរនៃរចនាសម្ព័ន្ធសំខាន់ៗមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍នាសម័យអាណានិគម ។ ជំរុញឲ្យមានការរាំងស្ទះដល់ស្ថានភាពពំនាក់អាស្រ័យរបស់កសិករ និងបានបំផ្លាញនូវឥទ្ធិពល ឬអំណាចស្របច្បាប់ដែលមានពីមុនរបស់ពួកគហបតីម្ចាស់ដី ។ សេចក្តីពន្យល់យ៉ាងសង្ខេប និងងាយយល់មួយនេះ អាចអនុវត្តន៍ទៅបាននៅតាមបណ្តាតំបន់ទាំងឡាយណា ដែលផលប្រយោជន៍នៃនយោបាយ និងសេដ្ឋកិច្ចរបស់ពួកអាណានិគមមានកម្រិតខ្ពស់ ប៉ុន្តែយើងយកតែចំណុចគោលៗមួយចំនួនមកពណ៌នាប៉ុណ្ណោះ ដោយមិនគិតពីចំណុចដែលពាក់ព័ន្ធដ៏ល្អៗជាច្រើនទៀតឡើយ ។

នៅក្នុងការគ្រប់គ្រងដោយផ្ទាល់ ទៅលើតំបន់ទំនាបកណ្តាល ជាពិសេសចំពោះតំបន់ដែលទើបតែមានការតាំងទីថ្មីៗ ដូចជា តំបន់ភូសាំងស៊ីន និងតំបន់ដីទំនាបនៅភូមានោះ យើងឃើញថា ការប្រែប្រួលដែលខ្ញុំបានពណ៌នា

ខាងលើ គឺមានការវិវឌ្ឍយ៉ាងលឿននិងពោរពេញទៅដោយការឈឺចាប់បំផុត ។ ស្ថានភាពរបស់កសិករនៅតំបន់ទាំងនោះ ទទួលរងនូវការបំផ្លិចបំផ្លាញយ៉ាងខ្លាំង ហើយចំណងទាក់ទងមួយដែលពោរពេញដោយភាពយុត្តិធម៌ និងមានស្ថិរភាព ហើយប្រកបដោយក្តីរីករាយ ក្នុងការពឹងពាក់អាស្រ័យទៅលើពួកចៅហ្វាយនាយនោះ បានប្រែប្រួលយ៉ាងលឿន ទៅជាប្រព័ន្ធមួយដែលពោរពេញទៅដោយភាពមិនប្រក្រតី និងការពឹងពាក់ដោយបង្ខំចិត្ត ។ ប៉ុន្តែគេសម្គាល់ឃើញថា នៅតាមតំបន់ភ្នំវិញមិនឃើញមានការអនុវត្តនូវនិន្នាការដូចគ្នានេះទេ គឺមានតែការប្រើនូវរបៀបគ្រប់គ្រងដោយប្រយោលប៉ុណ្ណោះ ។

យើងអាចនិយាយពណ៌នាពីផលប៉ះពាល់ ដែលកើតមានឡើងដោយសារបទ្លាស់ប្តូររបស់ពួកអាណានិគមទៅលើទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់បានតាមរយៈចំណុចគោលបីគឺៈ (១) ដំណើរការនៃសង្គមសម្បូរបែប (២) ការរីកចម្រើននៃរដ្ឋអាណានិគម និងចំណុចដែលសំខាន់បំផុតនោះ គឺ (៣) ការធ្វើពាណិជ្ជកម្មទៅលើវិស័យកសិកម្ម និងការប្រមូលផ្តុំភាពជាម្ចាស់ដី ។ ខ្ញុំនឹងធ្វើការបកស្រាយត្រួសៗនូវចំណុចពីរដំបូង ហើយនឹងនិយាយឲ្យបានលម្អិតលើចំណុចចុងក្រោយ ។

## ភាពខុសៗគ្នា យ៉ាងសម្បូរបែបនៅក្នុងសង្គម

ដំណើរនៃសង្គមដ៏សម្បូរបែប ប្រហែលជាមិនបានធ្វើឲ្យមានការប្រែប្រួលនូវកម្រិតនៃការពឹងពាក់អាស្រ័យរបស់បុគ្គលម្នាក់ៗ ច្រើនដូចនឹងការបែងចែក ឬការប្រមូលផ្តុំការពឹងពាក់នោះទេ តែដំណើរការនេះហាក់ដូចជាបានជំនួសនូវកន្លែងមួយ ឬមួយចំនួនក្នុងចំណងនៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័ស និងការពឹងពាក់អាស្រ័យ ជាមួយនឹងការពឹងពាក់ដ៏សម្បូរបែប ដែលជម្រើសនីមួយៗនៃភាពសម្បូរបែបនេះ មិនសូវជាមានឥទ្ធិពល និងវិសាលភាពនោះទេ ។[២៧] គេបានសង្ខេបយ៉ាងត្រឹមត្រូវ នូវការប្រែប្រួលនេះតាមរយៈគំនិតរបស់ ស្កាំកីតធើ ស្តីអំពីភាពផុយគ្នានៃវណ្ណៈអភិជនបុរាណ និងគហបតីពាណិជ្ជកម្មថ្មី ។

> កាលពីមុន ពួកវណ្ណៈសក្តិភូមិថ្នាក់ខ្ពស់ធ្លាប់ក្លាយទៅជាមេដឹកនាំកំពូល ក្នុងរចនាសម្ព័ន្ធសង្គមមួយដែលមានឋានានុក្រមជារាងពីរ៉ាមីត ប៉ុន្តែពួកគហបតីមិនដែលជួបប្រទះសោះ ក្នុងជីវិតរបស់ពួកគេ ។ ពួកអភិជនសក្តិភូមិធ្លាប់ធ្វើជាស្តេច និងជាចៅហ្វាយនាយនៅគ្រប់ស្រទាប់វណ្ណៈ និងគ្រប់ទីកន្លែងទាំងអស់ ដែលធ្វើឲ្យមានឡើងនូវកិត្យានុភាពខុសៗគ្នាជាច្រើន ដោយមិនអាចមានអ្នកណាបន្តធ្វើបានឡើយ ។[២៨]

អ្វីដែលធ្លាប់ជាទំនាក់ទំនងរបស់មនុស្សទាំងមូល បានប្រែប្រួលយ៉ាងលឿន ទៅជាប្រព័ន្ធនៃចំណងទាក់ទងជាផ្នែកៗ និងកាន់តែតូចចង្អៀតឡើង ។ កសិករត្រូវទៅទាក់ទងនឹងមនុស្សម្នាក់ដើម្បីជួលដី ហើយត្រូវទៅជួបមនុស្សម្នាក់ផ្សេងទៀត ដើម្បីចរចារឿងពន្ធលើខ្លួនមនុស្សម្នាក់ៗ និងត្រូវទៅទាក់ទងមនុស្សម្នាក់ផ្សេងទៀតដើម្បីសុំធ្វើការនៅរដូវសម្រាកពីការធ្វើស្រែចម្ការ ហើយប្រហែលជាត្រូវទៅជួបមនុស្សដទៃម្នាក់ទៀត ដើម្បីខ្ចីប្រាក់ឲ្យទាន់ពេលដែលត្រូវការ ។ ជាទូទៅ ពល់ប្រសិទ្ធភាពថ្មីរបស់ចៅហ្វាយនាយ ដែលបានមកពីបំរែបំរួលខាងលើ ហាក់ដូចជាផ្តោតសំខាន់ទៅនឹងតំបន់ ដែលមាននូវរចនាសម្ព័ន្ធសង្គមដ៏សម្បូរបែប ដែលខ្លួនអាចមានកន្លែងឈរជើងបាន ។ នៅពេលណាដែលពួកគេ (ចៅហ្វាយនាយ-អ្នកពឹងពាក់) គ្មានចំណងទាក់ទងជាក់លាក់ទេនោះ ភាពតូចចង្អៀត និងផុយស្រួយនៃចំណងទាក់ទង ចៅហ្វាយនាយ-អ្នកពឹងពាក់ បានផ្តល់ឲ្យភាគីទាំងពីរនូវកំណើននៃ

*វិសមភាព និងភាពមិនទៀតទាត់មួយ ។*

## ការចម្រើនឡើងនៃរដ្ឋអំណាចអាណានិគម

*ស្របពេលដែលរដ្ឋអំណាចអាណានិគមបានពង្រីក និងបង្កើននូវខ្សែបណ្ដាញខាងរដ្ឋបាល ទៅតាមទីជនបទដាច់ស្រយាល ដែលធ្វើឲ្យមានការបែកបាក់ដល់ប្រព័ន្ធរដ្ឋបាលចាស់នោះ ខ្លួនក៏បានបង្កើតឡើងផងដែរ នូវតួនាទីថ្មីរបស់ចៅហ្វាយនាយនៅក្នុងបណ្ដាញរបស់គេនោះ ។ រដ្ឋាភិបាល បានលូកដៃចូលទៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់អ្នកស្រុកកាន់តែច្រើនឡើងៗ បន្ទាប់មកពួកអាណានិគមនេះ បានបង្កើននូវសេចក្ដីព្យាយាមក្នុងការជំរុញឲ្យប្រជានជន ឲ្យទទួលរាប់អានរដ្ឋការអាណានិគមដោយក្ដីអនុគ្រោះ ឬដោយក្ដីរីករាយ តែដំណើរការនេះមិនទទួលបានជោគជ័យឡើយ ។ រចនាសម្ព័ន្ធតាមឋានានុក្រមនៃចៅហ្វាយនាយ នឹងកើតឡើងដោយឯកឯងជាមួយនឹងរចនាសម្ព័ន្ធពិតប្រាកដថ្មីមួយនៅក្នុងភូមិ នៅពេលដែលកសិករព្យាយាមការពារនូវផលប្រយោជន៍របស់ពួកគេលើបញ្ហា ពន្ធដារប័ណ្ណកាន់កាប់ដី អដ្ឋាប័ណ្ណផ្សេងៗ រឿងក្ដីក្ដាំ ។ល។*

*នៅក្នុងបរិបទនេះ ប្រសិទ្ធភាពដ៏សំខាន់នៃការគ្រប់គ្រងរបស់អាណានិគមទៅលើមន្ត្រីថ្នាក់ស្រុក គឺការប្ដូរនូវទំនាក់ទំនងរបស់មន្ត្រីទាំងនោះ ជាមួយនឹងសហគមន៍ម្ចាស់ស្រុកឲ្យបានទាំងស្រុង ។ នៅមុនសម័យអាណានិគម មន្ត្រីថ្នាក់ស្រុកភាគច្រើនមិនដែលពឹងផ្អែក ឬទទួលយកនូវឥទ្ធិពលពីមនុស្សខាងក្រៅ មកធ្វើជាខ្នងបង្អែករបស់ខ្លួនឡើយ តែពួកគេរក្សា និងពង្រឹងសុពលភាពនៃអំណាចនៅក្នុងតំបន់របស់ខ្លួន តាមរយៈការកែនគរនូវចំនួនអ្នកស្រុកដែលគាំទ្រពួកគេឲ្យមានស្ថិរភាព ក៏ដូចជាការប្រកាន់ខ្ជាប់នូវបទដ្ឋានគោលរបស់សហគមន៍ និងដើរតួរជាអ្នកការពារនូវការទាមទារពីខាងក្រៅ ក្នុងការប្រើប្រាស់ធនធានរបស់សហគន៍ឲ្យស្ថិតនៅក្នុងកម្រិតតិចតួចបំផុត ។ ក៏ប៉ុន្តែនៅពេលនេះឥទ្ធិរបស់ អាណានិគម បានផ្ដាច់នូវទំនាក់ទំនងនៃការពឹងទៅអ្នកស្រុកភូមិរបស់មន្ត្រីទាំងនោះអស់ ។ ជំនួសឲ្យភាពជាអ្នកតំណាងរបស់ប្រជាជនក្នុងស្រុក ដើម្បីចរចារជាមួយនឹងរដ្ឋអំណាចកណ្ដាលនោះ ពួកមន្ត្រីថ្នាក់ស្រុកទាំងនោះ បានក្លាយយ៉ាងលឿនទៅជាអ្នកតំណាងឲ្យរដ្ឋអំណាចកណ្ដាល ដើម្បីមកចរចារជាមួយនឹងអ្នកស្រុកវិញ ។ ដូច្នេះបើយោងទៅតាមទ្រឹស្ដីតុល្យភាព នៃការដោះដូររវាងមន្ត្រីថ្នាក់ស្រុក និងប្រជាកសិករបានបង្ហាញឲ្យឃើញថា នៅពេលដែលអំណាចមិនទៀតទាត់របស់ពួកចៅហ្វាយនាយ បានរីកសាយភាយឡើងយ៉ាងខ្លាំងក្លានោះ តម្រូវការចង់បានការគាំទ្រពីសំណាក់អ្នកភូមិបានថយចុះ ហើយទឹកចិត្តក្នុងការជួយដល់សហគន៍ ការពារប្រឆាំងទៅនឹងរដ្ឋអំណាចធំនោះ ក៏បានសាបសូន្យអស់ទៅដែរ ។*

*កម្រិតនៃរឿងនេះ មានការប្រែប្រួលនៅក្នុងតុល្យភាពនៃការដោះដូរនិងប្រែប្រួលទៅតាមល្បឿនដែលកើតមានឡើងផ្សេងៗគ្នាយ៉ាងទូលំទូលាយ ។ ស្ថិតនៅក្នុងវិសមភាពមួយ ផលប៉ះពាល់នៃការប្រែប្រួលបានប្រកាសឡើងច្រើនបំផុត នៅពេលដែលរដ្ឋអំណាចអាណានិគមមានឥទ្ធិពលខ្លាំងក្លាបំផុត និងនៅពេលដែលគេយកអ្នកក្រៅឲ្យមកគ្រប់គ្រងក្នុងតំបន់ ហើយពួកនេះទទួលប្រាក់ខែពីរដ្ឋអំណាចខាងលើនោះ ។ ផលប៉ះពាល់នេះកាន់តែតិចទៅៗ និង មិនសូវប្រកាសឲ្យដឹង នៅពេលដែលអំណាចរបស់អាណានិគមមិនសូវបានពង្រឹងឡើង និងនៅពេលដែលមន្ត្រីរាជការប្រចាំតំបន់ គឺជាសមាជិករបស់សហគមន៍ និងបានជ្រើសរើសឡើងដោយអ្នកស្រុក ។*

*ដោយមានពួកអាណានិគមជាខ្នងបង្អែកនោះ ពួកអ្នកមានទាំងនោះបានឆ្លៀតឱកាសយកចំណេញ ដោយប្រើអំណាចថ្មីរបស់គេ និងបានប្របាច់កអ្នកភូមិកាន់តែខ្លាំងឡើង ដែលទង្វើទាំងនេះ បានធ្វើឲ្យចំនួនអ្នកគាំទ្រពួកគេ*

*ហាក់ថមថយទៅៗ ហើយពួកគេក៏កាន់តែបាត់បង់ឥទ្ធិពលរបស់ខ្លួនដែរ ។[២៩] ការពិពណ៌នារបស់កាតូឌើរ៍ចូ ស្តីអំពីក្រុមព្រៃចាជី នៅតំបន់បែនថិន មុនបដិវត្តន៍កសិករឆ្នាំ ១៨៤៨ គឺដូចគ្នាទៅនឹងគំរូខាងលើនេះ ។[៣០] ដោយមានប្រទេសហូឡង់ ជាខ្នងបង្អែកនោះ ពួកគហបតីនៅក្នុងស្រុកបានបង្កើតជាបណ្តាញអ្នកគាំទ្រខ្លួនផ្ទាល់ ហើយបានបង្កើតនូវកំណែនបន្ថែម និងបង្កើតនូវសេវាដែលត្រូវតែបំពេញដោយខានមិនបាន សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ។ អ្នកនិពន្ធឈ្មោះបិនដា បានកត់សម្គាល់នៅក្នុងលក្ខខណ្ឌជាទូទៅមួយថា សម្ព័ន្ធភាពរបស់វណ្ណៈអភិជនជាមួយប្រទេសហូឡង់ «គឺហូឡង់បានដកហូតអធិបតេយ្យភាពទាំងស្រុងហើយបានពង្រឹងស្វ័យភាពរបស់ខ្លួន ក្នុងការត្រួតត្រាលើតានី » បន្ទាប់មកខ្លួនបានលើកតម្កើងពួកអ៊ូឡាម៉ា) ឡើង«នៅក្រោមក្រសែភ្នែករបស់វណ្ណៈកសិករដែលត្រូវគេធ្វើទុក្ខបុកម្នេញ»[៣១] ។ កំណើននៃចំនួនកសិករ ដែលប្រឆាំងទៅនឹងការិយាធិបតេយ្យបែបអាណានិគមនៅកន្លែងដទៃផ្សេងទៀត នៃតំបន់អាស៊ីអាគ្នេយ៍ប្រហែលជាអាចផ្តល់ជាទុន ក្នុងការសិក្សាប្រៀបធៀបគ្នានូវការអភិវឌ្ឍ ។[៣២]*

# ដី និងការដោះដូរគ្នារវាងចៅហ្វាយនាយ-អ្នកពឹងពាក់

*លទ្ធផលនៃការរីកចម្រើនលើផ្នែកពាណិជ្ជកម្មនាំចេញ និងការនិយមលក់ដូរដើម្បីចិញ្ចឹមជីវិតនៅជនបទ គឺជាកត្តាយ៉ាងសំខាន់បំផុតនៃការផ្លាស់ប្តូររបស់ពួកវណ្ណៈ ដែលមានដីស្រែសម្ការច្រើននៅតំបន់អាស៊ីអាគ្នេយ៍ចន្លោះឆ្នាំ ១៨៧០ និង ១៩៣០ ។ ក្នុងនាមជាអ្នកពាំនាំយកមក នូវទ្រឹស្តីបែបសេរីភាពនិយមនាសតវត្សរ៍ទី ១៩ នោះខ្ញុំជឿថាច្បាប់បុរាណដែលគ្រប់គ្រង ទៅលើសិទ្ធិក្នុងការកាន់កាប់ និងប្រើប្រាស់ដីធ្លី និងប្រព័ន្ធនៃការដោះដូរកម្លាំងពលកម្ម គឺជាឧបសគ្គរាំងស្ទះដល់ដំណើរនៃការរៀបចំដីធ្លី និងការងារ ឲ្យក្លាយទៅជារបស់ដែលអាចទិញលក់បាន នៅលើទីផ្សាររបស់ពួកអាណានិគម ដែលតម្លៃ និងការប្រើប្រាស់នោះ គួរតែត្រូវកំណត់ឡើងតាមរយៈឥទ្ធិពលនៃការផ្គត់ផ្គង់ និងការប្រើប្រាស់ ។ លទ្ធផលនៃគោលនយោបាយនេះ គឺមិនមែនកើតមានឡើងតែនៅតំបន់អាស៊ីអាគ្នេយ៍នោះទេ រឿងនេះប្រៀបបាននឹងជំនោចាស់មួយ ដែលធ្លាប់កើតមានរួចទៅហើយនាដើមដំបូងនៃការធ្វើពាណិជ្ជកម្មកសិផលនៅអឺរ៉ុប ។[៣៣] វិបាកជាចម្បងមួយចំនួននៃបន្លាស់ប្តូរសម្រាប់ភាពទូទៅ និងតុល្យភាពនៃការដោះដូរគ្នារវាងចៅហ្វាយនាយ-អ្នកពឹងពាក់នេះ គឺអាចសង្ខេបបានមកដូចខាងក្រោម ÷*

## កំណើននៃការពឹងពាក់លើជំនួយជាសំខាន់បែបដីធ្លី

*តម្រូវការចាំបាច់ក្នុងការប្រើប្រាស់ដីធ្លីផលនៃឥទ្ធិពលទីផ្សារនៅទីជនបទ បានជំរុញឲ្យមានការកើនឡើងនូវវណ្ណៈគហបតីម្ចាស់ដីថ្មីគ្រប់ជាន់ថ្នាក់ ដែលអំណាចរបស់ពួកគេបានមកពីភាពជាម្ចាស់ លើរបស់ដែលចាំបាច់បំផុតសម្រាប់អ្នកក្រអាចរស់រានមានជីវិតបាន ។ ក្នុងពេលជាមួយគ្នានេះដែរ ក៏មានការកើនឡើងនៃវណ្ណៈមួយដែលពោរពេញទៅដោយក្រុមអ្នកជួលដីស្រែចម្ការ និងអ្នកស៊ីឈ្នួលដោយប្រើកម្លាំងពលកម្ម ហើយពួកគេអាចរស់បានដោយអាស្រ័យលើដី ឬការងារដែលពួកអ្នកមានទាំងនោះផ្តល់ឲ្យ ។ នៅពេលដែលចំនួនប្រជាជនចេះតែកើនឡើងនោះ ការធានាឲ្យបាននូវដីសម្រាប់បង្កបង្កើនផល អាស្រ័យលើម្ចាស់ដីម្នាក់ដែលមានឥទ្ធិពលជាងគេនៅក្នុងស្រុក ។*

*លក្ខណៈនៃការផ្លាស់ប្តូរផលទៅលើទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់*

### ការចេះតែកើនឡើងនូវវិសមភាពក្នុងការកាន់កាប់ដី

*ការកាន់កាប់ដីធ្លី ក្លាយជាគន្លឹះដ៏សំខាន់ក្នុងការកាន់កាប់ដីរបស់ពួកចៅហ្វាយនាយ ។ តួនាទីនៃអ្នកកាន់កាប់ដីធ្លីកាន់តែមានឥទ្ធិពលឡើង ក្នុងការដោះស្រាយជាមួយអ្នកពឹងពាក់ ឬកសិករដែលមានបំណងចង់ប្រើប្រាស់ដីដែលមានកម្មសិទ្ធិហើយនោះ។*

### កំណើនប្រជាជន

*ធ្វើឲ្យតួនាទីរបស់ពួកម្ចាស់ដីមានអានុភាពកើនឡើង ក្នុងការចរចារជាមួយនឹងកំណើននៃការស្វែងរកដី ដើម្បីបង្កបង្កើនផលរបស់កសិករ ។*

### អតិផរណានៃថ្លៃលើដំណើរការផលិត

*ធ្វើឲ្យតួនាទីរបស់ពួកម្ចាស់ដីមានអានុភាពនៅឡើង នៅពេលដែលតម្រូវការរបស់ប្រជាកសិករទៅលើប្រាក់ឥណទានប្រាក់បុល និងអ្នកជួយស្វែងរកទីផ្សារ កាន់តែមានការកើនឡើង ។*

### ការបាត់បង់ធនធានសាធារណៈ (មានដូចជា បឹង ត្រី អុស ធ្យូង ។ល។)

*ធ្វើឲ្យចុះខ្សោយនៃយន្តការសុវត្ថិភាពនៃជម្រើសដ៏ទៃទៀតដែលកាន់តែធ្វើឲ្យឥទ្ធិពលរបស់កសិករក្នុងការចរចារជាមួយពួកអ្នកមានចុះខ្សោយ ។*

### ការសាបរលាបទៅនៃយន្តការ

*ធ្វើឲ្យការចុះខ្សោយនៃយន្តការសុវត្ថិភាពរវាងវណ្ណៈ ធ្វើឲ្យមានភាពស្មើគ្នារបស់អ្នកភូមិ និងឥទ្ធិពលរបស់កសិករក្នុងការចរចារជាមួយពួកអ្នកមាន ចុះអន់ខ្សោយ ។*

### រដ្ឋអាណានិគមការពារដល់សិទ្ធិគ្រប់គ្រង

*ធ្វើឲ្យពួកម្ចាស់ដីមិនសូវទាមទារចង់បាននូវកក្តីភាព លើអចលនទ្រព្យរបស់ពួកម្ចាស់ដី ពីពួកកសិករ (អ្នកពឹងពាក់) ក្នុងស្រុក ឬតំបន់របស់ខ្លួនប៉ុន្មាននោះទេ ដូច្នេះហើយពួកគេក៏មិនសូវជាមានចិត្តចង់បង្កើតនូវច្បាប់ដើម្បីការពារនូវតុល្យភាពនៃការដោះដូរប៉ុន្មានដែរ ។*

*ដំណើរមួយ ដែលមាននូវការប្រមូលផ្តុំគ្នានូវភាពជាម្ចាស់ដី ព្រមទាំងមានលេចឡើងមកនូវលំដាប់ថ្នាក់នៃអំណាចថ្មីមួយ គឺជាបម្រែបម្រួលដែលកើតឡើងតាមរយៈឥទ្ធិពលនៃពាណិជ្ជកម្ម និងប្រភេទនៃការតស៊ូនៅក្នុងសង្គមដែលគេបានជួបប្រទះ ។ នៅតំបន់ដីទំនាបក្នុងប្រទេសភូមា និងតំបន់ដីសណ្តនៃទន្លេមេគង្គ (ជាពិសេសមួយផ្នែកនៃភាគខាងលិច) បានបង្ហាញនូវទ្រង់ទ្រាយដ៏សំខាន់បំផុតមួយនៃទម្រង់ថ្មីមួយនេះ ។ ដោយហេតុថា តំបន់ទាំងពីរជាតំបន់ដែលមានព្រំប្រទល់ជាប់គ្នា ដែលសម្បូរទៅដោយដីមានជីជាតិ និងមិនសូវមាននូវចេនាសម្ព័ន្ធសង្គមបុរាណច្រើននោះ តំបន់ទាំងនេះក៏បានក្លាយទៅជាតំបន់ដ៏សំខាន់ ដែលពោរពេញទៅដោយសក្តានុពលនៃការធ្វើពាណិជ្ជកម្ម ។ នៅឆ្នាំ ១៩២៨ ក្នុងតំបន់វាលទំនាបនៃប្រទេសភូមា ឃើញមាននូវចំនួននៃវណ្ណៈអ្នកគ្មានដីជាកម្មសិទ្ធិជាច្រើន មានទាំងប្រជាជានជនភូមាផង និងក្រុមអ្នកចងការប្រាក់ផងបានជួលដីដែលអាចដាំដុះបានស្ទើរតែពាក់កណ្តាលនៅក្នុងតំបន់ជម្រុកស្រូវ ដើម្បីឲ្យអត្រាជួលដីកើនឡើងខ្ពស់ ។ នៅឆ្នាំ ១៩៣០ ក្នុងតំបន់កូសាំង*

ស៊ីនចំនួនម្ចាស់ដីមានត្រឹមតែ ២៥៥.០០០ នាក់ប៉ុណ្ណោះ ក្នុងចំណោមប្រជាជនសរុបចំនួន ៤ លាននាក់ក៏មាននូវនិន្នាការនៃបំណុល និងការជួលដីស្រដៀងគ្នាទៅនឹងតំបន់ខាងលើដែរ ។ និន្នាការ គឺមានលក្ខណៈដូចគ្នានៅគ្រប់ទីកន្លែង បើទោះបីជាដំណើររបស់តំបន់នីមួយៗមិនសូវដូនជាបក៏ដោយ តួយ៉ាងដូចជា តំបន់លូហ្សិនកណ្តាល តំបន់ខ្ពង់រាបនៃប្រទេសភូមា កោះជ្វាផ្នែកខាងលិច និងតំបន់បស្ចិមនៃសហព័ន្ធម៉ាឡេស៊ី ។ ចំណុចចុងក្រោយគឺថា សូម្បីតែនៅតំបន់នយោបាយរបស់អាណានិគម និងតំបន់ដែលប្រកាន់ខ្ជាប់នូវប្រពៃណីនៃការបែងចែកឡើងវិញ ដូចជាតំបន់ភាគកណ្តាល និងខាងលិចនៃប្រទេសភូមា និងតំបន់ដីសណ្តតុងកឹង ដែលបានធ្វើការប្រឆាំងតទល់នឹងកំណើននៃការកាន់កាប់ដីធ្លីយ៉ាងណាក៏ដោយ ក៏នៅតែមានការរីករាលដាលកាន់តែខ្លាំងឡើងនូវភាពខុសគ្នា ឬគម្លាតរវាងពួកវណ្ណៈកសិករថ្នាក់កណ្តាល ដែលមានស្ថានភាពមាំមួន និងពួកវណ្ណៈអ្នកជួលដី និងលក់កម្លាំងពលកម្មដែលមានស្ថានភាពមិននឹងធ្ងរ ។

កត្តាប្រជាសាស្ត្រ ក៏បានដើរតួនាទីយ៉ាងសំខាន់មួយផងដែរ ក្នុងការបន្ថែមទម្ងន់ទៅលើការទាក់ទងនៃការពឹងពាក់ ។ ការគំរាមកំហែង បានកើតមានឡើងជាមួយនឹងកំណើនប្រជាជនគួរឲ្យកត់សម្គាល់មួយ នៅក្នុងតំបន់ដែលមានត្រឹមតែ ៥៥ លាននាក់នៅឆ្នាំ ១៨៧០ និងបានឡើងរហូតដល់ ១៤៥ លាននាក់នៅឆ្នាំ ១៩៤០ ហើយកំណើននេះ បានធ្វើឲ្យឥទ្ធិពលក្នុងការចរចាររបស់កសិករ ជាមួយពួកម្ចាស់ដីដើម្បីចំណេញក្នុងការប្រើប្រាស់ដីនោះ កាន់តែចុះខ្សោយជាលំដាប់ ។ នៅពេលដែលតំបន់ដីវាលទាំងមូលមានគេកាន់កាប់អស់ ហើយតំបន់ដីមានជីវជាតិកាន់តែមានការគំរាមកំហែងឡើងនោះ ពួកម្ចាស់ដីកាន់តែមានឱកាសប្រចាច់កប្រជាកសិករឡើង (ឬផ្តល់នូវសេវាយ៉ាងតិចតួចបំផុត) ក្នុងរូបភាពនៃការជួលដី ឲ្យក្នុងទំហំកាន់តែតូចទៅៗដល់កសិករ ។[៣៥]

កំណើនកសិករដែលពឹងផ្អែកទៅលើពួកវណ្ណៈម្ចាស់ដី មិនមែនគ្រាន់តែជាបញ្ហានៃការស្រេកឃ្លានដីតែមួយនោះទេ គឺថែមទាំងជាវិបាកមួយ នៃកំណើននូវតម្រូវការដែលទាមទារឲ្យមានការការពារទប់ទល់នឹងភាពមិនស្ថិតស្ថេរ និងអសុវត្ថិភាព ក្នុងការដាំដុះលើដំណាំសម្រាប់លក់ ដែលផ្ទុយពីការធ្វើកសិកម្មសម្រាប់តែរស់បែបបុរាណនោះ ។

ការដាំដុះដើម្បីគ្រាន់តែចិញ្ចឹមជីវិត មានការលំបាកដើម្បីជានាការរស់នៅណាស់ ។ ប៉ុន្តែប្រព័ន្ធដាំដុះបែបប្រពៃណីកើតឡើងតាមរយៈឧត្តមគតិដ៏ល្អលើការអាស្រ័យផលយូរអង្វែងដើម្បីផ្គត់ផ្គង់នូវតម្រូវការចាំបាច់របស់សមាជិកក្រុមឲ្យមានស្ថិរភាព ។ យ៉ាងហោចណាស់ក៏កសិករសាមញ្ញម្នាក់អាចដឹងបានថា ការដាំដុះដែលជោគជ័យនោះ គឺអាចផ្គត់ផ្គង់គ្រួសារគាត់ឲ្យរស់បានរហូត ដល់ការប្រមូលផលឆ្នាំក្រោយទៀត ។ ផ្ទុយទៅវិញការដាំដុះ ដើម្បីលក់លើទីផ្សារគ្មានការធានាបាននូវតុល្យភាព ដូចការដាំដុះបែបប្រពៃណីនោះឡើយ ។ កសិករដែលដាំដំណាំសម្រាប់លក់លើទីផ្សារ ប្រហែលជាអាចជួបប្រទះនឹងវិបត្តិនៃការចុះថោក នូវផលិតផលដែលគាត់បានផលិតឬប្រហែលជាអាចជួបប្រទះនឹងការឡើងថ្លៃលើចំណីអាហារ និងរបស់ចាំបាច់ដែលគាត់ត្រូវទិញ ក្នុងរយៈនៃការដាំដុះរបស់គាត់ ។ យោងតាមករណីទាំងពីរនេះបានបង្ហាញឲ្យឃើញថា ការកំណត់ទៅលើតម្លៃនៃប្រាក់ចំណូលពិតប្រាកដរបស់កសិករមិនអាស្រ័យទៅលើបរិមាណនៃទិន្នផលនោះទេ គឺអាស្រ័យលើកត្តាផ្សេងៗជាច្រើនទៅវិញ ។ ប្រជាកសិករនៅតំបន់អាស៊ីអាគ្នេយ៍ កាន់តែមានការឈឺចាប់ឡើង ទៅលើបំរែបំរួលថ្លៃទិន្នផលរបស់ពួកគាត់ នៅពេលដែលពួកគេព្យាយាមបង្កើននូវទិន្នផលរបស់ខ្លួនបន្ថែម ដើម្បីលក់លើទីផ្សារ (មួយផ្នែក គឺធ្វើឡើងដើម្បីយកលុយមកបង់ថ្លៃជួលដី និងបំណុលគេ) ក៏ដូចជានៅពេលដែលពួកគេកាន់តែមានតម្រូវការផ្នែកថវិកាឡើង

ដើម្បីយកមកបង់ពន្ធ ដោះបំណុល ដើម្បីទិញម្ហូបអាហារ និងខោអាវជាដើមនោះ ។ យើងអាចឃើញយ៉ាងច្បាស់ថា ក្ដីឈឺចាប់បែបនេះច្រើនកើតមានឡើងចំពោះអ្នកដែលដាំ នូវដំណាំដើម្បីនាំចេញមានដូចជាដំណាំកៅស៊ូជាដើម ដែលគ្មានអ្នកត្រូវការនៅពេលដែលតម្លៃចុះថោកនោះ ។ ទន្ទឹមមានការកើនឡើង នូវចំនួនកម្មករស៊ីឈ្នួលធ្វើស្រែចម្ការឲ្យគេដើម្បីទទួលបានប្រាក់កម្រៃសម្រាប់ចិញ្ចឹមជីវិតប្រចាំថ្ងៃ ពួកគេតែងប្រាថ្នាចង់បាននូវការងារមួយដែលស្ថិតស្ថេរ ដូច្នេះក្ដីប្រាថ្នានេះ បានក្លាយទៅជាចំណុចដ៏សំខាន់មួយ សម្រាប់សុខុមាលភាពរបស់ពួកគេ ។

ការការពារប្រឆាំងនឹងចលនាទាំងអស់នេះ គឺជាក្ដីបារម្ភយ៉ាងខ្លាំងមួយរបស់វណ្ណៈកសិករ ដែលរស់នៅក្នុងកម្រិតត្រឹមតែមួយចម្អែត ឬត្រឹមតែមួយគ្រប់គ្រាន់ ក៏ដូចជាអ្នកដែលអាចជួបនឹងភាពលំបាកលំបិនខ្លាំង ដោយគ្រាន់តែមានការប្រែប្រួលនៃថ្ងៃតែបន្តិចនោះ ។ បើទោះជាមានការរីកចម្រើនលើផ្នែកនាំចេញក្ដី ក៏ប្រជាកសិករភាគច្រើននៅក្នុងតំបន់ នៅតែស្ថិតនៅក្បែរកម្រិតមួយដែលបានត្រឹមតែមួយរស់ដដែល ។ តួយ៉ាងដូចជា នៅតំបន់មួយភាគធំនៃប្រទេសវៀតណាម និងភូមា ដែលជាភស្តុតាងមួយបង្ហាញឲ្យឃើញថា កម្រិតសុខុមាលភាពលើរូបរាងកាយក្នុងចំណោមប្រជាកសិករ មានការធ្លាក់ចុះនៅក្នុងសម័យអាណានិគម ។[៣៥] ក៏ប៉ុន្តែក្នុងពេលនេះ ការឡើងចុះនៃប្រាក់ចំណូលជាមធ្យមមិនសូវជាសំខាន់នោះទេ អ្វីដែលសំខាន់ គឺថា នៅក្នុងកម្រិតណាមួយនោះប្រជាកសិករដែលស្ថិតនៅក្នុងវិស័យពាណិជ្ជកម្ម នឹងបានជួបប្រទះអសុវត្ថិភាពពេញទំហឹងទាំងក្នុងករណីប្រើប្រាស់ធនធានដែលអាចចិញ្ចឹមជីវិតបានផង និងទាំងកម្រិតនៃប្រាក់ចំណូលពិតប្រាកដរបស់គាត់ផង ។ ដំណើរការបន្តរបស់គាត់ចំពោះការប្រើប្រាស់ដីធ្លី ឬបម្រើការងារ គឺកាន់តែស្ថិតក្នុងភាពមិនប្រក្រតីឡើង ហើយការបង្កើតឡើងនូវតម្លៃពិតប្រាកដទៅលើដំណាំ ឬប្រាក់ខែរបស់ពួកគាត់ គឺប្រៀបបានទៅនឹងករណីដែលគាត់មិនអាចបញ្ជាបាន ។

ស្ថិតក្នុងស្ថានភាពមួយ ដែលពោរពេញទៅដោយភាពមិនប្រាកដប្រជាទាំងនេះ យើងកម្រនឹងឃើញមានកសិករណាម្នាក់ដែលមិនស្វះស្វែងរកនូវឥណទាន ឬការជួយជ្រោមជ្រែងដើម្បីរស់ នៅអំឡុងខែដែលលំបាកលំបិនមុនពេលដែលពួកគាត់ប្រមូលភោគផល នៅពេលដែលគាត់ជួបប្រទះនឹងកាតព្វកិច្ច ក្នុងការធ្វើពិធីផ្សេងៗដូចជាពិធីមង្គលការ និងពិធីបុណ្យសព្វ ឬដើម្បីយកទៅជួលដីស្រែចម្ការ និងការជួយស្វែងរកការងារឲ្យធ្វើនោះឡើយ ។ ជាប្រការសមហេតុសមផលបំផុតដែលថា ប្រជាកសិករបានស្វែងរកការគាំពារពីសំណាក់ពួកម្ចាស់ដី ដែលជាអ្នកមានដីធ្លីច្រើន និងជាប្រភពនៃឥណទាន ហើយពួកគេក៏ជាអ្នកដែលមានទំនាក់ទំនង ជាមួយនឹងអ្នកមានអំណាចខ្លាំងក្លាដទៃទៀតដែលអាចការពារគាត់ទប់ទល់នឹងទីផ្សារសេដ្ឋកិច្ច ដែលមានភាពមិនប្រក្រតី ។ ដូច្នេះហើយការធ្វើពាណិជ្ជកម្មលើផ្នែកកសិកម្ម បានជួយពង្រឹងនូវឥទ្ធិពលរបស់ពួកម្ចាស់ដី នៅក្នុងតុល្យភាពនៃការដោះដូរ ។

ការរីកចម្រើនរបស់កសិករពឹងផ្អែកលើក្រុមអ្នកមានដី ហើយមិនគ្រាន់តែជាបញ្ហាខ្វះខាតដីនោះទេ ក៏ប៉ុន្តែជាងនេះទៅទៀត នៅក្នុងកម្រិតណាមួយនោះ ប្រជាកសិករនៅក្នុងផ្នែកការធ្វើពាណិជ្ជកម្ម ដែលមិនមានបទពិសោធខាងផ្នែកអសុវត្ថិភាពពេញទំហឹង ទាំងករណីធនធានដែលអាចចិញ្ចឹមជីវិតបាន ទាំងកម្រិតនៃប្រាក់ចំណូលពិតប្រាកដផង ។ ដំណើរការបន្តរបស់គាត់ចំពោះដីធ្លី ឬក៏ការងារគឺជាភាពមិនច្បាស់លាស់មួយ ហើយ ការបង្កើតតម្លៃជាក់ស្ដែងនៃដំណាំ ឬក៏ប្រាក់ខែ មានភាពស្រដៀងគ្នា ដែលមិនអាចគ្រប់គ្រងបាន ។

ដោយមានបញ្ហាអសុវត្ថិភាពនៅក្នុងការប្រកបមុខរបររបស់ខ្លួនបែបនេះកម្រមានប្រជាកសិករណាដែលមិនត្រូវការខ្ចីឥណទាន ឬក៏ជំនួយផ្សេងៗ ដើម្បីស្រោចស្រង់ជីវិតរស់នៅនារដូវលំបាកវេទនា មុនពេលប្រមូលផលស្រូវ ឬដើម្បីចំណាយលើពិធីបុណ្យផ្សេងៗដូចជា ពិធីអាពាហ៍ពិពាហ៍ និងបុណ្យសព ឬដើម្បីជួលដីស្រែចម្ការ និង

ផ្គត់ផ្គង់ដល់ការប្រកបមុខរបរផងទាំងពួង ។ ប្រាកដណាស់ ប្រជាកសិករទាំងនោះបានស្វែងរកការការពារ និង ពឹងពាក់ពីម្ចាស់ដីដែលគ្រប់គ្រងលើដីធ្លី និងប្រភពឥណទាន និងអ្នកដែលមានទំនាក់ទំនងជាមួយអ្នកមានអំណាច ដែលអាចជួយការពារពួកគាត់ទប់ទល់នឹងអស្ថិរភាពនៃសេដ្ឋកិច្ចលើទីផ្សារ ។ ដូចច្នេះហើយ ការធ្វើពាណិជ្ជលើ វិស័យកសិកម្មកាន់តែធ្វើឲ្យអំណាចចៅហ្វាយនាយ ដែលជាម្ចាស់ដីរឹងមាំថែមទៀតនៅក្នុងដំណើរការដោះដូរ (ខាងលើ) ។

## ការសង្កេតឱ្យច្បាស់លើការពឹងផ្អែកលើដីធ្លី និងការឧបត្ថម្ភក្នុងស្រុក

នៅក្នុងអំឡុងកាលនោះទាំងមូល ប្រជាកសិករភាគច្រើនមានគោលបំណង ឬទិសដៅបែបចាស់ដដែល ពោល គឺពួកគាត់ត្រូវធ្វើយ៉ាងណាដើម្បីសម្រេច និងរក្សាឲ្យបាននូវការរស់រានមានជីវិតប្រកបដោយស្ថិរភាពផ្នែក ស្បៀងអាហារ ។ គោលដៅជីវិតបុរាណបែបនេះ អាចពន្យល់យ៉ាងច្បាស់នូវមូលហេតុដែលប្រជាកសិករកម្រមាន ឆន្ទៈធ្វើពាណិជ្ជកម្ម ដែលកាលពីអតីតកាលបានធ្វើឲ្យស្បៀងអាហារ អាចក្លាយជាប្រភពប្រាក់ចំណូលយ៉ាងខ្ពស់ តែ ប្រកបទៅដោយគ្រោះថ្នាក់ និងភាពមិនច្បាស់លាស់ ។[៣៦] តម្រូវការដីដែលនៅតែបន្តមាននៅក្នុងបរិបទបែប នេះ អាចឆ្លុះបញ្ចាំងមើលឃើញពីគុណតម្លៃ និងការវាយតម្លៃខ្ពស់របស់ប្រជាកសិករទៅលើ «ស្ថិរភាពយូរអង្វែងនៃ ប្រាក់ចំណូលដែលទទួលបានពីដីភោគៈ ជាជាងភាពមិនប្រាកដប្រជានៃទីផ្សារការងារ» ។[៣៧] ដូចគ្នានេះផងដែរ គោលដៅជីវិតដែលយកស្បៀងអាហារជាគោលសំខាន់ នៃការចិញ្ចឹមជីវិតអាចពន្យល់ពីមូលហេតុ ដែលប្រជា កសិករចូលចិត្តដាំដំណាំឧស្សាហកម្មសម្រាប់គ្រាន់តែជាការបំពេញបន្ថែមលើ (មិនមែនជំនួស) ការដាំដុះស្បៀង អាហារចិញ្ចឹមជីវិត ឬចូលចិត្តដាំដំណាំសម្រាប់បរិភោគបាន និងអាចលក់ដូរបាន ។ រឿងនេះអាចពន្យល់ហេតុផល ដែលថាអ្នកជួលដីជាធម្មតាចូលចិត្តកសិដ្ឋានប្រវាស់ ដែលរំលែកការប្រថុយប្រថាននៃការដាំដំណាំពុំសូវហុចផល រវាងម្ចាស់ដី និងអ្នកជួលដី ។ កសិករជួលដីត្រូវទទួលខុសត្រូវលើភាពព្រថុយប្រថាន (ការខូចខាត) តែតាមលើ ទំហំផ្ទៃដីដែលខ្លួនជួល ពោលគឺតាមរយៈថ្លៃឈ្នួលកំណត់ប្រចាំឆ្នាំ ។ រឿងនេះក៏អាចពីពន្យល់អំពីហេតុផលដែល ប្រជាកសិករចូលចិត្តជួលដីដាំដំណាំចិញ្ចឹមជីវិតនៅក្នុងភូមិ (កំណើត) ជាជាងចេញទៅប្រើតម្លៃពលកម្មរកប្រាក់ កម្រៃគ្មានស្ថិរភាពនៅភូមិខាងក្រៅ ។

ជាលទ្ធផលនៃការយកចិត្តទុកដាក់លើដីធ្លី កំណើនប្រជាជន និងអស្ថិរភាពនៃកសិពាណិជ្ជកម្ម គេឃើញ កាន់តែច្បាស់នូវទំនាក់ទំនងបែបពឹងពាក់គ្នា ដែលបណ្តាលមកពីតម្រូវការស្បៀងអាហារ សម្រាប់ចិញ្ចឹមជីវិតនៅឯ ទីជនបទ ។ មានន័យថា គោលបំណងចង់បានស្ថិរភាពស្បៀងអាហារ សម្រាប់ចិញ្ចឹមជីវិតនៃប្រជាកសិករ អាច នឹងសម្រេចបានកាន់តែច្រើន ប្រសិនពួកគាត់ក្លាយជាអ្នកស្វែងរកពំនាក់អាស្រ័យដោយធ្វើជាអ្នកជួលដី អ្នកខ្ចីបុល ឬក៏ពលករស្មោះស្ម័គ្រនឹងសមាជិកណាម្នាក់នៃវណ្ណៈម្ចាស់ដី និងចៅកែចងការប្រាក់ ។

គេអាចដឹងពីឋានៈ ឬឋាន:របស់អ្នកភូមិណាម្នាក់នៅក្នុងប្រព័ន្ធវណ្ណៈ និងរចនាសម្ព័ន្ធចៅហ្វាយនាយ-អ្នកពឹង ពាក់ប្រចាំភូមិស្រុកទាំងមូលបាន តាមរយៈការស្វែងយល់ថា តើជីវភាពរស់នៅរបស់គាត់មានស្ថិរភាពកម្រិតណា ហើយថាតើកម្រិតស្ថិរភាពនោះត្រូវអាស្រ័យលើទំនាក់ទំនងផ្ទាល់ខ្លួន ក្នុងការពឹងពាក់លើអ្នកធំ និងអ្នកមានជាង នៅក្នុងទំហំប៉ុណ្ណាដែរ ។

ជាការពិតណាស់ងារជាម្ចាស់ដីធំនៅក្នុងភូមិ គឺជាងារដែលគេគ្រប់គ្នាចង់បានយ៉ាងខ្លាំង ។ គ្រួសារដែលមាន

ដីធ្លីលើសពីទំហំសម្រាប់ដាំដំណាំជាស្បៀងអាហារ អាចមានទិន្នផលលើសដែលជាហេតុធ្វើឲ្យពួកគេទាញយកផលប្រយោជន៍ពីឱកាសធ្វើពាណិជ្ជកម្មបានយ៉ាងងាយស្រួល និងងាកទៅប្រកបរបររកស៊ីដទៃទៀត ដូចជាការដឹកជញ្ជូន ការធ្វើឈ្មួញកណ្ដាល ចងការប្រាក់ និងលក់ដូរ ។ ឥទ្ធិពលរបស់ពួកគេលើសេដ្ឋកិច្ចក្នុងស្រុក ធ្វើឲ្យពួកគេចាប់អារម្មណ៍លើការពឹងពាក់របស់អ្នកភូមិដែលខ្វះខាត ។

ងារជាម្ចាស់ដីតូចតាចមិនមែនជាអ្វីមួយអស្ចារ្យទេ ប៉ុន្តែជាអ្វីដែលអ្នកភូមិភាគច្រើនប្រាថ្នាចង់បានផងដែរ ។ យ៉ាងហោចណាស់ពួកគេមានដីគ្រប់គ្រាន់ សម្រាប់ប្រកបរបរចិញ្ចឹមជីវិត ដែលជួនកាលអាចផ្ដល់ទិន្នផលលើសដល់ពួកគេ សម្រាប់ទូទាត់នឹងតម្រូវការក្នុងពេលដំណាំណាមួយផ្ដល់ផលតិច ឬមើលជំងឺដោយមិនចាំបាច់លក់ដី ។ ទោះបីជាមានភាពម្ចាស់ការបន្តិចក្តី ម្ចាស់ដីតូចតាចទាំងនោះ ក៏មានការពឹងពាក់លើម្ចាស់ដីធំៗផងដែរដើម្បីទទួលយកនូវរបស់របរផ្សេងៗ ដូចជាការទិញគ្រាប់ធញ្ញជាតិ និងការដាំដុះ ការដឹកជញ្ជូន និងទីផ្សារ ការទាក់ទងជាមួយមន្ត្រី តម្រូវការផលទានម្ដងម្កាល ។ មានកត្តាផ្សេងទៀត ដែលបំពានដល់ការរស់រានមានជីវិតរបស់ម្ចាស់ដីតូចតាច ។ ដោយសារតែដីធ្លីកាន់តែតូច ហើយមានការចែកកេរមរត៌កបន្តដល់កូនចៅទៀត ការងាកទៅធ្វើពលកម្មលើដីធ្លីមានកំណត់បែបនោះ បានបង្ខំអ្នកមានដីធ្លីតិចធ្លាក់ខ្លួនជំពាក់បំណុលគេ ហើយរហូតដល់បាត់បង់ដីក៏មាន ។[៣៨] ដូច្នេះ ឋានៈរបស់ពួកគេត្រូវទម្លាក់មកជាអ្នកជួលដីនិងពលករ ។

តាមនិយមន័យអ្នកជួលដី ឬអ្នកប្រវាស់ដីដាំដំណាំត្រូវភ្ជាប់ទំនាក់ទំនងបែបពឹងពាក់ ជាមួយនឹងម្ចាស់ដីដែលពួកគេបានជួល ដូចច្នេះហើយ ពួកគេមានពេលតិចតួចសម្រាប់បង្កបង្កើនផលផ្ទាល់ខ្លួនពោល គឺបានទិន្នផលតិចជាងអ្នកមានដីតិចតួច ។ ដោយឡែក ភាពខុសគ្នាក្នុងចំនោមអ្នកជួលដីទាំងឡាយ គឺអាស្រ័យលើកម្រិតសុវត្ថិភាពនៃជីវភាពរស់នៅរបស់ពួកគេ ។ អ្នកជួលដីដែលមានសុវត្ថិភាព គឺជាអ្នកទាំងឡាយណាដែលជួលដីមានជីវជាតិល្អ ទំហំសមល្មម ក្នុងតម្លៃសមរម្យ ពីសាច់ញាតិដែលជួយជ្រោមជ្រែងគេ ឬយ៉ាងហោចណាស់មិនទារថ្លៃជួលនៅក្នុងគ្រាលំបាកដាំដំណាំមិនបានផល ។ ជំពូកអ្នកជួលដីទាំងនេះ យ៉ាងហោចណាស់ក៏គ្រាន់បើជាងអ្នកមានដីតិចតួចដែលមិនមានមេកើយណាម្នាក់សម្រាប់ពឹងពាក់ ។ គន្លឹះដ៏សំខាន់នៃការចិញ្ចឹមជីវិតប្រកបដោយស្ថិតស្ថេរ គឺការអាចដាំដុះលើដីដែលមានជីវជាតិ (មិនសំខាន់ថាគេជាម្ចាស់កម្មសិទ្ធិលើដីនោះទេ) និងការធានាអត្ថិភាពសង្គមក្នុងគ្រារកលំបាក ។ ហេតុនេះ គេចូលចិត្តក្លាយជាអ្នកជួលដីដែលមានសុវត្ថិភាព ជាជាងធ្វើជាម្ចាស់កម្មសិទ្ធិលើដីងាយរងគ្រោះ ដោយសារមិនមានគន្លឹះសំខាន់ទាំងពីរខាងលើ ។

ការជួលដីតូចៗហាក់ដូចជាមិនសូវពេញនិយមទេ ដោយហេតុថា ទំហំផ្ទៃដីតូចពិបាកធ្វើឲ្យគេអាចរកប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិតបានគ្រប់គ្រាន់ ក្រោយពីផាត់ថ្លៃជួលដីរួច ។ ប៉ុន្តែ ទោះបីជាមិនអាចធានាឲ្យមានសុវត្ថិភាពដទៃទៀតបានក៏ដោយ ក៏ការជួលដីទ្រង់ទ្រាយតូចៗបានផ្ដល់គុណសម្បត្តិសំខាន់ៗ មួយចំនួនសម្រាប់អ្នកទាំងឡាយណា ដែលមានជីវភាពរស់នៅបានព្រឹកខ្វះល្ងាច ។ គុណសម្បត្តិទី ១ ទំហំផ្ទៃដីតូចៗបានផ្ដល់នូវការការពារប្រឆាំងទៅនឹងការកំណត់តម្លៃតាមអំពើចិត្ត ក្នុងខណៈពេលដែលអ្នកជួលដីតូចៗត្រូវស៊ីឈ្នួលបញ្ចេញពលកម្មដើម្បីផ្គត់ផ្គង់ជីវភាពបន្ថែម ។ ទី ២ មានកស្តុតាងជាច្រើនបញ្ជាក់ថា ការជួលដីតូចៗត្រូវបានគេធ្វើបន្តទៀតមិនមែន ដោយសារតែអាចផ្ដល់ស្បៀងអាហារទេ ប៉ុន្តែដោយសារការជួលបែបនេះ អាចជួយសម្រួលដល់ការខ្ចីបុលប្រាក់ ពីម្ចាស់ដីមុនពេលរដូវប្រមូលផលមកដល់ៗ ការសិក្សារបស់តាកាហាហ្ស៊ី នៅតំបន់លូហ្សុនកណ្ដាលបង្ហាញពីបរិបទបែបនេះ ពោលគឺបង្ហាញពីរបៀប ដែលអ្នកជួលដីបានចំណាយពេលវេលាតិចតួច ធ្វើការលើផ្ទៃដីជួល

ដែលពួកគេត្រូវចែកភោគផលពាក់កណ្ដាលជាមួយម្ចាស់ដី ។ ផ្ទុយទៅវិញ ពួកគេសន្ធាតស៊ីឈ្នួលធ្វើពលកម្មយកប្រាក់កម្រៃនៅលើដីគេផ្សេងទៀត ដែលពួកគេមិនចាំបាច់ត្រូវចែករំលែក (ជាមួយអ្នកណា)ឡើយ ។ ពួកគេហាក់មានឋានៈជាអ្នកជួលដីដដែល ប៉ុន្តែ ពួកគេពុំចាំបាច់យកចិត្តទុកដាក់ថែទាំដំណាំលើដីចម្ការស្រែដែលពួកគេបានជួលឲ្យបានដិតដល់ទេ ដោយហេតុថា «ប្រសិនបើពួកគេនៅតែជាអ្នកជួលដី ពួកគេអាចរំពឹងខ្ចីបុលអ្វីៗ ដើម្បីចិញ្ចឹមជីវិតពីម្ចាស់ដី បុម្យ៉ាងទៀត អ្នកជួលដីយ៉ាងហោចណាស់ត្រូវបានម្ចាស់ដីធានាឲ្យមានកម្រិតជីវភាពមួយសមរម្យ ទោះជាមានកម្រិតទាបបំផុតយ៉ាងណាក៏ដោយ»។[៣៩] នៅផ្នែកខ្លះនៃតំបន់អាស៊ីអាគ្នេយ៍នេះដែរ គេចូលចិត្តជួលដីជាជាងស៊ីឈ្នួលធ្វើការប្រចាំថ្ងៃ បើទោះបីជាថ្ងៃឈ្នួលដីមានតម្លៃខ្ពស់យ៉ាងណាក៏ដោយ ។ ជាឧទាហរណ៍ នៅតំបន់ដីសណ្ដរតុងកឹង ការជួលដីគ្មានសុវត្ថិភាព យ៉ាងហោចណាស់អាចផ្ដល់ដល់អ្នកជួលដីនូវលទ្ធភាពដាំដុះលើផ្ទៃដីផលទានគ្រប់គ្រាន់សម្រាប់រស់នៅ និងលទ្ធភាពខ្លះ សម្រាប់ការចំណាយបន្ថែមនៅក្នុងអំឡុងពេលរដូវដាំដុះ ។[៤០] ការជួលដីទ្រង់ទ្រាយតូចៗភាគច្រើននៅតំបន់កោះជ្វាកណ្ដាល និងខាងកើតត្រូវគេឲ្យតម្លៃយ៉ាងខ្លាំងដោយសារគេអាចទទួលបានសុវត្ថិភាពស្បៀងអាហារពីម្ចាស់ដី ។ ចំណុចនេះចង់បញ្ជាក់ថា ទោះបីជាការជួលដីមានលក្ខណៈសង្កត់សង្កិន អាចទាញអ្នកជួលឲ្យធ្លាក់ក្នុងការជំពាក់បំណុលគេ ហើយអាចនឹងមិនទទួលបានផលចំណេញស្មើនឹងការស៊ីឈ្នួលគេធ្វើពលកម្មកក៏ដោយ ក៏កសិករជាច្រើននៅតែចូលចិត្តការជួលដីបែបនេះ ពីព្រោះតែអាចផ្ដល់ឲ្យពួកគេនូវទំនាក់ទំនងសង្គម ជាមួយនឹងមេកើយដ៏មានឥទ្ធិពល (ជាអ្នកធានាសុខុមាលភាពផ្នែកសម្ភារៈជាអប្បបរមារហូតដល់រដូវប្រមូលផល) ។ គុណសម្បត្តិនៃការពឹងពាក់បែបនេះ បានធ្វើឲ្យកសិករឃ្លាតឆ្ងាយពីការស៊ីឈ្នួលធ្វើពលកម្ម ។

> សូម្បីតែនៅក្រោមប្រព័ន្ធជួលដីបែបប្រពៃណី... អ្នកជួលដីមានលក្ខណៈប្រសើរជាងពលករស៊ីឈ្នួលធ្វើកសិកម្ម...។ អ្នកជួលដីបែបប្រពៃណី ហាក់ដូចជាមានឆន្ទៈអត់ទ្រាំនឹងភាពអយុត្តិធម៌ទាំងឡាយ ជាថ្នូរនឹងការទទួលបានសុវត្ថិភាពស្បៀងអាហារ។ ពួកគេនឹងមិនបោះបង់ចោលគុណសម្បត្តិទាំងនេះទេ បើសិនជាគេមិនទទួលបាននូវផលប្រយោជន៍ជាប្រាក់ចំណេញ ដែលអាចទូទាត់នឹងសុវត្ថិភាពដែលគេអាចបាត់បង់ ។[៤១]

វណ្ណៈនៃអ្នកស៊ីឈ្នួលធ្វើពលកម្មកសិកម្ម (ជាចំណាត់ថ្នាក់មួយនៅក្នុងវិស័យកសិពាណិជ្ជកម្ម) ជាធម្មតាខ្វះខាតការធានាសម្រាប់ជីវភាពរស់នៅជាអប្បបរមា ពោលគឺ សូម្បីតែលទ្ធភាពជួលដីតូចៗសម្រាប់ចិញ្ចឹមជីវិតក៏គ្មានផង ។ ទោះយ៉ាងណា នៅក្នុងវណ្ណៈនេះមានភាពខុសគ្នាបន្តិចបន្តួច ក្នុងផ្នែកសុវត្ថិភាពនៃការចិញ្ចឹមជីវិត ពីព្រោះក្រុមគ្រួសារភាគច្រើននៅក្នុងចំណាត់ថ្នាក់នេះ ស្ទើរតែគ្មានអ្វីសម្រាប់ចិញ្ចឹមជីវិត ។ ហេតុដូចនេះលោកហ្គូរូ បានបែងចែកភាពខុសគ្នា រវាងកម្មករធ្វើការពេញមួយឆ្នាំនៅតុងកឹង (ដែលត្រូវគេឲ្យប្រាក់កម្រៃប្រចាំឆ្នាំ ទទួលបានការផ្គត់ផ្គង់ផ្នែកសម្លៀកបំពាក់ ហូបអាហារជាមួយគ្រួសារខ្លួន ហើយជួនកាលអាចឲ្យកូនប្រុសធ្វើការងារបន្តពីខ្លួន) និងកម្មករស៊ីឈ្នួលប្រចាំសប្ដាហ៍ ឬថ្ងៃ ដែលរងឥទ្ធិពលទាំងស្រុងពីបំរែបំរួលតម្លៃពលកម្មភ្លាមៗក្នុងរយៈពេលខ្លី និងពីតម្រូវការពលកម្ម ហើយដែលជាអ្នកមានលទ្ធភាពផ្នែកសង្គមតិចតួច ក្នុងការស្វែងរកការជួយជ្រោមជ្រែងរយៈពេលខ្លី ។[៤២] ស្ថានភាពរបស់កម្មករប្រចាំឆ្នាំ អាចប្រដូចបានទៅនឹងស្ថានភាពរបស់អ្នកបម្រើកសិដ្ឋាននៅចុងសតវត្សទី ១៨ និងដើមសតវត្សទី ១៩ នៅប្រទេសអង់គ្លេស ដែលត្រូវគេជួលស្រដៀងគ្នាដែរ ពោលគឺត្រូវគេជួលស្របតាមតម្រូវការកសិកម្មប្រចាំឆ្នាំ ។ ពួកគេ គឺជាសមាជិកដែលមានសុវត្ថិភាពបំផុតក្នុងចំណោម

ផ្នែកកម្លាំងពលកម្មកសិកម្ម បើទោះបីជាពួកគេទទួលបានប្រាក់កម្រៃ និងភាពឯករាជ្យតិចតួចក៏ដោយ ។ពួកគេភាគច្រើនសុខចិត្តទទួលយកប្រាក់កម្រៃទាបពីការឃ្វាលចៀម ឬបម្រើការងារនៅកសិដ្ឋានជាងសាកល្បងចាប់យកឱកាសនៅលើទីផ្សារការងារ ។[៤៣] ការសិក្សារបស់លោកហ.ចិន ដាំ នៃភូមិនៅកោះដ្វា ក៏បង្ហាញឲ្យឃើញពីទំនាក់ទំនងដូចគ្នា រវាងការធានាសម្រាប់ជីវភាពរស់នៅជាអប្បបរមា និងកង្វះខាតឯករាជ្យ នៅក្នុងចំណោមកម្មករកសិដ្ឋានដែលមានសុវត្ថិភាព ។

> នៅក្នុងទំនាក់ទំនងថៅហ្វាយនាយ-អ្នកបម្រើនោះ កូនឈ្នួលត្រូវចងភ្ជាប់ទៅនឹងថៅហ្វាយនាយដោយប្រពៃណី ដោយប្រាក់កម្ចី... ហើយនៅក្នុងករណីមួយចំនួន ដោយសារប្រការដែលថា គាត់កំពុងតែរស់នៅលើដីរបស់ថៅហ្វាយ ។ នៅក្នុងស្ថានភាពដែលបានលើកឡើងនៅខាងក្រោយនេះ ពិតណាស់ដែលថាកូនឈ្នួលនោះត្រូវមានកាតព្វកិច្ចធ្វើកិច្ចការផ្សេងៗ ក្នុងពេលណាមួយដោយមិនចាំបាច់យកប្រាក់កម្រៃ...។ អ្នកបម្រើទទួលយកការណែនាំពីថៅហ្វាយនាយ ។ គំនិតនៃការយល់ដឹងអំពីវណ្ណៈរបស់ខ្លួន គឺមិនអាចអនុវត្តបានទេ ក្នុងទំនាក់ទំនងបែបនេះ...។[៤៤]

ការធ្វើពាណិជ្ជកម្មលើវិស័យកសិកម្ម នាំឲ្យមានការប្រែប្រួលសមាសធាតុនៃវណ្ណៈនៅជនបទ ។ ម្ចាស់ដីតូចៗហាក់ត្រូវគេគាបសង្កត់ ហើយត្រូវធ្លាក់ខ្លួនក្នុងវណ្ណៈអ្នកជួលដី ចំណែកអ្នកជួលដីដែលមានសុវត្ថិភាព ត្រូវក្លាយជាអ្នកជួលដីគ្មានសុវត្ថិភាព ចំណែកអ្នកជួលដីគ្មានសុវត្ថិភាព ត្រូវធ្លាក់ខ្លួនទៅក្នុងវណ្ណៈពលករ ដែលជាបន្តបន្ទាប់មកទៀតត្រូវក្លាយជាកម្មករស៊ីឈ្នួលប្រចាំថ្ងៃ (ដោយមិនមានការការពារផ្នែកសង្គម) ត្រូវរងឥទ្ធិពលទាំងស្រុង ពីការឡើងចុះនៃតម្លៃទំនិញ និងតម្រូវការការងារពលកម្ម ។ គេមានការលំបាកខ្លាំងណាស់ ក្នុងការបែងចែកពីវណ្ណៈនីមួយៗ ÷ ក្នុងពេលតែមួយកសិករម្នាក់អាចជាម្ចាស់ដីតូចៗផង និងអាចជាអ្នកជួលដីផង ឬថាអាចជាអ្នកជួលដីផង និងជាអ្នកស៊ីឈ្នួលធ្វើពលកម្មផង ។ យ៉ាងណាមិញការបែងចែកវណ្ណៈនៅជនបទ កាន់តែត្រូវគេធ្វើដោយឈរលើប៉ូល នៃភាពម្ចាស់ការ និងភាពពឹងពាក់ ។

> ហេតុនេះ គេនឹងសង្កេតឃើញថា កសិកម្មនៅតំបន់ឥណ្ឌូចិនមានបដិវត្តជាបណ្ដើរៗ ឆ្ពោះទៅរកចំណុចមួយដែលមានធាតុផ្សំខុសគ្នាពីរសំខាន់ៈ មួយផ្នែក គឺម្ចាស់ដីដែលមានដីច្រើន និងដីធំល្មម...ដែលបញ្ចេញឥទ្ធិពលរបស់ខ្លួនតាមរយៈអំណាចមន្ត្រី ក្រុមប្រឹក្សាតំបន់ និង ក្រុមប្រឹក្សាកសិកម្ម ។ល។ សមាគមរបស់ពួកគេ សារព័ត៌មាន និងប្រព័ន្ធឥណទាន ។ ហើយមួយផ្នែកទៀត គឺបណ្ដាប្រជាកសិករទាំងឡាយដែលកំពុងធ្វើការមានដូចជា : ម្ចាស់ដីតូចៗកសិករជួលដី កសិករប្រវាស់ដី អ្នករកប្រាក់កម្រៃ ដែលប្រភេទទាំងអស់នេះសុទ្ធតែជាប្រជាជនរណបរបស់ក្រុមទីមួយ ។[៤៥]

លើសពីនេះទៅទៀត នៅពេលដែលតួនាទី ឬវណ្ណៈ (ឥតទៀងទាត់) របស់កសិករមានការធ្លាក់ចុះលក្ខខណ្ឌនៃការពឹងពាករបស់គាត់ កាន់តែត្រូវគេសង្កត់សង្កិនជាលំដាប់ ដោយសារម្ចាស់ដីអាចទាញយកផលចំណេញពីតម្លៃសង្គម និងសេដ្ឋកិច្ចដែលចេះតែកើនឡើងសម្រាប់ដោះដូរនឹងកម្រិតធម្មតា ឬធ្លាក់ចុះនៃការធានាសុវត្ថិភាពនៃការចិញ្ចឹមជីវិត ។ ប៉ុន្តែសម្រាប់អ្នកដែលធ្លាក់ក្នុងវណ្ណៈបាតក្រោមបំផុត ការធានាសុវត្ថិភាពនៃការចិញ្ចឹមជីវិតមិនអាចទុកចិត្តបាន ឬក៏គ្មានសោះតែម្ដង ។

វណ្ណៈកសិករដែលកំពុងធ្លាក់ចុះ មិនគ្រាន់តែបង្កើតលក្ខខណ្ឌកេងប្រវ័ញ្ចការពឹងពាក់នៅក្នុងភូមិប៉ុណ្ណោះទេ ហើយថែមទាំងបង្កើតវណ្ណៈដូចកសិករ តែមិនមែនជាចំណែកមួយរបស់ភូមិ ហើយក៏មិនមែនជាផ្នែកនៃការទាក់ទងពឹងពាក់ដែលមានស្ថិរភាពដែរ ។ អ្នកដែលត្រូវគេរាប់បញ្ចូលក្នុងវណ្ណៈនេះ (ដែលនៅតែមានក្នុងទីជនបទ) គឺមិនត្រឹមតែជាកម្មករចំណាកស្រុក កម្មករនៅចម្ការ អ្នកជួញដូរកំប៉ិកកំប៉ុកប៉ុណ្ណោះទេ តែថែមទាំងរាប់បញ្ចូលសមាស-ធាតុបន្ទាប់បន្សំដទៃទៀត ដូចជាអ្នកសុំទាន ចោរព្រៃ និងអ្នករត់ពន្ធ ។ ពួកគេត្រូវចាត់ចូលក្នុងវណ្ណៈដូចកសិករ ពីព្រោះពួកគេលែងជាធាតុនៃប្រព័ន្ធវណ្ណៈក្នុងភូមិធម្មតា នៃសង្គមកសិកម្មទៀតហើយ ។[៤៦]

អត្ថិភាពនៃចំនួនប្រជាជនដែលគេទាត់ចោលពីសង្គម មិនមែនជារឿងអ្វីថ្មីនោះទេ ។ ដាក់ស្តែងក្នុងសង្គមជនបទបុរាណ តែងមានប្រជាជនមួយចំនួនតូចរស់នៅដាច់ដោយឡែកពីគេ ហាក់ដូចជាភូមិពិសេសមួយដែលកើតឡើងច្រើនគួរសមក្នុងពេលមានព្រឹត្តិការណ៍អាក្រក់ដូចជា ទឹកជំនន់ ការដាំដុះមិនបានផល ឬក៏សង្គ្រាមដែលរំខានដល់ទម្លាប់ដាំដុះចិញ្ចឹមជីវិត ។ ផ្ទុយទៅវិញ ការធ្វើពាណិជ្ជលើវិស័យកសិកម្មនៅតំបន់អាស៊ីអាគ្នេយ៍ និងនៅអឺរ៉ុបនាពេលមុន គឺជាអ្នកទទួលខុសត្រូវក្នុងការបង្កើតជាប្រចាំ នូវវណ្ណៈពលករជនបទ នៅពេលការផ្តោតអារម្មណ៍លើដីធ្លី និងទីផ្សារការងារកសិកម្មដែលកាន់តែរីកធំ បានបង្កើតកម្លាំងពលកម្មការងារមិនស៊ីសង្វាក់គ្នា ។ មួយវិញទៀតដើម្បីទទួលបានសុខុមាលភាពខាងសម្ភារៈ វណ្ណៈដូចកសិករបែបនេះ ត្រូវពឹងផ្អែកយ៉ាងខ្លាំងទៅលើផ្នែកនាំចេញនៅជនបទ ដូចច្នេះហើយ ទើបវណ្ណៈនេះងាយរងគ្រោះខ្លាំងណាស់ពីកម្លាំងទីផ្សារពិភពលោក ។ ដោយសារតែសន្ទុះខ្លាំងការនាំចេញ បានផ្តល់ឱកាសការងារពលកម្មជាច្រើននាដើមសតវត្សទី ២០ ទើបការធ្លាក់ចុះមកវិញ (នៃការនាំចេញ) នៅឆ្នាំ ១៩៣០ បានធ្វើឲ្យកម្មករជាច្រើននាក់ត្រូវគេបណ្តេញចេញពីការងារ ជាពិសេសកម្មករចម្ការដំណាំដែលចូលក្នុងសង្វាក់សេដ្ឋកិច្ចប្រពៃណីមិនចុះ ។ ដោយមិនអាចជៀសរួច អ្នកភូមិភាគច្រើនបានធ្លាក់ខ្លួនក្លាយជាពលកររកំប៉ិកកំប៉ុកនៅជនបទ ។ ដោយសារតែការធ្លាក់ចុះបែបនេះ គឺជាព្រឹត្តិការណ៍ចង្រៃតែ-មួយគត់សម្រាប់វណ្ណៈពលករទាំងមូល ដូច្នេះការឡើងចុះនៃដំណាំឧស្សាហកម្មដទៃទៀត ជាទូទៅកាន់តែធ្វើឲ្យមានអស្ថិរភាពនៃរចនាសម្ព័ន្ធវណ្ណៈ នៅជនបទទាំងមូលផង និងជាពិសេសកាន់តែបង្កឲ្យមានការប្រែប្រួលនៃទំហំ និងសមាសធាតុនៃវណ្ណៈពលករកសិកម្ម ។

## ការបាត់បង់ធនធានធម្មជាតិកំប៉ិកកំប៉ុកនៅក្នុងភូមិ

មុនសម័យអាណានិគម វណ្ណៈកសិករនៅតំបន់អាស៊ីអាគ្នេយ៍ត្រូវបានគេទុកឲ្យមានភាពពឹងពាក់លើខ្លួនឯងតាមរយៈការផ្តល់លទ្ធភាពប្រើប្រាស់ដីដែលអាចដាំដុះបាន ស្មៅ អុស និងធនធានសម្រាប់ចិញ្ចឹមជីវិតដទៃទៀតដែលត្រូវគេផ្តល់ឲ្យដោយឥតគិតថ្លៃ ឬផ្គត់ផ្គង់នៅតាមឃុំ ។ ការរួមផ្សំនៃបញ្ហា ដែលបណ្តាលមកពីសម្ពាធនៃកំណើនប្រជាជន កំណើនម្ចាស់កម្មសិទ្ធិឯកជន លើអ្វីដែលពីមុនមកជាធនធានសាធារណៈដ៏សំខាន់ និងការរឹតបន្តឹងលើការប្រើប្រាស់ដីធ្លី និងព្រៃឈើរបស់ពួកអាណានិគម កម្រិតព្រំដែនសេរីភាពខាងលើកាន់តែតូចឬឈានដល់ការលុបបាត់ទាំងអស់តែម្តង ។ ការកាត់បន្ថយភាពម្ចាស់ការ និងការឡើងចុះនៃជីវភាពរស់នៅរបស់ប្រជាកសិករ កាន់តែកាត់បន្ថយលទ្ធភាពរបស់ពួកគាត់ ក្នុងការរត់ចេញពីការពឹងពាក់គេដែលមានការសង្កត់សង្កិន ។

នៅសតវត្សទី ២០ ការបើកឲ្យប្រកបរបរលើដីថ្មីនាសម័យអាណានិគមនិយម ត្រូវគ្របសង្កត់ដោយសារកំណើនប្រជាជនយ៉ាងគំហុកៗ ជាឧទាហរណ៍នៅកោះជ្វា ចំនួនប្រជាជនស្ទើរតែ ៣ ដងមានការកើនឡើងនៅចន្លោះ

*ឆ្នាំ ១៨៧០ និង ១៩៤០ ។ កំណើននេះ មិនបន្សល់ទុកដីត្រង់កន្លែងណាមួយឲ្យនៅទំនេរនោះទេ ។ នៅតំបន់ផ្សេងៗ ក៏មានបទពិសោធដូចគ្នានេះដែរ បើទោះជាហាក់ដូចជាមិនមានបញ្ហាធំក៏ដោយ ។ ចំណែកតំបន់លូហ្សិនកណ្តាល តំបន់ខ្ពង់រាបនៅភូមា និងតំបន់ដីសណ្តទុងកឹងត្រូវគេដាក់សម្ពាធឲ្យផ្តល់ជីវភាព ដែលអាចរស់បានដល់ប្រជាពលរដ្ឋរបស់ខ្លួន ខណៈពេលនោះដែរ តំបន់ព្រំដែនដែលកំពុងរលុបរូបរាងនៅកូស៊ាំងស៊ីន និងតំបន់ដីសណ្តនៃប្រទេសភូមា មានដីថ្មីបន្តិចបន្តួចប៉ុណ្ណោះដែលអាចដាំដុះបាន ។ «ការធ្វើចម្ការចល័ត» មិនមែនជាវិធីសមស្របសម្រាប់វណ្ណៈប្រជាកសិករភាគច្រើនទៀតទេ។*

*អ្វីដែលសំខាន់ដូចគ្នានឹងករណីខាងលើ គឺជាការហាមឃាត់មិនឲ្យប្រើប្រាស់ដីរួមនៅតំបន់អាស៊ីអាគ្នេយ៍នៅចុងសតវត្សទី ១៨ និងនៅប្រទេសអង់គ្លេសនាដើមសតវត្សទី ១៩ ។ ភូមិសាមញ្ញនៅតំបន់អាស៊ីអាគ្នេយ៍ត្រូវរក្សាទុកដីមួយចំនួនសម្រាប់ប្រយោជន៍សាធារណៈ ។ ចំណែកខ្លះនៃដីប្រភេទនេះ ជាទូទៅត្រូវគេបើកចំហសម្រាប់គ្រប់គ្នា ដើម្បីតម្រូវការចិញ្ចឹមសត្វ ការបរបាញ់ ឬក៏សម្រាប់តម្រូវការអុសដុត សម្រាប់ករណីពិសេសខ្លះនៅតុងកឹង និងកោះជ្វា ដីដាំដំណាំត្រូវគេរក្សាទុកសម្រាប់រៀបចំពិធីបុណ្យផ្សេងៗតាមឃុំ សម្រាប់ផ្គត់ផ្គង់មន្ត្រីភូមិ និងសម្រាប់អ្នកទីទ័លក្រ ។ នៅគ្រប់ទីកន្លែងដីទាំងអស់នេះមានសារៈសំខាន់ណាស់ ចំពោះសុខុមាលភាពសង្គមនៃប្រជាជនតាមជនបទ ហើយនៅគ្រប់ទីកន្លែង ដីទាំងនេះចាប់ផ្តើមបាត់បង់ដោយការរំលោភយកពីសំណាក់ម្ចាស់កម្មសិទ្ធិឯកជន (ជាញឹកញយដោយមន្ត្រីក្នុងតំបន់) ឬត្រូវរឹតបន្តឹងដោយម្ចាស់អាណានិគម ដូចទៅនឹងការហាមឃាត់មិនឲ្យប្រើប្រាស់ដីនៅក្នុងប្រទេសអង់គ្លេសដែលបាន «កម្ទេចសេដ្ឋកិច្ចចិញ្ចឹមជីវិតដ៏លំបាក ទាំងទ្រង់ទ្រាយតូចរបស់ជនក្រីក្រ ដូចជា មេគោ ក្ងាន ឬអុសដុតរបស់សាធារណជន...»[៤៧] ភាពខ្សោយនៃយន្តការបុរាណនៅតំបន់អាស៊ីអាគ្នេយ៍ ក៏មានលទ្ធផលដូចគ្នានេះដែរ ដែលជាហេតុធ្វើឲ្យការពឹងអាស្រ័យលើគេ គឺជាផ្លូវតែមួយគត់ដើម្បីរស់។*

*សារៈសំខាន់របស់ធនធានធម្មជាតិកំប៉ិកកំប៉ុកបែបនេះ ចំពោះវណ្ណៈកសិករ ហើយនិងប្រតិកម្មដែលអាចកើតឡើងត្រូវបានបង្ហាញតាមរយៈចលនា «សាមិន» នៅដើមសតវត្សរ៍ទី ២០ នៅឯកោះជ្វា ។[៤៨] ប្រតិកម្មខ្លាំងបំផុតរបស់ពួកសាមិន ដែលត្រូវគេជ្រើសរើសឲ្យធ្វើការនៅតំបន់ជិតៗព្រៃឈើម៉ៃសាក់ គឺប្រតិកម្មតទល់នឹងការហាមឃាត់មិនឲ្យអ្នកដាំដុះ និងអ្នកកាប់អុសចូលក្នុងព្រៃ ព្រោះព្រៃទាំងនោះត្រូវអតិរក្សដោយនាយកដ្ឋានព្រៃឈើ ។ ដោយចង់សាកល្បងបិទច្រកសុវត្ថិភាពសេដ្ឋកិច្ចប្រពៃណី ដែលប្រជាកសិករគិតថាជាមត៌កដូនតារបស់គេ ជនជាតិហូឡង់ គឺជាអ្នកនាំឲ្យមានប្រតិកម្មតវ៉ាពីក្រុមសកម្មសាមិន និងបណ្តាលឲ្យមានការរំលោភបំពានលើច្បាប់ព្រៃឈើជាច្រើនពាន់ករណី ។*

*ការលុបបំបាត់ធនធានធម្មជាតិចាស់ៗអាចមានឥទ្ធិពលថែមទៀត ក្នុងការជំរុញឲ្យប្រជាកសិករជួបប្រទះនូវបញ្ហាអសន្តិសុខសេដ្ឋកិច្ច ។*

> ការធ្វើកសិកម្មសម្រាប់ចិញ្ចឹមជីវិតនៅសម័យបុរាណ កសិករអាចរកស្មៅ ឬស្បូវបានដោយសេរី ដើម្បីយកមកក្រង អាចរកឬស្សីដោយសេរី អាចយកឈើមកធ្វើជាអុសដុតពីដីសាធារណៈដែលទំនេរដោយសេរី ។ ពួកគេអាចរកត្រីពីស្រះទឹក ឬពីអូរនៅក្បែរផ្ទះ ហើយពួកគេអាចត្បាញសម្លៀកបំពាក់នៅផ្ទះរបស់គេបាន ។ នៅពេលដែលដីទំនេរនៅទីសាធារណៈបានក្លាយជាដីដែលដាំដុះបាន នៅពេលដែលការនេសាទត្រូវគេប្រកាសថាជាទ្រព្យសម្បត្តិរបស់រដ្ឋាភិបាល ហើយនៅពេលដែលការត្បាញនៅតាមផ្ទះមិនអាចហុចផលចំណេញ ម្ចាស់ទ្រព្យសម្បត្តិតូចៗភាគច្រើនដូចជាអ្នកជួលដីត្រូវមានភារកិច្ចកាន់តែច្រើន ក្នុងការរកលុយសម្រាប់ចំណាយលើតម្រូវការផ្សេងៗដែលកន្លងមកពួកគេអាចផ្គត់ផ្គង់ដោយខ្លួនឯងបាន ។[៤៨]

មន្ត្រីអាណានិគមនៅប្រទេសភូមា ដែលបានធ្វើការវាយតម្លៃដូចខាងលើ អាចពិពណ៌នាយ៉ាងត្រឹមត្រូវពីដីទំនាបជាច្រើនទៀត នៅតំបន់អាស៊ីអាគ្នេយ៍ ។

## កម្រោយយន្តការកម្រិតសមភាពក្នុងភូមិ និងការបន្ថយតម្រូវការរកអ្នកពឹងពាក់

សេដ្ឋកិច្ចបែបប្រពៃណី នៅក្នុងភូមិបានបង្កើតឲ្យមានសម្ពាធសង្គម ដែលជាកត្តាទប់ទល់កុំឲ្យមានភាពខុសគ្នាផ្នែកទ្រព្យសម្បត្តិ (គម្លាតខ្លាំងពេករវាងអ្នកមាន និងអ្នកក្រ) ។ ការច្រណែនឈ្នានីស និងការទាមទាររបស់អ្នកដែលមានអារម្មណ៍ថា ខ្លួនបាត់បង់ប្រយោជន៍ជាកម្លាំងរួមផ្សំជំរុញឲ្យអ្នកដែលមានទ្រព្យសម្បត្តិច្រើនជាង គេចែករំលែកទ្រព្យចំណេញមួយចំនួនធំរបស់ផងខ្លួន ឲ្យទៅអ្នកផ្សេងតាមរយៈសកម្មភាពមនុស្សធម៌ ការចំណាយលើពិធីបុណ្យ ផ្តល់ប្រាក់កម្ចី ឬក៏ទទួលយកការពឹងពឹងបន្ថែមទៀត ។ យ៉ាងណាមិញគេអាចនឹងខុសបើគេវិនិច្ឆ័យលក្ខណៈសហគមន៍បែបនេះថា ជាសង្គមសមភាពនិយម ។ ផ្ទុយទៅវិញការទាញសន្និកម្មហួសពីសម្ពាធ ធ្វើឲ្យមានសមភាពនៅក្នុងសង្គមបែបនេះ គឺជាសន្និកម្មបែបអភិរក្សនិយម ក្នុងការធានាឲ្យបានថាគ្រប់ៗគ្នានៅក្នុងភូមិមានជីវភាពរស់នៅដូចគ្នា ដែលបង្កើតឲ្យមាន «ទីកន្លែង ឬមុខរបរមួយ» សម្រាប់សមាជិកទាំងអស់នៅក្នុងសហគមន៍ ។

យន្តការចែករំលែក (ការមានបាន) នៅក្នុងភូមិជះឥទ្ធិពលពីរយ៉ាង ទៅលើទំនាក់ទំនងពឹងពាក់តាមភូមិស្រុក ។ ឥទ្ធិពលទីមួយ គឺថាយន្តការបែបនេះអាចទប់ល្បឿនកំណើនវិសមភាព និងការបែងចែកវណ្ណៈ (ក្នុងសង្គម) ដែលអាចផ្តល់ជាមូលដ្ឋានសេដ្ឋកិច្ច សម្រាប់ការពឹងពាក់ ។ ឥទ្ធិពលទីពី គឺនៅពេលណាមួយភាពខុសគ្នា (ក្នុងសង្គម) កាន់តែចេញរូបរាងច្បាស់ សម្ពាធនៃការកម្រិតសមភាពសង្គម មិនអាចស្រូបទាញយកទ្រព្យសម្បត្តិពីខាងណាមកប្រើប្រាស់ជាប្រយោជន៍សហគមន៍ទាំងមូល និងជួយទំនុកបម្រុងដល់ការចិញ្ចឹមជីវិតរបស់អ្នកក្រីក្រក្នុងភូមិបានទេ ។ អ្នកភូមិដែលមានឥទ្ធិពល ដែលយល់ដឹងពីទម្លាប់នៃការចែករំលែក (ភាពមានបាន) នឹងទទួលបាននូវរង្វាន់មកវិញជាមុខមាត់ថ្លៃថ្នូរ និងកិត្តិនាមខ្ពង់ខ្ពស់ដោយសប្បុរសធម៌ ។ ជាការពិត «ភាពសប្បុរសធម៌» របស់ពួកគេធានាបាននូវការពង្រឹងតួនាទីសង្គម របស់ពួកគេនៅក្នុងសហគមន៍ ។ នៅពេលដែលវិសមភាពសង្គមកើតមានឡើង សម្ពាធនៃការចែករំលែកភាពមានបាន អាចជួយធានាលក្ខខណ្ឌអប្បបរមាសម្រាប់អ្នកពឹងពាក់កាន់តែច្រើនដើម្បីជួយបង្កើតមូលដ្ឋាន ដែលធ្វើឲ្យទំនាក់ទំនងថៅហ្វាយនាយ-អ្នកពឹងពាក់មិនអាចដួលរលំបាន ។

បម្រែបម្រួលសង្គមក្នុងសម័យអាណានិគមនិយម មិនបានធ្វើឲ្យខូចនូវទម្លាប់ចែករំលែកភាពមានបាន នៅតាមស្រុកភូមិទេ ។ ជាការពិតណាស់ នៅតំបន់កូស៊ាំងស៊ីន និងវាលទំនាបភូមា ដែលជាកន្លែងតាំងទីលំនៅថ្មី និងមានការគ្រប់គ្រងដោយផ្ទាល់ គេពុំឃើញទម្លាប់បែបនេះ មានច្រើនជាងបណ្តាភូមិប្រពៃណីដែលមានសាមគ្គីភាពស្អិតរមួតនៅតំបន់តុងកឹង និងកោះជ្វានោះទេ ។ យ៉ាងណាមិញប្រសិទ្ធភាពនៃសម្ពាធទាំងនេះ (ឧទាហរណ៍លទ្ធភាពរបស់វាក្នុងការគាពារប្រជាកសិករ) ត្រូវអាស្រ័យយ៉ាងខ្លាំងលើ (ក) សមត្ថភាពរបស់វរជន ដែលមានការគាំទ្រពីកម្លាំងខាងក្រៅដើម្បីទាត់ចោលច្បាប់ទម្លាប់នៅក្នុងស្រុក (ខ) ប្រការដែលថាកម្មសិទ្ធិ និងទ្រព្យសម្បត្តិក្នុងស្រុកកាន់តែត្រូវអ្នកក្រៅគ្រប់គ្រងនិង (គ) សម្ពាធនៃកំណើនប្រជាជនលើសពីធនធាន ដែលមានក្នុងស្រុក។ ឧទាហរណ៍មួយចំនួននឹងបង្ហាញពីទំហំ និងឥទ្ធិពលចុះអន់ថយនៃយន្តការចែករំលែកភាពមានបាន និងបង្ហាញពីតម្លៃរបស់យន្ត

*ការនេះ ដែលនៅតែបន្តមានចំពោះកសិករក្រីក្រ ។*

*សាមគ្គីភាពដ៏រឹងមាំនៃសហគមន៍នៅកោះដ្លា ជាពិសេសនៅភូមិតូចៗ ត្រូវបានបង្ហាញតាមរបៀបជាច្រើន ។ សាមគ្គីភាពលេចរូបរាងក្នុងពិធីបុណ្យសាសនា គឺអ្នកជិតខាងជួយគ្នាទៅវិញទៅមកក្នុងការធ្វើម្ហូបអាហារ និងការទទួលស្គាល់ជារួម ក្នុងការគោរពទីសក្ការៈម្ចាស់ភូមិករ ។ តាមធម្មតា ភូមិតូចៗហាក់មានឯកលក្ខណភាពផ្នែកនយោបាយដោះស្រាយជម្លោះនៅក្នុងភូមិដោយផ្ទាល់ ហើយប្រការនេះជួយពង្រឹងទម្រង់ការដ៏មានស្ថិរភាព នៃការដោះដូរកម្លាំងពលកម្មគ្នាទៅវិញទៅមក ។ ទំនាក់ទំនងសង្គមដ៏ស្អិតរមួតធ្វើឱ្យអំពើចោរកម្មនៅក្នុងភូមិតូចៗទាំងនោះ «កម្រកើតមាន និងជាអំពើដែលគេមិនពេញចិត្ត» ។[៥០] សាមគ្គីភាពនេះបានរួមចំណែកឱ្យភូមិនៅកោះដ្លាមានសភាពល្អឡើងវិញ (ដូចក្នុងរឿងព្រេង) នៅពេលប្រឈមមុខទៅនឹងសម្ពាធសេដ្ឋកិច្ច និងកំណើនប្រជាជនយ៉ាងសម្បើម ។ នៅក្នុងដំណើរការដែលលោកហ្សែតស៍ បរិយាយថាជា «កសិកម្មរួមតូច» ឬ «ការពង្រីកតែមិនទៅមុខ» ភូមិដ្ឋានបានក្លាយជាជម្រកសម្រាប់ប្រជាជនយ៉ាងច្រើន ដែលពុំធ្លាប់មានកន្លងមកនៅលើផ្ទៃដីចាស់ ដោយ «ចែករំលែកភាពក្រីក្រ» ក្នុងលក្ខណៈមួយដោយផ្តល់ជម្រកដល់មនុស្សគ្រប់គ្នា ទោះបីជាទង្វើបែបនេះធ្វើឱ្យសុខុមាលភាព (ក្នុងភូមិទាំងមូល) មានការធ្លាក់ចុះក៏ដោយ ។[៥១]*

*ដំណើរការផ្តល់ទីជម្រកត្រូវធ្វើឡើងនៅជុំវិញតំបន់ដែលមានដីសាធារណៈ និងកម្លាំងពលកម្ម ។ ការតាំងលំនៅជាច្រើនបានកាត់ដីរដ្ឋ (ដែលអ្នកភូមិ ជួលដាំដំណាំ) ជាងពាក់កណ្តាល ជាហេតុធ្វើឱ្យចំនួនអ្នកភូមិដែលមានសិទ្ធិកាន់កាប់ដីធ្លីកើនជាពីរ ។ ម្ចាស់ដីក្នុងស្រុកជាច្រើន ត្រូវរងសម្ពាធជ្រៀកដីកម្មសិទ្ធិរបស់ខ្លួនដើម្បីជួលឱ្យអ្នកជួលដីកាន់តែច្រើន តាមតែអាចធ្វើទៅបាន ។ ដោយឡែក មានការតវ៉ាមិនឱ្យជួលដីទៅឱ្យអ្នកណាម្នាក់ ដែលនៅខាងក្រៅភូមិព្រោះថា ទង្វើនេះអាចកាត់បន្ថយទំហំដីសាធារណៈ សម្រាប់ការប្រើប្រាស់ជាទូទៅរបស់ម្ចាស់ស្រុក ។[៥២] នៅពេលដែលការចាប់ផ្តើមប្រើប្រាស់កណ្តៀវបានធ្វើឱ្យធ្លាក់ចុះនូវតម្រូវការកម្លាំងពលកម្មសម្រាប់ការច្រូតកាត់ អ្នកភូមិបានខិតខំព្យាយាមដោយទទួលបានជោគជ័យខ្លះៗ ដើម្បីរារាំងមិនឱ្យគេប្រើប្រាស់កណ្តៀវ ។ ដូចដែលលោក វែន ហ្គែលដឺរែន បានកត់សម្គាល់ឃើញថា «ទម្រង់សង្គមបុរាណមានអត្ថន័យចំពោះការពិតដែលថា ការផ្គត់ផ្គង់អាហារជាទូទៅ គឺត្រូវធ្វើឡើងក្នុងក្របខណ្ឌឃុំ ដើម្បីការពារសមាជិកភូមិឱ្យបានច្រើន តាមតែអាចធ្វើទៅបានតាមរយៈការចែករំលែកទិន្នផលដំណាំ»។[៥៣] ជាទីបញ្ចប់មិនទំនងសោះដែលថាការជួលអ្នកបម្រើ ទោះបីម្ចាស់ដីតូចៗជាអ្នកជួល ក៏ដូចជានៅកន្លែងផ្សេងទៀតដែរ អាចជាការបង្ហាញសម្ពាធទោះតាមមធ្យោបាយណាក៏ដោយ ទៅលើអ្នកពឹងពាក់ នៅក្នុងចំណោមអ្នកក្រីក្រក្នុងភូមិ ។[៥៤]*

*តាមលក្ខណៈប្រវត្តិសាស្ត្រ គេអាចមានការសោកស្តាយដូចលោកហ្សែតស៍ ចំពោះការអភិរក្សភូមិរបស់ពួកអាណានិគមហូឡង់ និងសម្ពាធចែករំលែកភាពមានបាន ដោយហេតុថា ពួកគេរារាំងមិនឱ្យមានការលេចឡើងនូវវណ្ណៈគូឡាក់ (កសិករធុនមធ្យមដែលមានដីធ្លី និងមានលទ្ធភាពជួលកម្មករ) រួមមានកសិករធ្វើជំនួញយ៉ាងជោគជ័យ ឬក៏វណ្ណៈពលករ ដែលអាចធ្វើឱ្យមានបម្រែបម្រួលបដិវត្តន៍ ។ ភូមិនៅកោះដ្លាពិតជាបានធ្វើឱ្យការបែងចែកវណ្ណៈជាពីរ ក្នុងសង្គមកសិកម្មដែលមានការអន់ថយ និងធ្វើឱ្យកសិករស្ថិតនៅថ្នាក់ក្រោមនៃប្រព័ន្ធឧបត្ថម្ភបែបប្រពៃណី ។ ប៉ុន្តែស្ថានភាពនេះអាចកើតមានឡើង ដោយសារតែរហូតមកដល់ពេលថ្មីៗនេះ ទំនាក់ទំនងទាំងនោះធានាបានយ៉ាងពិតប្រាកដ នូវការចិញ្ចឹមជីវិតជាអប្បបរមាសម្រាប់ប្រជាជន ដែលចេះតែកើនឡើង យ៉ាងណាមិញសូម្បីតែភូមិនៅកោះដ្លា ក៏មិនអាចសម្របខ្លួនបានយ៉ាងស្រួលដែរ ។ ការយកចិត្តទុកដាក់ក្នុងការធ្វើជាម្ចាស់កម្មសិទ្ធិដីធ្លី កាន់តែ*

បង្កើនចំនួនម្ចាស់ដីមកពីក្រៅភូមិ ដែលអាចនឹងព្រងើយកន្តើយចំពោះគំនិតអ្នកភូមិ ។ នេះជាហេតុធ្វើឲ្យមានកំណើនចំនួនកម្មករគ្មានដីធ្លី ដែលគេមិនអាចដោះស្រាយបញ្ហាទីជម្រកសម្រាប់ពួកគេនៅក្នុងវង្វង់ភូមិកំណើត គឺពេលនោះហើយដែលការបែងចែកវណ្ណៈកាន់តែលេចរូបរាងច្បាស់ ។ ជាធម្មតាមានធនធាន ដែលគ្រប់គ្រងត្រឹមកម្រិតស្រុក តែបន្តិចបន្តួចប៉ុណ្ណោះ សម្រាប់ការប្រើប្រាស់ទូទៅ លើសពីនេះទៅទៀតមានមនុស្សច្រើនពន់ពេកទាមទារសិទ្ធិប្រើប្រាស់ធនធានទាំងនោះ ជាហេតុធ្វើឲ្យមានសម្ពាធចែករំលែកភាពមានបាន ដើម្បីការពារលក្ខខណ្ឌនៃការដោះដូរមិនឲ្យគេបំពានអំណាច ដែលចេះតែរួញតូចទៅនៅក្នុងវណ្ណៈកសិករ ។

ដូចភូមិនៅកោះដូា ភូមិវៀតណាមនៅតំបន់ដីសណ្តទុងកឹងត្រូវគ្រប់គ្រងដោយម្ចាស់ដីតូចៗ ហើយមានដីឃុំសម្រាប់ទាំងការចិញ្ចឹមជីវិត និងមានទាំងសម្ពាធខ្លាំងសម្រាប់ការចែករំលែកភាពមានបាន ។ ដោយឥទ្ធិពលនៃកំណើនប្រជាជន អ្នកភូមិនៅទុងកឹងបានតស៊ូប្រឆាំងនឹងការបាត់បង់ដីធ្លីទល់នឹងអ្នកមកពីក្រៅ និងព្យាយាមធានាឲ្យបានថា គ្រប់ៗគ្នានៅក្នុងឃុំមានដីប្រើប្រាស់ ។

> ...អ្នកភូមិបញ្ចេញប្តឹងកពាជាសត្រូវដាក់ពួកគេ ហើយពុះពារគ្រប់បែបយ៉ាងដើម្បីការពារកុំឲ្យជន ចម្លែកទិញដីក្នុងភូមិបានសូម្បីតែមួយចំម្រៀកតូច ។ និន្នាការនេះនៅតែបន្តកើតមាន ហើយនៅក្នុងករណីជាច្រើន ប្រសិនបើជនណាហ៊ានទិញដីនៅក្នុងឃុំ ដែលមិនមែនជាទីកន្លែងកំណើតរបស់ខ្លួន ជននោះប្រាកដជាមានការខកចិត្តជាពុំខាន ។ អ្នកភូមិទាំងឡាយសាមគ្គីគ្នាជាក្រុមទប់ទល់នឹងការដកហូត កម្មសិទ្ធិដីធ្លីនៃអ្នកភូមិផងរបស់គេ ។ អ្នកទិញត្រូវគេរំពឹងថា នឹងជួលដីទៅឲ្យអ្នកលក់ធ្វើកសិកម្មវិញ ហើយគាត់មិនត្រូវយកថ្លៃឈ្នួលដីពេលណាដែលដំណាំមិនបានផលល្អ ។ ផ្ទុយទៅវិញ គាត់នឹងមិនអាចរកកសិករណាផ្សេងមកជួលដីគាត់បានទេប្រសិនបើគាត់ចង់ធ្វើការផ្លាស់ប្តូរ (ដៃគូរប្រវាស់ដី) ។[៥៦]

លក្ខណៈមូលដ្ឋាននៃការចិញ្ចឹមជីវិត របស់អ្នកភូមិទុងកឹងមានការរីកចម្រើនរហូតដល់មានរៀបចំជួលដីធ្លី និងការបែងចែកការងារ ។ សីលធម៌នៃការចិញ្ចឹមជីវិតនៅក្នុងភូមិយ៉ាងល្អប្រសើរបែបនេះ គេពុំឃើញមាននៅក្នុងកន្លែងណា ច្បាស់ជាងនៅក្នុងការពិពណ៌នារបស់លោក ហ្គូរូ ស្តីពីគ្រោះ ទុរ្ភិក្សនៅក្នុងភូមិមួយ ដែលមានតែការចែករំលែកភាពស្រេកឃ្លាននឹងគ្នាទេ ដែលអាចជួយអ្នកណាម្នាក់នៅក្នុងភូមិឲ្យរួចផុតពីសេចក្តីស្លាប់ ។[៥៧] ដោយឡែកលក្ខណៈចែករំលែកភាពមានបានរបស់ភូមិទុងកឹង មិនអាចទប់ទល់នឹងសម្ពាធពាណិជ្ជកម្ម និងកំណើនប្រជាជនដ៏ខ្លាំងក្លានោះបានទេ ។ អ្នកភូមិទុងកឹងរាប់ពាន់នាក់មិនមានជម្រើសអ្វីច្រើន ក្រៅពីធ្វើការនៅក្នុងអណ្តូងរ៉ែ ឬក៏បម្រើការជាកម្មករជាប់កិច្ចសន្យានៅភូមិភាគខាងត្បូង ស្ថិតក្នុងលក្ខខណ្ឌការងារដ៏លំបាកបំផុត ។ ប៉ុន្តែ កម្មករចំណាកស្រុកភាគច្រើនបានរក្សាទំនាក់ទំនងល្អជាមួយសហគមន៍ ដើម្បីទទួលបានសុវត្ថិភាពរស់នៅល្អ ។ បើទោះបីជាមានការប្រឆាំងពីអ្នកភូមិ ការដែលមានកម្មករជាច្រើនមិនត្រលប់ទៅស្រុកកំណើតវិញ (ក្រោយចប់កិច្ចសន្យា) ក្លាយជារឿងធម្មតា ហើយរហូតដល់ត្រឹមទសវត្សរ៍ឆ្នាំ ១៩៣០ មធ្យមភាគនៃចំនួនប្រជាជនដែលគ្មានដីធ្លីនៅតំបន់ដីសណ្តទុងកឹង បានកើនឡើងហួសពីចំនួនប្រជាជន ដែលគ្មានដីធ្លីនៅប្រទេសចិនភាគខាងត្បូង ។[៥៨] ការចែករំលែកធនធានធម្មជាតិកំប៉ិកកំប៉ុកនៅក្នុងភូមិស្រុក អាចធានាបាននូវការចិញ្ចឹមជីវិតសម្រាប់អ្នកភូមិមួយចំនួនតូចប៉ុណ្ណោះ ។

តាមប្រភពព័ត៌មានទាំងឡាយ ភូមិម៉ាឡេមានការសហការគ្នាតិចជាងភូមិនៅកោះដូា និងទុងកឹង ហើយមិន

ស្ងួរប្រឈមមុខនឹងកំណើនប្រជាជនទេ ។ ទោះជាយ៉ាងណា គេឃើញមានតឹងតាងបញ្ជាក់អំពីនិន្នាការ ធ្វើឲ្យមានសមភាពសង្គម (នៅទីនោះ) ។ លោកស្ទិហ្វបានពិពណ៌នាពីសម្ពាធសង្គម ដែលបង្អាក់ទឹកចិត្តអ្នកភូមិម៉ាឡេ ពីការខិតខំរកប្រាក់ចំណូលឲ្យបានច្រើនលើសពីកម្រិតមធ្យម (មានការទាមទារ រែអង្គាសពីអ្នកណា ដែលរកប្រាក់ចំណូលបានច្រើន) ហើយការធ្វើឲ្យច្បាស់នៃទំនាក់ទំនងបែបពឹងពាក់ ដែលក្នុងនោះអ្នកភូមិមានទ្រព្យសម្បត្តិច្រើនត្រូវជួយ «ក្រុមគ្រួសារក្រីក្រសម្រាប់ដោះស្រាយជីវភាពក្នុងគ្រាលំបាក» ដើម្បីជាថ្នូរនឹងកម្លាំងពលកម្មដោយឥតគិតថ្លៃ និងការជួយគាំទ្រពេលមានជម្លោះក្នុងភូមិ ។[៥៩] ទោះបីជាការធ្លាក់ចុះអំណាចអ្នកពឹងពាក់នៅម៉ាឡេមិនបន្តធ្លាក់ចុះខ្លាំងថែមទៀត ដូចនៅតំបន់ដីសណ្តរតុងកឹង ឬនៅកោះជ្វាមានភស្តុតាងច្បាស់លាស់ បញ្ជាក់អំពីការធ្លាក់ចុះនៃសមត្ថភាពការពាររបស់អ្នកភូមិនៅទីនោះផងដែរ ។ «...ការកើនឡើងនៃការយកចិត្តទុកដាក់លើភាពជាម្ចាស់ដីត្រូវជួយជំរុញដោយកំណើនប្រជាជន ហើយការពាក់ព័ន្ធនឹងប្រាក់កាស កាន់តែធ្វើឲ្យមានការបែងចែកសង្គមម៉ាឡេជាពីរមួយ គឺវណ្ណៈមន្ត្រីរដ្ឋការ និងម្ចាស់ដីដែលមានទំនាក់ទំនងតិចតួចជាមួយអ្នកភូមិ និងវណ្ណៈមួយទៀត គឺក្រុមអ្នកជួលដីគ្មានសុវត្ថិភាព និងពលករកសិកម្ម ។[៦០]

នៅក្នុងទិដ្ឋភាពជាច្រើន បណ្តាភូមិក្នុងតំបន់សម្បូរសេកម្មភាពពាណិជ្ជកម្ម នៃលូហ្សិនកណ្តាលបង្ហាញនូវករណីធ្ងន់ធ្ងរនៃសម្ពាធសមភាពក្នុងភូមិស្រុក ដែលធ្វើឡើងចំពោះតែធនធានរបស់សហគមន៍មួយផ្នែកតូច និងនៅក្នុងចំណោមប្រជាជនក្រីក្រមួយចំនួនធំ ។ ពួកគេ ពិតជាផ្លាស់ប្តូរឱកាសទាញយកធនធានមកចិញ្ចឹមជីវិត ដោយការជួលកម្លាំងពលកម្មពីគ្នាទៅវិញទៅមកឲ្យបានច្រើនបំផុត ដើម្បីធ្វើឲ្យប្រាក់ចំណូលភាគច្រើនមានចរាចរណ៍តែនៅក្នុងភូមិរបស់ពួកគេ ដោយការទាញយកកម្លាំងពលកម្មសល់ មកប្រើប្រាស់ក្នុងរដូវប្រមូលផល «ដើម្បីឲ្យពួកគេ (អ្នកជួយប្រមូលផល ដែលមិនមែនជាអ្នកធ្វើស្រែចម្ការផ្ទាល់ខ្លួន) អាចចិញ្ចឹមជីវិតបានដែរ» និងដោយការរក្សាសិទ្ធិបែបប្រពៃណីក្នុងការចិញ្ចឹមសត្វ និងរើសកួរស្រូវក្រោយពេលច្រូតកាត់ហើយ[៦១] ។ ប៉ុន្តែឥឡូវនេះ ដីក្នុងភូមិមួយភាគធំត្រូវកាន់កាប់ដោយអ្នកក្រៅ ដែលជាហេតុធ្វើឲ្យដំណើរការផ្ទៃក្នុងនៃការប្រើប្រាស់ធនធានរួម អាចកើតមានឡើងចំពោះតែធនធានបន្ទាប់បន្សំតែប៉ុណ្ណោះ ហើយឱកាសដែលនៅសល់តិចតួចនៅក្នុងដៃប្រជាពលករ ។

សរុបមកយើងឃើញថា ហាក់ដូចជាមានហេតុផល ៣ យ៉ាងដែលកាន់តែធ្វើឲ្យចុះខ្សោយនូវលទ្ធភាពរបស់សហគមន៍ក្នុងការរារាំងមិនឲ្យលេចឡើងភាពខុសគ្នាយ៉ាងខ្លាំងផ្នែកទ្រព្យសម្បត្តិ ឬក្នុងការធានាឲ្យមានការចិញ្ចឹមជីវិតជាអប្បបរមា នៅក្នុងរចនាសម្ព័ន្ធវិសមភាពណាមួយ ។ ហេតុផលទី ១ គឺថាអ្នកនៅក្នុងសហគមន៍ដែលគ្រប់គ្រងធនធាននៅក្នុងស្រុក លែងពឹងពាក់ទៅលើសុពលភាព និងការគាំទ្រនៅក្នុងស្រុក ដើម្បីបានដំណែងរបស់ពួកគេ (លែងលែងតែនៅក្នុងបរិបទនៃការបោះឆ្នោត) ដូចកាលពីមុនទៀតឡើយ ដែលកាលនោះពួកគេស្ថិតនៅក្នុងបរិបទប្រពៃណី ។ ដាធម្មតារដ្ឋដណ្តើមយកភាពជាម្ចាស់កម្មសិទ្ធិវិញ តាមរយៈតុលាការ និងកម្លាំងយោធារបស់ខ្លួនដូច្នេះហើយទើបជារឿយៗ ពួកគេអាចរំសាប់ការប្រឆាំងដំទាស់ ពីថ្នាក់ភូមិស្រុកដោយចំណាយបន្តិចបន្តួច ។[៦២] មូលហេតុទី ២ ក៏ជាហេតុផលសំខាន់ផងដែរ គឺថាសម្ពាធចែករំលែកភាពមានបានក្នុងភូមិ ផ្តោតខ្លាំងបំផុតតែលើធនធានដែលគ្រប់គ្រងនៅខាងក្នុងស្រុកប៉ុណ្ណោះ ។ ដោយមានការបាត់បង់ដីសាធារណៈ ការកើនឡើងនៃកម្មករជាប់កិច្ចសន្យាមិនវិលទៅស្រុក ដែលធ្វើការតាមរយៈភ្នាក់ងារជួលកម្លាំងពលកម្ម ការកើនឡើងនៃចំនួនអ្នកជួលដី និងពលករដែលធ្វើការនៅក្នុងភូមិប៉ុន្តែរស់នៅកន្លែងផ្សេងនិងដោយមានរចនាសម្ព័ន្ធខ្ទីបុល ដែលជារឿយៗបំផុតភ្ជាប់អ្នកភូមិទៅនឹងអ្នកក្រៅ ទើបយន្តការធ្វើឲ្យមានសមភាពសហគមន៍មួយ អាចផ្លាស់ប្តូរការប្រើប្រាស់ធនធាន

បានបន្តិចបន្តួចតែប៉ុណ្ណោះ ។ ជាលទ្ធផលចុងក្រោយ នាំឲ្យមានប្រព័ន្ធគ្រប់គ្រងសហគមន៍ក្នុងចំណោមវណ្ណៈទាបដែលមិនអាចធានាការចិញ្ចឹមជីវិតជាអប្បបរមាតទៅទៀតទេ ។ ហេតុផលចុងក្រោយ បើទោះបីជាសម្ពាធក្នុងការចែករំលែកភាពមានបានមិនបាន ចុះខ្សោយដោយសារការរកជំនួយគាំទ្រពីវរជនខាងក្រៅ និងការថយចុះដង្រួកធនធានក្នុងស្រុកក៏ដោយ ក៏កំណើនប្រជាជន និងអសន្តិសុខប្រព័ន្ធតម្លៃអាចមានឥទ្ធិពលខ្លាំង លើសកម្លាំងការពារសីលធម៌ចិញ្ចឹមជីវិតរបស់អ្នកភូមិដែរ ។ លក្ខខណ្ឌពាណិជ្ជកម្មកាន់តែអាក្រក់ គឺជាហេតុដែលមិនអាចទប់ទល់នឹងការរីកធំ នៃវណ្ណៈអ្នកជួលដី និងពលករបាន ។

## ការដោះដូរដែលត្រូវគេគេងប្រវ័ញ្ច និងការចាត់បង់ភាពស្របច្បាប់

*អំណាចតថ្លៃរបស់ម្ចាស់ដីនៅតំបន់ពាណិជ្ជកម្ម នៃអាស៊ីអាគ្នេយ៍មានកាន់តែខ្លាំង កាន់តែធ្វើឲ្យគាត់មិនសូវចូលរួមចំណែកធ្វើឲ្យមានសុខុមាលភាព និងសុវត្ថិភាពនៃវណ្ណៈកសិករ ។ តែផ្ទុយទៅវិញ គាត់បែរជាទាញយកប្រយោជន៍កាន់តែច្រើន ពីធនធានដែលនៅសល់ ។ ការចុះខ្សោយអំណាចតថ្លៃរបស់វណ្ណៈកសិករ បានធ្វើឲ្យពួកគេកាន់តែមានអារម្មណ៍ថា ទំនាក់ទំនង (រវាងពួកគេជាមួយម្ចាស់ដី) គ្មានភាពយុត្តិធម៌ ហើយត្រូវគេកេងយកចំណេញពីលើ ។ ជាពិសេសជាងនេះទំនាក់ទំនងនោះលែងផ្តល់ការធានា សម្រាប់ការចិញ្ចឹមជីវិតរស់នៅឲ្យបានត្រឹមត្រូវទៀតឡើយ ។ ពេលខ្លះអារម្មណ៍បែបនេះ បានធ្វើឲ្យពួកគេឈប់ធ្វើការងារទាំងមិនសប្បាយចិត្ត ប្រឆាំងជំទាស់ជាលក្ខណៈបុគ្គល និងក្រុមប្រព្រឹត្តិអំពើហិង្សា ខិតខំប្រឹងប្រែងជួយខ្លួន និងមានស្មៀតទប់ទល់នឹងការបង្ខិតបង្ខំពីវរជនជាម្ចាស់ដី ។*

*ទោះបីជាសម្ពាធខាងផ្នែកសេដ្ឋកិច្ច និងកំណើនប្រជាជនបានសង្កត់ទៅលើវណ្ណៈប្រជាកសិករនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ ក៏ល្បឿន និងទំហំនៃការផ្លាស់ប្តូរ ក៏ដូចជាទម្រង់រូបីរបស់សម្ពាធនេះ មានលក្ខណៈផ្សេងៗគ្នា ។ គេអាចប្រើប្រាស់ភាពខុសគ្នាបែបនេះ ដើម្បីរិះគន់ដល់ការពន្យល់ណាមួយ ស្តីអំពីការវាស់វែងពេលវេលា និងទម្រង់នៃការបះបោររបស់កសិករ នៅតំបន់ណាមួយជាក់លាក់នោះ ។ នៅក្នុងតំបន់ណា ដែលឱកាសសេដ្ឋកិច្ចធ្វើឲ្យការការពារពីសំណាក់ថៅហ្វាយនាយ ចំពោះកូនថៅមានការធ្លាក់ចុះ តែមិនសូវប៉ះពាល់ខ្លាំងដល់សុខុមាលភាពប្រជាកសិករ និងនៅកន្លែងណាដែលមានទំនាក់ទំនងថ្មីជាមួយអ្នកនយោបាយ និងវរជនដទៃៗកើតឡើងនោះ វរជនជនបទ អាចបាត់បង់ភាពស្របច្បាប់ដោយសន្តិវិធី មានន័យថា ពុំមានការបះបោរកើតឡើងទេ ។*

### កសិដ្ឋានស្រូវ ទីនិញ

*ការវិភាគយ៉ាងហ្មត់ចត់របស់ បែន ជ. ឃើកវ្លីយេ ស្តីអំពីប្រវត្តិសាស្ត្រសង្គមនៅកសិដ្ឋានស្រូវ នូអេវ៉ា អេស៊ីចា (លូហ្សុនកណ្តាលហ្វីលីពីន) ពីឆ្នាំ ១៩០០ រហូតដល់ ១៩៤៦ ពិព័ណនាយ៉ាងច្រើន ពីការធ្លាក់ចុះនៃតួនាទីវណ្ណៈប្រជាកសិករ ។[៦៣] គេអាចសង្កេតឃើញមានការផ្លាស់ប្តូរយ៉ាងច្បាស់ នៅក្នុងភាពខុសគ្នារវាងការគ្រប់គ្រងកសិដ្ឋានរបស់ម៉ានុយអែល ទីនិញ្ញូនៅប្រហែលឆ្នាំ ១៩០៥ រហូតដល់ ១៩២៤ និងកសិដ្ឋានរបស់កូនប្រុសគាត់ឈ្មោះ ម៉ាណូឡូ ពីឆ្នាំ ១៩២៤ រហូតដល់ ១៩៤០ ។*

*ម៉ានុយអែល ទីនិញ្ញូបានទាក់ទាញអ្នកជួលដីឲ្យមកជួលដីកសិដ្ឋានរបស់គាត់ ដោយផ្តល់ឲ្យពួកគេម្នាក់ៗនូវដីចំនួន ២-៤ ហិចតា និងដីផ្ទះមួយឡូ ។ ចំពោះសមាសធាតុនៃការដោះដូរដែលបានរៀបរាប់ពីខាងដើម លោកតាទីនិញ្ញូ បានផ្តល់មធ្យោបាយចិញ្ចឹមជីវិត ទៅដល់អ្នកជួលដីរបស់គាត់ក្នុងលក្ខណៈជាដីធ្លី ការបង្កើនដើមទុនមានដូច*

ជា ប្រព័ន្ធធារាសាស្ត្រ ការជួយចេញថ្លៃគ្រាប់ពូជ និងថ្លៃស្ទូង ហើយជួនកាលគាត់ព្រមទាំងឲ្យគេប្រើប្រាស់ក្របី ដោយឥតគិតថ្លៃផង ។ ដោយសារហេតុនេះគាត់បានទទួលយកទិន្នផលមួយចំណែកកន្លះ ដោយយោងតាមប្រព័ន្ធ ជួលដីកាសាម៉ា ។ ដោយឡែកទីនិញ្ញបានផ្តល់ឲ្យអ្នកជួលដីរបស់គាត់លើសពីលក្ខខណ្ឌមូលដ្ឋាននៃការជួលដីនោះ ដោយរួមមាននូវការធានាការចិញ្ចឹមជីវិតរស់នៅក្នុងគ្រាមានវិបត្តិ ទោះតិច ឬច្រើនក្តី ។ គាត់បានផ្គត់ផ្គង់ ទាំងក្នុង ខណៈពេលដែលដីកំពុងត្រូវគេកាប់ឆ្ការព្រៃ និងក្នុងចន្លោះពេលច្រូតកាត់ដោយមិនគិតការប្រាក់ ។ គាត់បានឲ្យ លុយគេខ្ចី (ដោយយកការប្រាក់) ហើយអាចពន្យាពេលយកថ្លៃជួលដីលើសពីមួយឆ្នាំ ជាពិសេសពេលទិន្នផល ប្រមូលបានតិចតួច ។ ក្នុងពេលក្រុមគ្រួសារអ្នកជួលដីសម្រាលកូន ធ្វើពិធីលាងបាប ពិធីរៀបអាពាហ៍ពិពាហ៍ ឬ មរណភាព ឬក៏នៅពេលដែលមានជំងឺយាយី ពួកគេអាចពឹងទីនិញ្ញឲ្យជួយផ្តល់វិភាគទានផ្ទាល់ខ្លួនសម្រាប់ក្រុម គ្រួសារកសិករទាំងនោះ ។ ម្ចាស់ដីរូបនេះ ក៏អនុញ្ញាតឲ្យអ្នកជួលដីយកផលស្រូវមួយចំនួនតូចដើម្បីចិញ្ចឹមមាន់ និង អនុញ្ញាតឲ្យរើសកួរស្រូវក្រោយពេលច្រូតកាត់រួចរាល់ ។ សេវាការពារមិនសូវជាសំខាន់ទេ បើទោះណាជាកសិ-ដ្ឋាននេះបានការពារសន្តិសុខពីក្រុមចោរលួចប្លន់ក៏ដោយ ហើយ ទីនិញ្ញអាចនឹងធានាដល់អ្នកជួលដីណា ដែលមាន ការជំពាក់ជំពិនរឿងផ្លូវច្បាប់ ។ អន្តរាគមន៍ និងឥទ្ធិពលរបស់ទីនិញ្ញមានសារៈសំខាន់ណាស់ក្នុងការស្វែងរកការ ងារឲ្យកូនរបស់អ្នកជួលដី ដែលចេញពីកសិដ្ឋាន និងជួយអ្នកដែលត្រូវការលិខិតផ្លូវការ ឬក៏អាជ្ញាប័ណ្ណផ្សេងៗ ។ ជាម្ចាស់ដីមានឥទ្ធិពលខ្លាំងតែមួយគត់នៅក្នុងតំបន់ ទីនិញ្ញបានផ្តល់សេវាជាច្រើនដល់សហគមន៍ទាំងមូល ចាប់តាំងពី ការរៀបចំចាត់ចែង និងចូលវិភាគទានដល់សកម្មភាពសប្បុរសធម៌នៅក្នុងស្រុក កិច្ចការសាធារណៈ និងពីធីបុណ្យ នានារហូតដល់ផ្សះផ្សាជម្លោះក្នុងស្រុក និងដើរតួជាអ្នកតំណាងការចរចារជាមួយនឹងអាជ្ញាធរខាងក្រៅ ។[៦៤]

នៅក្នុងការដំណើរការនេះ អ្នកជួលដីបានបំពេញសេវាការងារសំខាន់ៗ ដូចជាការកាប់ឆ្ការព្រៃ (និងការ បង្កើនដើមទុនផងដែរ) ការរាស់ ការភ្ជួរ និងការច្រូតកាត់ៗ លើសពីនេះទៅទៀត គាត់ក៏បានធ្វើការបន្ថែមសម្រាប់ កសិដ្ឋានតាមរយៈការធ្វើកសិដ្ឋាន និងថែទាំក្របី ។ ការចំណាយសម្រាប់ការបោកបែន និងការថែទាំប្រព័ន្ធធារា សាស្ត្រ ត្រូវចែកគ្នាស្មើជាមួយនឹងម្ចាស់កសិដ្ឋាន ។ ក្រៅពីសេវាកម្មការងារទាំងនេះ អ្នកជួលដីបានជួយផ្តល់ របស់របរ និងសេវាកម្មបន្ថែម ។ គាត់បានបរិច្ចាគកម្លាំងពលកម្មរបស់គាត់ និងរបស់ក្រុមគ្រួសារគាត់ ដើម្បីជួស ជុល និងថែទាំផ្ទះ និងឧបករណ៍ផ្សេងៗរបស់ម្ចាស់ដី ព្រមទាំងកិច្ចការផ្ទះជាច្រើនទៀត នៅពេលណាដែលម្ចាស់ដី ត្រូវការ ។ សន្តានចិត្តបន្តិចបន្តួចជាប្រចាំដូចជា ស៊ុតមាន់ទា និងនំនេកជាដើម គឺជាអំណោយត្រូវជូនតាមធម្មតា ផងដែរ ។ ជាចុងក្រោយ អ្នកជួលដីរបស់ម៉ានុយអែលទីនិញ្ញបានជួយបង្កើនផលប្រយោជន៍របស់ចៅហ្វាយនាយ ខ្លួន ដោយសម្តែងភក្តីភាពស្មោះស្ម័គ្រការយកចិត្តទុកដាក់រក្សាទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះចៅហ្វាយព្រមទាំងធន្ទះក្នុង ការទៅធ្វើជាអ្នកបោះឆ្នោតគាំទ្រគាត់ ។

ការពិតដ៏សំខាន់ក្នុងទំនាក់ទំនងដោះដូរនេះ គឺថាទំនាក់ទំនងនេះត្រូវអ្នកជួលដីចាត់ទុកថា មានភាពស្រប ច្បាប់ ។ «ចាស់ៗដែលនៅចាំមុខគាត់ បាននិយាយពីម៉ានុយអែលទីនិញ្ញ ជាអាថ៌ថា ជាអ្នកឧបត្ថម្ភ និងអ្នកការពារ របស់ពួកគេ» ។[៦៥]

ម៉ាណូឡូ ទីនិញ្ញដែលជាអ្នកស្នងដំណែងពីឪពុករបស់គាត់ បានកែទម្រង់តុល្យភាពនៃការដោះដូរ ។ គាត់បាន ផ្លាស់ប្តូរទីលំនៅទៅទីក្រុងក្នុងខេត្ត និងបានគ្រប់គ្រងកសិដ្ឋានតាមរយៈកាទីវ៉ាឡា (អ្នកមើលការខុសត្រូវ) ។ ការ យកចិត្តទុកដាក់ផ្ទាល់ និងការធ្វើអន្តរាគមន៍ដែលសុទ្ធតែជាចរិតលក្ខណៈរបស់ឪពុកគាត់ ត្រូវលោយអស់ហើយៗ

លើសពីនេះទៀត ក្រុមគ្រួសារអ្នកជួលដីដែលរៀបចំពិធីអាពាហ៍ពិពាហ៍ ពិធីលាងបាប ឬក៏មានការយាយីដល់ជីវិតដោយជំងឺ ឬគ្រោះមហន្តរាយនានា ទំនងជាមិនទទួលបានជំនួយឧបត្ថម្ភទៀតទេ ។ ទម្លាប់ផ្តល់ចំណីចិញ្ចឹមមាន់ដោយឥតគិតថ្លៃត្រូវបញ្ឈប់ ហើយការរើសគួរស្រូវត្រូវរឹតបន្តឹង និងត្រួតពិនិត្យយ៉ាងតឹងតែង ។ ចំពោះអ្នកជួលដីជំហានដ៏តឹងតែងបំផុត គឺការលែងផ្តល់រ៉ាសយិន (ស្រូវជម្រុកគាត់ផ្ទាល់) នៅចន្លោះរដូវប្រមូលផលពីសំណាក់ម្ចាស់ដី ។ ម៉ាណូឡូទីនិង្ហូបានបង្វែរការប្រើប្រាស់ធនធានរបស់គាត់បានយ៉ាងប្រសើរដោយ ដោយសារការឲ្យខ្ចីបែបនោះមិនទទួលបានការប្រាក់ ។ ហេតុដូច្នេះ អ្នកជួលដីត្រូវបង្ខំចិត្តទៅខ្ចីប្រាក់ពីអ្នករកស៊ីចងការប្រាក់ផ្ទាល់តែម្តង ពោលជាអ្នកដែលពួកគេរំពឹងទុកថា មានការអាណិតអាសូរបន្តិចបន្តួច (ចំពោះពួកគេ) ។ ក្នុងឋានៈជាម្ចាស់ដីដែលមិនមានវត្តមាននៅនឹងកន្លែង ម៉ាណូលូបានផ្តល់សេវាការពារតិចតួចបំផុតដល់អ្នកជួលដីគាត់ ។ គាត់ហាក់ដូចជាមិនសូវបានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនសម្រាប់ផលប្រយោជន៍ពួកកសិករ ។ ហើយជាការពិតណាស់ គាត់បានចូលរួមវិភាគទានតិចតួចបំផុតក្នុងឋានៈជាមេដឹកនាំ ឬអ្នកគាំទ្រជំនួយហិរញ្ញវត្ថុសម្រាប់គម្រោងធំៗ របស់សហគមន៍ ។ ក្នុងកម្រិតណាមួយ មានការកាត់បន្ថយមធ្យោបាយចិញ្ចឹមជីវិតដូចជាទំនិញ និងសេវាកម្មជាច្រើនដែលម្ចាស់ដីធ្លាប់ផ្តល់ដល់អ្នកជួលដីហើយក្នុងខណៈពេលនោះ អ្នកជួលដីផ្តល់សេវាកម្មការងារតិចតួចចំពោះម្ចាស់ដីនោះក៏ដោយ ក៏សមភាពការងារនេះ មិនអាចប៉ះប៉ូវដល់អ្នកជួលដីសម្រាប់អ្វីដែលពួកគេបានបាត់បង់ឡើយ ។

ច្បាស់លាស់ណាស់ដែលថាអ្វីដែលពួកគេបាត់បង់នោះ គឺជាស្ថិរភាពសេដ្ឋកិច្ចជាមូលដ្ឋាន ដែលធ្លាប់តែទទួលបានពីការធានាការចិញ្ចឹមជីវិតរស់នៅ ក្នុងគ្រាមានវិបត្តិនៃប្រព័ន្ធកសិដ្ឋានបុរាណ ។ អ្នកជួលដីរបស់លោកតាម៉ានុយអែលទីនិញ្ញូដឹងច្បាស់ណាស់ថា ប្រសិនបើដំណាំមិនបានផលច្រើន ប្រសិនបើក្រុមគ្រួសាររបស់ពួកគេប្រឈមមុខនឹងការខូចខាត ឬក៏ប្រសិនបើពួកគេត្រូវការឥទ្ធិពលរបស់អ្នកមានអំណាច ជាទូទៅពួកគេអាចពឹងពាក់រូបគាត់ឲ្យជួយ និងផ្តល់អាហារឲ្យពួកគេបានហូបចុកគ្រប់គ្រាន់ ។ ភក្តីភាពរបស់ពួកគេមួយចំណែកធំ គឺជាការដាក់ទុនដើម្បីធានាបាននូវការបន្តទំនាក់ទំនងជាមួយអ្នកការពារដ៏មានឥទ្ធិពល ។ ម៉ានុយអែលទីនិញ្ញូមិនបានផ្តល់សេវាកម្មទាំងអស់នេះ ដោយអារម្មណ៍សៅហ្មងនោះទេ ។ គាត់ទទួលផលចំណេញយ៉ាងធំធេង ដោយបានគេកាប់ឆ្ការរានព្រៃលើដីរបស់គាត់ក្នុងតម្លៃថោកដោយរក្សាបាននូវអ្នកជួលដីមានភក្តីភាព ក្នុងពេលដែលគាត់ត្រូវការអំណាចនៅក្នុងស្រុក និងដោយបង្កើតកម្លាំងការងារមានស្ថិរភាពរាល់ពេល ដែលមិនទាន់មានកង្វះដីធ្លីនៅឡើយ ។ ដោយឡែកអ្នកជួលដីរបស់កូនប្រុសគាត់ម៉ាណូឡូស្ថិតនៅក្នុងស្ថានភាពលំបាក និងខ្សោយជាង ។ ចំនួនប្រជាជនបានកើនឡើងហើយបញ្ហាកង្វះដីធ្លីក៏កាន់តែផ្ទុះឡើងគួរឲ្យព្រួយបារម្ភ ។ រដ្ឋអំណាចអាណានិគម បានដណ្តើមកាន់កាប់អចលនទ្រព្យដីធ្លីយ៉ាងមានប្រសិទ្ធភាពជាងមុន ហើយការធ្វើពាណិជ្ជកម្មសេដ្ឋកិច្ចមានន័យថា អ្នកជួលដីដែលព្យាយាមជួលដីនៅទីកន្លែងផ្សេងនឹងជួបប្រទះលក្ខខណ្ឌ (ជួលដី) ដូចៗគ្នា ។ ការប្រែប្រួលនៃតុល្យភាពអំណាចនេះហើយ ដែលបណ្តាលឲ្យម៉ាណូឡូ ធ្វើការកែទម្រង់ប្រព័ន្ធគ្រប់គ្រងកសិដ្ឋានរបស់គាត់ ដែលបង្កឲ្យមានវិបត្តិនៃការធានាការចិញ្ចឹមជីវិតរស់នៅ និងជំនួយផ្ទាល់ដែលអ្នកជួលដីរបស់ឪពុកគាត់ធ្លាប់ទទួលបានយ៉ាងរីករាយ ។ «ចំណងទាក់ទងពីមុន ដែលចងភ្ជាប់ទំនាក់ទំនងបិតុនិយម ត្រូវបានកាត់ផ្តាច់បន្តិចម្តងៗ រហូតនៅសល់តែផ្លូវសេដ្ឋកិច្ចតែមួយប៉ុណ្ណោះ» ។ ដោយឡែក សូម្បីតែទំនាក់ទំនងនេះក៏ត្រូវចុះខ្សោយជាលំដាប់ដែរ ដោយសារទំនាក់ទំនងសេដ្ឋកិច្ចមិនមានលក្ខណៈគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការចាំបាច់ សម្រាប់ការរស់នៅក្នុងកម្រិតអប្បបរមារបស់ប្រជាកសិករ» ។[៦៦] ការបាត់បង់សេវាកម្មចៅហ្វាយនាយសំខាន់ៗបែបនេះ ជំរុញឲ្យអ្នកជួលដីរងឥទ្ធិពលនៃអស្ថិរ

ភាពទីផ្សារ និងនាំឲ្យទំនាក់ទំនងរវាងម្ចាស់ដី និងអ្នកជួលដីត្រូវធ្លាក់ចុះ ។ មានភាពទោមនស្សក្នុងរូបភាពផ្សេងៗ អាស្រ័យតាមកាលៈទេសៈនៅក្នុងស្រុក ប៉ុន្តែជារឿយៗសំដៅប្រឆាំងនឹងម្ចាស់ដី ឬទ្រព្យសម្បត្តិពួកគេ ។

ប្រវត្តិនៃការផ្លាស់ប្តូរលក្ខខណ្ឌជួលដី លើអចលនទ្រព្យរបស់ទីនិញ្ញនៅសតវត្សទី ២០ ជាការចុះបញ្ជាំងពីប្រវត្តិភាគច្រើននៅលើកោះលូហ្សុនកណ្តាល ។ ក្នុងកោះលូហ្សុនកណ្តាល តំបន់ដែលមានការធ្វើពាណិជ្ជកម្មស្រូវខ្លាំងក្លាបំផុតដូចជានៅ បាំប៉ាញ៉ា - នុអេវ៉ា អ៊ីចា និងផ្នែកខ្លះនៃតំបន់បុឡាកាន់ពុលាចានធ្លាប់ជួបប្រទះបទពិសោធការផ្លាស់ប្តូរខ្លាំងជាងគេ ក្នុងខណៈពេលដែលនៅខេត្តខ្លះៗដូចជា ប៉ាញ៉ាស៊ីណាន តាក់ឡាក ឬ ប៉ាតានជាដើម អំណាចរបស់អ្នកជួលដីមិនធ្លាក់ចុះឆាប់រហ័សពេកទេ ឬមិនធ្លាក់ចុះទាំងស្រុងដូចច្នោះឡើយ ហើយនៅតំបន់ប៊ីសាយ៉ាន និងប៊ីកូលតួនាទីអ្នកជួលដីស្ទើរតែមិនធ្លាក់ចុះសោះតែម្តង ។ រហូតមកដល់ឆ្នាំ ១៩៦០ ទើបគេអាចបែងចែកភាពខុសគ្នារវាង«ប្រពន្ធជួលដីនៅតំបន់ភាគច្រើននៃបាំប៉ាញ៉ា» ដែលនៅទីនោះ «អ្នកជួលដីត្រូវគេអនុញ្ញាតឲ្យមានភាពរីករាយចំពោះតម្លៃខ្លួនឯង» និងប្រព័ន្ធអវត្តមាន (ម្ចាស់ដីមិននៅជាប់ជាមួយនឹងកសិដ្ឋានរបស់ខ្លួន) នៅក្នុង«តំបន់ជួលដីគ្មានសុវត្ថិភាពសោះដូចជានៅ នុអេវ៉ា អ៊ីចា និងបាំប៉ាញ៉ា» ដែល «គាត់ (អ្នកជួលដី) មិនទទួលបាននូវការអនុញ្ញាតបែបនោះទេ»។[៦៧] ដោយឡែក លក្ខណៈខុសគ្នាទាំងនេះមិនគួរលាក់បាំងទំនោរកណ្តាលឡើយ ។ ម្ចាស់ដីតូចៗកាន់តែច្រើនឡើងៗ បានធ្លាក់ខ្លួនក្នុងវណ្ណៈអ្នកជួលដី ឬពលករក្នុងខណៈពេលដែលម្ចាស់ដីប្រពៃណីក្នុងស្រុក ត្រូវជំនួសដោយវណ្ណៈមានដីជួលដែលកាន់កាប់ដីដើម្បីទទួលបានសន្តិសុខ ប្រាក់ចំណូល និងដែលផ្តល់ការការពារ ឬជំនួយផ្នែកសម្ភារៈបន្តិចបន្តួច ដែលគេទទួលបានពីបុព្វការីជនរបស់ពួកគេ ។ ទំនាក់ទំនងរវាងម្ចាស់ដី–អ្នកជួលដីទំនងជាមាន «លក្ខណៈមិនជិតស្និទ្ធ និងត្រូវកម្រិតមកត្រឹមទិដ្ឋភាពទំនាក់ទំនងសេដ្ឋកិច្ចតែប៉ុណ្ណោះ» ។[៦៨]

ការកើនឡើងនៃអំណាចម្ចាស់ដី ក្នុងការកំណត់លក្ខខណ្ឌនៃការដោះដូរ បានចុះបញ្ជាំងឲ្យឃើញតាមរយៈអ្វីដែលគេទាមទារពីអ្នកជួលដី (និងពលករ) និងអ្វីដែលពួកគេផ្តល់ឲ្យ ។ ជាធម្មតា អ្នកជួលដីត្រូវចេញថ្លៃច្រើនក្នុងដំណើរការដាំដុះ ការបែងចែកដំណាំជាញឹកញាប់ត្រូវផ្លាស់ប្តូរ តាមចំណង់ចំណូលចិត្តរបស់ម្ចាស់ដី ហើយ អ្នកជួលដីនៅពេលខាងមុខកាន់ត្រូវចេញ «លុយធំ» ដើម្បីជួលដី ។

ប៉ុន្តែ ភាគច្រើននៃកម្លាំងតម្លៃដែលចេះតែកើនឡើង របស់ម្ចាស់ដីត្រូវបានបង្ហាញយ៉ាងច្បាស់ តាមរយៈលទ្ធភាពរបស់ពួកគេក្នុងការបដិសេធមិនបំពេញសេវាកម្មទាំងឡាយ ដែលជាការរំពឹងរបស់អ្នកជួលដី ។ ព័ត៌មានស្តីពីប្រវត្តិកសិកម្មមួយចំនួន ដែលចែងថាទំនាក់ទំនងរវាងម្ចាស់ដី និងអ្នកជួលដីកាន់តែមានលក្ខណៈ «វិចារណញ្ញាណ» «ដូចជំនួញ» «មិនជិតស្និទ្ធិ» «គិតតែពីរឿងលុយសុទ្ធសាធ» និង «សក្តិភូមិតិចតួច» ចុះបញ្ជាំងពីការរលាយបាត់នៃការផ្តល់សេវាផ្ទាល់ខ្លួន និងជំនួយផ្នែកសម្ភារៈពីសំណាក់ម្ចាស់ដី។[៦៩] ការបាត់បង់សេវាកម្មបន្ទាប់បន្សំទាំងនេះអាចនឹងមិនមានឥទ្ធិពលខ្លាំងក្លាលើភាពស្របច្បាប់របស់ម្ចាស់ដី ប៉ុន្តែការឈប់ផ្តល់ស្រូវជម្រុកប្រាក់កម្ចី និងការឧបត្ថម្ភផ្ទាល់ បានលុបចោលនូវសេវាកម្មមួយ ដែលមានសារៈសំខាន់ចំពោះវណ្ណៈកសិករ ។ ទោះជាការពឹងពាក់ជាលក្ខណៈប្រពៃណីមានការលំបាកយ៉ាងណាក៏ដោយ ក៏ជាធម្មតាការពឹងពាក់នេះបានគិតបញ្ចូលទាំងសិទ្ធិសង្គមតិចតួច នៅក្នុងទម្រង់ជាកាតព្វកិច្ចវរជន ក្នុងការផ្តល់ការចិញ្ចឹមជីវិតដ៏សមស្របរបស់អ្នកមកពឹងពាក់ ។ មូលដ្ឋានសំខាន់នៃការដាក់ខ្លួនទៅពឹងពាក់គេរបស់អ្នកពឹងពាក់ គឺអាស្រ័យលើការសន្យាផ្តល់ជំនួយដ៏គួរឲ្យជឿជាក់ ។ ខណៈដែលសេវាកម្មផ្ទាល់ខ្លួនទាំងអស់ ដែលជាដំណាងការធានាផ្នែកសង្គមនេះ ត្រូវគេលុបបំបាត់

*ចោលអ្នកពឹងពាក់ក៏បាត់បង់នូវអ្វីដែលពួកគេគិតថា ជាសេវាកម្មដែលមានតួនាទីយ៉ាងសំខាន់ សម្រាប់ធ្វើឲ្យការពឹងពាក់របស់ពួកគាត់ត្រឹមត្រូវតាមច្បាប់ ។*

## ភាពគ្រប់គ្រាន់ និងការចែករំលែកហានិភ័យ

*ការផ្លាស់ប្តូរដែលត្រូវរៀបរាប់នៅខាងលើ អាចចាត់ទុកថាជាបន្លាស់ប្តូរយ៉ាងរហ័ស នៅក្នុងការចែករំលែកហានិភ័យនៅក្នុងវិស័យកសិកម្ម ។ ដូចច្នេះការដោះដូររវាង ម្ចាស់ដី-អ្នកជួលដី បុរាណផ្តល់សិទ្ធិឲ្យម្ចាស់ដីទទួលយកទិន្នផលលើសទៅបាន លុះត្រាគាត់បានផ្តល់ដល់អ្នកជួលដីនូវតម្រូវការសម្រាប់ការចិញ្ចឹមជីវិត ។ ការដោះដូរបែបនេះ ត្រូវអាស្រ័យទៅលើប្រាក់ចំណូលពិតប្រាកដរបស់ប្រជាកសិករ និងការជួយការពារពួកគេទប់ទល់នឹងអតិផរណានៃផលិតកម្ម ឬតម្លៃរបស់ទំនិញ ។ ដោយសារតែការធ្វើពាណិជ្ជកម្មលើវិស័យកសិកម្ម ការចែករំលែកហានិភ័យដែលចេះតែកើនឡើង ត្រូវបែងចែកទៅខាងអ្នកជួលដីកាន់តែច្រើន ព្រោះពួកគេមិនសូវមានលទ្ធភាពដើម្បីសម្របខ្លួនតាមការប្រែប្រួលទាំងនេះ ។*

> វិស័យកសិកម្មជានិច្ចជាកាល គឺជាសហគ្រាសមួយប្រភេទ ដែលពឹងផ្អែកលើយ៉ាងខ្លាំងលើព្រះអាទិទេព ។ ដោយសារតែការធ្វើពាណិជ្ជ-កសិកម្ម សហគ្រាសនេះ ត្រូវស្ថិតនៅក្រោយឥទ្ធិពលនៃការប្រែប្រួលចំនួនប្រាក់ចំណូលសរុបដែលទទួលបានពីសង្វាក់ផលិតកម្ម ។ ជាពិសេសអ្នកមានដីជួល ប្រសិនបើពួកគេជាអ្នកមូលធនកំពុងវិនិយោគដីធ្លីជាជាងអភិជន ដែលទទួលបានប្រាក់ចំណូលពីកេរខ្សែឪពុកបែបសក្តិភូមិរំលែកហានិភ័យជាកត្តាបរាជ័យយ៉ាងច្រើន និងយ៉ាងរហ័សទៅឲ្យអ្នកជួលដី ។ មិនប្រកាន់ថា ការជួលនេះជាការប្រវាស់ដី ឬការជួលដោយប្រាក់នោះទេ កម្រិតមិនទៀតទាត់នៃប្រាក់ចំណូលរបស់វណ្ណៈកសិករ ស្ទើរតែគ្រប់ករណីទាំងអស់មិនដែលទាបជាង ហើយជារឿយៗខ្ពស់ជាងកម្រិតមិនទៀងទាត់ នៃប្រាក់ចំណូលរបស់អ្នកមានដីជួល ។ ប្រការនេះធ្វើឲ្យកម្រិតមិនទៀតទាត់នៃប្រាក់ចំណូលរបស់វណ្ណៈប្រជាកសិករកើនឡើងខ្ពស់ ដែលបង្កឲ្យពួកគេមានការមិនពេញចិត្តផ្នែកនយោបាយ ។[៧០]

*គ្មានកន្លែងណាមួយដែលការបាត់បង់ការធានា សម្រាប់ការចិញ្ចឹមជីវិតមានរូបរាងច្បាស់លាស់ជាងនៅក្នុងព័ត៌មានរបស់រូបើត ស្តីពីសេដ្ឋកិច្ចកសិកម្មនៃតំបន់ដីសណ្តទន្លេមេគង្គ នៅសតវត្សទី ២០ នោះទេ ។[៧១] មុនឆ្នាំ ១៩៣០ ប្រហែលជាផ្នែកភាគច្រើននៃជំនួយ ក្នុងគ្រាមានវិបត្តិបានលេចចេញរូបរាងនៅក្នុងទំនាក់ទំនងម្ចាស់ដី-អ្នកជួលដីដូចដែលការពិពណ៌នារបស់ម្ចាស់ដីជំនាន់ចាស់ៗបានគូសបញ្ជាក់ថា ៖*

> កាលពីមុន ទំនាក់ទំនងរវាងម្ចាស់ដី និងអ្នកជួលដីមានលក្ខណៈជាបិតុនិយម ។ ម្ចាស់ដីចាត់ទុកអ្នកជួលដីជាសមាជិកតូចម្នាក់នៅក្នុងគ្រួសារដ៏ធំរបស់គាត់ ។ នៅពេលដែលឪពុករបស់អ្នកជួលដីស្លាប់ ម្ចាស់ដីមានភារកិច្ចផ្តល់លុយឲ្យអ្នកជួលដីសម្រាប់រៀបចំពិធីបុណ្យសព ហើយប្រសិនបើប្រពន្ធរបស់អ្នកជួលដីមានផ្ទៃពោះ ម្ចាស់ដីត្រូវផ្តល់លុយកាក់សម្រាប់ការសម្រាលកូន ម្យ៉ាងវិញទៀត ប្រសិនណាបើអ្នកជួលដីមានបញ្ហាខាងលុយកាក់ម្ចាស់ដីក៏ផ្តល់ជំនួយផងដែរ ហេតុដូច្នេះ អ្នកជួលដីត្រូវតែបញ្ចេញអាកប្បកិរិយារមទម្យ សមជាសមាជិកតូចម្នាក់នៃគ្រួសារដ៏ធំនោះ ។[៧២]

*ទោះណាជាទំនាក់ទំនងបែបនេះ អាចត្រូវគេចាត់ទុកថាជាការធ្វើដើម្បីខ្លួនឯង គេពុំមានការសង្ស័យច្រើនទេ*

ដែលថាសេវាកម្មទាំងអស់នេះមានការធ្លាក់ចុះយ៉ាងខ្លាំង នៅទសវត្សរ៍ឆ្នាំ ១៩៣០ នៅពេលដែលតម្រូវការដីសម្រាប់កសិកម្មកាន់តែកើនឡើង និងនៅពេលដែលការយកចិត្តទុកដាក់កាន់កាប់កម្មសិទ្ធិដីធ្លីមានសន្ទុះកើនឡើង ។ ទម្រង់នៃការជួលដីត្រូវផ្លាស់ប្តូរពីការប្រវាស់ដីដាំដំណាំចែកគ្នា ទៅជាការជួលគិតតម្លៃ ដាកម្លាំងពលកម្ម ឬទិន្នផលដោយផ្អែកលើការប៉ាន់ស្មាន ទិន្នផលបានពីផ្ទៃដីជួលក្នុងឆ្នាំដែលមានទិន្នផលខ្ពស់ ។ ហេតុនេះអ្នកជួលដីត្រូវរងនូវហានិភ័យ បណ្តាលមកពីការប្រមូលទិន្នផល (មិនល្អ) ក្នុងខណៈពេលដែលប្រាក់ចំណូលរបស់ម្ចាស់ដីមានស្ថិរភាព ។ ម្ចាស់ដី ជួលដីឲ្យតែអ្នកជួលដីណាអាចដាំដុះបានទិន្នផលច្រើន និងអាចទុកចិត្តបានដើម្បីកាត់បន្ថយតម្រូវការប្រាក់ខ្ចី និងជំនួយឧបត្ថម្ភ ។ «ការអត់ឱន» (ដែលជាទម្លាប់ គាត់បន្ថយថ្លៃឈ្នួលក្នុងករណីប្រមូលផលបានតិច) មិនសូវកើតមានទៀតទេ ដោយសារម្ចាស់ដីនៅតែទារយកថ្លៃឈ្នួលច្រើន នៅឆ្នាំទិន្នផលមិនសូវបានល្អក្នុងតម្លៃមួយស្មើតម្លៃជួលសារជាថ្មី ។ ជាទីបញ្ចប់ សុវត្ថិភាពនៃការជួលដីមានការធ្លាក់ចុះ ដោយសារតែម្ចាស់ដីបានបណ្តេញអ្នកជួលដីចាស់ ហើយជួលឲ្យអ្នកផ្សេងទៀតដែលហ៊ានជួលថ្លៃជាង ។ អំណាចម្ចាស់ដី និងតម្លៃជាមនុស្សបានលេចឡើងខ្លាំងបំផុត នៅអំឡុងទសវត្សរ៍ឆ្នាំ ១៩៣០ នៅពេលដែល (ទោះមានការធ្លាក់ចុះខ្លាំងនៃតម្លៃស្រូវនាំចេញ) ទំហំនៃការនាំចេញនៅក្បាបានដដែល ដោយមិនខ្វល់ពីតម្រូវការសម្រាប់ការចិញ្ចឹមជីវិតរស់នៅនៃវណ្ណៈកសិករដែលកាន់តែរីកធំ ។ បរិមាណស្រូវអង្ករសម្រាប់ហូបចុកក្នុងស្រុកនៅសម័យឆ្នាំ ១៩៣៥-៣៧ មានត្រឹមតែ ១២៧ គីឡូក្រាមសម្រាប់មនុស្សម្នាក់ៗ (បើប្រៀបធៀបជាមួយតួលេខជាមធ្យ ២៤០ គីឡូក្រាមសម្រាប់មនុស្សម្នាក់បរិភោគល្មម) ខណៈដែលប្រាក់កម្រៃជាមធ្យម របស់ពលករកសិកម្មបានធ្លាក់ចុះយ៉ាងគំហុក ។[៧៣] ដោយមិនអាចការពារវណ្ណៈកសិករ ដូចដែលតួលេខសរុបបានបង្ហាញនាពេលនេះ ម្ចាស់ដីអាចបន្ថយឥទ្ធិពលនៃការឡើងចុះនៃប្រាក់ចំណូលរបស់ពួកគេ ពីតម្រូវការសម្រាប់ការចិញ្ចឹមជីវិតរស់នៅរបស់ប្រជាកសិករ ។

ការជួលដីពីអ្នករកចំណូលដោយការជួលដី គឺជាទម្រង់ដែលគ្មានតុល្យភាពជាងគេ ហើយមានសកម្មភាពផុសផុលខ្លាំង នៅផ្នែកជាច្រើននៃតំបន់វាលទំនាបភូមា កូសាំងស៊ីន និងតំបន់លូហ្សុនភាគកណ្តាល។ ការជួលដីនៅតំបន់នេះបានបញ្ជាក់ន័យថា មានការលុបចោលរាល់សេវាកម្មម្ចាស់ដីទាំងអស់ លើកលែងតែការជួលដីក្នុងតម្លៃខ្ពស់ឥតថ្លៃបាន ។ អ្វីៗគ្រប់យ៉ាងបានត្រូវលុបចោល ដូចជា ៖ ការលុបចោលការធានានៅក្នុងជីវភាពរស់នៅសំខាន់ៗ សម្រាប់វណ្ណៈកសិករតូចតាច ជំនួយឧបត្ថម្ភផ្ទាល់ខ្លួន និងតួនាទីកណ្តាលរបស់ម្ចាស់ដី វិភាគទានជាក់ស្តែងរបស់វណ្ណៈម្ចាស់ដី ចំពោះសុខុមាលភាពក្នុងភូមិ និងវិភាគទានណាមួយគួរឲ្យកត់សម្គាល់សម្រាប់ការដាំដុះផ្ទាល់តែម្តង ។ អ្វីដែលនៅសេសសល់ គឺអំរែកដ៏ធ្ងន់សម្រាប់វណ្ណៈប្រជាកសិករ ដែលត្រូវរែកពុនភារកិច្ច និងភាពគ្រោះថ្នាក់ស្ទើរគ្រប់បែបយ៉ាងក្នុងការធ្វើកសិកម្ម ចំណែកវណ្ណៈម្ចាស់ដីមិនបានធ្វើអ្វីទាល់តែសោះ ក្រៅតែអំពីប្រមូលថ្លៃឈ្នួល ។ បើសិនម្ចាស់ដីបាត់ស្រមោល លទ្ធផលតែម្យ៉ាងគត់នៃអវត្តមានរបស់ពួកគេ គឺជាការដែលធ្វើឲ្យប្រជាកសិករមានការធូរស្បើយនៅក្នុងការបង់ថ្លៃជួលដី ។ មិនមានអ្វីគួរឲ្យឆ្ងល់ទេ ដែលវណ្ណៈម្ចាស់ដីបែបគ្មានវត្តមាននៅកន្លែងកាន់តែក្លាយជាអ្នកគេងចំណេញ នៅពេលដែលភាគីទាំងសងខាងកំពុងបែកបាក់ និងមិនបានរួមគ្នាឡើងវិញលើកលែងតែការប្រមូលយកថ្លៃជួល។

ដំណើរការដែលគេតាមដាននៅក្នុងការវិភាគនេះ ត្រូវគេកំណត់ព្រំដែនពិភាក្សាដោយចេតនា ថាជាការធ្លាក់ចុះនៃចំណងទាក់ទងសង្គមរវាងប្រជាកសិករ និងវរជនកសិកម្ម ។ ការធ្លាក់ចុះនៃចំណងទាក់ទងដ៏មានកក្តីភាពរវាងចៅហ្វាយនាយ និងអ្នកពឹងពាក់ គឺជាមូលហេតុ (សក្តានុពលលាក់លៀម) នាំឲ្យមានការប្រឆាំងពីប្រជាកសិករ

*និងស្ថាប័នវណ្ណៈ ថាតើគេបានដឹងពីសក្តានុពលនេះ ឬក៏អត់ (កុំគិតពីទម្រង់របស់វា) គឺត្រូវអាស្រ័យលើកត្តាជាច្រើនដែលខ្ញុំមិនបានបង្ហាញ ។ ខ្ញុំអាចធ្វើការសន្និដ្ឋានបានតិចជាងការផ្តល់យោបល់តែពីរ ឬបីបន្ទាត់នៃរបកគំហើញដែលទំនងជាមានសារៈសំខាន់សម្រាប់ការវិភាគក្រោយៗបន្ថែមទៀត ។*

*ជាបឋម យើងអាចនឹងធ្វើការបែងចែកភាពខុសគ្នា រវាងការផ្លាស់ប្តូរដែលនាំឲ្យមាន «ការឈឺចាប់ខ្លាំងជាង» និង «ការឈឺចាប់តិចជាង» នៅក្នុងតុល្យភាពនៃការដោះដូរ ដែលប៉ះពាល់ដល់វណ្ណៈកសិករ ។ ទោះបីជាការផ្លាស់ប្តូរនៃភាពស្របច្បាប់របស់វរជនកសិកម្ម ត្រូវអាស្រ័យលើការផ្លាស់ប្តូរនៃតុល្យភាពការដោះដូររវាងពួកគេ និងប្រជាកសិករការគេងចំណេញពីការផ្លាស់ប្តូរមួយ ដែលប៉ះពាល់ដល់ប្រយោជន៍ប្រជាកសិករទាំងមូល ត្រូវអាស្រ័យលើកម្រិតឥទ្ធិពលរបស់វា ចំពោះសុខុមាលភាពជាក់ស្តែងនៃវណ្ណៈកសិករ ។ នៅពេលដែលសុខុមាលភាពកសិករមិនមានការធ្លាក់ចុះ នៅពេលដែលទំនាក់ទំនងសង្គម ឧបមាថាជាទំនាក់ទំនងជាមួយអ្នកនយោបាយ និងមន្ត្រីផ្តល់យន្តការផ្សេងសម្រាប់ការពារសុវត្ថិភាព នៅពេលដែលការអភិវឌ្ឍទីក្រុង និងឧស្សាហកម្មផ្តល់ឱកាសពិតប្រាកដសម្រាប់កសិករដែលមិនមានជម្រកនៅក្នុងភូមិនោះវរជនកសិកម្មអាចបាត់បង់ភាពស្របច្បាប់ទោះតិច ឬច្រើនដោយសន្តិវិធី ។ សេដ្ឋកិច្ចរស់រវើក កម្មវិធីអភិវឌ្ឍជនបទ និងការឧបត្ថម្ភពីបក្សនៅក្នុងការបោះឆ្នោតតំណាងឲ្យការផ្តល់ដល់កសិករនូវឱកាស និងសេវាកម្មផ្សេងៗដែលធ្វើឲ្យលក្ខខណ្ឌនៃការធ្វើពាណិជ្ជកម្មដ៏លំបាកជាមួយ វរជនកសិកម្មមានការឈឺចាប់តិចជាង ។ ម្យ៉ាងវិញទៀត ប្រសិនបើសុខុមាលភាពរបស់កសិករនៅតែធ្លាក់ចុះ ប្រសិនបើការប្រកបរបរចិញ្ចឹមជីវិតរបស់គាត់នៅរងការគំរាមកំហែង ហើយប្រសិនបើមិនសូវមានមធ្យោបាយណាផ្សេងបើកចំហសម្រាប់ពួកគាត់ នោះដំណើរការនេះអាចទៅមុខលឿន ។*

*ទីពីរជាកត្តាចាំបាច់ណាស់ក្នុងការភ្ជាប់កម្រិតនៃ «ការឈឺចាប់» ដែលប្រជាកសិករធ្លាប់ជួបប្រទះទៅនឹងមធ្យោបាយដែលពួកគេមានដើម្បីធ្វើសកម្មភាព ។ នេះហាក់ដូចជាភាពខុសគ្នាដ៏ធំបំផុត រវាងពលករជនបទដែលនៅក្រៅភូមិ និងអ្នកជួលដី ឬពលករនៅក្នុងភូមិ ។ ពលករជនបទដែលនៅក្រៅភូមិ ហាក់ដូចជាក្រុមដែលពិបាកគ្រប់គ្រងខ្លាំងជាងគេ នៅក្នុងចំណោមវណ្ណៈកសិករ ហេតុនេះហើយទើបមានលក្ខណៈមិននឹងនរ ។ ក៏ប៉ុន្តែពួកគេជាធម្មតារស់នៅរាយប៉ាយ ជាហេតុធ្វើឲ្យគេមិនអាចធ្វើកំណែនបាន ។ ផ្ទុយទៅវិញ ក្រុមអ្នកនៅក្នុងភូមិដែលហាក់មានភាពប្រសើរជាងខាងផ្នែកសម្ភារៈ ជារឿយៗមានភូមិដ្ឋានជារចនាសម្ព័ន្ធដើមនៃការសហការ និងការប្រតិបត្តិ ។ ចំពោះប្រជាកសិករបែបនេះប្រពៃណីតិចតួច និងភូមិដ្ឋាន គឺជាអ្វីមួយមានមុខងារដូចតៀមស្រារោងអ្នកតា-រោងទេវតា និងសង្គមមេត្រីដែលជួយបង្កើត និងធានាការបង្កើត និងបណ្តុះស្មារតីស្គាល់វណ្ណៈខ្លួនរបស់កម្មករអង់គ្លេសនៅសតវត្សទី ១៩ ។ ការវិវឌ្ឍប្រព័ន្ធកាន់កាប់ដីបែបអវត្តមាននៅនឹងកសិដ្ឋាន អាចមានសារៈសំខាន់ខ្លាំងនៅក្នុងបរិបទបែបនេះផងដែរ ដោយហេតុថា ការចាកចេញនៃពួកម្ចាស់ដី បន្សល់ទុករចនាសម្ព័ន្ធភូមិឲ្យស្ថិតនៅក្នុងកណ្តាប់ដៃរបស់អ្នកជួលដី និងម្ចាស់ដីតូចៗ ។*[៧៨]

*កេរតំណែលស្ថាប័នដែលប្រជាកសិករទើបបានកាន់កាប់ មិនមែនថាមិនមានការទូទាត់សងថ្លៃនោះទេ ។ ហេតុតែភាពទោមនុស្សកើតមានឡើងក្នុងសហគមន៍ដ៏តូចនេះ ការគ្រប់គ្រងស្ថាប័ននោះទំនងមានលក្ខណៈក្នុងស្រុកច្រើន និងយកចិត្តទុកដាក់លើបញ្ហាតូចៗ ប៉ុន្តែគម្រោងការសង្គមនៃការប្រឆាំង អាចកំណត់ព្រំដែនបាន ។ នេះជាហេតុផលដែលសម្ព័ន្ធភាពបច្ចុប្បន្ន នៃការរៀបចំសង្គមដែលឈានដល់ភាពល្អប្រសើរ លើសពីកម្រិតតំបន់ (ប្រសិនបើស្ថាប័ននោះកើតមានឡើងពិតមែន) ប្រហែលជានឹងត្រូវសម្រុះសម្រួលគ្នាដោយវរជនប្រឆាំងនឹងក្រុម*

ដែលមិនមែនជាកសិករ ដែលមានទំនាក់ទំនងជាមួយនឹងទីក្រុង ។ តាមប្រវត្តិសាស្ត្រនៅតំបន់អាស៊ីអាគ្នេយ៍ មន្ត្រីសាសនាដែលមានមូលដ្ឋាននៅក្នុងភូមិ ទោះជាប៉ុងជីយីស នៅក្នុងព្រះពុទ្ធសាសនាថេរវាទក្តី ឬក៏គីចាជី ក្នុងភូមិ ឬ ហ្គុរុ តារេកាត នៅក្នុងក្រុមសាសនាតស្វាមក្តី ជារឿយៗតែងបានផ្តល់សីលធម៌ជាអ្នកដឹកនាំ និងមេរៀនអប់រំកសិករ ។ នៅពេលថ្មីនេះទៀតសោត ករណីធ្ងន់ធ្ងរជាច្រើនផ្នែកអាណាចក្រ និងចលនាបដិវត្តន៍បានផ្គត់ផ្គង់ខ្សែរយៈទាំងនេះ ។

ការព្រួយបារម្ភនៅពេលថ្មីនេះចំពោះបដិវត្តន៍កសិករ ទំនងជាលាក់បាំងបច្ច័យអាក្រក់សម្រាប់ក្រុមកសិករភាគច្រើន និងស្ទើរគ្រប់ពេលវេលាទាំងអស់ រួមទាំងអំណាចប្រឆាំង ឬក៏ជាឧបសគ្គផ្ទៃក្នុងក្នុងការកែនមនុស្ស (ជាឧទាហរណ៍ការបំបែកក្រុមសាសនាក្រុមជនជាតិ និងការបែងចែកភូមិសាស្ត្រ ជាដើម) ទាំងអស់នេះបានរារាំងមិនឲ្យមានអំពើហិង្សាធ្ងន់ធ្ងរ ដែលអាចកើតមាន ការសម្របខ្លួនរបស់ប្រជាកសិករចំពោះតថភាពនេះ ទំនងជារឿងនយោបាយដើម្បីមានជីវិតរស់នៅជាដាង រឿងនយោបាយបដិវត្តន៍ ។ ភាពទន់ច្រក ការចាប់ផ្តើមទាំងខុស និង-ផ្លូវងងឹតសូន្យឈឹង គឺជាលក្ខណៈសម្គាល់ការខិតខំប្រឹងប្រែងរបស់ប្រជាកសិករ ដើម្បីការពារខ្លួនហើយការបន្តជីវិតរស់នៅ គឺជាប្រវត្តិសាស្ត្រផ្ទៃក្នុងនៃវិស័យកសិកម្មនៅតំបន់អាស៊ីអាគ្នេយ៍ដែលមិនទាន់មានគេសរសេរនៅឡើយ ។ ខ្ញុំជឿជាក់ថាក្នុងកម្រិតអប្បបរមាគេអាចចង់បែងចែកភាពខុសគ្នា រវាងការខិតខំប្រឹងប្រែងដើម្បីស្តារតុល្យភាព នៃការដោះដូរពីអតីតកាល (ការខិតខំជួយខ្លួនឯង) និងការបង្កើតខ្សែរយៈជំនួយឧបត្ថម្ភថ្មី ។ ការប្រឆាំងរបស់ប្រជាកសិករពីដំបូង ជារឿយៗមានលក្ខណៈអភិរក្សនិយម ពោល គឺវាមានគោលបំណងដើម្បីសម្រាលការឈឺចាប់ក្នុងបរិបទនៃការរេណបគេ ក្នុងការស្តារមុខមាត់ចាស់នៅក្នុងតុល្យភាពនៃការដោះដូរ ។ ការប្រឹងប្រែងដើម្បីសុំឲ្យគេលុបបំបាត់ពន្ធថ្មីផ្តល់ប្រាក់កម្ចីជាថ្មីទៀត ផ្តល់សុវត្ថិភាពដល់ការជួលដីជារឿយៗ គឺជាដំណាងនៃការខ្នះខ្នែងដើម្បីឲ្យពួកវរជនបំពេញភារកិច្ចចាស់របស់ខ្លួន ។ ទោះបីជាពួកគេមានការចាប់អារម្មណ៍លើទំនៀមទម្លាប់ និងប្រពៃណី និងទទួលយកប្រព័ន្ធវណ្ណៈដែលមានស្រាប់ ការប្រឆាំងរបស់ប្រជាកសិករបែបនេះ ជាញឹកញាប់តែងមានអំពើហិង្សាច្រើន នឹងបានជួយពង្រឹងចំណងទាក់ទងក្នុងចំនោមវណ្ណៈកសិករគ្នាឯង ។(៧៥)

ការជួយខ្លួនឯងដែលជារូបភាព នៃការឆ្លើយតបរបស់ប្រជាកសិករ សំដៅទៅទាំងការសម្របខ្លួនជាលក្ខណៈបុគ្គលយ៉ាងស្ងាត់ស្ងៀម ដូចជាការផ្លាស់ប្តូរពីការដាំដំណាំពីស្រូវទៅពោតទៅមើមដំឡូង ដែលអាចបង្កើនការផ្គត់ផ្គង់កាឡូរីក្នុងពេលបាត់បង់សារជាតិបម្រុងរាងកាយ និងការសម្របសម្រួលយ៉ាងសកម្ម ដូចជាការលួចប្លន់ និង «បទឧក្រិដ្ឋ» ដទៃទៀត ។ ការជួយខ្លួនឯងជាក្រុម ឬជួយគ្នាទៅវិញទៅមកមានសណ្ឋានច្រើនយ៉ាងណាស់ ដោយរាប់ចាប់ពីការខ្ចីបណ្តាក់ប្រាក់ និងការជួយគ្នារៀបចំបុណ្យសព រហូតការលួចប្លន់ជាក្រុមធំៗ ។ សណ្ឋាននៃការជួយគ្នាទៅវិញទៅមកមានសារៈសំខាន់ខ្លាំងណាស់ ដោយសារជាញឹកញាប់វាដំណាងឲ្យការផ្តួចផ្តើម ពីក្នុងវណ្ណៈកសិករផ្ទាល់ ដើម្បីរកដំណោះស្រាយដោយខ្លួនឯង ។ សំណល់នៃគំនិតផ្តួចផ្តើមបែបនេះជារឿយៗ ជួយជំរុញឲ្យមានចំណងកាន់តែរឹងមាំសម្រាប់ភាពជាអ្នកដឹកនាំក្រុម និងស្ថាប័ននៃវណ្ណៈ នាពេលអនាគត ។

ការឆ្លើយតបតាមរយៈការជួយខ្លួនឯងផ្នែកខាងក្នុង (ទោះជាវាអាចជួបប្រទះកង្វះខាតសម្រាប់តម្រូវការក្នុងរយៈពេលខ្លី) មិនអាចឋិតថេរក្នុងដំណើរដ៏វែងឆ្ងាយ ក្រៅពីផ្នែកដែលពាក់ព័ន្ធដល់ការចិញ្ចឹមជីវិតរស់នៅតែម្យ៉ាងនោះទេ ។ មួយចំណែកធំនៃដី និងផលដំណាំ ឱកាសការងារ ការអប់រំព្រមទាំងឥណទានរបស់សហគមន៍កសិករត្រូវបានគ្រប់គ្រងដោយអ្នកក្រៅទាំងអស់ ។ ដូចច្នេះហើយតម្រូវការរកទំនាក់ទំនងខាងក្រៅ ដើម្បីស្វែងរកការ

ឧបត្ថម្ភ និងសេវាកម្មឈ្នួញកណ្ដាល កាន់តែមានសារៈសំខាន់ខ្លាំងសម្រាប់ផ្ដល់តម្រូវការចិញ្ចឹមជីវិត និងសុវត្ថិភាព ។ នយោបាយដើម្បីការមានជីវិតរស់នៅ តម្រូវឲ្យកសិករក្ដាប់យកទំនាក់ទំនងដែលពួកគេមាន គឺដោយសារការបំពេញតម្រូវការជាក់ស្ដែងបានទើបស្ថាប័នថ្មី និងបុគ្គលថ្មី ទាំងបែបអភិរក្ស និងទំនើប អាចទទួលបានភាពស្របច្បាប់ និងការគាំទ្រពីវណ្ណៈកសិករ ។

ការពិតទៅ ទំនាក់ទំនងជាមួយចៅហ្វាយថ្មី គឺជាមធ្យោបាយពេញនិយមរបស់ប្រជាកសិករ ដើម្បីឆ្លើយតបចំពោះស្ថានភាពគ្រោះថ្នាក់របស់ពួកគេ បើប្រៀបធៀបទៅនឹងការជួយខ្លួនឯងជាក្រុម វាមានគុណសម្បត្តិខ្លាំងដាង ។ ទំនាក់ទំនងថ្មីនេះផ្ដល់ឲ្យប្រជាកសិករនូវអំណាច ការឧបត្ថម និងការការពារពីខាងក្រៅ ។ ទំនាក់ទំនងនេះអាចផ្ដាច់ភាពឯកោនៃការតស៊ូព្យាយាមនៅក្នុងស្រុក ប៉ុន្តែមានតែមធ្យោបាយនៃចំណងទាក់ទងក្នុងស្រុកពិសេសបែបនេះទេ ដែលអាចធ្វើឲ្យកម្លាំងបះបោរ ឬកម្លាំងនយោបាយដែលកើតចេញពីការមិនសប្បាយចិត្តរបស់ប្រជាកសិកររួបរួមគ្នាវិញ តាមរយៈការចងសម្ព័ន្ធមិត្ត ។ ជាទីបញ្ចប់ ដូចទម្រង់អាលីវ៉ាន នៅកោះជ្វាវាទំនងជាពង្រីកព្រំដែនមនោគមវិជ្ជានយោបាយរបស់ប្រជាកសិករក្នុងតំបន់ និងដឹកនាំពួកគេឲ្យស្ថិតនៅក្នុងខ្សែបន្ទាត់ប្រព័ន្ធនយោបាយជាតិ ។

ដោយឡែកមានមតិផ្ទុយថា គំរូសម្រាប់ចំណងទាក់ទងពីលើដល់ក្រោមបែបនោះ ទំនងគឺជាមានទំនាក់ទំនងបែបចៅហ្វាយនាយ-កូនចៅ ទោះបីជាវាមានទម្រង់ខ្សោយ និងមានលក្ខណៈផ្លូវលោកដាង ។ គោលដៅនៃចំណងទាំងនេះ គឺផ្លូវដែលមានលក្ខណៈបុគ្គល ជាជាងផ្លូវរួមសម្រាប់ឆ្ពោះទៅរកការការពារ និងស្ថិរភាពសេដ្ឋកិច្ច ។ អាស្រ័យហេតុនេះ ខណៈពេលណាដែលទំនាក់ទំនងមានគុណសម្បត្តិតាមលក្ខណៈរួម ជារឿយៗចំណងទាំងនោះគឺជាការចម្លងស្ទើល ចំណងទាក់ទងចាស់ដោយសេចក្ដីគោរព ។ ចំណងទាក់ទងបែបនោះសូម្បីនៅក្នុងសង្គមវណ្ណៈធម្មតា (ដូចជាកគីនៅប្រទេសឥណ្ឌូនេស៊ី) អាចលំអាននៃចំណងទាក់ទងចាស់ ពីវណ្ណៈលើដល់វណ្ណៈក្រោម ។

សណ្ឋានមួយទៀតនៃការឆ្លើយតប គ្មានមធ្យោបាយណាអាចបែងចែកដាច់នោះទេ សណ្ឋានទាំងនោះកើតឡើងទន្ទឹមគ្នា ហើយជាញឹកញាប់មានជាអាថ៌ ការផ្ដួចផ្ដើមតូចតាចនៅក្នុងស្រុក ដែលចាក់ឫសគល់យ៉ាងជ្រៅនៅក្នុងទម្រង់ប្រពៃណី និងសហគមន៍ក្នុងស្រុក ។ ក្នុងន័យម្យ៉ាង ការសិក្សាលើការឆ្លើយតបបែបនេះ គឺជាការសិក្សាលើភាពបរាជ័យជាច្រើន ទោះយ៉ាងណា ភាពបរាជ័យបែបនេះមានសារៈសំខាន់ ដោយសារហេតុផលយ៉ាងតិចពីរ ។ ទី ១ វាជួយបំភ្លឺទម្រង់គុណធម៌ជំនឿ និង ការចងសម្ព័ន្ធភាព ដែលជាគន្លឹះសំខាន់សម្រាប់នយោបាយកសិករ ។ ទី ២ វាជាផ្នែកនៃដំណើរការ ដែលវណ្ណៈកសិករបានក្លាយជាអ្នកទទួលអសកម្ម នៃការប្រែប្រួលជាប្រព័ន្ធ ហើយចាប់ផ្ដើមបង្កើតបទពិសោធផ្ទាល់ខ្លួន ៕

# ជំពូកទី ១

*១-នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងមូល ក្រុមជាតិពន្ធុនីមួយៗមានជំនាញការងាររៀងៗខ្លួន ។*

*២-ចូរប្រៀបធៀបរវាង ឌូប្រឺអ៊ីល,* (Dubreuil) *ទំ. ៧៣-៤, និងអ៊ី,*(Y) *ទំ. ១៦៩លើបញ្ហាអាភៀននៅកូសាំងស៊ីន ។ ស្តេនប៊ឺហ្គ* (Steinberg) *ពិពណ៌នាថា «អាភៀនត្រូវបានរដ្ឋាភិបាលកាន់កាប់ផ្តាច់មុខជាយូរណាស់មកហើយ ហើយវាគឺជាប្រភពចំណូលថវិកាជាតិដ៏ធំមួយ ។ នៅឆ្នាំ ១៩៣៨ វាមានតម្លៃស្មើនឹង ១៥% នៃថវិកាសរុបប្រចាំតំបន់ឥណ្ឌូចិនទាំងមូលទោះបីជាមានការរត់ពន្ធជារឿយៗបែបណាក៏ដោយ» ។ (ស្តេនប៊ឺហ្គ ទំ. ២៥០) ។*

*៣-ក្រុមហ៊ុនសង្គមបារាំងបិតស្រានៅឥណ្ឌូចិន* (La Société Française des Distilleries de l'Indochine) *ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩០២ ។ រោងចក្រមួយក្នុងចំណោមរោងចក្រទាំងប្រាំរបស់គេ មានទីតាំងនៅក្រុងភ្នំពេញ ។ នៅមានរោងចក្រចំនួន ៥០ ផ្សេងទៀតនៅក្នុងតំបន់ឥណ្ឌូចិនបារាំងនាសម័យមុនសង្គ្រាម ដោយរួមមានទាំងមូលធនរបស់បារាំង ចិន និងអណ្ណាម (រ៉ូប៊ឺកាំង* (Robequain) *២៧៧) ។*

*៤-សម្រាប់ដំណើរការជាតូបនីយកម្ម ដែលប៉ះពាល់ដល់ជនជាតិចិនសូមមើលហ្វ្រីដម៉ែន និង វ. វីល មូតត៍ .* (Freedman and W. Willmott) *និងប្រភពជាបន្តបន្ទប់ទៀតសម្រាប់ប្រទេសដូចខាងក្រោម÷*

> *វៀតណាមខាងត្បូង: «រចនាបថចិននៅវៀតណាមខាងត្បូង–* Chinoiseries in S. Vietnam*», «លោកយៀមបោកចំបាប់សមមិត្តចិនរបស់ខ្លួន» រដូវស្លឹកឈើជ្រុះ «បញ្ហារបស់វៀតណាមជុំវិញចំណោទជនជាតិចិន»។*
> *ឥណ្ឌូនេស៊ី: ឌី វីល មូតត៍ ១៩៦១, ទំ. ៧៤-៧៦*
> *ប្រទេស ថៃ: ស្គីននរ័ ១៩៥៧, គូលីន ទំ. ១២៧-១៣៨*
> *ហ្វីលីពីន : អាប់ប៉ែលតុន ។*

*៥-ប្រភពព័ត៌មានប្រវត្តិសាស្ត្ររបស់លោកហ្គារីមិនគ្រប់គ្រាន់ទេ ដោយសារគាត់និយាយពីចិនហៃណានដែលមកតាមសំពៅខូចនៅកូស៊ាំងស៊ីន ហើយបោះទីលំនៅនៅមីថូ* (Mytho) *នាឆ្នាំ ១៦៨១ (ហ្គារី* (Garry) *ទំ. ១៣៣-៤) ។ ចំណែកប្រភពព័ត៌មានផ្សេងពីនេះភាគច្រើនយល់ស្របថា ជនជាតិចិនដែលចូលចតនៅព្រះរាជវាំងនាក្រុងវ៉េនៅអណ្ណាមក្នុង ឆ្នាំ ១៦៧៩គឺ ជាចិនកន្តាំង ។ លោកហ្គារីបានចង្អុលបង្ហាញថា ការបង្កើនពន្ធដារលើជនជាតិចិននៅអណ្ណាម (តាមការបញ្ជារបស់ស្តេចជីឡុង និងមិញម៉ាង) បណ្តាលឲ្យជនជាតិចិនផ្លាស់លំនៅដ្ឋានពីកូស៊ាំងស៊ីនទៅខេត្តកំពត នៃប្រទេសកម្ពុជា ។ លោកឌែលវឺត* (Delvert) *បានផ្តល់ការពិភាក្សាសង្ខេបពីវប្បធម៌ផលិតម្រេចនៅកម្ពុជា (ឌែលវឺត ទំ. ២៨ អេហ្វ) ។*

*៦-បីជាច្បាប់តម្រូវឲ្យមានការចុះឈ្មោះ និងការរៀបចំបញ្ជីចម្ការម្រេចដែលត្រូវអនុម័តនាឆ្នាំ ១៩០៩ និងត្រូវបានគេធ្វើវិសោធនកម្មនាឆ្នាំ ១៩១២ (រឺគ្យូអែល* (Recuel) *ទំ. ១០៦៣-៤) ស្ថិតិស្តីពីផលិតផលម្រេចនៅកម្ពុជាមិនអាចទុកចិត្តបានទេ ។ លោកហ្គារីបានផ្តល់តារាងទំនិញនាំចេញចាប់តាំងពីឆ្នាំ ១៨៩២ (ហ្គារី ទំ. ១៤១, តារាង ៧) ប៉ុន្តែប្រហែលជាតួលេខមុនពេលសង្គ្រាម ជាទិន្នន័យនៃឥណ្ឌូចិនទាំងមូលសម្រាប់ជាទិន្នន័យប្រចាំសតវត្សរ៍ទី ១៩ ដែលជាទិន្នន័យផ្តល់ដោយប្រភពព័ត៌មានមុនៗ* ("La Production") *។ ប្រភពព័ត៌មាននោះបានបញ្ជាក់ថា កម្ពុជាផលិតបានម្រេចជាមធ្យម ១ ឆ្នាំ បាន ១.៥០០ តោនក្នុងចំណោមចំនួនសរុប ១.៧០០-១.៨០០ តោនដែលផលិតបានក្នុងតំបន់ឥណ្ឌូចិនទាំងមូល ហើយប្រសិនបើសមាមាត្រនេះនៅតែបន្ត នោះតួលេខដែលលោកហ្គារីច្បាស់ជាខុស ។ ការសិក្សាយ៉ាងលម្អិតស្តីពីម្រេចនៅឥណ្ឌូចិន គឺជាសៀវភៅរបស់លោកឈេវ៉ាលីយេ* (Chevalier) *ដែលមានចំណង*

ដើងថា «ម្រេចនៅឥណ្ឌូចិន-Poivre en Indochine» តែសំណាងមិនល្អខ្ញុំរកវាមិនឃើញទេ។

៧- កីតម្បាញខ្មែរមានរាងវែងដោយទាញសន្ទឹងផ្ដេកប្រវែងប្រហែល ១០ យ៉ាត ។ ចំណែកកីតម្បាញចិនត្រូវយ៉ាងតឹងណែនដោយបត់កីជុំវិញរមូរ ។ កីតម្បាញចិនមានខ្នារហោះ ចំណែកឯកីខ្មែរអំបោះត្រូវត្បាញដោយដៃ ។

៨-អានស្ដាត រីត្រូ (An. Stat. Retro) 1958 -61 / តារាង១១-១ ទិន្នន័យត្រូវគេបែងចែកដូចខាងក្រោម (គិតជា លានរៀល)៖

| | | |
|---|---|---|
| ១៩៥៦: | ការនាំចូល: ១៩៩៨ | ការនាំចេញ: ១២៨២ |
| ១៩៦១: | ៣៣៩៥ | ២២២០ |

ក្នុងអំឡុងពេលនេះដែរ ចំណុះដឹកទំនិញបានកើនឡើងពី ២៦៣ ទៅ ៤២៦ ពាន់តោនសម្រាប់ការនាំចូល ហើយសម្រាប់ការនាំចេញកើនពី ២៣៦ ទៅ ៦៤៧ ពាន់តោន ដែលធ្វើឲ្យចំនួនសរុបនៃពាណិជ្ជកម្មអន្តរជាតិកើនឡើងដល់ ១១៥ %។ ភាពខុសគ្នារវាងកំណើនជាភាគរយនៃទំនិញ និងតម្លៃទំនិញពិតប្រាកដ ប្រហែលជាមកពីការធ្លាក់ចុះនៃតម្លៃជាអន្តរជាតិសម្រាប់ផលិតផលកៅស៊ូ និងម្រេច ។

៩-អាន ស្ដាត រីត្រូ ១៩៥៨-៦១, តារាង១១-១ រោងកិនស្រូវបានកើនឡើងចំនួន ៩៣.៨% នៅក្នុងអំឡុងពេលនេះដែរ ដូចច្នេះហើយកំណើនឧស្សាហកម្មដែលមិនមែនជារោងម៉ាស៊ីនកិនស្រូវ បានកើនឡើងដល់ ៣៨% ។

១០-ខែមបែល (Campbell) អះអាងសេចក្ដីថ្លែងការបន្ទាប់អំពីស្ថានការណ៍នៅក្នុងទសវត្សរ៍ឆ្នាំ ១៨៥០ (ខែមបែល) ជនជាតិចិនធ្វើដំណើរទៅទិញត្រីនៅបាត់ដំបង ឧដុង្គ និងទីកន្លែងផ្សេងទៀត ហើយបន្ទាប់មកនាំចេញទៅកាន់ក្រុងកូស៊ាំងស៊ីន ដែលជាទីត្រីត្រូវបានគេលក់ក្នុងតម្លៃពី បីទៅបួន ទីកាល់ (ticals) ក្នុងមួយ ពីកាល់ (picals) អ្នកនេសាទទាំងអស់ជាជនជាតិកម្ពុជា ហើយប្រជាប់ប្រជានេសាទដូចជាសំណាញ់ស្ទើរតែព័ទ្ធជុំវិញបឹង ។ ទោះបីជា ខែមបែល អាចខុសពីសញ្ជាតិរបស់អ្នកនេសាទ ដែលទំនងជាជនជាតិអណ្ណាមទិន្នន័យរបស់គាត់បង្ហាញថា ជំនួញត្រីមានទំហំធំ ហើយស្ថិតនៅក្នុងកណ្ដាប់ដៃជនជាតិចិន ។ អំឡុងទសវត្សរ៍ឆ្នាំ ១៩៥១-១៩៦០ស្រូវមានទំហំ ៣៩% នៃការផ្ទុកទុកជាតោន និងចំនួន ២% នៃតម្លៃនាំចេញ ចំណែកទំនិញត្រីគ្រប់ប្រភេទ (ត្រីស្រស់ ត្រីងៀត និងត្រីឆ្អើ) មានទំហំត្រឹមតែ ២% នៃការផ្ទុកទុកជាតោននិងចំនួន ២,៥% នៃតម្លៃសរុប (ដកស្រង់ចេញពី អាន ស្ដាត រីត្រូ ១៩៥៨-៦១. ៩៩ និង ១១៤អេហ្វ, តារាង ១១-១ និង ១១-៦) ។

១១-ពិសេសខេត្តបាត់ដំបង ទោះបីជានៅពេលនោះ ទឹកដីនេះជាផ្នែកមួយរបស់សៀមក៏ដោយ (លោកឌុយប៉ុយ-Dupuy)

១២-ក្នុងរយៈកាលជាង ៥ ឆ្នាំ ១៩៥៧-៦១ ផលិតផលស្រូវមានចំនួនជាមធ្យមចំនួន ១.៣៥១.៦០០ តោនក្នុងមួយឆ្នាំ, ស្រូវដែលនាំចេញមានចំនួនជាមធ្យម ២៨០.៦០០ តោន (អាន ស្ដាត រីត្រូ ១៩៥៨-៦១, ទំ. ៣៥ និង១១៤ តារាង៤-១ និង១១-៦) ។

១៣-ក្រុមហ៊ុនដែលគេចាត់ទុកថាមិនមែនជាក្រុមហ៊ុនចិន គឺជាក្រុមហ៊ុនទាំងឡាយណាដែលមិនមានឈ្មោះសរសេរជាអក្សរចិន រួមទាំងឈ្មោះចិនត្រូវបានគេសរសេរតាមសូរជាអក្សរខ្មែរ (ឬតណ្ឌា) ឬបកប្រែជាភាសាបារាំង (លើកលែងតែឈ្មោះ ដែលត្រូវបានគេស្គាល់តាមរយៈការស្រាវជ្រាវថាជារបស់ចិន) ។ ក្រុមហ៊ុនចិនតែងតែមានឈ្មោះដែលមានរុងរឿងប្រសើរ មានត្រកូល ឬយកឈ្មោះតាមទីកន្លែងកំណើតរបស់ម្ចាស់ក្រុមហ៊ុន ប៉ុន្តែក៏មានករណីដែលក្រុមហ៊ុនចិនមួយចំនួនមានឈ្មោះជាភាសាបារាំង ហើយត្រូវបានគេចាត់ទុកជាក្រុមហ៊ុនមិនមែនជារបស់ចិន (ឧ.«Cie. de Commerce et de Navigation d'Orient») ។

*១៤-នៅឆ្នាំ ១៩៦២ គេដាក់ចេញលិខិតអនុញ្ញាតឲ្យធ្វើពាណិជ្ជកម្មចំនួន ៣៦.៦០១ ។ នាយកដ្ឋាននាំចេញ មិនបាន រក្សាទុកនូវស្ថិតិ ស្តីពីសញ្ជាតិរបស់អ្នកដែលទទួលបាននូវលិខិតអនុញ្ញាតទេ ប៉ុន្តែមានគេផ្តល់យោបល់ប្រាប់ខ្ញុំថា ពួកអ្នកទាំងនោះស្ទើរតែទាំងអស់សុទ្ធតែជាជនជាតិចិន ទោះបីជាថា ពួកគេមានសញ្ជាតិជាជនកម្ពុជាក៏ដោយ ។*

*១៥-លោក អ៊ូជិនដា បានផ្តល់យោបល់ថា ជនជាតិចិននៅក្រៅប្រទេស(ចិន)មិនបានវិនិយោគទុនលើវិស័យ ឧស្សាហកម្មទេ ដោយសារមានការការពារតិចតួចចំពោះការវិនិយោគទុនមានកំណត់ នៅអាស៊ីអាគ្នេយ៍ (អ៊ូជិនដា, ទំ. ៥៩៣) ។ យ៉ាងណាមិញ នៅកម្ពុជាប្រហែលជាមានហេតុផលច្បាស់លាស់ជាងនោះ គឺផលិតកម្មអាចផ្តល់ប្រាក់ ចំណេញដល់ពួកគេតិចតួច បើប្រៀបធៀបជាមួយប្រាក់ចំណូលបានមកពីវិស័យជំនួញ ។ ជាការពិតណាស់ ជន ជាតិចិនជាច្រើនប្រកបរបរទាំងពីរនេះ ÷ តួយ៉ាងដូចជាក្រុមហ៊ុនជីបតុង ដែលរកស៊ីនាំចូល-នាំចេញ ត្បាញសូត្រ ឧស្សាហកម្មកៅស៊ូ និងវត្ថុធ្វើពីផ្លាស្ទិក (ជៀនពូចាយ សាងអ៊ីម៉ាវយី នៀនជៀន (សូមមើល) ការផ្សព្វផ្សាយពាណិជ្ជកម្ម នៅគម្របខាងក្រោយ) ។*

*១៦-ពីបណ្តាធនាគារចុះបញ្ជីក្នុងជៀនពូចាយ សាងអ៊ី ម៉ាវយី នៀនជៀន ទំ. ២៦២-៣៦៩ និង ស៊ីនបៀន សាងអ៊ី ស៊ូជេ ។ ក្នុងចំណោមធនាគារទាំងនេះ មានតែធនាគារពីរប៉ុណ្ណោះ ដែលមានកម្រិតជាសាខារបស់ធនាគារអន្តរ-ជាតិ នៅក្រុងភ្នំពេញ ។*

*១៧-* OROC *បានផ្តល់ប្រាក់ឥណទានចំនួន ១៨៣.៤២៣.៧៧៥ រៀលអំឡុងពេល ១០ ខែ ចាប់ពីខែមករាដល់ខែ តុលា ឆ្នាំ១៩៦២ ហើយប្រាក់កម្ចីចំនួន ១៥២.៨៣៨.៤២១ រៀល ត្រូវបានគេផ្តល់សម្រាប់ក្រុមសហករណ៍ នៅតាម ខេត្ត ខណៈពេលដែលប្រាក់កម្ចីចំនួន ៣០០.៥៨៥.៣៥៤ រៀល ត្រូវបានផ្តល់ទៅឲ្យគេខ្ចីជាលក្ខណៈបុគ្គល* (Réalisation,*២) ។*

*១៨-សម្រាប់ការពិពណ៌នាអំពីការប្រតិបត្តិការ និងការរួបរួមសគ្គមក្នុងផ្នែកឥណទានជនបទ នៅក្នុងសគ្គមកសិករ សូមមើល* Ward *១៩៦០។*

*១៩-ការប៉ាន់ស្មាននេះផ្អែកលើចំនួនប្រជាជន និងចំនួនដីដែលគេធ្វើការដាំដុះ ។ កិច្ចសន្យាដួលកម្មករម្រេចពី ចិនហៃណាន តែងតែមានរយៈកាលបីឆ្នាំម្តង ។*

*២០-ខ្ញុំដឹងថា មិនមានការសិក្សាអំពីអ្នកជាក់ស៊ីក្លូខ្មែរទេ ។ ការអះអាងនេះ ផ្អែកលើព័ត៌មានពីអ្នករាយការណ៍ និង យោបល់នៅក្នុងសៀវភៅលោកឌេលវីត ទំ. ៣១ ។ សម្រាប់ស្ថានភាពស្រដៀងគ្នានេះ សូមមើលការសិក្សាពីអ្នក បើកឡានតូចជាក់ដោយជើង* (pedicap) *នៅក្រុងបាងកក ដោយលោកបណ្ឌិត រ៉ូប៊ឺត តិចទ័រ* (Robert Textor) *។*

## ជំពូកទី ២

*១-គេបានបោះបង់ចោលចំពោះគំនិតដែលថា តាមប្រវត្តិសាស្ត្រជនជាតិចិន ទទួលបាននូវបុព្វសិទ្ធិពិសេសមួយ ក្នុងមជ្ឈដ្ឋានរបស់ប្រទេសកម្ពុជា (ដែលមានចាប់តាំងពីសម័យមុនៗមក នៅពេលដែលចិនកំពុងតែមានឥទ្ធិពលខ្លាំង ក្លា នៅពាសពេញតំបន់នោះ) ដោយចាត់ទុកដូចជាគំនិតឥតន័យ ឬគ្មានប្រយោជន៍ និងមិនសមហេតុផល ។ បើ តាមអ្នកនិពន្ធជាច្រើនបានឲ្យដឹងថា អ្នកចរចាចិនបានលើកយកបញ្ហានេះមកធ្វើការជជែកវែកញែកនៅណានគីង* (Nanking) *ក្នុងឆ្នាំ ១៩២៩ (សូមមើល អា.អឹម.* (A.M.) *ទំ. ២៩៩, អ៊ី.ស.* (E.C.) *ទំ. ៣៤៨, និង តំបន់ឥណ្ឌូចិនតាមរយៈ សន្ធិសញ្ញាបារាំង-ចិន* (L'Indochine et le traité franco-chinois),*ទំ. ៤០៨)*

២-ជាប្រព័ន្ធដែលបង្កើតឡើងដោយបារាំងក្នុងប្រទេសកម្ពុជា ដោយតម្រូវឲ្យជនបរទេសទាំងអស់ ដែលរស់នៅលើទឹកដីខ្មែរប្រមូលផ្តុំគ្នាជាក្រុម ហើយមានអ្នកតំណាងរបស់ខ្លួនម្នាក់ ដែលចេញមកពីការជ្រើសរើសរបស់ក្រុម ឲ្យមើលការខុសត្រូវក្នុងក្រុម ដោះស្រាយជម្លោះក្នុងក្រុម និងរាយការណ៍ ឬធ្វើទំនាក់ទំនងជាមួយនឹងរដ្ឋបាលបារាំង ហើយមេក្រុមនេះ ក៏មានភារៈកិច្ចប្រមូលពន្ធពីសមាជិកនៃក្រុមរបស់ខ្លួន ដើម្បីយកទៅឲ្យរដ្ឋាភិបាលបារាំងផងដែរ ។ ម្យ៉ាងវិញទៀត ប្រធានក្រុមម្នាក់ៗមានសិទ្ធិនិរទេសសមាជិករបស់ក្រុមខ្លួនឲ្យចេញពីក្រុម ឬប្រទេសបានដោយគ្មានទោស ។ ធ្វើបែបនេះ រដ្ឋាភិបាលបារាំងអាចចំណេញទាំងទៅលើការគ្រប់គ្រងផ្នែកពន្ធដារ និងអាចក្តាប់បានទាំងស្រុងនូវចំនួនជនបរទេសទាំងអស់ ព្រមទាំងសកម្មភាពប្រចាំថ្ងៃរបស់ពួកគេថែមទៀតផង ។

៣-ឡឺក្លែរ ១៨៩៨ ទំ. ៨៩: យើងអាចនិយាយបានថា ក្រមស្រុក គឺជាក្រមច្បាប់មួយដែលយកតាមលំនាំច្បាប់បុរាណដែលមានអាយុកាលជាងពីរសតវត្សមកហើយនោះ ។ ក៏ប៉ុន្តែជាអកុសល ការវាយឆ្មក់ម្តងហើយម្តងទៀតរបស់សៀមមកលើក្រុងឧត្តុង្គ បានបំផ្លាញនូវរាល់ឯកសារទាំងអស់របស់កម្ពុជាគ្មានសល់ ជាហេតុធ្វើឲ្យច្បាប់ក្រមស្រុកក្នុងឆ្នាំ ១៦៩៣ ក្លាយទៅជាក្រមច្បាប់ដែលមានអាយុកាលចាស់ជាងគេបំផុតមួយ របស់ប្រទេសកម្ពុជា (សូមមើល ម៉ូណូដ Monod ទំព័រ៧-១២) ។

៤-អត្ថន័យដើម :

Pour les étrangers, on doit choisir parmi eux leurs chefs(chautéa) et les chefs des jeux. . Qu’un chautéa laotien soit chargé de la direction des piroques laotiennes ;qu’un chautéa annamite ait la direction ses compatriotes ;qu’un chautéa chams soit chargé de la sorveillance des chams ; qu’un chautéa malais soit chargé de la sorveillance des chvéa (javanais, malais) ; qu’un chautéa chinois soit chargé de sorveillance ses compatriotes ; qu’un chautéa japonais soit chargé de la sorveillance les japonais

៥-មានអ្នកសិក្សានៅតំបន់ឥណ្ឌូចិនស្ទើរតែទាំងអស់គ្នាបានសន្និដ្ឋានថា ប្រព័ន្ធសហគមន៍ជាតិពន្ធុ (congrégation system) មានដើមកំណើតមកពីអាណាចក្រអណ្ណាម ដែលការសន្និដ្ឋានបែបនេះធ្វើឡើងតាមរយៈភាពលម្អៀងទូទៅមួយរបស់អ្នកប្រវត្តិសាស្ត្រ ដោយសារពួកគេចាត់ទុកថា អណ្ណាមជាចំណុចស្នូលនៃតំបន់ឥណ្ឌូចិន ។ សូមមើលត្រង់សេចក្តីផ្តើម កំណត់សម្គាល់លេខ ១៩ ។

៦-អត្ថន័យដើម

Nous ne parlons que de la réglementation annamite en laissant de coté celle du pays cambodgien qui était peu compliquée. Avant l’occupation française, il n’y avait pas au Cambodge d’organisation de Chinois en groupement spéciaux comme en Annam. Ces immigrants y étaient considérés commes des régnicoles aux point de vue fiscal, juridictionnel et législatif : par rapport aux Cambodgiens, ils étaient soumis aux mêmes impôts decapitation, acquittaient les  mêmes juges et des mêmes lois en cas de crime, délit ou contravention. Tout juste, le code Cambodgien contenait-il quelques dispositions sur les étrangers selon lesquelles ceux-ci.étaient placés dans les localités ou ils residaient sous l’autorité.d’un chef (Chautéa) ; chef laotien pour les Laotiens, chef chinois pour le Chinois, etc.........(Nguyen.21n 5)

៧-អត្ថន័យដើម .‘La perception sur les jeux doit être confiée á un Chinois’

៨-អត្ថន័យដើម

Ici................ les métis Chinois ne pouvaient se prévaloir d'une nationalité étrangère à l'encontre du Roi du Cambodge, donc étaient regnicoles de fait, surtout à partir de la seconde géneration (levasseur, 56)

៩-ជាអន្តរាគណ្ដាលដែលធ្វើការទាក់ទងពីភាគីម្ខាង ទៅភាគីម្ខាងទៀត ។

១០-ចំពោះសេចក្ដីលម្អិតដែលពណ៌នាពីប្រព័ន្ធ ដែលបានប្រកាសឲ្យប្រើជាផ្លូវការដោយស្ដេច កៃ ឡុង និង ស្ដេចគ្រងរាជក្រោយៗមកទៀតនោះ សូមមើល ង្វៀន (Nguyen) ២៧-៤២ ។ ប្រព័ន្ធនេះ ត្រូវបានអ្នកគ្រងរាជក្រោយមកទៀត យកមកតាក់តែងឡើងវិញក្នុងព្រះរាជប្រកាសនៃឆ្នាំ១៨២៤, ១៨២៩, ១៨៣២, ១៨៤២, ១៨៤៩, និង១៨៥៨ (ង្វៀន (Nguyen)៣០) ។

១១-សំដៅទៅលើជនជាតិ ដែលមានកំណើតនៅក្នុងទ្វីបអាស៊ីទាំងឡាយ ដែលរស់នៅក្នុងប្រទេសកម្ពុជា ។

១២-អត្ថន័យដើម

Sa Majesté le Roi du Cambodge acceptait toutes le réformes administative, judiciaires, financiéres et commerciales auxquelles le gouvernment de la République franç aise jugerait, à l'avenir, utile de procéder, pour faciliter l'accomplissement de son protectorat.(lafargue, 54)

១៣-ចំពោះករណីដែលថាជនជាតិចិន គឺជាប្រភពចំណូលដ៏សំខាន់មួយចំពោះផ្នែករដ្ឋាលនោះ គឺបង្ហាញឲ្យឃើញតាមរយៈពន្ធនាំមុខគេតែឯងមួយ ដែលបារាំងអាចប្រមូលបាន ២៦៥.០០០ ពៀស (piastres) ពីជនជាតិចិននៅក្នុងប្រទេសកម្ពុជានាឆ្នាំ ១៩០៩ និង ១០.០០០ ពៀស(piastres) ផ្សេងទៀត បានមកពីការបង់ទៅលើលិខិតឆ្លងដែន ។ ការបង់លើប័ណ្ណប៉ាតង់ (អាជ្ញាប័ណ្ណសម្រាប់ប្រកបរបរពាណិជ្ជកម្ម) បានផ្ដល់នូវតម្លៃស្មើរតែទ្វេដង ពីចំនួនខាងលើនេះទៅទៀត បើយោងទៅលើច្បាប់ដែលប្រកាសឲ្យប្រើនៅ ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ១៨៩៧ ដែលបង្កើតឲ្យមានឡើងនូវការបង់ពន្ធប្រចាំឆ្នាំដូចខាងក្រោម ៖

៨៨ ពៀស សម្រាប់អត្តភាពអាជីវកម្មទាំងឡាយណា ដែលបានបង់ពន្ធប៉ាតង់ ១០០ ពៀស

៣៣ ពៀស សម្រាប់អត្តភាពអាជីវកម្មទាំងឡាយណា ដែលបានបង់ពន្ធប៉ាតង់ចន្លោះពី ៣០ ទៅ ១០០ ពៀស

៧ ពៀសសម្រាប់អត្តភាពអាជីវកម្មទាំងឡាយណា ដែលបានបង់ពន្ធប៉ាតង់តិចជាង ៣០ ពៀស

១៤-អត្ថន័យដើម៖

Chinois, colons ou anciens soldats, qui vivent paisiblement en Annam, en se livrant à aucune reproche, jouiront, pour leurs personnes et pour leurs biens, de la même securité que les protégés français .(Michel, 15)

១៥-បើតាមលោកសាស្ត្រាចារ្យ ឃិន សុខ ថា ៖ ពាក្យនេះ គឺសំដៅទៅលើជនជាតិអណ្ណាម (យួន) ។ មានមតិខ្លះទៀតថា ពាក្យនេះអាចសំដៅទៅលើទាំង អណ្ណាម លាវ ។

១៦-អ្នកទាំងនេះ គឺសម្គាល់លើជនបរទេសទាំងឡាយណាដែលបានចូលសញ្ជាតិខ្មែរ ដោយផ្អែកទៅតាមច្បាប់ដែលបានកំណត់ ឧទាហរណ៍ដូចជាជនជាតិចិនជាដើម ។

១៧-បញ្ហានេះកើតមានមុនតុលាការក្រុង សៃហ្គន ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៨៨៩ (ឡេវ៉ាស័រ ទំ.១៣៣) ។ ក្ដីបារម្ភរបស់បារាំងចំពោះសិទ្ធិកាន់កាប់ គ្រប់គ្រងទៅលើអចលនវត្ថុក្នុងតំបន់ឥណ្ឌូចិន អាចនឹងចាប់ផ្ដើមឡើងបន្ទាប់ពីបានមើលឃើញទៅលើទំហំ នៃការកាន់កាប់ដីរបស់ជនជាតិចិនរួចមក ។ លោក នីកូឡា បាននិយាយថា ជនជាតិចិន

បានកាន់កាប់ទំហំដីជាង ១០០.០០០ ហិកតា នៅក្នុងតំបន់ឥណ្ឌូចិន ហើយបានគ្រប់គ្រងលើអចលនវត្ថុនៅក្នុងតំបន់ទីក្រុង បុរីប្រជុំជននានា ដែលមានតម្លៃជាង ១០០.០០០ ពៀស (piastres) (នីកូឡាស ទំ. ១៦២) ។ បើគិតតែនៅក្នុងប្រទេសកម្ពុជាមួយ ជនជាតិចិនបានកាន់កាប់ដីប្រហែលជា មួយម៉ឺន ហិកតា នៅពេលដែលច្បាប់កម្រិតចំពោះជនបរទេសក្នុងការកាន់កាប់អចលទ្រព្យបានប្រកាសឡើងនៅក្នុងឆ្នាំ ១៩២៤ (ឡេវ៉ាស័រ ទំ. ១៣២) ។

១៨-ការអនុញ្ញាតឲ្យសហគ្រាសរបស់ជនជាតិចិនធ្វើការដេញថ្លៃទៅលើកិច្ចសន្យាផ្គត់ផ្គង់ផ្នែករដ្ឋបាលរបស់អាណានិគម បានក្លាយទៅជាទំនាស់ដ៏ក្ដៅគគុកមួយ រវាងពួកអ្នកគ្រប់គ្រងដឹកនាំ និងពួកពាណិជ្ជករបារាំង ដែលបានទាមទារថា ផ្នែកគ្រប់គ្រងរដ្ឋបាលគួរតែលើកទឹកចិត្តឲ្យមានផលប្រយោជន៍ ផ្នែកពាណិជ្ជកម្មដល់អាណានិគម ។ ក្នុងព្រឹត្តិបត្រ ឡាRevue Indochinoise (ជាកាសែតបង្ហាញពីបញ្ហាផលប្រយោជន៍ទាំងនេះ) បានលើកឡើងយ៉ាងទទូចថា cette question Indochinoise... du Chinois envahissant nos colonies។ មានអ្នកនិពន្ធម្នាក់ដែលហៅខ្លួនគាត់ថា អ៊ី (Y) បានសរសេរនៅក្នុងព្រឹត្តិបត្រតែមួយនេះថា៖ Dans un sentiment de générosité excessive nous avons admis les chinois et quelques autres Asiatiques étrangers aux bénéfices des lois et contumes indigènes (Y 162) ។ ព្រឹត្តិបត្រនេះបានបង្ហាញថា នៅអំឡុងពេលដែលបារាំងកំពុងតែវាយប្រយុទ្ធជាមួយនឹងកងទ័ពចិននៅតុងគឹង នោះបារាំងនៅតែបន្តផ្ដល់ឲ្យជនជាតិចិននៅតំបន់ឥណ្ឌូចិននូវក្ដីស្រលាញ់រាប់អានដូចមុនដដែល ដោយមិនចាំបាច់មានការយល់ព្រមពី អាល្ហឺម៉ង់ រឺ ចក្រភពអង់គ្លេសឡើយ ។ សមាជិកសភាពាណិជ្ជកម្មនៅគ្រប់រដ្ឋក្នុងតំបន់ឥណ្ឌូចិនទាំងអស់ ជាតំណាងឲ្យគ្រឹះស្ថានពាណិជ្ជកម្មសំខាន់ៗទាំងឡាយរបស់បារាំង បានទាមទារយ៉ាងទទូចឲ្យមានការគ្រប់គ្រងដ៏តឹងរឹងមួយទៅលើជនជាតិចិន បើទោះបីជាពួកគេមិនស្ថិតនៅក្រោមអាណានិគមន៍ក៏ដោយ ។ លោក រ៉េស៊ីដង់ ស៊ុបពែរីយេ ប្រចាំនៅប្រទេសកម្ពុជា បង្ហាញពីការយល់ព្រមតាមការទាមទាររបស់សភាពាណិជ្ជកម្មក្នុងប្រទេសកម្ពុជានាឆ្នាំ ១៩០០ ហើយយ៉ាងហោចណាស់ក៏វាជាពេលវេលាមួយ ដែលគេបានបញ្ឈប់ជនជាតិចិនលែងឲ្យដាក់ពាក្យស្នើសុំដេញថ្លៃដូចមុនៗ នៅក្នុងប្រទេសនេះទៀតដែរ។

១៩-អត្ថបទស្ដីពីកិច្ចព្រមព្រៀងក្រុង ណានគីង ( Nanking ) អាចមើលបាននៅក្នុងឧបសម្ព័ន្ធរបស់លោក ឡេវ៉ាស៊ឺ (Levasseur) និង នៅក្នុង «L'Indochine et le traité franco-chinois de Nankin» ទំ. ៤០៩-១២ ប្រកពចុងក្រោយមិនបានបង្ហាញនូវកំណត់ចំណាំទាំងអស់ ដែលបានផ្លាស់ប្ដូរគ្នាទៅវិញទៅមករវាងភាគីទាំងសង្ខាង ក្នុងពេលចុះហត្ថលេខានោះទេ ។ ចំពោះការពិភាក្សាពីផលប៉ះពាល់ របស់កិច្ចព្រមព្រៀងនៅលើតំបន់ឥណ្ឌូចិន សូមមើល A.M. 288f និង Maybon, ទំ. ២៣៤។

២០-សូមមើល « the South China Morning Post » ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៣០ នៅទំ. ២ នៅក្រោមការដាក់ឱសានុវាទរបស់ទីក្រុងប៉ារីស អ្នកយកព័ត៌មានបានរាយការណ៍មកថា រដ្ឋាភិបាលបារាំងបានធ្វើសម្បទានដល់រដ្ឋាភិបាលក្រុងណានគីង ក្នុងក្ដីសង្ឃឹមថា នឹងអាចរក្សាបាននូវសិទ្ធិគ្រប់គ្រងលើទឹកដីនៅក្រុងសៀងហៃរបស់ខ្លួន ក៏ដូចជាសន្ធិសញ្ញាប្រើប្រាស់កំពង់ផែជាច្រើនទៀត ។ ក៏សូមមើលផងដែរនូវអត្ថបទរបស់លោក Thompson ដែលមកដល់ពេលនេះលោកបាននិយាយថា បើយោងទៅតាមសន្ធិសញ្ញា ឃើញថាស្ថាប័ន «សហគមន៍ជាតិពន្ធុ»ត្រូវបានទទួលរងនូវការកៀបសង្កត់ ។ ចំពោះប្រតិកម្មរបស់ វៀតណាម ទៅលើការចរចា សូមមើល Indochine, Généralités'in Asie-française លេខ ២៦៨, ទំ. ១៣៣ ។ នៅក្នុងអំឡុងពេលនៃសន្ធិសញ្ញាជប៉ុន-បារាំងឆ្នាំ ១៨៨៦ នោះបារាំងបានចាត់ទុកជនជាតិជប៉ុនក្នុងតំបន់ឥណ្ឌូចិនដូចជា Asiatiques assimilés ដែលមានន័យថា ជនជាតិអាស៊ី

*ដែលស្រដៀងគ្នាទៅនឹងពួកអឺរ៉ុប*(Huckel, *ទំ. ៧៣៨*)។
*២១-អត្ថន័យដើម*

J'ai l'honneur de vous confirmir qu'il n'est pas dans les intentios de mon Gouvernment de retirer aux resortissants chinois le bénéfice des privileges dont ils jouissent actuellement sur le territoire de l'Indochine Français.

*២២-*Compare E.C., *ទំ. ៣៤៧ ។ មាននូវការបកស្រាយមួយជុំវិញបញ្ហតស៊ូប្រឆាំងរវាង ស្ថានកុងស៊ុលចិន និងរដ្ឋអំណាចបារាំង ទៅលើការគ្រប់គ្រង ប្រព័ន្ធសហគមន៍ជាតិពន្ធុនៅក្រុង ហាណូយ ក្នុងស្នាដៃរបស់លោក* Tournier *ទំ. ៩៤-៦។*

*២៣-បទបញ្ញត្ត កៃ ឡុង* ( Gia-Long ) *បានធ្វើឲ្យមានការបែងចែកកូនកាត់ ចិនអណ្ណាម (ហៅជាទូទៅថា មិញ ហ៊ង* Minh Houng) *ដែលមាននៅក្នុងខេត្តនីមួយៗ ជាប្រព័ន្ធសហគមន៍ជាតិពន្ធុថ្មីមួយ ដែលដាច់ចេញពីប្រព័ន្ធសហគមន៍ជាតិពន្ធុចិន ។ នៅក្នុងមាត្រាទី ៥ នៃព្រះរាជប្រកាសរបស់ព្រះរាជានៃប្រទេសកម្ពុជាឆ្នាំ ១៨៩១ ក៏បានបែងចែកពួក មិញ ហ៊ង ចេញជាប្រព័ន្ធជាតិពន្ធុថ្មីមួយពីប្រព័ន្ធសហគមន៍ជាតិពន្ធុចិនចាស់ដែរ ។ ស្តេចនរោត្តមប្រហែលជាប្រើពាក្យនេះសំដៅទៅលើជនជាតិ ចិនកាត់អណ្ណាម ដែលរស់នៅក្នុងប្រទេសកម្ពុជា ជាជាងសំដៅទៅលើជនជាតិខ្មែរកាត់ចិន ព្រោះទ្រង់តែងចាត់ទុកកូនខ្មែរកាត់ចិនថា ជាប្រជារាស្ត្រកម្ពុជារួចទៅហើយ ។ ភ្លាមៗនោះប្រព័ន្ធសហគមន៍សម្រាប់ក្រុម មិញ ហ៊ង បានរលត់បាត់ទៅវិញ ហើយក៏គ្មានការនិយាយពីបញ្ហានេះទៀតដែរទាំងនៅក្នុងច្បាប់ និងប្រវត្តិសាស្ត្រ ។ គេក៏មិនបានដាក់ប្រព័ន្ធនេះទៅក្នុងច្បាប់អន្តោប្រវេសន៍ ដែលបានធ្វើនៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ១៩១៩ ដែរ* (JOIF 1919, *ទំ. ២៥០៨*)។

*២៤-ក្នុងស្នាដៃរបស់លោកឡេវ៉ាសឺ ឡេវាសសុរ នៅទំព័រទី ៤៤ និយាយថានៅក្នុងឆ្នាំ ១៩៣៣ លោកទេសាភិបាលបានប្រកាសថាគ្រប់កុមារទាំងអស់ ដែលកើតនៅក្នុងតំបន់ឥណ្ឌូចិន ត្រូវដាក់ឲ្យនៅក្រោមការគ្រប់គ្រងរបស់បារាំង ដោយមិនគិតពីសែលោហិត ឬច្បាប់ នោះទេ ហើយប្រទេសដែលនៅក្រោមអណាព្យាបាលបារាំង (អណ្ណាម និង កម្ពុជា) អាចមានសិទ្ធិប្រគល់សញ្ជាតិរបស់គេដល់ក្មេងៗទាំងនោះ ឲ្យតែសញ្ជាតិនោះស្ថិតនៅក្រោមការគាំពាររបស់បារាំង ។ ជាការដាក់ស្តែង យុទ្ធសាស្ត្រនេះគ្មានប្រសិទ្ធភាពឡើយនៅក្នុងប្រទេសកម្ពុជា ហើយគេមានចម្ងល់ថាតើវាមានប្រសិទ្ធភាពនៅក្នុងប្រទេសវៀតណាមដែរ ឬទេ។*

*២៥- អាចមានករណីដែលថា មានការបើកផ្លូវសម្រាប់ការចូលសញ្ជាតិមុននេះទៅទៀត ព្រោះនៅក្នុងរបាយការណ៍ខ្លីមួយ ផ្ញើទៅកាន់រដ្ឋមន្ត្រីអាណាព្យាបាល ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ១៩០៩ លោករដ្ឋមន្ត្រីក្រសួងការបរទេស បានដាក់ភ្ជាប់មកជាមួយនូវលិខិតពីស្ថានកុងស៊ុលបារាំងប្រចាំនៅគង់តុង មានចុះកាលបរិច្ឆេទថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩០៨ ដែលស្ថានកុងស៊ុលនៅទីនោះ បានចាប់អារម្មណ៍ទៅលើការខិតខំតមកដល់នៃសកម្មភាពរបស់រដ្ឋាភិបាលទប់ទល់ទៅនឹងជនជាតិចិនដែលចូលសញ្ជាតិប្រទេសផ្សេង* (Archive, B13[6]) *។ ប្រហែលជាចំណុចនេះសំដៅទៅលើក្រុមដែលអជ្ញាធរចិនចាត់ទុកថាជាជនជាតិចិន ដំណាលពេលដែលអជ្ញាធរអាណានិគមចាត់ទុកពួកនេះថាជាជនជាតិម្ចាស់ស្រុក ព្រោះខ្ញុំមិនឃើញមានច្បាប់ណាមួយនិយាយពីការចូលសញ្ជាតិ ត្រូវប្រកាសឡើងនៅក្នុងតំបន់ឥណ្ឌូចិន មុនព្រះរាជប្រកាសចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៤០ នោះទេ។*

*២៦-ចំណុចសំខាន់បំផុតនោះ គឺថា គណៈកម្មការផ្សះផ្សាទាំងនេះមិនដាក់បញ្ចូលនូវប្រធានក្រុមសហគមន៍ជាតិពន្ធុឡើយ ។ មិត្តរបស់ខ្ញុំម្នាក់ប្រាប់ខ្ញុំពីភាពមិនធម្មតាមួយ ដែលគណៈកម្មការនៃសហគមន៍ជាតិពន្ធុទាំងមូលបានដឹង*

ពុគ្រប់ៗគ្នានៅក្រុងភ្នំពេញ ដោសារតែទទួលបានរឿងក្ដីដាក់ស្ដែងមួយ ពីស្ត្រីម្នាក់ទាមទារលែងលះ ព្រោះស្វាមីរបស់គាត់បានធ្វើការវះកាត់អាវៈយវៈភេទ ហើយអវៈយវៈនេះលែងមានប្រវែង វែងគ្រប់គ្រាន់សម្រាប់ធ្វើឲ្យគាត់មានសេចក្ដីសុខ ។ គណៈកម្មការបានទទួលធ្វើការដោះស្រាយរឿងក្ដីនេះ ប៉ុន្តែមិត្តរបស់ខ្ញុំមិនបានដឹងពីលទ្ធផលនៃដំណោះស្រាយនោះទេ ។

២៧-ក្រុមប្រឹក្សានៃសហគមន៍ជាតិពន្ធុមួយ (A conseil des congrégations réunies) រួមបញ្ចូលនូវ ប្រធានក្រុម និង អនុប្រធានក្រុម ដែលមកពីសហគមន៍ជាតិពន្ធុផ្សេងៗគ្នា បង្កើតឡើងដោយច្បាប់តំបន់ឥណ្ឌូចិនក្នុងឆ្នាំ ១៨៦៣ (Nguyen, ទំ. ១២២) ។ ខ្ញុំរកមើលមិនឃើញមានច្បាប់ណាមួយ ទាក់ទងនឹងការបង្កើតក្រុមប្រឹក្សានេះនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែ យើងបានដឹងយ៉ាងច្បាស់ថា ក្រុមប្រឹក្សានេះគឺជាផ្នែកមួយដែលបានមកពីដំណើរការនិរទេសខ្លួនក្នុងឆ្នាំ ១៩១៩ ព្រោះថាច្បាប់អន្តោរប្រវេសន៍នៅឆ្នាំនោះ បាននិយាយពីរឿងនេះនៅក្នុងមាត្រាទី៩ (JOIF, 1919, 2509)។

២៨-ចំណុចនេះ គឺ អាចមាននូវកិច្ចសន្យាដែលមិនបានផ្សព្វផ្សាយមែន ព្រោះខ្ញុំបានពុថា ចំណងមត្តិភាពរវាងកម្ពុជាចិន និងកតិកាសញ្ញាមិនឈ្លានពានគ្នាឆ្នាំ ១៩៦០ មិនដែលបានផ្សព្វផ្សាយ នូវអត្ថន័យទាំងស្រុងរបស់វានៅក្នុងប្រទេសកម្ពុជាទេ គឺមានតែសម្រង់ខ្លីៗដែលមាននៅក្នុងការបោះពុម្ពក្នុងស្រុក ។ ការស្រាវជ្រាវរបស់ខ្ញុំតាមរយៈ Journal Officiel du Cambodge បានបង្ហាញឲ្យឃើញថា គ្មានសន្ធិសញ្ញាណាមួយបានធ្វើឡើងរវាង ប្រទេសចិន និង ប្រទេសឯករាជកម្ពុជា ។

២៩-ក្នុងអំឡុងពេលដែលកម្ពុជាទទួលបានឯករាជ្យជាបន្តបន្ទាប់នោះ (បារាំងបានធ្វើឲ្យមាននូវនាំងថ្មីមួយទៀតចំពោះរដ្ឋាភិបាលថ្មី) គឺមាននូវការខ្វែងគំនិតគ្នាខ្លះ មុនពេលដែលទទួលបានឯករាជ្យពេញបរិបូរណ៍ ។ បើទោះបីជាមិនទាន់មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងចតុភាគី រហូតដល់ឆ្នាំ ១៩៥៤ ក៏ដោយ ក៏កម្ពុជាបានប្រារព្ធធ្វើពិធីអបអរសាទរនៃការយាងត្រឡប់មកវិញរបស់សម្ដេច នរោត្តម សីហនុ មកកាន់រដ្ឋធានីវិញ ដោយទ្រង់បានធ្វើសេចក្ដីប្រកាសជាសាធារណៈមួយ ពីការទទួលបាននូវឯករាជ្យពេញបរិបូរណ៍ ហើយបានកំណត់ថ្ងៃទី ៩ ខែ វិច្ឆិកា ឆ្នាំ១៩៥៣ ជាថ្ងៃបុណ្យឯករាជជាតិ ។ នៅដើមខែ មីនា ឆ្នាំ ១៩៥៣ ប្រទេសកម្ពុជាទទួលបាននូវការទុកចិត្ត ឲ្យមានតំណាងផ្នែកការទូតរបស់ខ្លួននៅប្រទេសក្រៅ (Nhiek Tiouliong, 2. See also Liver jaune)

៣០-ជាការពិតណាសថា បន្ទាស់ប្ដូរនយោបាយរបស់ក្រុង ប៉េកាំង ចំពោះជនជាតិចិននៅក្រៅប្រទេស គឺមានភាពស្មុគស្មាញជាងអ្វី ដែលបាននិយាយសង្ខេបមកខាងលើនេះទៅទៀត ។ នៅពេលដែលប្រទេសចិនប្ដូរទៅរកការផ្សះផ្សារ ជាមួយនឹងរដ្ឋាភិបាលនៃប្រទេសដទៃទៀតជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ដោយបដិសេធន៍ចោលនូវការទាមទារ (សញ្ជាតិចិន) របស់ជនជាតិចិនភាគតិច ដែលកើតលើទឹកដីប្រទេសទាំងនោះ នៅប្រហែលឆ្នាំ ១៩៥៤ (Skinner 1959, 146 ; Freedman and W.Willmott, 250 ; Barnett, 188f ) ពួកគេក៏បានផ្លាស់ប្ដូរផងដែរនូវនយោបាយរបស់គេចំពោះជនជាតិចិន

៣១-អត្ថន័យដើម

En attendant l'intervention des conventions qui viendraient á être conclues avec leurs pays intéressés, les étrangers qui sont déjá par les réglements actuellement en vigueur en ce qui concerne notamment la formation et le fonctionnement de leurs congrégations.

៣២- យើងមិនអាចរកបាននូវកស្តុតាងដែលអាចបង្ហាញពីស្ថិតិ និងការប្តឹងទាមទារសញ្ជាតិកម្ពុជានោះទេ ។ ខណៈពេលដែលមានបទ្ទាស់ប្តូរនីមួយៗ តម្រូវឲ្យមាននូវលិខិតបញ្ជាក់ជាផ្លូវការពីតុលាការនោះ ប្រហែលជាយើងអាចទទួលបានព័ត៌មានជាក់លាក់មួយតាមរយៈព្រឹត្តិបត្រ Journal Officiel du Cambodge ប៉ុន្តែខ្ញុំមិនអាចធ្វើដូចនេះបានទេ ។ យើងមិនអាចយកស្ថិតិពីក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ ដើម្បីធ្វើការទស្សន៍ទាយពីអត្រានៃអ្នកសុំចូលសញ្ជាតិ ព្រោះថវិកាប្រចាំឆ្នាំដែលបានមកពីការបង់ពន្ធលើកាត គឺបញ្ជូនផ្ទាល់ទៅកាន់ផ្នែកសេវាកម្មអន្តោប្រវេសន៍ ដើម្បីគ្រប់គ្រងលើតម្លៃចំណាយនៃដំណើរការទាំងមូល ដូច្នេះមិនបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុឡើយ ។ ផ្នែកសេវាកម្មអន្តោប្រវេសន៍ បានបដិសេធមិនឲ្យខ្ញុំនូវរាល់ទិន្នន័យស្ថិតិទាំងអស់ ។
៣៣- បើតាមខ្ញុំដឹង មុខងាររបស់ប្រធានក្រុមសហគមន៍ជាតិពន្ធុ ត្រូវបាត់បង់ទៅតាមរយៈសារាចររបស់នាយករដ្ឋមន្ត្រីចុះថ្ងៃទី ១ ខែ ឧសភា ឆ្នាំ១៩៥៨ ។ ខ្ញុំបានឮគេនិយាយថា នៅក្នុងសារាចរនោះមិនបានបង្ហាញពីវត្តមានស្របច្បាប់របស់ប្រព័ន្ធសហគមន៍ជាតិពន្ធុនោះទេ ។ នៅក្នុងច្បាប់ឆ្នាំ ១៩៣៥ គេបានចាត់ទុកប្រព័ន្ធសហគមន៍ជាតិពន្ធុប្រៀបដូចជាកិច្ចសហប្រតិបត្តិការមួយតែប៉ុណ្ណោះ ប៉ុន្តែច្បាប់បានកំណត់ថា ប្រធានក្រុមមានតួនាទីសំខាន់ក្នុងដំណើរការរបស់ពួកគេ ដោយហេតុនេះហើយ ទើបមានតែពួកមេក្រុមនេះទេដែលមានច្បាប់ទទួលស្គាល់ពីមុខដំណែងរបស់ពួកគេ ។ ដូច្នេះ នៅពេលដែលតួនាទីរបស់មេក្រុមត្រូវបាត់បង់ទៅ ធ្វើឲ្យប្រព័ន្ធសហគមន៍ជាតិពន្ធុស្ថិតក្នុងស្ថានការមិនច្បាស់លាស់មួយនៅក្នុងច្បាប់ ព្រោះវាក្លាយជាប្រព័ន្ធដែលគ្មានមុខងារ រីឯចនាសម្ព័ន្ធច្បាស់លាស់ៗ ភាពមិនច្បាស់លាស់នេះ នៅតែមានរហូតមកដល់សព្វថ្ងៃនេះ ÷ មានអចលនទ្រព្យមួយចំនួននៅតែស្ថិតនៅក្រោមការគ្រប់គ្រងរបស់ប្រព័ន្ធសហគមន៍ជាតិពន្ធុដដែល ទោះបីជាពួកគេគ្មានភ្នាក់ងារស្របច្បាប់ក៏ដោយ។

## ជំពូក ទី ៣

១- សម្រាប់ការពិភាក្សាលម្អិតពីឥទ្ធិពលនៃការលេចឡើងចលនាជាតិនិយម ក្នុងចំណោមជនជាតិចិននៅកោះជ្វា សូមអាន វីលៀម និងស្គីននឺរ ១៩៥៨ ទំ. ១៦៥-១៧១។
២- សម្រាប់ការសិក្សាពីរចនាសម្ព័ន្ធសមាគមន៍ចិននៅក្រៅប្រទេសសូមមើល ឌ. វីលម៉ូត ១៩៦០, ស្គីននឺរ ១៩៥៨, ទៀន, អាមយ៉ូត, ហ្វ្រីមែន ១៩៦០, វ. វីលម៉ូត ១៩៦៤, លីមែន ។
៣- ឈ្មោះដារឿយៗទាំង ១៦ របស់ចិននៅស្រុកខ្មែរមានឈិន (១៥,២%), លីន(៧,៥%), ហ៊្វួង (៥,៧%), ហ្សាង (៥,៥%), វូ(២,៩%), វ៉ាង (២,៨%), ចៃ(២,៨%), ហ្គួ (២,៨%), ហ៊្សុី (២,៤%) ។ សមាគមត្រកូលមានឈ្មោះដូចជាត្រកូលឈិនលីន, ហ៊្វួង, លី, ហ្សាង, វូ, វ៉ាង, និងហ៊្សុី ។ សមាគមនៅស្រុកខ្មែរ ខុសប្លែកពីសមាគមចិននៅក្រៅប្រទេសទាំងអស់ ដោយសារគេមិនបង្កើតសមាគមសែស្រឡាយអស់រយៈពេលជាច្រើនទស្សវត្សមកហើយ ។ មូលហេតុ គឺដោយសារតែប្រព័ន្ធប្រមូលផ្តុំដែលផ្តល់អំណាចឲ្យមេដឹកនាំសមាគម ហ៊ុយ កន ក្នុងការរារាំង និងបំផ្លាញដល់ការប៉ុនប៉ងទាំងឡាយណាក្នុងការបង្កើតសមាគមផ្សេងៗ (ស៊ីអែហ្វ. វ. វីលមូតត៍ ១៩៦៤ទំ. ២៤៦-៨) ។
៤- ពាក្យហ៊ុយកនត្រូវបានប្រើក្នុងចំណោមចិននៅក្រៅប្រទេស សំដៅលើសមាជិកដែលត្រូវបានចុះឈ្មោះដោយឈរលើមូលដ្ឋានតំបន់ ។ ខ្ញុំបានរក្សាទុកបច្ចេកសព្ទចិន ដែលសំដៅលើសមាគមក្រុមភាសានៅក្នុងការសិក្សារបស់ខ្ញុំ ពីព្រោះវាមានសារៈសំខាន់ក្នុងការស្វែងយល់ពីប្រវត្តិសង្គមចិននៅកម្ពុជា ។
៥- នៅមុនសង្គ្រាមចិន-ជប៉ុនសមាគមក្នុងស្រុកដែលសហការជាមួយសមាគមហ៊ុយកន ត្រូវបានរៀបចំឡើងសម្រាប់

បញ្ជូនពួកចិនកាតាំងដែលចាញ់សង្គ្រាមឲ្យត្រលប់ទៅស្រុកនៅកង់តុងវិញ ។ កិច្ចការនេះមិនអាចកើតឡើងបាន រហូតដល់ឆ្នាំ ១៩៣៩ ។ ខ្ញុំត្រូវបានគេស្នើថា សមាគមចិននៅក្នុងស្រុកក្នុងចំណោមជនជាតិចិនក្រៅប្រទេស ផ្តោតការយកចិត្តទុកដាក់ជាមួយស្រុកកំណើត រីឯសមាគមសែស្រឡាយផ្តោតការយកចិត្តទុកដាក់ជាមួយបញ្ហា ដែលជនជាតិចិនកំពុងប្រឈមនៅក្នុងប្រទេសដែលពួកគេកំពុងស្នាក់នៅ ។ សូមមើល វ.វីលមូតត៍ ១៩៦៤ អេ, ទំ. ៣៤ អែហ្វអែហ្វ ។

៦-ការរៀបចំបែបនេះ អាចប្រៀបបានទៅនឹងស្ថាប័នប្រពៃណីចិន (ហ៊ែកហ៊ុង), (ជីហ្វាង) និងត្រូវបានរៀបរាប់យ៉ាងដូចច្នេះដោយពួកចិនកាតាំងនៅកម្ពុជា។

៧-មឺរេ បានសរសេរពីការអប់រំរបស់ជនជាតិចិននៅអាស៊ីអាគ្នេយ៍ ។ គាត់បានបង្ហាញថា ការសាយភាយសាលារៀនចិននៅកម្ពុជាមិនទាន់មានច្រើនប៉ុន្មានទេ ប៉ុន្តែការកើនឡើងនេះវាអាស្រ័យទៅតាមព្រឹត្តិការណ៍នយោបាយពិសេសទំនាក់ទំនងដ៏គួឲ្យចាប់អារម្មណ៍រវាងកម្ពុជា-ចិន (មឺរេទំ. ៨២) ។

៨-តួលេខរបស់រដ្ឋាភិបាលកម្ពុជាស្តីពីការចូលរៀនរបស់ជនជាតិចិន គឺសំដៅលើការចុះឈ្មោះចូលរៀននៅសាលាដែលទទួលស្គាល់ដោយរដ្ឋ ។ ការប៉ាន់ប្រមាណរបស់ខ្ញុំ ពីចំនួនសិស្សសាលានៅសាលារៀនចិននៅភ្នំពេញឈរលើការសម្ភាស និងចំនួនគ្រូដែលមានការអនុញ្ញាតស្របច្បាប់ ។ ប្រៀបធៀបជាមួយវិធីសាស្ត្ររបស់មឺរេ (ទំព័រ ៨២-៣) ដែលប៉ាន់ប្រមាណថា មានសិស្សសរុបពីបីម៉ឺនទៅបួនម៉ឺននាក់នៅក្នុងសាលារៀនចិនក្នុងប្រទេសកម្ពុជាទាំងមូល ។ បើយោងតាមការគណនាទិន្នន័យជំរឿនឆ្នាំ ១៩៦១ ចំនួនកូនក្មេងចិនដែលមានអាយុចន្លោះពី ៥ ទៅ ១៥ ឆ្នាំនៅភ្នំពេញមានចំនួន ៣៨.០០០ នាក់ ។ កូនក្មេងចិនភាគច្រើនបានចូលរៀនសាលារដ្ឋ ហើយស្ទើរតែគ្រប់ជនជាតិចិនសុទ្ធ តែបានបញ្ជូនកូនឲ្យទៅរៀនមិនថា ត្រូវធ្វើពលិកម្មយ៉ាងណានោះទេ ។

៩-ខ្ញុំដឹងថា មានសាលាតែបីគត់នៅកម្ពុជាដែលបង្រៀនភាសាចិនផ្សេងពីភាសាកុកងឺ ក្រៅពីថ្នាក់ទីមួយ ។ ទីមួយគឺសាលាកង់តុង តូចមួយស្ថិតនៅជនបទខេត្តបាត់ដំបង ហើយសាលាពីរទៀតស្ថិតនៅខេត្តរតនគីរី ដែលបង្រៀនទាំងចិនកុកងឺ និងចិនខិ ។ សាលាកង់តុងធំជាងគេនៅភ្នំពេញមានបង្រៀនទាំងកង់តុង និងកុកងឺសម្រាប់តែថ្នាក់ទីមួយប៉ុណ្ណោះ ។

១០-កាសែតទាំង ១៣ បោះពុម្ពជារៀងរាល់ថ្ងៃនៅភ្នំពេញ ត្រូវបានបែងចែកដូចខាងក្រោម (កាសែតបារាំងមួយបោះពុម្ព បីដងក្នុងមួយសប្តាហ៍)៖

| ចំនួនកាសែត និងភាសា | ការបោះពុម្ពផ្សាយ |
|---|---|
| កាសែតភាសាខ្មែរ ៤ | ១០.១០០ ច្បាប់ |
| កាសែតភាសាបារាំង ៣ | ៧.៩០០-៨.៤០០ ច្បាប់ |
| កាសែតភាសាវៀតណាម ១ | ៤.៦០០ ច្បាប់ |
| កាសែតភាសាចិន ៥ | |
| មៀនហ្វារបោវ | ៦.០០០ ច្បាប់ |
| កុងសាងរបោវ | ៦.០០០ ច្បាប់ |
| ម៉ីជៀវរបោវ | ៧.២០០ ច្បាប់ |
| សេងហ្វ៊ូវបាវ | ៣.៥០០ ច្បាប់ |

| | |
|---|---|
| *ស៊ីនបាវ* | *៦.០០០ ច្បាប់* |
| *កាសែតភាសាចិនសរុប* | *២៨.៧០០ ច្បាប់* |
| *ការបោះពុម្ពផ្សាយសរុប* | *៥១.៣០០-៥១.៨០០ ច្បាប់* |

*(តួលេខពីការបោះពុម្ពផ្សាយរបស់ការិយាល័យសារព័ត៌មាននៃក្រសួងព័ត៌មាន) ។ កាសែតទាំងអស់នេះបោះពុម្ពផ្សាយទូទាំងប្រទេស ហើយចែកចាយជារៀងរាល់ថ្ងៃនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ ឧត្តមភាពរបស់កាសែតភាសាចិន មិនមែនត្រឹមតែតំណាងឲ្យចំនួនអ្នកអាននៅភ្នំពេញប៉ុណ្ណោះទេ (តែបូករួមទាំងជនជាតិចិននៅតាមជនបទផងដែរ) ។*

*ក្នុងចំណោមកាសែតភាសាចិនទាំងនោះកាសែតមៀនហ្វ និងកុងសាងគឺជាកាសែតសំខាន់ជាងគេដែលនាំមកនូវទាំងព្រឹត្តិការណ៍ជំនួញជាតិ និងអន្តរជាតិ ។ កាសែតម៉ីជៀង និងកាសែតសេងហ្វពោរពេញទៅដោយការផ្សាយពាណិជ្ជកម្ម និងកម្រងប្រលោមលោក ។ រីឯកាសែតស៊ីនបាវវិញ មានទំនោរចុះផ្សាយពីទស្សនវិស័យរបស់សហគម ដែលមានទំនោរទៅពួកកួមីងតាង។*

*១១- ការពិភាក្សាលម្អិតពីការប្រតិបត្តិជំនឿរបស់ជនជាតិចិននៅកម្ពុជា អាចរកឃើញនៅក្នុង វ.វីលមូតត៍ ១៩៦៤ ស៊ី ទំ. ២៩៤-៣២៤*

*១២-រចនាសម្ព័ន្ធតូចដាច់ដោយឡែក ដែលរួមបញ្ចូលទាំងកាសែត សាលាមួយចំនួន និងក្លឹបកីឡាបីរឺបួន បានភ្ជាប់សមាគមមួយចំនួនតូចនេះ ដោយមានមេដឹកនាំដែលលម្អៀងទៅរកពួកកួមីងតាង ។ បើទោះបីជាមេដឹកនាំខ្លះដែលលម្អៀងទៅរកពួកកួមីងតាង គឺជាសមាជិករបស់គណៈកម្មាធិការមន្ទីរពេទ្យក៏ដោយ ក៏កម្រិតនៃការដាច់ពីគ្នារវាងរចនាសម្ព័នទាំងពីរនៅមានការប្រទាញប្រទង់ ។ កាសែតបានបញ្ឈប់ការផ្សាយនៅឆ្នាំ១៩៦៤។*

## ជំពូក ទី ៤

*១-ច្បាស់ណាស់ថា ការតាំងទីលំនៅទាំងពីរប្រភេទនេះ គេឃើញមាននៅក្នុងផ្នែកជាច្រើនទៀតនៃតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសម៉ាឡាយ៉ា និងប្រទេសថៃ ។ កត្តាដែលមានដីធ្លីគ្រប់គ្រាន់សម្រាប់ការតាំងទីលំនៅក្នុងតំបន់ឧបទ្វីបឥណ្ឌូចិន យ៉ាងសន្សឹមៗពីរសតវត្សកន្លងទៅនេះ បានដាក់ប្រស្នាចំពោះអ្នកជំនាញភូមិសាស្ត្រមួយចំនួន ។ លោក* Zelinski *និយាយអំពីតំបន់នេះថា ជា «ប្រជាជនអនិយ័ត» សម្រាប់ការបង្ហាញនូវដង់ស៊ីតេប្រជាជនគួរឲ្យចាប់អារម្មណ៍ ក្រោមលក្ខខណ្ឌតំបន់ជិតខាង និងមានទិដ្ឋភាពដូចគ្នា ។ ដើម្បីឆ្លើយតបទៅនឹងចម្ងល់ដែលថា តើមូលហេតុអ្វីក៏រឿងនេះទៅជាដូច្នេះនោះ លោកបានស្នើហេតុផលបីឡើងមកគឺ៖ ១)-«លក្ខណៈដែនដីលយចូលក្នុងស្រុកផ្សេង* (Corridor character)» *នៃតួដួរភ្នំជាច្រើន ដែលអាចឲ្យគេធ្វើចំណាកស្រុកជាប្រចាំពីផ្ទៃខាងក្នុង ដោយគ្មានឧបសគ្គដល់ការតាំងទីលំនៅ ។ ២)-«ការតាំងលំនៅជាស្ថួល» មានទំហំតូចតាច ។ ៣)-ពុទ្ធសាសនាប្រតិស្ថានដោយគ្មានតម្លៃសម្រាប់បច្ចាជន ហើយធម្មភាពបូជារបស់បុព្វបុរសក៏ត្រូវបាត់បង់ ។ បើក្រឡេកមើលប្រទេសកម្ពុជាវិញ បរិមាណមួយភាគបួន និងប្រហែលជាហេតុផលសំខាន់បំផុតដែលគប្បីបន្ថែមថា សង្គ្រាមប្រឆាំងនឹងពួកអណ្ណាម និងថៃ បានដឹកនាំឲ្យមានការកាប់សម្លាប់អ្នកលក់ដូរជុំជាច្រើន និងការចាប់ពង្រត់ខ្មែរអស់រយៈពេលបួនសតវត្សរ៍ចន្លោះការធ្លាក់ចុះនៃមហាអំណាចអង្គរ និងការបង្កើតសន្ធិសញ្ញាសន្តិភាពព្រមព្រៀងរួម រស់នៅក្រោមមហាអំណាចមួយ បីដូច* The pax gallica *(ឈ្មោះសន្ធិសញ្ញាសន្តិភាពដែលពួកហ្គោល ឬបារាំងបុរាណត្រូវទទួលស្គាល់អំណាច*

*របស់រ៉ូមលើប្រទេសបារាំង កាលពីសតវត្សទី ១ មុនគ.ស. ដើម្បីបញ្ចប់សង្គ្រាមរវាងភាគីទាំងពីរ)។*

*២-នេះ គឺពិតជាដូចគ្នានឹងជនជាតិចិនខិ ដែលជាអ្នកដាំដំណាំកៅស៊ូនៅកោះសារ៉ាវ៉ាក់ (គៀន) និងពួកចិនទាជីវ ដែលជាអ្នកដាំបន្លែនៅម៉ាឡាយ៉ា (ញូវែល) ។*

*៣-កត្តាដែលកម្មករជាតិចិននៅបរទេស តែងតែមានមហិច្ឆតាដូចៗគ្នា នៅខណៈពេលដែលពួកបញ្ញវន្តធ្វើការវិភាគតាមទ្រឹស្តីម៉ាក់និយមទៅលើការលំបាក និងការដឹកនាំខុសខាងសង្គមរបស់ពួកជនជាតិចិននៅឯនាយសមុទ្រ ។ Simoniya បានព្យាយាមធ្វើការវិភាគបែបនេះ ប៉ុន្តែមិនសូវបានជោគជ័យល្អទេ (វ. វីលមូតត៍១៩៦៣) ។*

*៤-គំនិតសង្គមចម្រុះកើតមាននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ផ្តល់អាទិភាពដល់ការរាតទីរបស់ពួកអឺរ៉ុប ដែលហាក់ដូចជាគេចចេញពីគំនិតរបស់ហ្វឺនីវ៉ល ដែលមិនមែនជាអ្នកប្រវត្តិសាស្ត្រ សម្រាប់អ្វីដែលគាត់ចង្អុលបង្ហាញថា សង្គមចម្រុះ គឺជាការបង្កើតឡើងពីគោលនយោបាយរបស់ពួកអាណានិគម (Furnivall ១៩៤២,ទំ. ១៩៨-៩) ។ វាពិតណាស់ថា អ្នកកាន់អំណាចអាណានិគម បានជួយជំរុញលក្ខខណ្ឌសេដ្ឋកិច្ចសម្រាប់សង្គមចម្រុះ និងថា របបអាណានិគមខ្លះ ជាពិសេសហូឡង់ និងបារាំង បានផ្តល់នូវនិយមន័យស្របច្បាប់ បង្កើតទម្រង់សារជាតិចម្រុះនៃសង្គមអាណានិគម។ ប៉ុន្តែ បើតាមយោបល់ខ្ញុំ វាគ្មានហេតុផលអ្វី ត្រូវទាត់ចោលនូវលទ្ធគោលការណ៍ និងចក្រពត្តិនិយមរបស់អាស៊ីអាគ្នេយ៍មុនរបបអាណានិគម អំពីគំនិតនេះដែរ ។*

*៥-វិកបើក បាននិយាយបន្ថែមនូវរឿងដូចគ្នានេះ នៅប្រទេសហ្វីលីពីន (Wickberg ១៩៦២ ទំ. ២៧៦-៧) ។ នៅទំ. ២៨៥ គាត់ធ្វើការអះអាងយ៉ាងច្បាស់លាស់ អំពីនិក្ខេបបទរបស់លោក វើធីម ៖*

> ក្រោយឆ្នាំ ១៨៥០ កំណើនបរិមាណ ល្បាយ និងអំណាចសេដ្ឋកិច្ចរបស់ជនជាតិចិន បាននាំមកនូវសភាពការណ៍ប្រកួតប្រជែងគ្នា ជាមួយអាជីវកម្មរបស់ពួកកូនកាត់អេស្ប៉ាញ-អាមេរិកាំង (mestizo) និងពួកហ្វីលីពីន ដែលបានអភិវឌ្ឍន៍តាំងពីអំឡុងមួយសតវត្ស ១៧៥០-១៨៥០ មកហើយ ។ គម្លាតគ្នាខាងវប្បធម៌បានកើតឡើងយ៉ាងច្បាស់ក្រឡែត នៅក្នុងជម្លោះប្រឆាំងពួកចិននៅរវាងទសវត្សរ៍ ១៨៨០ និង ១៨៩០ ។ ប៉ុន្តែកត្តាសេដ្ឋកិច្ចបានធ្វើឲ្យមានឥទ្ធិពលដល់ការសម្រេចចិត្ត ។
>
> កត្តាអាទិភាពចំពោះ អារម្មណ៍ប្រឆាំងជនជាតិចិន នៅក្នុងសតវត្សរ៍ទី ១៦ និង ១៧ បានជំរុញឡើង និងប្រើប្រាស់ដោយពួកអេស្ប៉ាញ ។ ប៉ុន្តែវាខ្វះនូវមូលដ្ឋានបង្អែកសេដ្ឋកិច្ចក្នុងចំណោមពួកហ្វីលីពីន ។

*៦-នៅឆ្នាំ ១៩១៩ បាតុកម្មនៅសៃហ្គន ប្រកាន់យកទម្រង់នៃការបដិសេធចោលនូវពាណិជ្ជកម្មចិន និងការប្រឹងប្រែងរបស់ពួកយួន ដើម្បីបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរបស់ខ្លួនឯង ជំនួសតួនាទីរបស់ចិន ។ បំណងនោះត្រូវបរាជ័យ នៅពេលពួកចិនទារយកប្រាក់ចងការយ៉ាងច្រើនទាំងអស់នោះមកវិញ ។ កុបកម្មនៅទីក្រុងហៃហ្វុង ត្រូវគេផ្តើមធ្វើនៅខែសីហា ឆ្នាំ ១៩២៦ ហើយដឹកនាំឲ្យមានការដុតបំផ្លាញសង្កាត់ចិននៅទីក្រុងនេះ ដោយពួកកម្មករកំពង់ផែយួន (Dennery ១៩៣១ទំ. ១៥៦) ។ លោករ៉ូប៊ីកាំង ទំ. ៤០) និងគូឡេត (Coulet) ផ្តល់កាលបរិច្ឆេទនៃកុបកម្មនៅហៃហ្វុងថានៅ ឆ្នាំ ១៩២៧ ។ អនុលោមតាមលោក គូឡេត លទ្ធផលនៃកុបកម្មនោះធ្វើឲ្យមនុស្ស ៦ នាក់ស្លាប់១០០ នាក់របួស,បំផ្លាញផ្ទះអស់ ៣០ ខ្នង ដុតបំផ្លាញអគារ ៨ ខ្នង មនុស្ស ១៥០ នាក់ត្រូវចាប់ខ្លួន ហើយ ៥៧ នាក់ក្នុងចំណោមនោះ ត្រូវផ្តន្ទាទោសដោយកាត់ក្តីព្យួរទោសពី ៣ខែទៅ៦ខែ (គូឡេត ទំ. ៤៦៤)។*

*៧-សូមមើល ឌែលវីត ទំ. ៤៨៨-៥០១, ជាពិសេសទំ. ៤៩៥ ដែលគាត់ផ្តល់ជាបន្តបន្ទាប់នូវល្បាយនៃផ្ទាស់ដី (ម្ចាស់កម្មសិទ្ធិអចលនទ្រព្យ) ចំនួន ៧២៧.០០០ នាក់ នៅក្នុងការសិក្សាអង្កេតរបស់គាត់ ដែលបានរួមបញ្ចូលនូវដីស្រែ*

រាលទំនាបភាគច្រើនបំផុតនៃប្រទេសកម្ពុជា ៖

| | | |
|---|---|---|
| ៤០២.០០០ (៥៥%) | មានដីស្រែ | តិចជាង ១ ហិចតា |
| ១៨៣.០០០ (២៥%) | មានដីស្រែពី | ១ ហិចតាទៅ ២ ហិចតា |
| ៩០.០០០ (១២%) | មានដីស្រែពី | ២ ហិចតាទៅ ៤ ហិចតា |
| ៤៨.០០០ (៧%) | មានដីស្រែពី | ៥ ហិចតាទៅ ១០ ហិចតា |
| ៩.៣០០ (១%) | មានដីស្រែពី | ១០ ហិចតាទៅ ២០ ហិចតា |
| ១.១៩១ | មានដីស្រែ | លើសពី ២០ ហិចតា |

៨-ខ្មែរឥស្សរៈ ឬ «រណសិរ្សខ្មែរសេរី» ដែលបានធ្វើការប្រយុទ្ធជាសង្គ្រាមឧទ្ទាមទ័ពព្រៃ ប្រឆាំងនឹងបារាំងតាំងពីឆ្នាំ ១៩៤៥ ត្រូវគេសម្រួលឲ្យនៅក្រោមក្រសែភ្នែករបស់ខ្មែរ ដោយទំនាក់ទំនងជាមួយចលនាជាតិនិយមវៀត-ណាម ។ ពិតណាស់ថា ព្រះរាជបូជនីយកិច្ចរបស់ព្រះមហាក្សត្រ មិនអាចដំណើរការទៅមុខដោយជោគជ័យទេ បើបារាំងមិនបានប្តេជ្ញាចិត្តខ្ពស់ក្នុងការប្រើប្រាស់យោធា ដើម្បីប្រឆាំងនឹងពួកវៀតមិញ ក្នុងន័យការពារតំបន់មានសារៈសំខាន់ខាងសេដ្ឋកិច្ចនៃដីសណ្ត ទន្លេក្រហម និងទន្លេមេគង្គ ។ ពួកគេមិនអាចប្រឹងប្រែងធ្វើសកម្មភាពពីក្រោយខ្នងប្រឆាំងខ្មែរឥស្សរៈនៅក្នុងតំបន់តែមួយបានទេ គឺកម្ពុជា ។ សម្រាប់គំនិតពួកគេ គឺមានតែនៅតំបន់ឆ្ងាយពីទីក្រុងប៉ុណ្ណោះ យ៉ាងណាក៏ដោយ ចលនានីមួយៗរំកិលទៅមុខដោយសារបារាំង បែរផ្ទោះទៅរកការប្រគល់ឲ្យនូវឯករាជ្យ ដែលត្រូវបង្ខិតបង្ខំដោយសកម្មភាពជាក់លាក់មួយចំនួនរបស់ស្តេច និងវរជនទាំងអស់ដែលកំពុងធ្វើការជាមួយព្រះអង្គ ។ កម្ពុជាជណ្តើមបានឯករាជ្យរបស់ខ្លួន ចំនួន ៨ ខែមុនសន្និសីទហ្សឺណែវ ត្រូវបើកឡើងបន្ទាប់ពីការបរាជ័យរបស់បារាំងនៅឌៀនបៀនហ្វូ (មួយថ្ងៃ) និងដែលបានពុះចែកប្រទេសវៀតណាម ។ សម្រាប់រឿងរ៉ាវផ្លូវការនៃការតស៊ូ ដើម្បីឯករាជ្យជាតិរបស់កម្ពុជា សូមមើល ញ៉ឹក ជូឡុង, Livre Jaune; សម សារី, ទំ. ១-១២០ ។ បទសង្ខេបដ៏សំខាន់មួយស្តីពី «រាជបូជនីយកិច្ចដើម្បីឯករាជ្យ» មានផ្តល់ឲ្យនៅក្នុងជំពូកទី៣ របស់អាមស្ត្រង (Armstrong) ទំ. ៥៣-៧៥។

៩-មានការព្រមព្រៀងគ្នាជាទូទៅមួយក្នុងចំណោមអ្នកផ្តល់សម្ភាសន៍ថា មិនប្រាប់ឈ្មោះបុរសអ្នកមានបំផុតទាំងអស់នោះថាជាអ្នកណានោះទេ ។ ទម្រង់អតីតកាលដែលត្រូវយកមកប្រើនៅក្នុងកថាខណ្ឌនេះ ពីព្រោះមានអ្នកមានបំផុតម្នាក់ឈ្មោះ លោក សុងសាក់ គិច្ចប៉ានិច្ច (អ៊ូ សុងសាន) បានភៀសខ្លួនចេញពីប្រទេសនៅខែធ្នូ ឆ្នាំ ១៩៦៣ បន្ទាប់ពីលេចបទអាស្រូវហិរញ្ញវត្ថុជាមួយនឹងលក្ខណ៍ឋាននយោបាយ (Réalités Cambodgiennes, No. 386, Dec. 28, 1963, p.5) ។ បុរសនេះមានដើមកំណើតជាសញ្ជាតិថៃ និងជាកូនប្រុសពៅរបស់ធនាគារិកម្នាក់នៅបាងកក លោក សុងសាក់គិច្ចប៉ានិច្ច បានក្លាយជាពលរដ្ឋកម្ពុជា ដោយសារការសម្រេចរបស់សភាជាតិកាលពីឆ្នាំ ១៩៥៧ (JOC 1957, 4730) ។ គាត់មានប្រភពចំណូលខាងហិរញ្ញវត្ថុជាច្រើន រួមទាំងធនាគារធំមួយ កម្មសិទ្ធិអចលនទ្រព្យ រោងចក្រកេសដ្ឋៈ សណ្ឋាគារមួយចំនួន រមណីយដ្ឋានសណ្ឋាគារទាបមួយចំនួន (Resort bungalows) ក្រុមហ៊ុនធ្វើដំណើរមួយ ក្រុមហ៊ុនអាហារណែនីរហរណៃមួយ និងក្លឹបកម្សាន្តរាត្រីមួយ ។

ទោះបីក្រុមហ៊ុនបារាំងបួន-ប្រាំមានលក្ខណៈធំជាងក្រុមហ៊ុនចិននៅក្នុងប្រទេសនេះក៏ដោយ ក៏ទាំងប្រធានសាជីវកម្ម និងទាំងម្ចាស់របស់ក្រុមហ៊ុនទាំងនោះ មិនបានរស់នៅក្នុងប្រទេសកម្ពុជាដែរ ។

គួរឲ្យចាប់អារម្មណ៍ដែរថា គ្មានចិនកន្តាំងនៅក្នុងចំណោមចិនអ្នកមានបំផុតប៉ុន្មាននាក់នេះទេ ។ នេះប្រហែល

មកពីទ្រព្យសម្បត្តិរបស់ពួកចិនកន្ដាំងប្រមូលផ្ដុំតែនៅសៃហ្គន-ឆោឡុន នៅពេញមួយអំឡុងពេលអាណានិគមបារាំង ។ ភាគច្រើននៃក្រុមហ៊ុនធំៗបំផុតរបស់ពួកចិនកន្ដាំងនៅភ្នំពេញ ធ្វើសកម្មភាពដូចជាភ្នាក់ងារសម្រាប់ពួកគេ ម៉្លោះហើយ វាគ្មានការប្រមូលធនដោយខ្លួនឯងឡើយ ។
១០- ការសិក្សាទូលំទូលាយបំផុតមួយក្នុងពេលថ្មីៗនេះ អំពីគោលនយោបាយការបរទេសរបស់កម្ពុជា ត្រូវបានផ្ដល់ឲ្យដោយលោកសាស្ដ្រាចារ្យ Roger Smith ។ លោក អាមស្ត្រង ពិភាក្សាហេតុផលសម្រាប់អព្យាក្រឹតភាពរបស់កម្ពុជាយ៉ាងវែង ។ សូមមើល ជាពិសេសជំពូកទី ៥ និង ៦ ។ លោក មីសែល ឡេហ្វ័រ ផ្ដល់នូវការវិភាគដោយខ្វះក្ដីជ្រះថ្លា ។ សូមមើល Leifer, 1961, 1962, 1963 ។

## ជំពូក ទី ៤

១-ពាក្យនេះសរសេរជាភាសាអង់គ្លេសថា «Patron-Client » ។ Patron សំដៅលើអ្នកមានឥទ្ធិពលលើអ្នកដទៃទៀតនៅក្នុងសហគមន៍ ភូមិ ឃុំ ហើយពួកនេះមាននាទីជួយការពារ និងឧបត្ថម្ភដល់ ពួក Client ទប់ទល់នឹងឥទ្ធិពលពីខាងក្រៅ ឬនៅពេលដែលជលិនេតជួបនឹងវិបត្តិផ្សេងៗ និងជាអ្នកទទួលរ៉ាប់រងលើពិធីប្រចាំភូមិផ្សេងៗ។ Patron អាចជា អ្នកមានក្នុងភូមិដែលមានទ្រព្យសម្បត្តិ និងដីស្រែចម្ការជាច្រើន ឬពួកវរជនដែលស្ថិតក្នុងត្រកូលល្បីល្បាញប្រចាំភូមិ ។ ចំណែកឯ Client វិញ គឺជាអ្នកដែលទន់ខ្សោយ ក្រីក្រ ហើយត្រូវរស់ដោយពឹងទៅលើពួក Patron ក្នុងការខ្ចីលុយ ជួលដី ឬទទួលការឧបត្ថម្ភពីពួកនេះ ។ Client អាចជាកសិករ អ្នកក្រីក្រក្នុងភូមិ ។ ដូច្នេះ ទំនាក់ទំនង«Patron-Client» អាចនិយាយបានថាជាទំនាក់ទំនង ចៅហ្វាយនាយ-អ្នកពឹងពាក់ ឬទំនាក់ទំនង អ្នកមាន-អ្នកក្រ ឬទំនាក់ទំនងអ្នកធំ-អ្នកតូច ឬទំនាក់ទំនងថៅកែ-កម្មករ ។ល។ ជាទូទៅនៅក្នុងសហគមន៍មួយ ភាគីទាំងសងខាងតែងត្រូវការគ្នាទៅវិញទៅមក ដូចជា.Client ត្រូវការ Patronដើម្បីធានាឲ្យបាននូវសន្តិសុខស្បៀង ដើម្បីឲ្យពួកគេអាចរស់រានមានជីវិតបាន និងជួយរកទីផ្សារលក់ផលិតផលឲ្យពួកគេ ។ ចំណែកឯ Patron វិញត្រូវការពួក Client ឲ្យជួយគាំទ្រខ្លួន ឬឲ្យស្ម័គ្រចិត្ត ទទួលស្គាល់អំណាចខ្លួន គោរពខ្លួន និងរីករាយក្នុងការបម្រើខ្លួន ហើយតម្រូវឲ្យពួក Client លក់ផលិតផលកសិកម្ម ដែលគេផលិតបានឲ្យទៅខ្លួន ។ ដើម្បីឲ្យមានតុល្យភាពនៃតម្រូវការរវាងភាគីទាំងសងខាងនោះ ពួកគេត្រូវធ្វើការចរចាដោះដូរគ្នា ( Barganing of exchange) ។ ក្រោយពីការចរចារួចពួកគេនឹងទទួលបាននូវតុល្យភាពនៃការដោះដូរគ្នាមួយ ដែលហៅថា Banlance of exchange ហើយលទ្ធផលនេះ គឺអាស្រ័យនឹងរឿងដែលថា តើភាគីណាត្រូវការភាគីណាជាង ។ ជាទូទៅ ភាគីណាដែលគេត្រូវការច្រើនតែងមានឥទ្ធិពល ឬមានប្រៀបជាង ភាគីដែលត្រូវការគេ ក្នុងតុល្យភាពនៃការចរចា ។
២-ខាល ឡែនឌី (Carl Lande) ជាមនុស្សដំបូងគេដែលបានប្រើប្រាស់ទ្រឹស្ដីចៅហ្វាយនាយ និងអ្នកពឹងពាក់ លើនយោបាយអាស៊ីអាគ្នេយ៍ យល់ថា បញ្ហានេះជាឧបករណ៍យ៉ាងសំខាន់ ក្នុងការពន្យល់ ពីអវត្តមានភាពនៃការបោះឆ្នោតថ្នាក់មូលដ្ឋាន និងសម្ព័ន្ធភាពរវាង «អ្នកធំ » និង «អ្នកតូច» ដែលមានលក្ខណៈដូចជាគណបក្សនៅហ្វីលីពីនៗ ឡែនឌី(Lande) : មេដឹកនាំ ការបែកបាក់ និង គណបក្ស (រចនាសម្ព័ន្ធនៃនយោបាយហ្វីលីពីន ( ញូ ហេវិន (New Haven) : ការសិក្សាអាស៊ីអាគ្នេយ៍នៅសាកលវិទ្យាល័យយេល ១៩៦៤) សូមមើលអត្ថបទរបស់គាត់ស្ដីអំពី : ក្រុម និងបណ្ដាញនៅអាស៊ីអាគ្នេយ៍ ដែលបានផ្ដល់ទៅ ឲ្យក្រុមហ៊ុនប្រឹក្សាអភិវឌ្ឍន៍អាស៊ីអាគ្នេយ៍ ទីក្រុងញូយក ខែវិច្ឆិកា ១៩៦៩ និងទស្សនាវដ្ដី វិទ្យាសាស្ត្រនយោបាយអាមេរិក ដែលនឹងចេញផ្សាយនៅពេលឆាប់ៗខាងមុខនេះ ។ ការ

សិក្សាដ៏ប្រុងប្រយ័ត្ននៃនយោបាយអ្នកភូមិ នៅប្រទេសភូមាភាគខាងលើ ដោយ ណាស ។ ការសិក្សានេះបានសន្និដ្ឋានថាការសម្រេចចិត្តខាងផ្នែកនយោបាយជាមូលដ្ឋាន របស់អ្នកភូមិ គឺដើម្បីចូលរួម ជាមួយចៅហ្វាយនាយល្អ ដែលអាចការពារ និងជំរុញផលប្រយោជន៍របស់ពួកគាត់ ។ មែន ណាស់ (Manning Nash): វិថីមាសឆ្ពោះទៅកាន់ភាពទំនើប (ញូ យក: វីលី ១៩៦៥) ។ នយោបាយក្នុងស្រុកនៅម៉ាឡាយ៉ា និងប្រទេសថៃ បានពន្យល់បច្ចេកសព្ទដូចគ្នា ។ សូមមើល: ម.ហ្ស.ស្វីហ្វ (M. G. Swift) សង្គមកសិករម៉ាឡេ នៅជេឡេប៊ូ (ឡុងដុង: សារព័ត៌មាន ១៩៦៥)។ សូម្បីតែនៅកោះជ្វាជនបទ ដែលជាកន្លែងស្វាកស្វាមគណបក្សស្មើឡើង មិនស៊ីសង្វាក់គ្នាផ្នែកមនោគមវិជ្ជា ការបកស្រាយភាគច្រើនបានសង្កត់ធ្ងន់ទៅលើចរិត នៃការបែកបាក់គ្នាចំពោះការប្រេះឆាសានទ្រីអាបានប្តូន ដែលក្រុមនីមួយៗត្រូវដឹកនាំដោយ គ្រូឌី (ស្រេគ្រូឌី) ដែលជាអ្នកនាំយកមកជាមួយ សាច់សាលោហិតរបស់គេ អ្នកជិតខាង និងអ្នកមកពឹងពាក់ ។ រ៉ូបើត រ.ចាយ សាសនា និងនយោបាយ នៅជនបទនៃតំបន់ជ្វាកណ្តាល ប្រព័ន្ធនៃរបាយការណ៍វប្បធម៌ (ញូហេវិន: ការសិក្សាតំបន់អាស៊ីភាគអគ្នេយ៍នៃសាកលវិទ្យាល័យយេល ១៩៦៣) ទំ. ៩៨-៩៩ ។ ចំពោះបញ្ហានេះសូមមើលស្នាដៃ របស់ ដូណាល់ ហ៊ីនលី គណបក្សកុម្មុយនីសរបស់ប្រទេសឥណ្ឌូនេស៊ី ឆ្នាំ ១៩៥១-១៩៦៣ (បើកខេីលី: សាកលវិទ្យាល័យកាលីហ្វូនី, ១៩៦៦) ជំពូកទី ១៤ ផង រិច ម៉រទីម័រ, «វណ្ណៈ ជម្លោះសង្គម និងកុម្មុយនីស-និយមឥណ្ឌូនេស៊ី» ឥណ្ឌូនេស៊ី លេខ ៨ (ខែតុលា, ១៩៦៩) ទំ. ១-២០ និង វ.ហ្វ.វើសេម «ពីអាលីរ៉ានទៅការតស៊ូវណ្ណៈ នៅជនបទនៃកោះជ្វា» ទស្សនាវដ្តីលេខ ៥៥ សន្និសីទអន្តរជាតិស្តីអំពី: ប្រវត្តិសាស្ត្រអាស៊ី ថ្ងៃទី ៥-១០, ខែសីហា ឆ្នាំ ១៩៦៨ កូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។

៣–មានស្នាដៃមួយចំនួនផ្សេងទៀត ដែលមានការពាក់ព័ន្ធនៅក្នុងចំណងទាក់ទងចៅហ្វាយនាយ-អ្នកពឹងពាក់ ដែលខ្ញុំបានស្រាវជ្រាវស្នាដៃសំខាន់ៗទាំងនោះរួមមាន: ចច ម.ហ្វូស្ទ័រ «កិច្ចសន្យាទ្វេភាគី នៅហ្សីនហ្សុនហ្សាន់: ទំនាក់ទំនងរវាងចៅហ្វាយនាយ-អ្នកពឹងពាក់» នរវិទូអាមេរិក ៦៥ (១៩៦៣) ទំ. ១២៨០-១២៩៤ ។ រិក វូល «សាច់សាលោហិត មិត្តភាព និងទំនាក់ទំនងចៅហ្វាយនាយ-អ្នកពឹងពាក់,» នៅក្នុង ម. បានថុន (បណ្ណាធិការ) នរវិទ្យាសង្គមនៃសង្គមមានបញ្ហាស្មុគ្រស្មាញ (ញូ យក: ប្រេចជ័រ, ១៩៦៦) ។ ដ. ខេមបែល គ្រួសារថ្ងៃថ្នូរ និងបរិបាលកិច្ច (ការឧបត្ថម្ភ) (អកហ្វឺត: សារព័ត៌មាន ក្លារែនដិន ១៩៦៤) ។ ចន ដាន់ខិន ផូវែល, «សង្គមកសិករ និងនយោបាយអ្នកអតិថិតា» ទស្សនាវដ្តីវិទ្យាសាស្ត្រនយោបាយអាមេរិក ឡឃ្វី, ២ (ខែមិថុនា ឆ្នាំ ១៩៧០) ។ ខាល ឡែនឌី, មេដឹកនាំជម្លោះ និងគណបក្ស: រចនាសម្ព័ន្ធនយោបាយប្រទេសហ្វីលីពីន ដូចឯកសារមុន និង អាឡិច វីនហ្វ្រាត់ «ចៅហ្វាយការឧបត្ថម្ភ និងគណបក្សនយោបាយ» ការសិក្សាប្រៀបធៀបនៅក្នុងសង្គម និងប្រវត្តិសាស្ត្រ១៩ (ខែ កក្កដា ឆ្នាំ១៩៦៨)ទំ. ១១៤២-១១៥៨ ។ សូមមើលផងដែរស្នាដៃខ្ញុំ «នយោបាយចៅហ្វាយនាយ-អ្នកពឹងពាក់ និងបម្រែបម្រួលនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍» ទស្សនាវដ្តីវិទ្យាសាស្ត្រនយោបាយអាមេរិក ៦៦:១ (ខែ មីនា ឆ្នាំ ១៩៧២) ទំ. ៩១-១១៣ ។

៤–ខ្ញុំបានជំពាក់ដល់ប៉ារីងតុន ម័រ អំណះអំណាង ដែលទាក់ទាញអាជីវកម្មភាគច្រើននោះ គឺថា ទំនាក់ទំនងសំខាន់នោះ ដែលបង្ហាញអារម្មណ៍អំពីអាជីវកម្មក្នុងការទទួលយកទំនាក់ទំនង ចំពោះសេវាកម្ម គហបតីផ្តល់ឲ្យកសិករនូវអ្វីដែលជាគេបានបន្សល់ទុកឲ្យ ។ ដើមកំណើតសង្គមនៃរបបផ្តាច់ការ និងប្រជាធិបតេយ្យ (ប៊ូស្តុន: សារព័ត៌មានប៊ីខិន ១៩៦៦) ទំ. ៤៥៣-៤៨៣ ។ អំណះអំណាងរបស់គាត់គឺមានការជឿនលឿនទៅមុខ ដោយការអនុវត្តដ៏ជោគជ័យនៅតំបន់អ៊ីតាលីកណ្តាល ដែលជាប្រភេទនៃបម្រែបម្រួលបានត្រូវវិភាគដោយយកចិត្តទុកដាក់ របស់ ស៊ីដែល ហ្វ.

ស៊ីលវើមែន ។ «ដីដែលគេធ្វើការយកផល នៅតំបន់ជនបទ នៃអ៊ីតាលីកណ្ដាល: រចនាសម្ព័ន្ធ និង មនោគមវិជ្ជា នៅក្នុងការសិក្សាជាន់ថ្នាក់» ការសិក្សាប្រៀបធៀបក្នុងសង្គម និងប្រវត្តិសាស្ត្រ ១២ (១៩៧០) ទំ. ៣២៧-៣៣៩ ។ ការសិក្សានេះមានប្រភពមកពី ម៉រ និងស៊ីលវើមែន និងស្នាដៃខាងទ្រឹស្ដីរបស់ គីតធើ ប៉ូវ៉ី ស្ដីពីទ្រឹស្ដីបម្រែបម្រួល និងអំណាចនៅក្នុងជីវិតសង្គម (ញូយក: វីលី,១៩៦៤) ដែលបញ្ញត្តកម្មទំនាក់ទំនងកសិកម្មរបស់ខ្ញុំត្រូវគេទាញយក ។ សូមមើល សិក្សាកថារបស់ អាស័រ ស្ទីនឆុមប៊ី ស្ដីអំពី «ទំនាក់ទំនងវណ្ណៈនៅជនបទ នៅក្នុង» ទស្សនាវដ្ដីសង្គមវិទ្យាអាមេរិក លេខ ៦៧ (១៩៦១ទំ. ៦២) ជាពិសេសផ្នែកខាងការជួលទំហំគ្រួសារ? ។

៥-បច្ចេកស័ព្ទនេះ គឺជា របស់ អ៊ី.ភី. ថមសុន ដែលបានអនុវត្តក្នុងទម្រង់ស្រដៀងគ្នានៃថ្នាក់ការងារដំបូងរបស់អង់គ្លេស និងឥរិយាបថចំពោះតម្លៃនំបុ័ង ។ សូមមើលស្នាដៃតន្ទីរបស់គាត់ ស្ដីពី ការបង្កើតថ្នាក់ការងាររបស់អង់គ្លេស (ញូយក: វិនទិក,១៩៦៦) ទំ. ២០៣ ។

៦-ប្រភេទរបស់ខ្ញុំ គឺត្រូវរៀបចំផ្សេងគ្នាបន្តិចពីស្នាដៃរបស់ ស៊ីលវើមែន ដូចឯកសារពីមុន ទំ. ៣៣១-៣៣៣ ប៉ុន្តែខ្ញុំបានទាញយកគុណប្រយោជន៍យ៉ាងច្រើន អំពីការពិពណ៌នារបស់នាងស្ដីអំពីប្រទេសអ៊ីតាលីកណ្ដាល ។

៧-ការពិភាក្សាជាច្រើនទៀតនៃសញ្ញាណ «តុល្យភាពនៃបម្រែបម្រួល» និងភាពស្របច្បាប់របស់ថៅហ្វាយនាយ អាចរកឃើញនៅក្នុងស្នាដៃរបស់ ដេម ស្កត់ និងប៊ីនីឌិក ឃើកវ្លេត «បែបបទនៃការបាត់បង់ភាពស្របច្បាប់របស់ថៅហ្វាយនាយនៅជនបទសម័យបុរាណ: ទ្រឹស្ដី និងគន្លងនិទ្ទេសពិសេសនៅតំបន់ដីទំនាបនៃអាស៊ីអាគ្នេយ៍» ការសិក្សាប្រៀបធៀបនៅក្នុងសង្គម និងប្រវត្តិសាស្ត្រ ចេញផ្សាយនៅឆ្នាំ ១៩៧៣ ។

៨-ស្របតាមការពិសោធ ការគោរពប្រតិបត្តិដែលមិនស្រុះស្រួលគ្នា អាចមានការលំបាកក្នុងការបែងចែកពីការគោរពប្រតិបត្តិដែលមានការស្រុះស្រួលគ្នា ប្រសិនបើគ្មានមធ្យោបាយក្នុងការបង្ហាញការមិនពេញចិត្ត ។

៩-នេះមិនមែនជាការបដិសេធ និយាមសមភាព នៅក្នុងតុល្យភាពនៃការប្រែប្រួលនោះទេ ប៉ុន្តែមិនមានលក្ខណៈផ្សេងៗគ្នាពីវប្បធម៌ មួយទៅវប្បធម៌មួយទៀត ។ ពួកគេប្រាកដជាធ្វើ ប៉ុន្តែជាពិសេស នៅក្នុងបរិបទវប្បធម៌ និងប្រវត្តិសាស្ត្រ ការប្រែប្រួលនៃតុល្យភាព ទំនងជាបង្កើតការប្រែប្រួលស្របគ្នា នៅក្នុងការវាយតម្លៃបទបញ្ជាស្របច្បាប់ ។

១០-ការផ្លាស់ប្ដូរអាចកើតឡើងដោយ: ក.បម្រែបម្រួលនៅក្នុងន័យប្រវាស់ដៃ ឧទាហរណ៍ ម្ចាស់ដីកាត់បន្ថយ ឬលុបចោលប្រាក់កម្ចីមុនពេលប្រមូលផល ខ.ការប្រែប្រួលតម្លៃកម្រៃ ឬសេវាកម្ម ឧទាហរណ៍ តម្លៃការការពារថៅហ្វាយនាយសម័យសក្តិភូមិ គឺជាការកាត់បន្ថយដោយការរីកចម្រើនរដ្ឋកណ្ដាល និង គ.ការប្រែប្រួលនៅក្នុងតម្លៃកម្រៃ ឬសេវាកម្ម ឧទាហរណ៍ ជាធម្មតា សេវាក្នុងស្រុក នៅក្នុងគេហដ្ឋានថៅហ្វាយនាយអាចកាន់មានថ្លៃ នៅពេលដែលឱកាសប្រាក់ខែកម្មករអាចតម្លើង ។ គុណភាពនៃបម្រែបម្រួលដែលទាក់ទងគ្នា ត្រូវការទាមទារការគួសបញ្ជាក់ ។ ការវិភាគនៃបម្រែបម្រួលដោយស្របច្បាប់ នៃគហបតី ចាំបាច់ផ្ដោតទៅលើ ការប្រែប្រួលនៃការផ្លាស់ប្ដូរ ហើយមិនមែនអំណាចនៃវណ្ណៈកសិករទាមទារនោះទេ ។ ទោះបីជា ការផ្លាស់ប្ដូរនៅក្នុងការទាក់ទង និងការផ្លាស់ប្ដូរនៅក្នុងសុខុមាលភាពរបស់វណ្ណៈកសិករអាចស្របស្រួលគ្នា ហើយពួកគេអាចមានឱកាសរួបរួមគ្នាផងដែរ ។

១១-អ៊ី.ជេ.ហប់ស្បន និងចចរូដេ គ្រូវាត់មេដឹកនាំ (ញូយក: ប៉ង់គេអុង ១៩៦៨) ។

១២- សន្មតថា ខាងក្រោមនេះគឺមានតម្លៃ ការខ្វះខាតអ្នកពឹងពាក់ដែលមានថាមពល និងការប្រកួតប្រជែង នៅក្នុងចំណោមថៅហ្វាយនាយ ដែលនឹងផ្ដល់ផលប្រយោជន៍ដល់កសិករ ។ នេះគឺជាការបង្ហាញដោយទុក្ខព្រួយ ដោយ

ឥទ្ធិពលមរណភាពពណ៌ខ្មៅស្តីពី លក្ខខណ្ឌ ទាសករ នៅអឺរ៉ុប ។ នៅពេលដែលរោគពិសបំផ្លាញប្រជាជន ពលករមានការខ្វាចរអា និងលក្ខខណ្ឌនៃទាសករមានភាពងាយស្រួល ។

១៣-សូមមើលរ៉ូបឺត ត្រូកូល ហែន ហ្គែលឌើន ការកកើតរដ្ឋ និងរាជាធិបតេយ្យ នៅតំបន់អាស៊ីអាគ្នេយ៍ (អ៊ីតាកា, ញូយ៉ក: កម្មវិធីអាស៊ីអាគ្នេយ៍របស់សាកលវិទ្យាល័យខរណែល, ១៩៥៦), និង ហ្សុក សឺដេស រដ្ឋឥណ្ឌានីយកម្មនៃតំបន់អាស៊ីអាគ្នេយ៍ (ហូណូលូលូ: សារព័ត៌មានមជ្ឈមណ្ឌលអាស៊ីបូព៌ា-បស្ចិម ១៩៦៤ ។

